

# ប្រជុំភាណវារ

## បាលី_ប្រែ ពិសេស

© ធម្មទាន ដោយ ក្រុមធម្មមាមកជនសហគមន៍ធម្មទាន




របនាអត្ថបទ (សាជាថ្មីឡើងវិញ) និង របនាវិចិត្រក្របសៀវភៅ ដោយ ព្រហ្ម-មេត្តា ហៅ ជយវរិន្ទ ក្នុងឆ្នាំរក អដ្ឋស័ក ព.ស.២៥៦០

# ប្រជុំគាថាហារ

## (បាលី-ប្រែ ពិសេស)

*ប្រមូលរៀបរៀង ដោយ លោកសាស្ត្រាចារ្យ* **សែម-សួរ**

(ក្នុង **ពុទ្ធសករាជ ២៥០៨**) **(1966)**

រចនាអត្ថបទ ផ្ទៀងផ្ទាត់ និង រចនាសោភណភាពសៀវភៅឡើងវិញ

*ដោយ*

**ព្រហ្ម-មេត្តា គតបណ្ឌិតោ** (ហៅ **ជយវរិទ្ធ**)

**ការផ្សាយរបស់មណ្ឌលពុទ្ធិត្រៃគុណ**

**បោះពុម្ពផ្សព្វផ្សាយជាធម្មទាន**

ដោយ **ក្រុមធម្មាមកជន សហគមន៍ធម្មទាន** ក្នុង និង ក្រៅប្រទេស

( *បោះពុម្ពលើកទី១* )

ឆ្នាំ **វក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០** **(2016)**

# ត្រៃគុណ

## បញ្ញាគុណ វិសុទ្ធិគុណ ករុណាគុណ

# ព្រះរតនត្រ័យ

## ព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ ព្រះសង្ឃរតនៈ



# ព្រះត្រៃបិដក

## ព្រះវិនយ ព្រះសុត្តន្ត ព្រះអភិធម្ម

## បរិយត្តធម៌ បដិបត្តធម៌ បដិវេធធម៌



## ចក្កព្រះធម៌តម្រង់ទិសជីវិតសត្វលោក

# អដ្ឋង្គិកមគ្គ ឬ មជ្ឈិមប្បដិបទា

# ត្រៃសិក្ខា : សីល សមាធិ បញ្ញា



# ព្រះសម្មាសម្ពុទ្ធ ព្រះបរមសាស្តា

**~ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**សូមនមស្ការ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ !**

# ប្រារព្ធកថា

ការបានទូវអត្ថិភាពនៃជីវិតជាមនុស្សគ្រប់រូប របស់យើងទាំងអស់គ្នា ទាន់មានព្រះពុទ្ធសាសនានៅជាធរមាននៅឡើយនេះ គឺជាឱកាសមួយដ៏ថ្លៃថ្លា និង មានដោយកម្របំផុត ។ ប្រសិនបើយើងប្រកបដោយសេចក្ដីប្រមាទ ហើយបោះបង់ចោលនូវឱកាសដ៏មានតម្លៃ ដ៏កម្រនេះ ដោយមិនខិតខំព្យាយាមសិក្សាឈ្វេងយល់ ឱ្យដល់ទីជម្រៅនៃសច្ចធម៌តាមគន្លងអរិយសច្ចៈ ដែល **ព្រះសម្មាសម្ពុទ្ធ ជាព្រះបរមសាស្ដា** ទ្រង់បានត្រាស់ដឹង និង ទ្រង់បានត្រាស់ទូន្មានប្រៀនប្រដៅនោះទេ ហើយបែរទៅជាចំណាយ (ជីវិត) ពេលវេលាដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីស្វែងរកនូវសេចក្ដីសុខ ប្រកបដោយភាពមាយាសាវ៉ានៃលោកធម៌ នៅខាងក្រៅខ្លួន អំពីអ្នកដទៃ ឬអំពីការបំពេញនូវបំណងប្រាថ្នានៃតណ្ហា ដែលវាបានបញ្ឆោរយើងផង បញ្ឆាយើងផង បញ្ឆោតយើងផង ឱ្យយើងវង្វេងវិលវក់ ឈ្លក់វង្វេង លេងប្រឡែងល្បែងស្រវឹង (ដោយភាពអវិជ្ជា) គ្មានទីបញ្ចប់នោះ, នោះយើងពិតជាត្រូវខាតបង់ដោយពិតប្រាកដ ដោយបានចំណាយជីវិតរស់នៅក្នុងភាពងងឹត ដោយឥតបានស្គាល់ ឥតបានក្រេបនូវអម្រឹតរសនៃអរិយសច្ចធម៌ ហើយយើងក៏ពុំបានជួបប្រទះនូវពន្លឺរស្មីសច្ចធម៌ ដើម្បីបំភ្លឺជីវិតចរចេញចាកពីភាពងងឹត ពោលគឺសេចក្ដីទុក្ខក្នុងវាលវដ្តសង្សារ (វដ្តទុក្ខ)ពិតប្រាកដបានឡើយ ។

ដោយយល់ឃើញថា សៀវភៅនេះនឹងនៅតែជាឧបករណ៍ធម្មសិក្សាចាំបាច់ ក្នុងពុទ្ធសាសនមណ្ឌល សម្រាប់ទាំងព្រះថេរានុត្ថេរៈ

ទាំងនវភិក្ខុ ទាំងនវសាមណេរ ឧបាសក-ឧបាសិកា ជារៀងរហូតតទៅ ដើម្បីទ្រទ្រង់ការប្រតិស្ឋានតាំងនៅ នៃ **ព្រះពុទ្ធសាសនា** រហូតគ្រប់ ៥.០០០ ព្រះវស្សានោះ ខ្ញុំព្រះករុណា-ខ្ញុំ ដោយសទ្ធាបញ្ញាសម្បយុត្ត សម្រេចបាននូវមហាកុសលចិត្តប្បាទ ដើម្បីប្រារព្ធរៀបចំរចនាធ្វើសៀវ-ភៅនេះ ឱ្យមានសោភណភាពថ្មីឡើងវិញ ដោយរក្សាទុកនូវខ្លឹមសារ ដើមទាំងស្រុង គ្រាន់តែរចនាលក្ខណៈតួអក្សរ សោភណភាពសៀវភៅ ជាថ្មី សមស្របតាមសម័យកាលទំនើបនៃវិស័យពត៌មានវិទ្យា និង កែ ជួសតម្រូវបំពេញនូវអក្ខរាវិរុទ្ធខ្លះដែលមិនច្បាស់ រលប់ ឬមានការលើស ខ្វះ ខ្លះៗ... ព្រោះកាលសម័យដើម វិស័យបោះពុម្ពមិនមែនទំនើបដូច សម័យបច្ចុប្បន្ននេះឡើយ !

សេចក្ដីព្យាយាមក្នុងរចនាឡើងវិញនូវសៀវភៅនេះ គឺជាសក្ខី ភាពបញ្ជាក់នូវគារវ-ភក្តីភាព ដ៏ធំធេងជ្រាលជ្រៅ ឥតត្រើយត្រាណ ឥតប្រមាណបាន ចំពោះព្រះមហាគុណព្រះសម្មាសម្ពុទ្ធព្រះបរមសាស្តា គុណព្រះរតនត្រ័យ បុព្វការីជន មាតា-បិតា ព្រះគ្រូឧបជ្ឈាយាចារ្យ និង អស់លោក-អ្នកមានឧបការៈគុណទាំងអស់គ្រប់ជំនាន់ គ្រប់សម័យកាល ដែលបានប្រមូលចងក្រងរៀបរៀង បន្សល់ទុកនូវព្រះពុទ្ធវចនៈសច្ចវិជ្ជា-បញ្ញាដែលព្រះសម្មាសម្ពុទ្ធ ជាព្រះបរមគ្រូទ្រង់បានត្រាស់ដឹង កាត់ផ្តាច់ កម្ចាត់បង់នូវភាពអវិជ្ជា ដែលរួបរឹតជីវិតសត្វលោក ក្នុងវាលវដ្តសង្សារ ដើម្បីយើងបានសិក្សា រៀនរស់ រៀនស្លាប់ ដើម្បីសម្លាប់នូវសេចក្តីស្លាប់ វិលវល់ក្នុងអន្លង់វដ្តៈ ប្រកបដោយភាពអវិជ្ជាមិនចេះអស់មិនចេះហើយ

នេះ ហើយស្ទុះរកព្រះធម៌ មានព្រះធម៌ជាទីពឹង ដើម្បីជាការប្រតិបត្តិរួចចាកទុក្ខ ឆ្ពោះទៅរកបរមសុខពិត ពោលគឺ **ព្រះនិព្វាន** ។

សូមឧទ្ទិសនូវបុណ្យកុសលទាំងឡាយ ជូនដល់បដិសន្ធិវិញ្ញាណលោកបណ្ឌិតសាស្ត្រាចារ្យ **សែម_សូរ** ដែលលោកបានខិតខំកសាងបន្សល់ទុកនូវមរតកសៀវភៅនេះ សម្រាប់ជនានុជនជំនាន់ក្រោយ បានសិក្សារៀនសូត្រតរៀងមក, សូមលោក បានសម្រេចនូវឥដ្ឋមនុញ្ញផលគឺផលបុណ្យជាទីគាប់ចិត្ត សមតាមបំណងអធ្យាស្រ័យរបស់លោកចុះ !

សូមមេត្តាខន្តីអភ័យទោសដោយសេចក្តីអនុគ្រោះ ចំពោះការខ្វះខាត និង ការខុសឆ្គងដោយអចេតនាខ្លះ ដែលអាចកើតមានជាយថាហេតុ នៅក្នុងការរចនារៀបចំឡើងវិញនូវសៀវភៅនេះ ។

**៙ នត្ថិ សន្តិ បរំ សុខំ !**

សុខក្រៅពីសេចក្តីស្ងប់ មិនមាន !

**៙ មានអ្វីមិនស្មើមានព្រះធម៌**

**ល្អអ្វីមិនស្មើល្អចិត្តជាបុណ្យ !**

**ដោយសេចក្តីគោរព និង មេត្តាធម៌ដ៏ជ្រាលជ្រៅក្នុងន័យព្រះធម៌ !**

អំពីយើងខ្ញុំ-ក្រុមធម្មាកជន សហគមន៍ធម្មទាន

និង អំពីខ្ញុំព្រះករុណា-ខ្ញុំបាទ អ្នករចនាអត្ថបទ និង ផ្ទៀងផ្ទាត់

(វស្សានរដូវ ឆ្នាំ វក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០)

# មាតិកានុក្រម


ប្រារព្ធកថា ........ ទំព័រ ៥

## ផ្នែកទី ១ : ធម៌នមស្ការព្រះរតនត្រ័យ

- បទសរភញ្ញ ........ ទំព័រ ១២
- អភិវាទនកថា ........ ទំព័រ ១៣
- បទនមស្ការព្រះរតនត្រ័យ (សង្ខេប) ........ ទំព័រ ១៤ -៤៤

## ផ្នែកទី ២ : បច្ចវេក្ខណវិធី (ទំព័រ ៤៥ - ៥៩)

- ធាតុប្បច្ចវេក្ខណៈ ........ ទំព័រ ៤៦
- បដិកូលប្បច្ចវេក្ខណៈ ........ ទំព័រ ៤៩
- តំខណិកប្បច្ចវេក្ខណៈ ........ ទំព័រ ៥១
- អតីតប្បច្ចវេក្ខណៈ ........ ទំព័រ ៥៥

## ផ្នែកទី ៣ : ភត្តានុមោទនាវិធី (ទំព័រ ៦០ - ៨៦)

- ភត្តានុមោទនាគាថា ........ ទំព័រ ៦០
- សាមញ្ញានុមោទនាគាថា ........ ទំព័រ ៦១
- មង្គលចក្កវាឡ ........ ទំព័រ ៦២
- វិសេសានុមោទនាវិធី ........ ទំព័រ ៦៧
- កាលទានសុត្តគាថា ........ ទំព័រ ៦៨
- វិហារទានសុត្តគាថា ........ ទំព័រ ៧០

៙ ឧទ្ទិសបុណ្យចំពោះទេវតា ........ ទំព័រ ៧២
៙ អគ្គប្បសាទសុត្តគាថា ........ ទំព័រ ៧៣
៙ ជីវតត្តានុមោទនាគាថា ........ ទំព័រ ៧៥
៙ បុព្វបេតពលិទានានុមោទនាគាថា ........ ទំព័រ ៧៦
៙ តិរោកុណ្ឌកណ្ឌគាថា ........ ទំព័រ ៧៨
៙ យាគុអនុមោទនាគាថា ........ ទំព័រ ៨៣
៙ សិទ្ធិយាចនគាថា ........ ទំព័រ ៨៤
៙ យានទានានុមោទនាគាថា ........ ទំព័រ ៨៥

## ៙ ផ្នែកទី ៤ : ធម៌សូត្រពិធីដារវេរ និង បំសុកូល (ទំព័រ ៨៧_១១៤)

➢ អភិធម្មបិដក៧គម្ពីរ (មាតិកា) ........ ទំព័រ ៨៧_១០២
➢ តិរោកុឌ្ឌកណ្ឌគាថា_យទិហីនេ ........ ទំព័រ ១០៣
➢ បដិច្ចសមុប្បាទ ........ ទំព័រ ១០៧
➢ សំវេជនីយគាថា ........ ទំព័រ ១១០

## ៙ ផ្នែកទី ៥ : ធម៌សូត្រមន្ត_សត្តបរិត្ត (ទំព័រ ១១៥_១៨៩)

➢ នមស្សការ ........ ទំព័រ ១១៧
➢ សម្ពុទ្ធេ ........ ទំព័រ ១១៩
➢ មង្គលសូត្រ ........ ទំព័រ ១២៤
➢ រតនសូត្រ ........ ទំព័រ ១៣១
➢ ករណីយមេត្តសូត្រ ........ ទំព័រ ១៤២

- **ខន្ធបរិត្ត** ........ ទំព័រ ១៤៦
- **មោរបរិត្ត** ........ ទំព័រ ១៥០
- **ធជគ្គសូត្រ** ........ ទំព័រ ១៥៣
- **អាដានាដិយបរិត្ត** ........ ទំព័រ ១៦៦
- **អង្គុលិមាលបរិត្ត ~ ពោជ្ឈង្គបរិត្ត** ........ ទំព័រ ១៧៣
- **អភយបរិត្តគាថា** ........ ទំព័រ ១៧៦
- **ជយបរិត្តគាថា** ........ ទំព័រ ១៧៩
- **សក្កត្វា ពុទ្ធរតនំ** ........ ទំព័រ ១៨២
- **មង្គលចក្កវាឡ** ........ ទំព័រ ១៨៥


## ៙ <u>ផ្នែកទី ៦</u> : ទ្វាទសបរិត្ត (ទំព័រ ១៩០_២៧៦)


- **រតនសុត្តារម្ភោ** ........ ទំព័រ ១៩២
- **ឆទ្ទន្តបរិត្ត** ........ ទំព័រ ១៩៤
- **វដ្តកបរិត្ត** ........ ទំព័រ ១៩៥
- **អាដានាដិយបរិត្ត** ........ ទំព័រ ១៩៧
- **អភយបរិត្ត** ........ ទំព័រ ២០៣
- **ជយបរិត្ត** ........ ទំព័រ ២០៤
- **ធម្មចក្កប្បវត្តនសូត្រ** ........ ទំព័រ ២០៦
- **អនត្តលក្ខណសូត្រ** ........ ទំព័រ ២២៧
- **អាទិត្តបរិយាយសូត្រ** ........ ទំព័រ ២៤៥
- **គិរិមានន្ទសូត្រ** ........ ទំព័រ ២៥៧

## ៙ ផ្នែកទី ៧ : វិវិធគាថា (ទំព័រ ២៧៧_៣១៥)


- ➢ ពុទ្ធជយមង្គល (ពាហុំ) ........ ទំព័រ ២៧៧
- ➢ សរណាទិបិគាថា ........ ទំព័រ ២៨៣
- ➢ ឆលិទ្ធសុត្តគាថា ........ ទំព័រ ២៨៤
- ➢ គារវសុត្តគាថា ........ ទំព័រ ២៨៥
- ➢ ភាសិតោវាទសង្ខេប ........ ទំព័រ ២៨៩
- ➢ វិធីបកសករាជ ........ ទំព័រ ២៩៩
- ➢ ពុទ្ធបាទនមស្សការគាថា ........ ទំព័រ ៣០០
- ➢ ធាតុចេតិយនមស្សការគាថា ........ ទំព័រ ៣០២

- ➢ បាលីសម្រាប់សូត្រកឋិនកម្ម ........ ទំព័រ ៣០៨
- ➢ វិធីពិន្ទុកប្បចីវរ ........ ទំព័រ ៣១២


## ៙ ផ្នែកទី ៩ : ព្រះត្រៃបិដកសង្ខេប_សត្តប្បករណាភិធម្ម


- ➢ ព្រះត្រៃបិដកសង្ខេប ........ ទំព័រ ៣១៦
- ➢ សត្តប្បករណាភិធម្ម ........ ទំព័រ ៣២១
- ➢ ផ្សាយមេត្តាធម៌ ........ ទំព័រ ៣៨៥


## ៙ ផ្នែកទី ១០ : ទំព័របន្ថែម (ទំព័រ ៣៨៨_៤០០)


- ធម្មទស្សនទាន ........ ទំព័រ ៣៩៦
- ឧទ្ទិសកថា ........ ទំព័រ ៤០០

# បទសរភញ្ញ

( បទនិពន្ធរបស់ **សម្ដេចព្រះមហាសុមេធាធិបតី ជួន_ណាត** ជោតញ្ញាណោ
**ព្រះសង្ឃរាជ គណៈមហានិកាយ** )

១_ សូមថ្វាយបង្គំ **ព្រះសម្ពុទ្ធ** ប្រសើរបំផុត ក្នុងលោកា
ជាគ្រូនៃមនុស្ស និង ទេព្ដា ទ្រង់ត្រាស់ទេសនា ប្រដៅសត្វ ។
_ ចង្អុលឱ្យដើរ ផ្លូវកណ្ដាល មាគ៌ាត្រកាល អាចកំចាត់
ទុក្ខភ័យចង្រៃ ឱ្យខ្ចាយខ្ចាត់ អាចកាត់សង្សារ_ ទុក្ខបាន ។

២_ សាសនាព្រះអង្គ នៅសព្វថ្ងៃ សត្វមាននិស្ស័យ ពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ ចេះចាំបាន កាន់តាមលំអាន បានក្ដីសុខ ។
_ ឥតមានសុខណា ស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខ ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ តទៅមុខ ក្ដីសុខនឹងមាន ព្រោះធម៌ស្ងប់ ។

៣_ ខ្ញុំសូមបង្គំ ឆ្ពោះ **ព្រះធម៌** **ព្រះសង្ឃ** បវរ ទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្ន គួរគោរព ជាម្លប់ត្រជាក់ នៃលោកា ។
_ ព្រះរូបព្រះធាតុ នៃ **ព្រះពុទ្ធ** វិសុទ្ធតាងអង្គ **ព្រះសាស្ដា**
សូមគុណត្រៃរ័ត្ន ជួយខេមរា ឱ្យបានសុខា តរៀងទៅ !

# អភិវាទនកថា

( បទនិពន្ធ របស់

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត-សាវង្ស** )

~ **អហំ** រីខ្ញុំ បង្គំវន្ទា ឆ្ពោះ**ព្រះភគវា ព្រះធម៌**ថ្លៃថ្លា
ព្រមទាំង**ព្រះសង្ឃ** ផ្លូវផង់សីលា ចិន្តាលំអុត **ព្រះពុទ្ធនិយាម** ។

~ សូមឱ្យសព្វសត្វ បដិបត្តិតាមធម៌ សាសនាបវរ ល្អដូចព្រះនាម
**អរហំ សម្មា** គ្មានការទាក់ទាម កិលេសរវាម រវាតសូន្យបង់ ។

~ សូមឱ្យសាសនា **សម្មាសម្ពុទ្ធ** បរិស័ទមោះមុត រួមចិត្តទ្រទ្រង់
ឋិតថេរចិរកាល អភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ ផ្ចិតផ្ចង់សិក្ខា។

~ សូមមនុស្សទេវតា មានការគោរព ទាំងថ្ងៃទាំងយប់ ក្នុងព្រះសាសនា
សូមបានសម្រេច ដូចក្តីប្រាថ្នា អស់នូវតណ្ហា ទុក្ខាចប់ហោង !

# នមត្ថុ រតនត្តយស្ស វន្ទាមិ !

ខ្ញុំព្រះអង្គ សូមនមស្ការចំពោះ **ព្រះភគវន្តមុនី អរហន្តសម្មា-សម្ពុទ្ធ** ព្រះអង្គនោះ ដែលព្រះអង្គទ្រង់ប្រកបទៅដោយ ព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និង ព្រះមហាករុណាគុណ ដ៏ធំធេងផង, ដូច្នេះខ្ញុំព្រះអង្គ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយសេចក្តីគោរព !

ខ្ញុំព្រះអង្គ សូមនមស្ការចំពោះ **ព្រះសទ្ធម្ម** ទាំង **៨៤.000** ព្រះធម្មក្ខន្ធ ដែលជានិយ្យានិកធម៌ សម្រាប់ដឹកនាំចម្លងសត្តនិករទាំងឡាយ ឱ្យឆ្លងផុតចាកវាលវដ្តសំសារ ឆ្ពោះទៅរកសេចក្តីសុខ សេចក្តីចម្រើន, ដូច្នេះខ្ញុំព្រះអង្គ សូមនមស្ការចំពោះព្រះសទ្ធម្មនោះ ដោយសេចក្តីគោរព !

ខ្ញុំព្រះអង្គ សូមនមស្ការចំពោះ **ព្រះសង្ឃ** ទាំងពីរពួក មាន ព្រះអរិយសង្ឃ និង សម្មតិសង្ឃ ដែលសព្វសត្តនិករទាំងឡាយ នាំគ្នាកំណត់ទុកជា " **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** " ជាស្រែបុណ្យ មានជីវជាតិល្អ ដែលរាល់សព្វសត្តនិករទាំងឡាយ រមែងតែងតែយកពូជធារទៅសាបព្រោះឱ្យលូតលាស់ដុះដាល រីកចម្រើនកើនទៅជាផលានិសង្សបាន, ដូច្នេះខ្ញុំព្រះអង្គ សូមនមស្ការចំពោះព្រះសង្ឃអង្គនោះ ដោយសេចក្តីគោរព !

# ធម៌នមស្សការ

## រតនៈបូជា

**ឥមេហិ ទីបធូបាទិសក្ការេហិ**

**ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ,**

*ប្រែៈ ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និង ធូបជាដើមនេះ ដើម្បីសេចក្ដីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតា-បិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង!*

# ពុទ្ធរតនប្បណាម

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

(*សូត្រ ៣ដង*)

*ប្រែៈ វីកិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្ត ដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ!*

(*ថ្វាយបង្គំម្តង*)

## ថ្វាយបង្គំព្រះពុទ្ធរតនៈ

☸ **យោ សន្និសិន្នោ វរពោធិមូលេ**
**មារំ សសេនំ មហតិំ វិជេយ្យោ**
**សម្ពោធិមាគច្ឆិ អនន្តញាណោ**
**លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។**

ប្រែថា : ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបា-នស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវ

សម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព!

(ក្រាបថ្វាយបង្គំម្តង)

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**
**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។**

ប្រែថា : **ព្រះសម្មាសម្ពុទ្ធ** ទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វានកន្លងទៅហើយក្តី **ព្រះសម្មាសម្ពុទ្ធ**ទាំងឡាយអង្គឯណាដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី **ព្រះសម្មាសម្ពុទ្ធ**ទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង!

(ក្រាបថ្វាយបង្គំម្តង)

(បង្អោនកាយវាចា ហើយតាំងចិត្តរលឹកដល់ **ព្រះពុទ្ធគុណ** ទាំង ១០ ព្រះនាម [១])

[១] **ត្រៃរតនគុណ** មានក្នុងសុត្តន្តបិដក សំយុត្តនិកាយ "**ធជគ្គសូត្រ** បិ. ៣០, ទំ. ២៤៣"

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។**

ប្រែថា : **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និង វចីបយោគ ;

**សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ;

**វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយ វិជ្ជា៣ និង វិជ្ជា៨ និង ចរណៈ ១៥ ;

**សុគតោ** ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន;

**លោកវិទូ** ទ្រង់ព្រះនាមថា**លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក;

**អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គ ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន;

**បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន;

**សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និង មនុស្សទាំងឡាយ;

**ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចៈ ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង;

**ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធគុណ ថា :

~ **នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា : **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណាមិនមានឡើយ;

**ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា;

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

(ក្រាបថ្វាយបង្គំម្តង)

<u>រួចហើយត្រូវសូមខមាទោសចំពោះព្រះពុទ្ធគុណ ដូច្នេះថា</u> :

~ **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

<u>ប្រែថា</u> : **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តម គឺត្បូង,

**ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់,

**ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោស នោះដល់ខ្ញុំព្រះករុណា ។

(<u>ក្រាបថ្វាយបង្គំម្តង</u>)

* <u>**កំណត់សម្គាល់:**</u> ក្នុងការប្រើស្រៈនិស្ស័យ ិ ី ឹ ឺ លើតួព្យញ្ជនៈ **ភ គ ត ភ ទ** ដោយប្រើ **Font Unicode** <u>Khmer OS Muol</u> មានការប្រែទិដ្ឋភាពពី **ភិ ភី ភឹ ភឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ទិ ទី ទឹ** ទៅជាយ៉ាងនេះវិញ ៖ **ភ ភ ភ ភ. គ គ គ គ, ត ត ត ត, ភ ភ ភ ភ, ទ ទ ទ**... (**ជារបៀបសំណេរបែបបុរាណជូនតាខ្មែរ**), អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ និង អស់លោក-អ្នកសិក្ខាកាមទាំងឡាយ មេត្តាជ្រាប និង គប្បីបានស្គាល់យល់ដឹង ។

# ធម្មរតនប្បណាម

## ថ្វាយបង្គំព្រះធម្មរតនៈ

☸ អដ្ឋង្គិការិយបថោ ជនានំ
មោក្ខប្បវេសាយ ឧជូ ច មគ្គោ
ធម្មោ អយំ សន្តិករោ បណីតោ
និយ្យានិកោ តំ បណមាមិ ធម្មំ ។

__ប្រែថា__ : **ព្រះសទ្ធម្ម** ឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឱ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសទ្ធម្មនោះដោយគោរព !

(__ថ្វាយបង្គំម្តង__)

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា
បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។

__ប្រែថា__ : ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌

របស់ព្រះសម្មាសម្ពុទ្ធនឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង !

(ថ្វាយបង្គំម្តង)

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ--បស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

ប្រែថា : **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ( **ធម្មោ** ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺ : **មគ្គ៤ ផល៤ និព្វាន១** ),

**សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង;

**អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ;

**ឯហិបស្សិកោ** ជាធម៌គួរដល់**ឯហិបស្សវិធី** គឺថាបើព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឱ្យចូលមកមើលបាន,

**ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា,

**បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គល ជាដើម គប្បីដឹង គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួន ចំពោះព្រះធម្មគុណ ថា :

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

ប្រែថា : **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណាមិនមានឡើយ, **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា, **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(ក្រាបថ្វាយបង្គំម្តង)

<u>រួចហើយត្រូវសូមខមាទោសចំពោះព្រះធម្មគុណ</u> ថា :

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**
**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។**

<u>ប្រែថា</u> : **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការគឺ **ព្រះបរិយត្តិធម៌** និង **ព្រះនព្វលោកុត្តរធម៌** ដោយអវយវៈ ដ៏ឧត្តមគឺត្បូង, **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់, **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

<u>ក្រាបថ្វាយបង្គំម្តង</u>

* <u>**កំណត់សម្គាល់:**</u> ក្នុងការប្រើស្រៈនិស្ស័យ ិ ី ឹ ឺ លើតួព្យញ្ជនៈ **ភ គ ត ភ ទ** ដោយប្រើ **Font Unicode** <u>Khmer OS Muol</u> មានការប្រែទិដ្ឋភាពពី **ភិ ភី ភឹ ភឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ទិ ទី ទឹ** ទៅជាយ៉ាងនេះវិញ ៖ **ភ ភ ភ ភ. គ គ គ គ, ត ត ត ត, ភ ភ ភ ភ, ទ ទ ទ**... (ជារបៀបសំណេរបែបបុរាណដូនតាខ្មែរ), អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ និង អស់លោក-អ្នកសិក្ខាកាមទាំងឡាយ មេត្តាជ្រាប និង គប្បីបានស្គាល់យល់ដឹង ។

# សង្ឃរតនប្បណាម

## ថ្វាយបង្គំព្រះសង្ឃរតនៈ

☞ **សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**
**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**
**គុណេហិនេកេហិ សមិទ្ធិបត្តោ**
**អនាសវោ តំ បណមាមិ សង្ឃំ ។**

**ប្រែថា** : ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះឱណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព !

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**
**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

**ប្រែថា** : ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និង ផល កន្លងទៅហើយក្ដី ព្រះសង្ឃទាំងឡាយឯណាដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និង ផល ក្នុងកាលខាងមុខក្ដី ព្រះសង្ឃទាំងឡាយ

ឯណា ដែលជាព្រះសង្ឃបានសម្រេច **មគ្គ** និង **ផល** ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

បង្អោនកាយវាចា ហើយតាំងចិត្តរលឹកដល់សង្ឃគុណ ថា :

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**
**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**
**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**
**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**
**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា**
**ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ**
**បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ**
**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

__ប្រែថា__ : **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌,

**ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិម--ប្បដិបទា,

**ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹង នូវព្រះនិព្វាន ជាស្ពានក្បៀមផុតចាកទុក្ខទាំងពួង,

**សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តគួរដល់ **សីល សមាធិ បញ្ញា,**

**យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវ **សោតាបត្តិមគ្គ** និង **សោតាបត្តិផល**ជាគូ១, **សកទាគាមិមគ្គ** និង **សកទាគាមិផល**ជាគូ១, **អនាគាមិមគ្គ** និង **អនាគាមិផល**ជាគូ១, **អរហត្តមគ្គ** និង **អរហត្តផល**ជាគូ១,

**អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គល មាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវ **សោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ១ អរហត្តផល១,**

**ឯស ភគវតោ សាវក សង្ឃោ** ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,

**អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា,

**បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និង មិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា,

**ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និង ផលនៃកម្ម ហើយបូជា,

**អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ,

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

(ក្រាបថ្វាយបង្គំម្តង)

តទៅគប្បីប្រកាសប្តេជ្ញាខ្លួន ចំពោះព្រះសង្ឃគុណ ថា :

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

**ប្រែថា** : **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណា មិនមានឡើយ, **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរលឹក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា, **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយា ពោលនូវពាក្យសច្ចៈនេះ ។

រួចហើយត្រូវសូមខមាទោស ចំពោះព្រះសង្ឃគុណ ថា :

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**
**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។**

**ប្រែថា** : **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការគឺ **សម្មតិសង្ឃ** និង **អរិយសង្ឃ** ដោយអវយវៈដ៏ឧត្តម គឺត្បូង, **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់, **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

# ត្រៃបណាមសង្ខេប

## ព្រមទាំងបូជាគ្រឿងសក្ការៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

(*ប្រែដូចមុន*)

**ឥតិបិ សោ ភគវា អរហំ** ។ល។ **ភគវាតិ** (*ប្រែដូចមុន*)

**តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

*ប្រែថា:* **តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថា* **អរហំ** *ជាដើមនោះ ដោយសិរសា គឺត្បូង,*

**តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។*

(*ក្រាបថ្វាយបង្គំម្តង*)

**ស្វាក្ខាតោ ភគវតា ធម្មោ** ។ល។ **បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ** ។ (*ប្រែដូចមុន*) ។

**តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ។

*ប្រែថា:* **តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា* **ស្វាក្ខាតោ** *ជាដើមនោះ ដោយសិរសា គឺត្បូង,*

**តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។*

(*ក្រាបថ្វាយបង្គំម្តង*)

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ។ល។ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ** ។ (*ប្រែដូចមុន*) ។

**តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

*<u>ប្រែថា:</u>* **តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា* **សុបដិបន្នោ** *ជាដើមនោះ ដោយសិរសា គឺត្បូង,*

**តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។*

(*<u>ក្រាបថ្វាយបង្គំម្តង</u>*)

* <u>**កំណត់សម្គាល់:**</u> ក្នុងការប្រើស្រៈនិស្ស័យ ិ ី ឹ ឺ លើតួព្យញ្ជនៈ **ក គ ត ភ ខ** ដោយប្រើ **Font Unicode** <u>**Khmer OS Muol**</u> មានការប្រែទិដ្ឋភាពពី **កិ កី កឹ កឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ខិ ខី ខឹ** ទៅជាយ៉ាងនេះវិញ ៖ **កិ កី កឹ កឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ, ខិ ខី ខឹ**... (**ជារបៀបសំណេរបែបបុរាណជូនតាខ្មែរ**), អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ និង អស់លោក-អ្នកសិក្ខាកាមទាំងឡាយ មេត្តាជ្រាប និង គប្បីបានស្គាល់យល់ដឹង ។

# សុមង្គលគាថា

☞ **ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**

**សព្វពុទ្ធានុភាវេន**
**សព្វធម្មានុភាវេន** } **សោត្ថី ហោតុ និរន្តរំ ។**
**សព្វសង្ឃានុភាវេន**

<u>*ប្រែថា:*</u> **ហោតុ សព្វំ សុមង្គលំ សុមង្គល** គឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ, **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ,

**សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ,

**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង,

**សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង,

**សោត្ថី ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

# បណាមគាថា

➢ យោ កប្បកោដីហិបិ អប្បមេយ្យំ
កាលំ ករោន្តោ អតិទុក្ករានិ
ខេទំ គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស !

- ព្រះពុទ្ធជាទីពឹង ជាពំនឹង សព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាង អស់កាលយូរ ។

- រាប់ដោយកោដិកប្បា ច្រើនគណនា ហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ច្បាស់ជាគ្រូ លើភពថាន ។

- ធ្វើកម្មជាកម្រ មនុស្សនិករ ត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ ដល់សព្វសត្វ ។

- ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នា បង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទី ពឹងសព្វកាល ។

- អសម្ពុធំ ពុទ្ធនិសេវិតំ យំ

ភវាភវំ គច្ឆតិ ជីវលោកោ

នមោ អវិជ្ជាទិកិលេសជាលំ

វិទ្ធំសិនោ ធម្មវរស្ស តស្ស !

- សត្វតែងកើតស្លាប់បង់ ព្រោះចំណង់ កម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូច និង ភពធំ ។

- ហេតុតែមិនដឹងធម៌ បរិសុទ្ធល្អ ស្អាតសុខុម
គឺ ព្រះពុទ្ធសេពសម ចិត្តខ្ញុំសូម នមស្សការ ។

- នូវធម៌ប្រពៃពិត វិសេសសុទ្ធ នោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញ កិលេសហើយ ។

- **គុណេហិ យោ សីលសមាធិបញ្ញា**

**វិមុត្តិញ្ញាណប្បវរេហិ យុត្តោ**

**ខេត្តញ្ជនានំ កុសលត្ថិកានំ**

**តមរិយសង្ឃំ សិរសា នមាមិ !**

- ព្រះសង្ឃ អង្គសាវ័ក មានសំវរៈ សទ្ធាទ្រង់
កបដោយគុណ **សីល** ត្រង់ និង **សមាធិ បញ្ញា**...

- ... និង **វិមុត្តិញ្ញាណ** កិលេសគ្មាន ក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការ ជាកុសល ។

- ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គល ដល់សព្វសត្វ ។

# **ថ្វាយបង្គំសុំសេចក្ដីសុខ!**

☞ **ឥច្ចេវមច្ចន្ត** **នមស្សនេយ្យំ**
**នមស្សមានោ** **រតនត្តយំ យំ**
**បុញ្ញាភិសន្ទំ** **វិបុលំ អលត្ថំ**
**តស្សានុភាវេន** **ហតន្តរាយោ ៗ**

- ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី
  បង្គំគុណទាំង ៣ ខ្ពស់លើសលប់ត្រៃលោកា ។
- សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
  ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
- សូមអោយកម្ចាត់បង់ អពមង្គលទាំងឡាយ
  ឱ្យចៀសចេញចាកឆ្ងាយ ក្ដីអន្តរាយកុំបីមាន ។
- ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
  កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
- ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
  សូមអានិសង្សនោះ **ដាក់ដល់ឋាននិព្វានហោង** (១) ។

(១) តាមពិត **ព្រះនិព្វាន** ពុំមែនជាទីស្ថានដូចដែលយើងធ្លាប់សូត្រថា ត។ គ្នាមកនោះទេ ។ **និព្វាន** ជាអសង្ខតធម៌គ្មានបច្ច័យតាក់តែង គ្មានបួងសួងបន់ស្រន់បានឡើយ។ព្រះនិព្វានជាបរមសុខពិតប្រាកដ ព្រោះការរលត់អស់ទាំងស្រុងនូវ លោភៈ ទោសៈ មោហៈ ។ បើយើងអាចសូត្របានថា ...សូមអានិសង្សនោះតម្រង់ឆ្ពោះនិព្វានហោង, *ក៏ជាការគួរប្រកបដោយហេតុ_ផលម្យ៉ាងដែរ!*

# បត្តិទានគាថា

ពុទ្ធសាសនិកជន ដែលបានធ្វើធ្វើកុសលឯណាមួយរួចហើយ បើមានប្រាថ្នានឹងឱ្យចម្រើន នូវផលានិសង្សដល់ខ្លួន ដោយច្រើនឡើងទៀតនោះ គប្បីឧទ្ទិសផ្សាយផលនៃកុសលនោះ ដល់សត្វទាំងឡាយ ដោយ **កុសលចិត្តជាបុញ្ញកិរិយាវត្ថុ**១យ៉ាង ដែលហៅថា **បត្តិទាន** គឺកិរិយាឱ្យនូវចំណែកបុណ្យដល់អ្នកដទៃដោយ **បត្តិទានគាថា** ដូច្នេះថា:

☞ **យំ កិញ្ចិ កុសលកម្មំ**[(១)] **កត្តព្វំ កិរិយំ មម**
**កាយេន វាចាមនសា** **តិទសេ សុគតំ កតំ**
**យេ សត្តា សញ្ញិនោ អត្ថិ** **យេ ច សត្តា អសញ្ញិនោ**
**កតំ បុញ្ញផលំ មយ្ហំ** **សព្វេ ភាគី ភវន្តុ តេ**
**យេ តំ កតំ សុវិទិតំ** **ទិន្នំ បុញ្ញផលំ មយា**
**យេ ច តត្ថ ន ជានន្តិ** **ទេវា គន្ត្វា និវេទយុំ**
**សព្វេ លោកម្ហិ យេ សត្តា** **ជីវន្តាហារហេតុកា**
**មនុញ្ញំ ភោជនំ សព្វេ** **លភន្តុ មម ចេតសា** ។

<u>*ប្រែថា:*</u> **យំ កិញ្ចិ កុសលកម្មំ កតព្វំ កិរិយំ មម** អំពើជាកុសលណាមួយដែលខ្ញុំគប្បីធ្វើ , **កាយេន វាចា មនសា** ដោយទ្វារ

(១) **សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន** បិដកលេខ ៧២, ទំព័រ ៩-១០ ។

ទាំង៣ គឺ កាយ វាចា ចិត្ត , **តិទសេ សុគតំ កតំ** អំពើជាកុសល ទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុង ស្ថានត្រៃត្រឹង្សសួគ៌បាន, **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយ ឯណា គឺមនុស្ស ទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី , **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វដែល ឥតសញ្ញាក្តី, **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំង ឡាយទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរ សោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឱ្យទៅ នេះចុះ, **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែល ខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វ ទាំងឡាយនោះចូរឱ្យបានសោយនូវផល ដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះ ចុះ, **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើ សត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ, **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹង ដល់សត្វទាំងឡាយនោះ ឱ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ ៗ ចូរ អនុមោទនាត្រេកអរ នឹងបុណ្យគេនោះចុះ , **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែល

អាស្រ័យនូវអាហារហើយរស់នៅ, **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា‌តិ** សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជន ជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយទៅឱ្យនេះចុះ !

## **បត្តិទានគាថា** (ម្យ៉ាងទៀត)

**យា ទេវតា សន្តិ វិហារវាសិនី**
**ថូបេ ឃរេ ពោធិ ឃរេ តហឹ តហឹ**
**តា ធម្មទានេន ភវន្តុ បូជិតា**
**សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ**
**ថេរា ច មជ្ឈា នវកា ច ភិក្ខវោ**
**សារាមិកា ទានបតី ឧបាសកា**
**គាមា ច ទេសា និគមា ច ឥស្សរា**
**សប្បាណភូតា សុខិតា ភវន្តុ តេ**
**ជលាពុជា យេបិ ច អណ្ឌសម្ភវា**
**សំសេទជាតា អថវោបបាតិកា**
**និយ្យានិកំ ធម្មវរំ បដិច្ច តេ**
**សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។**

**ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ សមគ្គោវ អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ ។**

<u>ប្រែ</u> : **យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃ ឰដ៏ខឿនព្រះសថូប ឰដ៏ខឿនព្រះពោធិព្រឹក្ស ក្នុងទីនោះ ៗ,

**តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គល គឺយើងទាំងឡាយបូជាហើយ ដោយធម្មទាន,

**សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្ត ជាទីនៅនៃសង្ឃនេះ,

**ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយ ជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី,

**សារាមិកា ទានបតី ឧបាសកា** ឧបាសក និង ឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្តី,

**គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈ ជាធំក្តី,

**សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ,

**ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថោប-បាតិកា** មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី,

**និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ,

**ឋាតុ ចិរំ សតំ ធម្មោ** សូមឱ្យធម៌របស់សប្បុរសទាំងឡាយ ឋិតនៅអស់កាលយូរអង្វែងទៅ,

**ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ចូរឋិតនៅអស់កាលយូរអង្វែងទៅ,

**សង្ឃោ ហោតុ សមគ្គោ វ** សូមព្រះសង្ឃព្រមព្រៀងគ្នា,

**អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង,

**អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ, សូមរក្សានូវអ្នក ដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង,

**វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** សូមឱ្យយើងទាំងឡាយបានដល់នូវ សេចក្តីចម្រើនក្នុងធម៌ ដែលព្រះអរិយៈទាំងឡាយលោកសម្តែងហើយ ។./.

# អនុមោទនារក្ខាយាចនគាថា

~ **អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវានាគា មហិទ្ធិកា**
**បុញ្ញំ នោ**[១] **អនុមោទន្តុ   ចិរំ រក្ខន្តុ សាសនំ ។**

ប្រែថា : ទេវតាទាំងឡាយ ដែលឋិតឮដ៏អាកាសក្តី ដែលឋិតនៅលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមឱ្យអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះពុទ្ធសាសនា (ឱ្យឋិតថេរ និង ឱ្យរុងរឿង) យូរអង្វែងទៅ ។

~ **អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវានាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ រាជានោ ។**

ប្រែថា : ទេវតាទាំងឡាយ ដែលឋិតឮដ៏អាកាសក្តី ដែលឋិតនៅលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមឱ្យអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមឱ្យរក្សានូវព្រះរាជាទាំងឡាយ (ឱ្យឋិតក្នុងរាជ្យ និង ឱ្យមានជ័យ) ជាអង្វែងទៅ ។

~ **អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវានាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ ញាតយោ ។**

ប្រែថា : ទេវតាទាំងឡាយ ដែលឋិតឮដ៏អាកាសក្តី ដែលឋិតនៅលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមឱ្យអនុមោទនា

[១] **បុញ្ញំ នោ** បើសូត្រម្នាក់ឯងត្រូវថា **បុញ្ញំ មេ** ប្រែថា : បុណ្យរបស់ខ្ញុំ ។

នូវបុណ្យរបស់យើងទាំងឡាយ សូមឱ្យរក្សានូវពួកញាតិទាំងឡាយ (ឱ្យចម្រុងចម្រើន និង ឱ្យសុខសាន្ត) ជាអង្វែងទៅ ។

~ **អាកាសដ្ឋា ច ភុម្មដ្ឋា ទេវានាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតកេ** ។

ប្រែថា : ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតនៅលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមឱ្យអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមឱ្យរក្សានូវសត្វទាំងឡាយ (ឱ្យចម្រុងចម្រើន និង ឱ្យសុខសាន្ត) ជាអង្វែងទៅ ។

~ **អាកាសដ្ឋា ច ភុម្មដ្ឋា ទេវានាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ**[១] **សទា** ។

ប្រែថា : ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតនៅលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមឱ្យអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ (ឱ្យចម្រុងចម្រើន និង ឱ្យសុខសាន្ត) យូរយារ គ្រប់កាលទាំងពួង ។

---

[១] **បុញ្ញំ នោ** បើសូត្រម្នាក់ឯងត្រូវថា **បុញ្ញំ មេ** ប្រែថា : បុណ្យរបស់ខ្ញុំ ។

# បច្ចវេក្ខណវិធី

កុលបុត្រដែលបួសក្នុងព្រះពុទ្ធសាសនា ត្រូវសិក្សាក្នុងបច្ចវេក្ខណៈលក្ខណៈ សម្រាប់ពិចារណានូវបច្ច័យ ដែលខ្លួនត្រូវអាស្រ័យ ឲ្យចេះចាំស្ទាត់ទាំងបាលី និង សេចក្ដីប្រែជាសម្រាយ ឯបច្ច័យដែលបព្វជិតត្រូវអាស្រ័យនោះ មាន ៤ គឺៈ

- **ចីវរប្បច្ច័យ** សំពត់ដែលបព្វជិតត្រូវស្លៀកដណ្ដប់ប្រើប្រាស់បាន មានត្រៃចីវរជាដើម១,

- **បិណ្ឌបាតប្បច្ច័យ** ភោជនាហារ ដែលបព្វជិតត្រូវបរិភោគបាន តាំងអំពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ មានបាយ នំ ជាដើម១,

- **សេនាសនប្បច្ច័យ** ទីសេនាសនៈដែលបព្វជិតត្រូវអាស្រ័យប្រើប្រាស់បាន មានកុដិ សាលាជាដើម១,

- **គិលានប្បច្ច័យ** ថ្នាំសម្រាប់មនុស្សមានជំងឺ ដែលបព្វជិតត្រូវបរិភោគប្រើប្រាស់បាន មានសប្បិជាដើម១ ។

ក្នុងបច្ច័យមួយ ៗ នោះ ពោលដោយបច្ចវេក្ខណៈ គឺលក្ខណៈសម្រាប់ពិចារណាមាន ៤ គឺ **ធាតុបច្ចវេក្ខណៈ**១ **បដិកូលបច្ចវេក្ខណៈ**១, **តទុភយបច្ចវេក្ខណៈ**១ និង **អតីតបច្ចវេក្ខណៈ**១ ។

## ១- ធាតុបច្ចវេក្ខណៈ

**ធាតុបច្ចវេក្ខណៈ**នោះ គឺឲ្យពិចារណាក្នុងការដែលទទួលនូវបច្ច័យ៤ ឲ្យឃើញជា **ធាតុ** ។

*កាលដែលទទួលនូវ **ចីវរបច្ច័យ** ឲ្យពិចារណាដូច្នេះថា:

- **យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

***សំពត់ចីវរ***ឯណានេះ ***សំពត់ចីវរ***នេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកប្រើប្រាស់នូវសំពត់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

* *កាលដែលទទួលនូវ* **<u>បិណ្ឌបាតបច្ច័យ</u>** *ឲ្យពិចារណាដូច្នេះថា:*

- **យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ <u>បិណ្ឌបាតោ</u> តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

*<u>ចង្ហាន់បិណ្ឌបាត</u>ឯណានេះ <u>ចង្ហាន់បិណ្ឌបាត</u>នេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺ អាត្មាដែលជាអ្នកបរិភោគនូវចង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។*

* *កាលដែលទទួលនូវ* **<u>សេនាសនបច្ច័យ</u>** *ឲ្យពិចារណាដូច្នេះថា:*

- **យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ <u>សេនាសនំ</u> តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

*<u>**ទីសេនាសនៈ**</u>ឯណានេះ <u>**ទីសេនាសនៈ**</u>នេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺ*

*អាត្មា ដែលជាអ្នកបរិភោគប្រើប្រាស់**ទីសេនាសនៈ**នោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។*

* *កាលដែលទទួលនូវ* **គិលានប្បច្ច័យ** *ឲ្យពិចារណាដូច្នេះថា:*

- **យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។**

*គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ, គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។*

## ២- **បដិកូលប្បច្ចវេក្ខណៈ**

**បដិកូលប្បច្ចវេក្ខណៈ** *គឺឱ្យពិចារណាក្នុងខណៈដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ ៤ ឱ្យឃើញថាជារបស់បដិកូល គួរខ្ពើមរអើម ។*

**កាលដែលប្រារព្ធនឹងប្រើប្រាស់នូវ* **ចីវរប្បច្ច័យ** *ឱ្យពិចារណាដូច្នេះថាៈ*

- **សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។**

*សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។*

**កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់នូវ* **បិណ្ឌបាតប្បច្ច័យ** *ឱ្យពិចារណាដូច្នេះថាៈ*

- **សព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។**

*ចង្ហាន់បិណ្ឌបាតទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។*

**កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់នូវ* **សេនាសនប្បច្ច័យ** *ឱ្យពិចារណាដូច្នេះថា:*

- **សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។**

*ទីសេនាសនៈទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។*

**កាលដែលប្រារព្ធនឹងបរិភោគនូវ* **គិលានប្បច្ច័យ** *ឱ្យពិចារណាដូច្នេះថា:*

- **សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។**

*គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំ ជាបច្ច័យដល់អ្នកជំងឺទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។*

## ៣- **តង្ខណិកបច្ចវេក្ខណៈ**

**តង្ខណិកបច្ចវេក្ខណៈ***នោះ គឺពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យ ៤ ។*

* *កាលដែលប្រើប្រាស់នូវ* **ចីវរបច្ច័យ** *ឱ្យពិចារណាថា:*

- **បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសប សម្ផស្សានំ បដិឃា--តាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

*បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ កំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវ*

សម្ផស្ស រំបោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំ ទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្ដីខ្មាសអៀនឱ្យកម្រើក ។

*  កាលដែលបរិភោគនូវ **<u>បិណ្ឌបាតប្បច្ច័យ</u>** ឱ្យពិចារណាដូច្នេះ ថា:

- **បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ-ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរា-ណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បា-ទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។**

បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានះស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរ ដូចអ្នកលេងរបាំក៏ទេ,

*បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់នូវសេចក្ដីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយៈ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្ដីឃ្លានដែលមានហើយផង និងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង, កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្ដី សេចក្ដីមិនមានទោស មានមិនប្រអូសកាយ មិនប្រអូសចិត្តជាដើមក្ដី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្ដី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។*

* *កាលដែលប្រើប្រាស់នូវ* **សេនាសនប្បច្ច័យ** *ឱ្យពិចារណាដូច្នេះ ថា:*

- **បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ--ឃាតាយ ឌំសមកស វាតាតបសិរីសប សម្ផស្សា-នំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។**

*បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគប្រើប្រាស់នូវទីសេនាសនៈនេះ កំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូចពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបន្ទោបង់នូវគ្រោះក្រវល់ក្រវាយដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។*

* *កាលដែលបរិភោគនូវ* **<u>គិលានបច្ច័យ</u>** *ឱ្យពិចារណាដូច្នេះ ថា:*

- **បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។**

*បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំ ជាបច្ច័យដល់អ្នកជំងឺ កំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។*

## ៤- អតីតប្បច្ចវេក្ខណៈ

**អតីតប្បច្ចវេក្ខណៈ**នោះ គឺឲ្យពិចារណានូវបច្ច័យ ៤ ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានតែក្នុងថ្ងៃនោះ គឺក្នុងវេលាយប់១ ថ្ងៃ១ កុំឲ្យអរុណរះឡើងទាន់, ក្នុងបច្ចវេក្ខណៈមួយៗ ពិចារណា១ចប់ ឬ ២ចប់ ឬ ៣ចប់ក៏បាន ។

* កាលដែលនឹងពិចារណានូវ **ចីវរប្បច្ច័យ** ឱ្យពិចារណាដូច្នេះថា:

- **អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវ--ទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតា--យ ឌំសមកស វាតាតបសិរឹសប សម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់កំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្ដីអៀនខ្មាសឱ្យកម្រើក ។

* *កាលដែលនឹងពិចារណានូវ* **បិណ្ឌបាតប្បច្ច័យ** *ឱ្យពិចារណាដូច្នេះថា:*

- **អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។**

*ចង្ហាន់បិណ្ឌបាតឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ ចង្ហាន់បិណ្ឌបាតនោះ អញបរិភោគដើម្បីនឹងលេង ដូចក្មេងអ្នកស្រុកក៏ទេ, ដើម្បីនឹងឱ្យកើតបុរិសមានះស្រវឹងដូចអ្នកប្រដាល់ក៏ទេ, ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរីក៏ទេ, ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរ ដូចអ្នកលេងរបាំក៏ទេ, បរិភោគកំណត់ទុកដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់នូវសេចក្ដីលំបាក ដើម្បីនឹងអនុគ្រោះ*

*ដល់ព្រហ្មចរិយៈ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្ដីឃ្លានដែលមានហើយផង និង ញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង, កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្ដី សេចក្ដីមិនមានទោស មានមិនប្រអូសកាយ មិនប្រអូសចិត្តជាដើមក្ដី កិរិយានៅសប្បាយក្នុងឥរិ-‌-យាបថទាំង ៤ ក្ដី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។*

* *កាលដែលនឹងពិចារណានូវ* **សេនាសនប្បច្ច័យ**
*ឱ្យពិចារណាដូច្នេះថា:*

- **អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកស វាតាតបសិរឹសប សម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោ-‌ទនំ បដិសល្លានារាមត្ថំ ។**

*ទីសេនាសនៈឯណា ដែលអញមិនបានពិចារណាហើយ បរិភោគប្រើប្រាស់ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគប្រើប្រាស់កំណត់ទុក ដើម្បីនឹងការពារនូវ*

*ត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំទាំងឡាយ, កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវគ្រវល់គ្រវាយដែលកើតឡើងអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។*

* *កាលដែលនឹងពិចារណានូវ* **<u>គិលានប្បច្ច័យ</u>**
*ឱ្យពិចារណាដូច្នេះថា:*

- **អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ គិលានប្បច្ចយ--ភេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្ប-ន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។**

*គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ, គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំ ជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។*

**ចំណាំ:** បើកាលដែលទទួល និង កាលដែលប្រារព្ធដើម្បីបរិភោគ និង កាលដែលបរិភោគនោះ បានពិចារណាដោយ **ធាតុប្ប-ច្ចវេក្ខណៈ** ដោយ **បដិកូលប្បច្ចវេក្ខណៈ** ដោយ **តទុភយ-កប្បច្ចវេក្ខណៈ** រួចសព្វគ្រប់ហើយ នឹងមិនបាច់ពិចារណាក្នុង **អតីតប្បច្ចវេក្ខណៈ** ទៀត ក៏បាន ។៚

(**ចប់បច្ចវេក្ខណៈវិធី**)

(បានផ្ទៀងផ្ទាត់ជាមួយនឹងសៀវភៅ **សាមណេរវិន័យ** របស់ព្រះគ្រូសង្ឃសត្ថា**ជួន-ណាត**, ព្រះគ្រូសង្ឃវិជ្ជា **ហួត-តាត** និង ព្រះគ្រូវិមលប្បញ្ញា **អ៊ុម-ស៊ូ** *ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ* ក្នុង **ពុទ្ធសករាជ ២៥១៥**)

* **កំណត់សម្គាល់:** ក្នុងការប្រើស្រៈនិស្ស័យ ិ ី ឹ ឺ លើតួព្យញ្ជនៈ **ក គ ត ភ ខ** ដោយប្រើ **Font Unicode** Khmer OS Muol មានការប្រែទិដ្ឋភាពពី **កិ កី កឹ កឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ខិ ខី ខឹ** ទៅជាយ៉ាងនេះវិញ ៖ **ក ក ក ក. គ គ គ គ, ត ត ត ត, ភ ភ ភ ភ, ខ ខ ខ**... (**ជារបៀបសំណេរបែបបុរាណជូនតាខ្មែរ**), អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ និង អស់លោក-អ្នកសិក្ខាកាមទាំងឡាយ មេត្តាជ្រាប និង គប្បីបានស្គាល់យល់ដឹង ។

# ភត្តានុមោទនាវិធី

## ភត្តានុមោទនារម្ភគាថា

បើភិក្ខុសាមណេរអង្គឯណា ដែលបានទទួលនូវបច្ច័យអំពីទាយកទាយិកាហើយ គួរលោកដែលជាថេរៈ អនុមោទនាផ្តើមជាមុន ថាៈ

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ** *ផ្លូវទឹកទាំងឡាយ មានទន្លេ និង ស្ទឹងជាដើមដ៏ពេញ ដែលញ៉ាំងសាគរ គឺសមុទ្រឲ្យពេញព្រៀប ដូចម្តេចមិញ,*

**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ** *ទានដែលទាយក-ទាយិកា ឧទ្ទិសឲ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់អ្នកដែលចែកស្ថានទៅកាន់បរលោកហើយ ដូច្នោះឯង,*

**ឥច្ឆិតំ បត្ថិតំ តុម្ហំ ខិប្បមេវ សមិជ្ឈតុ** *សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរឲ្យសម្រេចដល់អ្នក ឲ្យបានឆាប់រួសរាន់ទាន់ចិត្ត,*

**សព្វេ បូរេន្តុ សង្កប្បា** *សូមតម្រិះត្រូវទាំងពួង ចូរពេញ (ដល់អ្នក),*

**ចន្ទោបណ្ណរសោ យថា** ដូចព្រះចន្ទ្រក្នុងថ្ងៃ១៥កើត,

**មណិ ជោតិរសោ យថា**[១] (ពុំនោះសោត) ដូចកែវមណី មានរស្មីដ៏រុងរឿង ជាកែវវិសេស អាចញុំាងសេចក្ដីប្រាថ្នាទាំងពួងឲ្យសម្រេចបាន ៕

## សាមញ្ញានុមោទនាគាថា

លោកអង្គឯទៀតទទួល ថា:

**សព្វីតិយោ វិវជ្ជន្តុ** សូមឲ្យចង្រៃទាំងពួង ទាំងឡាយប្រាសចេញ គឺថា ចូរឲ្យចៀសវាងចេញឆ្ងាយទៅ,

**សព្វរោគោ វិនស្សតុ** សូមឲ្យរោគទាំងពួង (របស់អ្នក) ជាសះស្បើយទៅ,

**មា តេ ភវត្វន្តរាយោ** អន្តរាយកុំបីមានដល់អ្នកឡើយ,

**សុខី ទីឃាយុកោ ភវ** សូមឲ្យអ្នកជាបុគ្គលមានសេចក្ដីសុខ មានអាយុវែង,

---

[១] ក្នុងគម្ពីរទាំងពួង លោករៀបបាលីជាពីរគាថា គឺ **ឥច្ឆិតំ បត្ថិតំ តុម្ហំ ...ចន្ទោបណ្ណរសោ យថា** ។ **ឥច្ឆិតំ បត្ថិតំ តុម្ហំ ... មណិ ជោតិរសោ យថា** ។

***សព្វីតិយោ វិវជ្ជន្តុ*** *សូមឲ្យចង្រៃទាំងពួង ទាំងឡាយប្រាសចេញ គឺថា ចូរឲ្យចៀសវាងចេញឆ្ងាយទៅ,*

..........................................................................................

***សុខី ទីឃាយុកោ ភវ*** *សូមឲ្យអ្នកជាបុគ្គលមានសេចក្ដីសុខ មានអាយុវែង ។* (៣ដង)

* **អភិវាទនសីលិស្ស　　និច្ចំ វុឌ្ឍាបចាយិនោ**
**ចត្តារោ ធម្មា វឌ្ឍន្តិ　　អាយុ វណ្ណោ សុខំ ពលំ!**

***ធម៌*** *គឺពរទាំងឡាយ ៤ ប្រការ គឺ អាយុ១ ពណ៌សម្បុរកាយ១ សេចក្ដីសុខ១ កម្លាំង១ រមែងចម្រើនអស់កាលជានិច្ចដល់អ្នកដែលមានសេចក្ដីឱនកាយថ្វាយបង្គំ ដល់ព្រះរតនត្រៃ ជាប្រក្រតី និង អ្នកដែលមានសេចក្ដីគោរពកោតក្រែងដល់បុគ្គល ដែលជាអ្នកមានសេចក្ដីចម្រើន ដោយគុណមានសីលគុណជាដើម ឬ ដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ ។*

# មង្គលចក្កវាឡ

**សព្វពុទ្ធានុភាវេន** *ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ,*

**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង

**សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង,

**ពុទ្ធរតនំ ធម្មរតនំ សង្ឃរតនំ តិណ្ណំ រតនានំ អានុភាវេន** ដោយអានុភាពនៃព្រះរតនៈទាំង៣ គឺពុទ្ធរតនៈ១ ធម្មរតនៈ១ សង្ឃរតនៈ១,

**ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន** ដោយអានុភាពនៃព្រះធម្មក្ខន្ធ ៨ម៉ឺន ៤ពាន់,

**បិដកត្តយានុភាវេន** ដោយអានុភាពនៃព្រះត្រៃបិដក,

**ជិនសាវកានុភាវេន** ដោយអានុភាពនៃសាវ័កនៃព្រះជិនស្រី,

**សព្វេ តេ រោគា** រោគទាំងឡាយទាំងពួងនៃអ្នក,

**សព្វេ តេ ភយា** ភ័យទាំងឡាយទាំងពួងនៃអ្នក,

**សព្វេ តេ អន្តរាយា** អន្តរាយទាំងឡាយទាំងពួងនៃអ្នក

**សព្វេ តេ ឧបទ្ទវា** ឧបទ្រពទាំងឡាយទាំងពួងនៃអ្នក

**សព្វេ តេ ទុន្និមិត្តា** និមិត្តអាក្រក់ទាំងឡាយទាំងពួងនៃអ្នក

**សព្វេ តេ អវមង្គលា** អពមង្គលទាំងឡាយទាំងពួងនៃអ្នក,

**វិនស្សន្តុ** សូមឲ្យវិនាសបាត់ទៅ!

**អាយុវឌ្ឍកោ** *សេចក្តីចម្រើនដោយអាយុ,*

**ធនវឌ្ឍកោ** *សេចក្តីចម្រើនដោយទ្រព្យ,*

**សិរីវឌ្ឍកោ** *សេចក្តីចម្រើនដោយសិរីសួស្តី,*

**យសវឌ្ឍកោ** *សេចក្តីចម្រើនដោយយសបរិវារ,*

**ពលវឌ្ឍកោ** *សេចក្តីចម្រើនដោយកម្លាំង,*

**វណ្ណវឌ្ឍកោ** *សេចក្តីចម្រើនដោយពណ៌សម្បុរកាយ,*

**សុខវឌ្ឍកោ** *សេចក្តីចម្រើនដោយសុខ,*

**ហោតុ សព្វទា** *សូមឱ្យមានដល់អ្នកឱ្យបានសព្វៗកាល,*

**ទុក្ខរោគភយា វេរា** *សេចក្តីទុក្ខ និង រោគ និង ភ័យ និង ពៀរទាំងឡាយក្តី,*

**សោកា សត្តូ ចុបទ្ទវា** *សេចក្តីសោកទាំងឡាយក្តី សត្រូវ និង ឧបទ្រពទាំងឡាយក្តី,*

**អនេកា អន្តរាយាបិ** *អន្តរាយទាំងឡាយដ៏ច្រើនក្តី,*

**វិនស្សន្តុ ច តេជសា** *សូមឲ្យវិនាសបាត់ទៅ ដោយតេជះ (នៃអានុភាព មានពុទ្ធានុភាពជាដើមនោះ),*

**ជយសិទ្ធិ ធនំ លាភំ** *សេចក្តីសម្រេចនៃជ័យជំនះក្តី ទ្រព្យក្តី លាភក្តី,*

**សោត្ថិភាគ្យំ សុខំ ពលំ** *សួស្តីក្តី ជោគជ័យល្អក្តី សេចក្តីសុខក្តី កម្លាំងក្តី,*

**សិរិ អាយុ ច វណ្ណោ ច** *បុញ្ញសិរីក្តី អាយុក្តី ពណ៌សម្បុរកាយក្តី,*

**ភោគំ វុឌ្ឍី ច យសវា** *ភោគសម្បទាក្តី សេចក្តីចម្រើនក្តី មានយសក្តី,*

**សតវស្សា ច អាយូ ច** *អាយុប្រមាណ ១រយឆ្នាំក្តី,*

**ជីវសិទ្ធី ភវន្តុ តេ** *សេចក្តីសម្រេចនៃកិរិយាចិញ្ចឹមជីវិតជាសុខក្តី (ទាំងអស់នេះ សូមឲ្យមានដល់អ្នក) !*

❋

☸ **ភវតុ សព្វមង្គលំ** *មង្គលទាំងពួង ចូរមានដល់អ្នក!*

**រក្ខន្តុ សព្វទេវតា** *សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក),*

**សព្វពុទ្ធានុភាវេន** *ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ,*

**សទា សោត្ថី ភវន្តុ តេ** *សួស្តីទាំងឡាយ ចូរមានដល់អ្នក ឲ្យបានសព្វកាល សព្វវេលា!*

☸ **ភវតុ សព្វមង្គលំ** មង្គលទាំងពួង ចូរមានដល់អ្នក!

**រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក),

**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង,

**សទា សោត្ថី ភវន្តុ តេ** សួស្តីទាំងឡាយ ចូរមានដល់អ្នក ឲ្យបានសព្វកាល សព្វវេលា!

☸ **ភវតុ សព្វមង្គលំ** មង្គលទាំងពួង ចូរមានដល់អ្នក!

**រក្ខន្តុ សព្វទេវតា** សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក),

**សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង,

**សទា សោត្ថី ភវន្តុ តេ** សួស្តីទាំងឡាយ ចូរមានដល់អ្នក ឲ្យបានសព្វកាល សព្វវេលា!

# វិសេសានុមោទនាវិធី

## កេណិយានុមោទនាគាថា

**អគ្គិហុត្តមុខា យញ្ញា** *គ្រឿងបូជាទាំងឡាយ មានការបូជាភ្លើងជាប្រធាន (ក្នុងសាសនារបស់ព្រាហ្មណ៍),*

**សាវិត្តី ឆន្ទសោ មុខំ** *គម្ពីរសាវិត្តិសាស្ត្រ ជាប្រធាននៃគម្ពីរឆន្ទសាស្ត្រ,*

**រាជា មុខំ មនុស្សានំ** *ស្តេចទ្រង់រាជ្យ ជាប្រធានរបស់មនុស្សទាំងឡាយ,*

**នទីនំ សាគរោ មុខំ** *សាគរ គឺសមុទ្រ ជាប្រធានរបស់ទន្លេ និង ស្ទឹងទាំងឡាយ,*

**នក្ខត្តានំ មុខំ ចន្ទោ** *ព្រះចន្ទ្រ ជាប្រធានរបស់នក្សត្រ គឺផ្កាយទាំងឡាយ (ឰដ៏អាកាស),*

**អាទិច្ចោ តបតំ មុខំ** *ព្រះអាទិត្យ ជាប្រធានរបស់កំដៅទាំងឡាយ (ដូចម្តេចមិញ),*

**បុញ្ញមាកង្ខមានានំ សង្ឃោ វេ យជតំ មុខំ** *ព្រះសង្ឃ ជាប្រធានរបស់ជនទាំងឡាយ អ្នកប្រាថ្នានូវបុណ្យប្រគេនទាន (ក៏ដូច្នោះឯង) ៕*

# **កាលទានប្បកាសនគាថា**

## (**គាថាសម្រាប់ប្រកាសកាលទាន**)

**ភណិស្សាម មយំ គាថា កាលទានប្បទីបិកា** *យើងទាំងឡាយ នឹងសូត្រនូវព្រះគាថាទាំងឡាយ ដែលសម្តែងនូវកាលទាន,*

**ឯតា សុណន្តុ សក្កច្ចំ ទាយកា បុញ្ញកាមិនោ** *ទាយក ទាយិកា ទាំងឡាយ ជាអ្នកប្រាថ្នានូវបុណ្យ ចូរស្តាប់នូវព្រះគាថាទាំងនេះ ដោយគោរពចុះ!*

(ត្រង់ពាក្យថា **កាលទានប្បទីបិកា** នេះ បើប្រកាសពីវិហារទានវិញ ត្រូវផ្លាស់ថា **វិហារទានប្បទីបិកា** ដូច្នេះ) ។

# **កាលទានសុត្តគាថា**

**កាលេ ទទន្តិ សប្បញ្ញា វទញ្ញូ វីតមច្ឆរា** *ជនអ្នកមានប្រាជ្ញាទាំងឡាយ ជាអ្នកដឹងនូវពាក្យពេចន៍នៃអ្នកប្រាជ្ញ ជាអ្នកមានសេចក្តីកំណាញ់ប្រាសចេញហើយ រមែងឱ្យនូវទានក្នុងកាល,*

**កាលេន ទិន្នំ អរិយេសុ ឧជុភូតេសុ តាទិសុ** *ទានដែលបុគ្គលឲ្យហើយ ដល់ព្រះអរិយបុគ្គលទាំងឡាយ ដែលជាបុគ្គលមានកាយ និង ចិត្តត្រង់ ជាអ្នកមិនញាប់ញ័រ ដោយលោកធម៌ទាំង៨ប្រការ ដោយត្រូវតាមកាលហើយ,*

**វិប្បសន្នមនា តស្ស វិបុលា ហោតិ ទក្ខិណា** *ទក្ខិណាទានរបស់បុគ្គលនោះ ជាទានមានផលពេញវិសេស ព្រោះមានចិត្តជ្រះថ្លា,*

**យេ តត្ថ អនុមោទន្តិ វេយ្យាវច្ចំ ករោន្តិ វា** *ជនទាំងឡាយឯណា គ្រាន់តែអនុមោទនា គឺត្រេកអរតាម ឬ គ្រាន់តែធ្វើនូវការខ្វល់ខ្វាយ គឺជួយខ្នះខ្នែងគេក្នុងទាននោះ,*

**ន តេន ទក្ខិណា ឩនា** *ទក្ខិណាទាន (របស់អ្នកទាំងនោះ) នឹងបានឈ្មោះថា ជាទានថយថោក ព្រោះហេតុគ្រាន់តែអនុមោទនា ឬធ្វើនូវការខ្វល់ខ្វាយ គឺជួយខ្នះខ្នែងគេនោះ* ***ក៏ទេ****,*

**តេបិ បុញ្ញស្ស ភាគិនោ** *ជនទាំងឡាយដែលជាអ្នកគ្រាន់តែអនុមោទនា ឬគ្រាន់តែជួយខ្នះខ្នែងគេនោះ ជាអ្នកមានចំណែកបុណ្យដោយពិត ។*

**តស្មា ទទេ អប្បដិវានចិត្តោ យត្ថ ទិន្នំ មហប្ផលំ** *ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលឯណា ជាទានមានផលានិសង្សច្រើន ជនដែលមានចិត្តមិនរួញរា គប្បីឲ្យ (នូវទានដល់បុគ្គលនោះ) ។*

**បុញ្ញានិ បរលោកស្មឹ បតដ្ឋា ហោន្តិ បាណិនំ** *(ព្រោះថា) បុណ្យទាំងឡាយ រមែងជាទីពឹងអាស្រ័យរបស់សត្វទាំងឡាយក្នុងលោកខាងមុខ ។*

# វិហារទានសុត្តគាថា

- **សីតំ ឧណ្ហំ បដិហន្តិ ততោ វាឡមិគានិ ច**
  **សរីសបេ ច មកសេ សិសិរេ ចាបិ វុដ្ឋិយោ ។**

(វិហារគឺទីអាវាស ឬទីសេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ) រមែងការពារនូវរងារផង នូវក្ដៅផង នូវម្រឹគសាហាវទាំងឡាយផង នូវពស់តូច ពស់ធំ នូវសត្វល្អិតទាំងឡាយផង នូវមូសទាំងឡាយផង នូវត្រជាក់ផង នូវគ្រាប់ភ្លៀងទាំងឡាយផង ក្នុងទីនោះ,

**តតោ វាតាតបោ ឃោរោ សញ្ជាតោ បដិហញ្ញតិ** ខ្យល់ និងកំដៅថ្ងៃដ៏ក្លាខ្លាំង ដែលកើតហើយរមែងត្រឡប់បាត់ទៅព្រោះវិហារនោះ,

**លេណត្ថញ្ច សុខត្ថញ្ច ឈាយិតុំ ច វិបស្សិតុំ**
**វិហារទានំ សង្ឃស្ស អគ្គំ ពុទ្ធេហិ វណ្ណិតំ**

វិហារទាន គឺកិរិយាឱ្យនូវអាវាស ឬទីសេនាសនៈជាទីនៅ (ដែលបុគ្គលបានឱ្យហើយ) ដល់សង្ឃ ដើម្បីជាទីជ្រកកោនផង ដើម្បីសេចក្តីសុខកាយសុខចិត្តផង ដើម្បីដុតបង់នូវបាបធម៌ផង ដើម្បីឃើញច្បាស់នូវសង្ខារ គឺចម្រើនវិបស្សនាផង ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់ត្រាស់សរសើរថា ជាទានដ៏ប្រសើរ ។

**តស្មា ហិ បណ្ឌិតោ បោសោ សម្បស្សំ អត្ថមត្តនោ** ព្រោះហេតុនោះ បុរស(ស្ត្រី)ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍នៃខ្លួន,

**វិហារេ ការយេ រម្មេ វាសយេត្ថ ពហុស្សុតេ** គប្បីកសាងវិហារ ទីអាវាស ឬទីសេនាសនៈទាំងឡាយ ឱ្យជាទីគួររីករាយហើយ គប្បីញ៉ាំងលោកជាពហុស្សូត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយ ឱ្យនៅក្នុងទីនោះ,

**តេសំ អន្នញ្ច បានញ្ច វត្ថសេនាសនានិ ច**
**ទទេយ្យ ឧជុភូតេសុ វិប្បសន្នេន ចេតសា**

គប្បីមានចិត្តជ្រះថ្លាក្នុងលោកទាំងឡាយ ដែលមានកាយ និង ចិត្តត្រង់ហើយ ឱ្យនូវម្ហូបចំណីផង នូវទឹកផង នូវសំពត់ និង សេនាសនៈទាំងឡាយផង ដល់លោកទាំងនោះ,

**តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខា បនូទនំ** លោកទាំងឡាយនោះ រមែងសំដែងនូវធម៌ជាគ្រឿងបន្ទោបង់ នូវសេចក្ដីទុក្ខទាំងពួងដល់អ្នកនោះ,

**យំ សោ ធម្មមិធញ្ញាយ បរិនិព្វាត្យនាសវោ** អ្នកនោះ លុះបានដឹងនូវធម៌ឯណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏រមែងជាអ្នកមិនមានអាសវៈ នឹងបានដល់នូវព្រះនិព្វាន (ព្រោះកិរិយាដឹងនូវធម៌នោះ) ។

## ទេវតោទ្ទិស្សទក្ខិណានុមោទនាគាថា

**យស្មឹ បទេសេ កប្បេតិ វាសំ បណ្ឌិតជាតិយោ** *ជនមានជាតិជាបណ្ឌិត សម្រេចនូវទីលំនៅក្នុងប្រទេសឯណា,*

**សីលវន្តេត្ថ ភោជេត្វា សញ្ញតេ ព្រហ្មចារិនោ** *បានញុំាំងលោកអ្នកមានសីល ជាព្រហ្មចារិបុគ្គល ដែលជាអ្នកសង្រួមទាំងឡាយ ឲ្យឆាន់ក្នុងទីនោះ,*

**យា តត្ថ ទេវតា អាសុំ តាសំ ទក្ខិណមាទិសេ** *ទេវតាទាំងឡាយឯណាមានហើយក្នុងទីនោះ (ជនមានជាតិជាបណ្ឌិតនោះ) គួរឧទ្ទិសផ្សាយនូវផលនៃទក្ខិណាទាន ដល់ទេវតាទាំងឡាយនោះផង,*

**តា បូជិតា បូជយន្តិ មានិតា មានយន្តិ នំ** *ទេវតាទាំងឡាយនោះ ជាបុគ្គលគឺបណ្ឌិតនោះបូជាហើយ រាប់អានហើយ (ដោយផលនៃទក្ខិណាទាននោះ) រមែងបូជា រមែងរាប់អានន្ទូវបណ្ឌិតនោះវិញ,*

**តតោ នំ អនុកម្បន្តិ មាតា បុត្តំវ ឱរសំ** *ព្រោះហេតុដែលបណ្ឌិតនោះ បានឧទ្ទិសផលនៃទក្ខិណាទានដល់ខ្លួន (ទេវតាទាំងឡាយនោះ) រមែងអនុគ្រោះនូវបណ្ឌិតនោះ ដូចជាមាតាអនុគ្រោះនូវកូនបង្កើត,*

**ទេវានុកម្បិតោ បោសោ សទា ភទ្រានិ បស្សតិ** *បុរស (ស្ត្រី) ដែលទេវតាបានអនុគ្រោះហើយ រមែងឃើញនូវកម្មដ៏ចម្រើនទាំងឡាយ ក្នុងកាលទាំងពួង ។*

## អគ្គប្បសាទសុត្តគាថា

~ អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ

**អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ**
**អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។**

បុណ្យដ៏ប្រសើរ រមែងចម្រើន, អាយុដ៏ប្រសើរផង សម្បុរកាយដ៏ប្រសើរផង យសសក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែងចម្រើនដល់ជនទាំងឡាយ ដែលដឹងច្បាស់នូវធម៌ដ៏ប្រសើរ ដែលជាអ្នកជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរដោយពិត, ដែលជ្រះថ្លាក្នុងព្រះពុទ្ធជាបុគ្គលដ៏ប្រសើរលើសលប់ ជាទក្ខិណេយ្យបុគ្គល រកអ្នកឯណាមួយឱ្យស្មើនឹងព្រះអង្គគ្មាន, ដែលជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌រម្ងាប់បង់នូវរាគាទិកិលេស ជាធម៌នាំមកនូវសេចក្តីសុខ (ដល់អ្នកប្រតិបត្តិ ), ដែលជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យ រកស្រែបុណ្យឯទៀតឱ្យក្រៃលែងជាងគ្មាន, ដែលជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើរ,

**អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ** បុគ្គលមានប្រាជ្ញា ដែលមានចិត្តតម្កល់ក្នុងធម៌ដ៏ប្រសើរហើយ ជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើរ,

**ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតិ** តែងនឹងបានទៅហើយជាទេវតា ឬមនុស្ស ក៏រមែងបានដល់នូវភាវៈជាអ្នកប្រសើរ ហើយរីករាយសប្បាយ ។

# ជីវភត្តានុមោទនាគាថា

**បណ្ឌុបលាសោវទានិសិ** ខ្លួនអ្នកក្នុងកាលឥឡូវនេះ ជាបុគ្គលប្រៀបដូចស្លឹកឈើទុំមានពណ៌លឿង,

**យមបុរិសាបិ ច តេ ឧបដ្ឋិតា** បុរស (ជាបំរើ) នៃយមរាជ គឺមរណៈសោត ក៏ប្រាកដដល់អ្នកហើយ,

**ឧយ្យោគមុខេ បតិដ្ឋសិ** អ្នកជាបុគ្គលឋិតនៅក្នុងប្រធាន នៃសេចក្តីសាបសូន្យ,

**បាថេយ្យំបិ ច តេ ន វិជ្ជតិ** ស្បៀងគឺកុសលរបស់អ្នកសោតក៏គ្មាន,

**សោ ករោហិ ទីបមត្តនោ** ចូរអ្នកធ្វើនូវទីពឹងនៃខ្លួនចុះ,

**ខិប្បំ វាយម បណ្ឌិតោ ភវ** ចូរអ្នកតាំងព្យាយាមរួតរះ ជាអ្នកឈ្លាស (កុំជាមនុស្សល្ងង់ខ្លៅឡើយ),

**និទ្ធន្តមលោ អនង្គណោ ទិព្វំ អរិយភូមិមេហិសិ** អ្នក (កាលធ្វើយ៉ាងនេះ) នឹងជាបុគ្គលមានមន្ទិល (មានរាគៈជាដើម) ខ្ជាត់ចេញ មិនមានគ្រឿងពួន គឺកិលេស ហើយនឹងដល់នូវអរិយភូមិដ៏ជាទិព្វ ។

# បុព្វបេតពលិទានានុមោទនាគាថា

- **យំកិញ្ចារម្មណំ កត្វា ទជ្ជា ទានមមច្ឆរី**
  **បុព្វេ បេតេ ច អារព្ភ អថ វា វត្ថុទេវតា**

*កុលបុត្រធ្វើនូវហេតុឯណានីមួយឲ្យជាអារម្មណ៍ គឺប្រារព្ធនូវមាតា និង បិតាទាំងឡាយ ដែលរំលាងខន្ធទៅកាន់បរលោកហើយ ក្នុងកាលមុនបង្អស់រួចហើយ (គប្បីប្រារព្ធ) នូវទេវតាទាំងឡាយ ដែលអាស្រ័យនៅក្នុងទីទាំងឡាយ មានទីផ្ទះជាដើម ហើយត្រូវកុំកំណាញ់ ត្រូវឱ្យនូវទាន,*

- **ចត្តារោ ច មហារាជេ លោកបាលេ យសស្សិនោ**
  **កុវេរញ្ច ធតរដ្ឋំ វិរូបក្ខំ វិរូឡ្ហកំ**

*(គប្បីប្រារព្ធ) នូវទេវតាជាលោកបាលទាំងឡាយ ដែលជាស្តេចធំ ៤ គឺៈ ព្រះបាទ**កុវេរៈ**១ ព្រះបាទ**ធតរដ្ឋ**១ ព្រះបាទ**វិរូបក្ខៈ**១ ព្រះបាទ**វិរុឡ្ហកៈ**១ ដែលជាស្តេចនៃទេវតា មានយសបរិវារ,*

**តេ ចេវ បូជិតា ហោន្តិ ទាយកា ច អនិប្ផលា**

*ស្តេចទេវតាទាំងឡាយនោះ បើគេបានបូជាហើយ (ដោយ*

ឧទ្ទិសផលបុណ្យជូនទៅ) អ្នកដែលឧទ្ទិសផលបុណ្យជូនទៅនោះ មិនមែនជាឥតផលទេ គឺបានផលានិសង្សជាប្រាកដ,

**ន ហិ រុណ្ណំ វា សោកោ វា យាចញ្ញា បរិទេវនា** កិរិយាយំក្តី សោកសៅក្តី សេចក្តីខ្សឹកខ្សួលណាមួយដទៃក្តី ក៏ឥតអំពើ,

**ន តម្បេតានមត្ថាយ ឯវំ តដ្ឋន្តិ ញាតយោ** កិច្ចមានយំសោកជាដើមនោះ មិនមែនជាប្រយោជន៍ដល់អ្នកដែលទៅកាន់បរលោកនាយហើយទាំងឡាយឡើយ កាលបើបុគ្គលយំសោក ខ្សឹកខ្សួល អាល័យ ខាងក្រោយដូច្នេះ ញាតិទាំងឡាយ (ដែលទៅកាន់បរលោកនាយហើយនោះ) ក៏ឥតបានដឹងបានឮឡើយ (ជាការឥតប្រយោជន៍ទទេ),

**អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុបតដ្ឋិតា** បើទក្ខិណាទាន ដែលបុគ្គលបានឲ្យហើយនេះឯង ជាទានតម្កល់នៅល្អហើយក្នុងព្រះសង្ឃ,

**ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ** ទក្ខិណាទាននោះ ទើបអាចសម្រេចផល ដើម្បីជាប្រយោជន៍ដល់

*ញាតិ ដែលទៅកាន់លោកខាងនាយហើយនោះ អស់កាលដ៏អង្វែងទៅ ដោយសមតាមហេតុ គឺទី ដែលគួរសម្រេចបាន ។*

(ហេតុដែលគួរសម្រេចបាននោះ គឺ **ខុប្បិបាសិកវន្តប្រេត បរទត្តុបជីវិតប្រេត និជ្ឈាមតណ្ហិកប្រេត** ជាអាទិ៍) ។

# តិរោកុឌ្ឍកណ្ឌគាថា

- **តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសឹឃាដកេសុ ច**
**ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ**

*ពួកប្រេតទាំងឡាយមកហើយ កាន់ផ្ទះនៃញាតិដោយគិតថាផ្ទះរបស់ខ្លួន រមែងឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និង ផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និង ទ្វារផ្ទះទាំងឡាយខ្លះ,*

**បហុតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ** នាកាលបាយ និងទឹក និងបង្អែម និងចំអាបដ៏ល្មមគ្រាន់ គឺពួកញាតិចូលទៅតាំងទុកហើយ,

**ន តេសំ កោចិ សរតិ សត្តានំ កម្មប្បច្ចយា** ញាតិណាមួយ មិននឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយ ជាបច្ច័យ,

**ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា**
**សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ**

ញាតិទាំងឡាយឯណា តែងអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹក និង ភោជនដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ ជាអ្នកលះលោកនេះ ទៅហើយនោះ យ៉ាងនេះថា :

**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ**
ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្តីសុខ !

**តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា**
ក៏ប្រេតជាញាតិទាំងឡាយនោះ មកប្រជុំគ្នាហើយ ក្នុងស្ថានដែលឱ្យទាននោះ ជាអ្នកមកហើយដោយបំណងល្អ,

**បហូតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ**
កាលបើថ្វាយបាយ និង ទឹកដ៏ល្មមគ្រាន់ ក៏គប្បីអនុមោទនាដោយគោរពថា :

**ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាម សេ** យើងទាំងឡាយបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយឯណា សូមញាតិទាំងឡាយនោះរបស់យើងទាំងឡាយ ចូររស់នៅយឺនយូរ,

**អម្ហាកញ្ច កតា បូជា** ក៏បូជាគឺញាតិទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយ,

**ទាយកា ច អនិប្ផលា** ឯទាយកគឺអ្នកឱ្យទាន ក៏មិនឥតផល,

**ន ហិ តត្ថ កសី អត្ថិ** កសិកម្មគឺការភ្ជួរស្រែចំការក៏មិនមានក្នុងភូមិនៃប្រេតនោះ,

**គោរក្ខេត្ថ ន វិជ្ជតិ** គោរក្ខកម្មគឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេតនោះ,

**វណិជ្ជា តាទិសី នត្ថិ** ពាណិជ្ជកម្មគឺការជួញ ដែលជាហេតុបានសម្បត្តិដូច្នោះ ក៏មិនមាន,

**ហិរញ្ញេន កយាកយំ** មិនមានការលក់ទិញផ្លាស់ប្តូរដោយប្រាក់

**ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហឹ**

បុគ្គលទាំងឡាយ ធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិឱ្យហើយអំពីលោកនេះ,

**ឧណ្ណតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ**
**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ**

ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទំនាប ដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ,

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ**

**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**

ជ្រលងផ្លូវទឹកទាំងឡាយ មានទន្លេ និង ស្ទឹងជាដើម រមែងញុំាងសាគរឱ្យពេញព្រៀបដូចម្ដេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ។

**អទាសិមេ អការសិមេ ញាតិមិត្តា សខា ច មេ**

**បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ**

បុគ្គលកាលរលឹកឃើញ នូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះ បានឱ្យរបស់នេះដល់អញ, អ្នកនេះ បានធ្វើគុណនេះដល់អញ, ជនទាំងឡាយនោះ ជាញាតិមិត្រ និង ជាសម្លាញ់របស់អញ ដូច្នេះហើយ គួរឱ្យទក្ខិណាទាន ដើម្បីប្រេតទាំងឡាយ,

**ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា** ការយំ ឬការសោកសៅ ឬការខ្សឹកខ្សួលដទៃ ៗ មិនមានប្រយោជន៍ឡើយ,

**ន តំ បេតា នមត្ថាយ** ធ្វើដូច្នេះរកបានជាប្រយោជន៍ ដល់ប្រេតទាំងឡាយគ្មាន,

**ឯវំ តិដ្ឋន្តិ ញាតយោ** ញាតិទាំងឡាយរមែងស្ថិតនៅ ឥតបានដឹង បានឮ យ៉ាងនេះ,

**អយញ្ច ខោ ទក្ខិណា ទិន្នា** បើទក្ខិណាទាន ដែលបុគ្គលបាន ឱ្យហើយនេះឯង,

**សង្ឃម្ហិ សុប្បតិដ្ឋិតា** ជាទានតម្កល់នៅល្អហើយក្នុងសង្ឃ,

**ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ** ទក្ខិណាទាន នោះ ទើបចូលទៅសម្រេចតាមស្ថាន ដើម្បីជាប្រយោជន៍ដល់ប្រេត ទាំងនោះ អស់កាលជាយូរអង្វែង,

**សោ ញាតិធម្មោ ច អយំ និទស្សិតោ** ក៏ញាតិធម៌នោះ គឺអ្នកបានសំដែងជាបែបយ៉ាងហើយ,

**បេតាន បូជា ច កតា ឧឡារា** ការបូជាដ៏ថ្លៃថ្លា ចំពោះដល់ ប្រេតទាំងឡាយ គឺអ្នកបានធ្វើហើយ,

**ពលញ្ច ភិក្ខូនមនុប្បទិន្នំ** កម្លាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះ ថា គឺអ្នកបានបំពេញឱ្យហើយ,

**តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ** បុណ្យគឺអ្នកសន្សំទុកហើយ មិនមែនតិចដូច្នេះ ។./.

# យាគុអនុមោទនាគាថា

\- យោ សញ្ញតានំ បរទត្តភោជិនំ
កាលេន សក្កច្ច ទទាតិ យាគុំ
ទសស្ស ឋានានិ អនុប្បវេច្ឆតិ
អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច ។

\- បដិភាណមស្ស ឧបជាយតេ តតោ
ខុទ្ទំ បិបាសំ ព្យបនេតិ វាតំ
សោធេតិ វត្ថិំ បរិណាមេតិ ភត្តំ
ភេសជ្ជមេតំ សុគតេន វណ្ណិតំ ។

\- តស្មា ហិ យាគុំ អលមេវ ទាតុំ
និច្ចំ មនុស្សេន សុខត្ថិកេន
ទិព្វានិ វា បត្ថយតា សុខានិ
មនុស្សសោភគ្គតមិច្ឆតា វា ។

ជនឯណា បានឱ្យបបរដោយគោរពដល់ពួកសមណៈ ដែលជាអ្នកសង្រួម ជនបរិភោគភោជន ដែលអ្នកដទៃឱ្យក្នុងកាលដ៏គួរ (ជននោះ) ឈ្មោះថា ឱ្យនូវហេតុនៃអានិសង្សទាំង ១០ យ៉ាង គឺ ៖ អាយុ១, ពណ៌សម្បុរ១, សេចក្តីសុខ១, កម្លាំងកាយ១, ប្រាជ្ញារបស់បុគ្គលនោះតែងកើតឡើង១, បបរនោះតែងកំចាត់បង់សេចក្តីឃ្លាន១ សេចក្តីស្រេក១,

និង ញ៉ាំងខ្យល់ (ឱ្យបានដើរស្រួល១), ញ៉ាំងសរសៃឱ្យបានស្អាត១, ញ៉ាំងភត្តឱ្យរលួយ១, នេះភេសជ្ជៈដែល **ព្រះសុគត** ទ្រង់សរសើរហើយ ។

*ព្រោះហេតុនោះ អ្នកមានសេចក្ដីត្រូវការ ចង់បានសេចក្ដីសុខជារបស់មនុស្សក្ដី ប្រាថ្នាសេចក្ដីសុខជារបស់ទិព្វក្ដី ចង់បានសេចក្ដីល្អរុងរឿងក្នុងមនុស្សក្ដី គួរឱ្យបបរជានិច្ចចុះ ។*

# សិទ្ធិយាចនគាថា

- **សិទ្ធមត្ថុ សិទ្ធមត្ថុ សិទ្ធមត្ថុ ឥទំ ផលំ**
  **ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ**

*សូមផលនៃចិត្ត ដែលជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ ផលនេះ ចូរជាផលសម្រេច! ចូរជាផលសម្រេច! ចូរជាផលសម្រេច!*

# យានទានានុមោទនាគាថា

(មានក្នុងសុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ បិ. ២៩, ទំ. ៨០)

~ **អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ**
**សេយ្យាវសថំ បទីបេយ្យំ ទានវត្ថូ ឥមេ ទស**

ទានវត្ថុទាំងឡាយ ១០ យ៉ាងនេះ គឺ : បាយ ទឹក សំពត់ យាន ជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសំណាក់អាស្រ័យ គ្រឿងប្រទីប គឺចង្កៀងគោម ។

- **អន្នទោ ពលទោ ហោតិ** អ្នកឱ្យរបស់ស៊ី ឈ្មោះថាឱ្យកម្លាំង,
- **វត្ថទោ ហោតិ វណ្ណទោ** អ្នកឱ្យសំពត់ ឈ្មោះថាឱ្យពណ៌,
- **យានទោ សុខទោ ហោតិ** អ្នកឱ្យយាន ឈ្មោះថាឱ្យសេចក្ដីសុខ,
- **ទីបទោ ហោតិ ចក្ខុទោ** អ្នកឱ្យប្រទីប ឈ្មោះថាឱ្យចក្ខុ គឺភ្នែក,
- **មនាបទាយី លភតេ មនាបំ** អ្នកឱ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត,
- **អគ្គស្ស ទាតា លភតេ បុនគ្គំ** អ្នកឱ្យវត្ថុដែលលើស រមែងបាននូវវត្ថុដែលលើស,
- **វរស្ស ទាតា វរលាភី ច ហោតិ** អ្នកឱ្យរបស់ល្អ រមែងបានរបស់ល្អ,
- **សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ** អ្នកឱ្យទីស្ថានដ៏ប្រសើរ រមែងចូលទៅដល់ទីស្ថានដ៏ប្រសើរ,

- **អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ** នរជនប្រុសស្រីឯណា ឱ្យរបស់ដែលលើស ឱ្យរបស់ដែលល្អ និង ទីស្ថានដ៏ប្រសើរ,

- **ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ** នរជនប្រុសស្រីនោះ កើតក្នុងទីណា ៗ រមែងជាអ្នកមានអាយុយឺនយូរ មានយសក្នុងទីនោះ ៗ,

**ឯតេន សច្ចវជ្ជេន** ដោយភាសិតសច្ចវាចានេះ,

**សុវត្ថិ ហោតុ សព្វទា អរោគិយសុខញ្ចេវ កុសលញ្ច អនាមយំ**

សូមឱ្យសេចក្តីសួស្តី និង សេចក្តីសុខ ដែលកើតអំពីសេចក្តីមិនមានរោគ និង អនាម័យ គឺ សេចក្តីប្រាសចាកទុក្ខព្យាធិ ស្រួលងាយ ចូរមានដល់អ្នកទាំងឡាយ ឱ្យបានគ្រប់កាល ។ ./.

* **កំណត់សម្គាល់:** ក្នុងការប្រើស្រះនិស្ស័យ ◌ិ ◌ី ◌ឹ ◌ឺ លើតួព្យញ្ជនៈ **ភ គ ត ភ ខ** ដោយប្រើ **Font Unicode** **Khmer OS Muol** មានការប្រែទិដ្ឋភាពពី **ភិ ភី ភឹ ភឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ខិ ខី ខឹ** ទៅជាយ៉ាងនេះវិញ ៖ **ភ ភ ភ ភ. គ គ គ គ, ត ត ត ត, ភ ភ ភ ភ, ខ ខ ខ**... (**ជារបៀបសំណេរបែបបុរាណជូនតាខ្មែរ**), អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ និង អស់លោក-អ្នកសិក្ខាកាមទាំងឡាយ មេត្តាជ្រាប និង គប្បីបានស្គាល់យល់ដឹង ។

# ធម៌សម្រាប់សូត្រដារវេរ និង បំសុកូល

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

(សូត្រ ៣ ដង)

## អភិធម្មបិដក ធម្មសង្គណិ

**(មាតិកា)**

១- **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា,**

២- **សុខាយ វេទនាយ សម្បយុត្តា ធម្មា, ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា, អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា,**

៣- **វិបាកា ធម្មា, វិបាកធម្មធម្មា, នេវ វិបាកនវិបាកធម្មធម្មា,**

៤- **ឧបាទិណ្ណុបាទានិយា ធម្មា, អនុបាទិណ្ណុបាទានិយា ធម្មា, អនុបាទិណ្ណានុបាទានិយា ធម្មា,**

៥- **សង្កិលិដ្ឋសង្កិលេសិកា ធម្មា, អសង្កិលិដ្ឋសង្កិលេសិកា ធម្មា, អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា,**

៦- **សវិតក្កសវិចារា ធម្មា, អវិតក្កវិចារមត្តា ធម្មា, អវិតក្កា-វិចារា ធម្មា,**

៧- **បីតិសហគតា ធម្មា, សុខសហគតា ធម្មា, ឧបេក្ខាសហគតា ធម្មា,**

៨- ទស្សនេន បហាតព្វា ធម្មា, ភាវនាយ បហាតព្វា ធម្មា, នេវទស្សនេន ន ភាវនាយ បហាតព្វា ធម្មា,

៩- ទស្សនេន បហាតព្វហេតុកា ធម្មា, ភាវនាយ បហាតព្វហេតុកា ធម្មា, នេវទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា,

១០- អាចយគាមិនោ ធម្មា, អប្បចយគាមិនោ ធម្មា, នេវាចយគាមិនោ នាប្បចយគាមិនោ ធម្មា,

១១- សេក្ខា ធម្មា, អសេក្ខា ធម្មា, នេវ សេក្ខា នាសេក្ខា ធម្មា,

១២- បរិត្តា ធម្មា, មហគ្គតា ធម្មា, អប្បមាណា ធម្មា,

១៣- បរិត្តារម្មណា ធម្មា, មហគ្គតារម្មណា ធម្មា, អប្បមាណារម្មណា ធម្មា,

១៤- ហីនា ធម្មា, មជ្ឈិមា ធម្មា, បណីតា ធម្មា,

១៥- មិច្ឆត្តនិយតា ធម្មា, សម្មត្តនិយតា ធម្មា, អនិយតា ធម្មា,

១៦- មគ្គារម្មណា ធម្មា, មគ្គហេតុកា ធម្មា, មគ្គាធិបតិនោ ធម្មា,

១៧- ឧប្បន្នា ធម្មា, អនុប្បន្នា ធម្មា, ឧប្បាទិនោ ធម្មា,

១៨- អតីតា ធម្មា, អនាគតា ធម្មា, បច្ចុប្បន្នា ធម្មា,

១៩- អតីតារម្មណា ធម្មា, អនាគតារម្មណា ធម្មា, បច្ចុប្បន្នារម្មណា ធម្មា,

២០- អជ្ឈត្តា ធម្មា, ពហិទ្ធា ធម្មា, អជ្ឈត្តពហិទ្ធា ធម្មា,

២១- អជ្ឈត្តារម្មណា ធម្មា, ពហិទ្ធារម្មណា ធម្មា, អជ្ឈត្តពហិទ្ធា-
រម្មណា ធម្មា,

២២- សនិទស្សនសប្បដិឃា ធម្មា, អនិទស្សនសប្បដិឃា ធម្មា,
អនិទស្សនាប្បដិឃា ធម្មា ។

ពាវីសតិតិកមាតិកា ធម្មសង្គណិបករណំ នាម សមត្តំ ។

(គម្ពីរឈ្មោះ ធម្មសង្គណី ដែលមានមាតិកា ២២ ចប់តែប៉ុណ្ណេះ)

# វិភង្គ (ក្នុងអដ្ឋកថា)

(តទនន្តរំ វិភង្គប្បករណំ នាមេតំ)

(លំដាប់អំពីធម្មសង្គណិប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវ វិភង្គប្បករណ៍ ដូចតទៅ) :

ខន្ធវិភង្គោ អាយតនវិភង្គោ ធាតុវិភង្គោ សច្ចវិភង្គោ ឥន្ទ្រិយវិភង្គោ បច្ចយាការវិភង្គោ សតិប្បដ្ឋានវិភង្គោ សម្មប្បធានវិភង្គោ ឥទ្ធិបាទវិភង្គោ ពោជ្ឈង្គវិភង្គោ មគ្គវិភង្គោ ឈានវិភង្គោ អប្បមញ្ញាវិភង្គោ សិក្ខាបទវិភង្គោ បដិសម្ភិទាវិភង្គោ ញាណវិភង្គោ ខុទ្ទកវត្ថុវិភង្គោ ធម្មហទយវិភង្គោតិ ។

(អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ)

(វិភង្គប្បករណ៍ ចែកចេញដោយវិភង្គ ១៨ ប្រការ ចប់តែប៉ុណ្ណេះ)

# ធាតុកថា (ក្នុងអដ្ឋកថា)

**(តទនន្តរំ ធាតុកថាបករណំ នាមេតំ)**

**សង្គហោ អសង្គហោ សង្គហិតេន អសង្គហិតំ អសង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន អសង្គហិតំ សម្បយោគោ វិប្បយោគោ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ សម្បយុត្តេន សម្បយុត្តំ វិប្បយុត្តេន វិប្បយុត្តំ សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ សម្បយុត្តេន សង្គហិតំ អសង្គហិតំ អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ ។**

**(ចុទ្ទសវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ)**

(ធាតុកថាបករណ៍ ចែកចេញដោយធាតុ ១៤ ប្រការ ចប់តែប៉ុណ្ណេះ)

# បុគ្គលបញ្ញត្តិ (ក្នុងអដ្ឋកថា)

**(តទនន្តរំ បុគ្គលបញ្ញត្តិប្បករណំ នាមេសា)**

**ខន្ធបញ្ញត្តិ អាយតនបញ្ញត្តិ ធាតុបញ្ញត្តិ សច្ចបញ្ញត្តិ ឥន្ទ្រិយបញ្ញត្តិ បុគ្គលបញ្ញត្តីតិ ។**

**(ឆវិធេន វិភត្តំ បុគ្គលបញ្ញត្តិប្បករណំ នាម សមត្តំ)**

(បុគ្គលបញ្ញត្តិប្បករណ៍ ចែកចេញដោយបញ្ញត្តិ ៦ ប្រការ ចប់តែប៉ុណ្ណេះ)

# កថាវត្ថុ (ក្នុងអដ្ឋកថា)

**(តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ)**

**សកវាទិបញ្ចសុត្តសតានិ បរវាទិបញ្ចសុត្តសតានីតិ សុត្ត-សហស្សំ សមោធានេត្វាន វិភត្តំ កថាវត្ថុប្បករណំ នាម សមត្ថំ ។**

**( ឆវិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ)**

(កថាវត្ថុប្បករណ៍ ដែលប្រជុំចែកជា ១.០០០ សូត្រ, គឺ ៥០០សូត្រ របស់សកវាទិ ៥០០ សូត្រ របស់បរវាទី ចប់តែប៉ុណ្ណេះ)

# យមក (ក្នុងអដ្ឋកថា)

**(តទនន្តរំ យមកប្បករណំ នាមេតំ)**

**មូលយមកំ ខន្ធយមកំ អាយតនយមកំ ធាតុយមកំ សច្ចយមកំ សង្ខារយមកំ អនុសយយមកំ ចិត្តយមកំ ធម្មយ-មកំ ឥន្ទ្រិយយមកន្តិ ។**

**( ទសវិធេន វិភត្តំ យមកប្បករណំ នាម សមត្តំ)**

(យមកប្បករណ៍ ចែកចេញដោយយមកៈ ១០ ប្រការ ចប់តែប៉ុណ្ណេះ)

# បដ្ឋាន (ក្នុងអដ្ឋកថា)

**(តននន្តរំ មហាបដ្ឋានប្បករណំ នាមេត្តំ)**

**ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោតិ ។**

**(បច្ចយវសេន តា ចតុវីសតិវិធេន វិភត្តំ មហាប្បដ្ឋានប្បករណំ នាម សមត្តំ** មហាបដ្ឋានប្បករណ៍ ចែកចេញជាធម៌ ២៤ ប្រការ ដោយអំណាចនៃបច្ច័យ ចប់តែប៉ុណ្ណេះ) ។

# ខន្ធវិភង្គ (ក្នុងបាលី)

## (តននន្តរំ វិភង្គប្បករណំ នាមេតំ)

**បញ្ចក្ខន្ធា** រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។

តត្ថ កតមោ រូបក្ខន្ធោ ។

យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ។

តត្ថ កតមោ វេទនាខន្ធោ ។

យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វេទនាខន្ធោ។

តត្ថ កតមោ សញ្ញាខន្ធោ ។

យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សញ្ញាខន្ធោ ។

តត្ថ កតមោ សង្ខារក្ខន្ធោ ។

យេ កេចិ សង្ខារា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សង្ខារក្ខន្ធោ ។

តត្ថ កតមោ វិញ្ញាណក្ខន្ធោ ។

យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ។

(អយំ ខន្ធវិភង្គោតិ អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ)

(នេះឈ្មោះថាវិភង្គ មានខន្ធវិភង្គជាដើម, បករណៈ ឈ្មោះ វិភង្គ ដែលលោកចែកហើយ ដោយចំណែក ១៨ ប្រការ ចប់តែប៉ុណ្ណេះ)

# ធាតុកថា (ក្នុងបាលី)

(តទនន្តរំ ធាតុកថាបករណំ នាមេតំ)

សង្គហោ អសង្គហោ សង្គហិតេន អសង្គហិតំ អសង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន អសង្គហិតំ សម្បយោគោ វិប្បយោគោ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ សម្បយុត្តេន សម្បយុត្តំ វិប្បយុត្តេ-

ន វិប្បយុត្តំ សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ សម្បយុត្តេន សង្គហិតំ អសង្គហិតំ អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារស ធាតុយោ ចត្តារិ សច្ចានិ ពាវីសតិន្ទ្រិយានិ បដិច្ចសមុប្បាទោ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា ចត្តារិ ឈានានិ ចតស្សោ អប្បមញ្ញាយោ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ ផស្សោ វេទនា សញ្ញា ចេតនា ចិត្តំ អធិមោក្ខោ មនសិការោ ។ តីហិ សង្គហោ តីហិ អសង្គហោ ចតូហិ សម្បយោគោ ចតូហិ វិប្បយោគោ សភាគោ វិសភាគោ សព្វាបិ ធម្មសង្គណិ ធាតុកថាយ មាតិកា ។

**(នយមាតិកាតិ បញ្ចវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ)**

(នេះឈ្មោះមាតិកាមាន **នយមាតិកា**ជាដើម, **បករណៈ** ឈ្មោះ **ធាតុកថា** ដែលលោកចែកហើយ ដោយចំណែក៥ប្រការ ចប់តែប៉ុណ្ណេះ)

# បុគ្គលបញ្ញត្តិ (ក្នុងបាលី)

**(តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសា)**

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ ។

កិត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ ។ យាវតា បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឯត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ ។

កិត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ ។ យាវតា ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ មនាយតនំ ធម្មាយតនំ ឯត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ ។

កិត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ ។ យាវតា អដ្ឋារស ធាតុយោ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ឯត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ ។

កិត្តាវតា សច្ចានំ សច្ចប្បញ្ញត្តិ ។ យាវតា ចត្តារិ សច្ចានិ ទុក្ខសច្ចំ សមុទយសច្ចំ និរោធសច្ចំ មគ្គសច្ចំ ឯត្តាវតា សច្ចានំ សច្ចប្បញ្ញត្តិ ។

កិត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយបញ្ញត្តិ ។ យាវតា ពាវី-
សតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ
កាយិន្ទ្រិយំ មនិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ
សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ
ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ
បញ្ញិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតា-
វិន្ទ្រិយំ ឯត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយបញ្ញត្តិ ។

កិត្តាវតា បុគ្គលានំ បុគ្គលបញ្ញត្តិ ។ សមយវិមុត្តោ អសម-
-យវិមុត្តោ កុប្បធម្មោ អកុប្បធម្មោ បរិហានធម្មោ អបរិហានធម្មោ
ចេតនាភព្វោ អនុរក្ខនាភព្វោ បុថុជ្ជនោ គោត្រភូ ភយូបរតោ
អភយូបរតោ ភព្វាគមនោ អភព្វាគមនោ និយតោ អនិយតោ
បដិបន្នកោ ផលេ ឋិតោ សមសីសី ឋិតកប្បី អរិយោ អនរិ-
យោ សេក្ខោ អសេក្ខោ នេវសេក្ខោ នាសេក្ខោ តេវិជ្ជា ឆឡ-
ភិញ្ញោ សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ ឧភតោ ភាគវិមុត្តោ បញ្ញា-
វិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធា-
នុសារី សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជី សកទាគាមី អនា-
គាមី អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី
សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី សោតាបន្នោ សោ-
-តាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិ-

ផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយា-យ បដិបន្នោ អរហា អរហត្តផលសច្ឆិកិរិយាយ បដិបន្នោតិ ។

*(អយំ ខន្ធប្បញ្ញត្តាទិ ឆវិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាមសមត្តំ នេះឈ្មោះថា បញ្ញត្តិ មានខន្ធប្បញ្ញត្តិជាដើម, បករណៈ ឈ្មោះ បុគ្គលប្បញ្ញត្តិ ដែលលោកចែកហើយដោយចំណែក ៦ ប្រការ ចប់តែប៉ុណ្ណេះ) ។*

# កថាវត្ថុ (ក្នុងបាលី)

## (តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ)

បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ ។ អាមន្តា ។ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋ-បរមដ្ឋេនាតិ ។

ន ហេវំ វត្តព្វេ ។ អាជានាហិ និគ្គហំ ហញ្ចិ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេន តេន វត រេ វត្តព្វេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ ។

យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋ-បរមដ្ឋេន នោ ច វត្តព្វេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ មិច្ឆា ។

នោ ចេ បន វត្តព្វេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ នោ វត រេ វត្តព្វេ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ ។

យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋ-បរមដ្ឋេន នោ ច វត្តព្វេ យោ សច្ចិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេនាតិ មិច្ឆា ។

**អនុលោមបញ្ចកំ** ចប់អនុលោមបញ្ចកៈ ។

**(សកវាទេ បញ្ចសុត្តសតានិ បរវាទេ បញ្ចសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វាន វិភត្តំ កថាវត្ថុប្បករណំ នាម សមត្តំ)**

(**បករណៈ** ឈ្មោះ **កថាវត្ថុ** ដែលលោកប្រជុំមកនូវសូត្រ ១.០០០ គឺ ៥០០ សូត្រ ក្នុងសកវាទី, ៥០០ ក្នុងបរវាទី ដែលលោកចែកហើយ ចប់តែប៉ុណ្ណេះ)។

# យមក (ក្នុងបាលី)[១]

**(តទនន្តរំ យមកប្បករណំ នាមេតំ)**

(១) យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា យេ វា បន កុសលមូលា សព្វេ តេ ធម្មា កុសលា ។ (២) យេកេចិ

(១) នៅក្នុង **យមក** ផ្នែកបាលីនេះ ទាំងក្នុងសៀវភៅ **ប្រជុំភាណវារ** ច្បាប់ដើម របស់លោកសាស្ត្រាចារ្យ **សែម_សូរ** បោះពុម្ពក្នុង ព.ស.២៥០៨ (1966) ក្តី, សៀវភៅ **សត្តបរិត្ត_ទ្វាទសបរិត្ត** ដែលបោះពុម្ពដោយគណៈកម្មការធម្មវិន័យព្រះពុទ្ធសាសនា ក្នុងពុទ្ធសករាជ ២៥៣២ (1988) ក្តី និង ក្នុងគម្ពីរ **អភិធម្មបិដក យមក បឋមភាគ** (ភាគ៨៧, ទំ. ១_២) មានការប្លែកគ្នាទាំងអស់, ខ្ញុំ (ព្រហ្ម-មេត្តា) សម្រេចចិត្តចម្លងតាមគម្ពីរព្រះអភិធម្មបិដកចុះ ។ អាស្រ័យហេតុនេះ សូមលោកម្ចាស់ព្រះថេរានុត្ថេរៈ ដែលបានប្រើប្រាស់សៀវភៅនេះ ព្រមទាំងអស់លោក_អ្នក អ្នកសិក្សាទាំងឡាយ មេត្តាជ្រាបតាមការគួរ សមតាមធម្មធ្យាស្រ័យផងចុះ ។

កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលា យេ វា បន កុសលមូលេន ឯកមូលា សព្វេ តេ ធម្មា កុសលា ។ (៣) យេកេចិ កុសលមូលេន ឯកមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា សព្វេ តេ ធម្មា កុសលា ។ (៤) យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា យេ វា បន កុសលមូលមូលា សព្វេ តេ ធម្មា កុសលា ។ (៥) យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលា យេ វា បន កុសលមូលេន ឯកមូលមូលា សព្វេ តេ ធម្មា កុសលា ។ (៦) យេកេចិ កុសលមូលេន ឯកមូលមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលា សព្វេ តេ ធម្មា កុសលា ។ (៧) យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលកា យេ វា បន កុសលមូលកា សព្វេ តេ ធម្មា កុសលា ។ (៨) យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលកា យេ វា បន កុសលមូលេន ឯកមូលកា សព្វេ តេ ធម្មា កុសលា ។ (៩) យេកេចិ កុសលមូលេន ឯកមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលកា សព្វេ តេ ធម្មា កុសលា ។ (១០) យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលកា យេ វា បន កុសលមូលមូលកា សព្វេ តេ ធម្មា កុសលា ។ (១១)

យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលកា យេ វា បន កុសលមូលេន ឯកមូលមូលកា សព្វេ តេ ធម្មា កុសលា ។ (១២) យេកេចិ កុសលមូលេន ឯកមូលមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលកា សព្វេ តេ ធម្មា កុសលាតិ ។

**មូលំ ហេតុនិទានញ្ច សម្ភវោ បភវេន ច**
**សមុដ្ឋានាហារារម្មណា បច្ចយោ សមុទយេន ចាតិ ។**
**(មូលយមកាទិ ទសយមកប្បដិបណ្ឌិតំ យមកប្បករណំ នាម សមត្តំ)**
(**បករណៈ**ឈ្មោះ **យមកៈ** ដែលប្រដាប់ដោយ **យមកៈ** ១០
មានមូលយមកៈជាដើម ចប់តែប៉ុណ្ណេះ) ។

# បដ្ឋាន (ក្នុងបាលី)

## (តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ)

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ

វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ច-
-យោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ
អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ ។

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមម្ហិ នយា សុគម្ភិរា ។

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយម្ហិ នយា សុគម្ភិរា ។

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភិរា ។

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច តិកត្តិ
កញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ភិរាតិ ។

**(ចតុវីសតិប្បច្ចយវសេន អយំ សមន្តប្បដ្ឋានប្បករណវណ្ណនា និដ្ឋិតា)**

(**វណ្ណនា នៃ បដ្ឋានប្បករណៈ** ជាទីបំផុតនេះដោយអំណាចនៃ **បច្ច័យ ២៤** ចប់តែប៉ុណ្ណេះ)

# តិរោកុឌ្ឌកណ្ឌ

## តិរោកុឌ្ឌកណ្ឌំ

~ តិរោកុឌ្ឌេសុ តិដ្ឋន្តិ　　សន្ធិសិង្ឃាដកេសុ ច
ទ្វារពាហាសុ តិដ្ឋន្តិ　　អាគន្ត្វាន សកំ ឃរំ ។
បហុតេ អន្នបានម្ហិ　　ខជ្ជភោជ្ជេ ឧបដ្ឋិតេ
ន តេសំ កោចិ សរតិ　　សត្តានំ កម្មបច្ចយា
ឯវំ ទទន្តិ ញាតីនំ　　យេ ហោន្តិ អនុកម្បកា
សុចឹ បណីតំ កាលេន　　កប្បិយំ បានភោជនំ
ឥទំ វោ ញាតីនំ ហោតុ　　សុខិតា ហោន្តុ ញាតយោ
តេ ច តត្ថ សមាគន្ត្វា　　ញាតិបេតា សមាគតា
បហុតេ អន្នបានម្ហិ　　សក្កច្ចំ អនុមោទរេ
ចិរំ ជីវន្តុ នោ ញាតី　　យេសំ ហេតុ លភាមសេ
អម្ហាកញ្ច កតា បូជា　　ទាយកា ច អនិប្ផលា
ន ហិ តត្ថ កសី អត្ថិ　　គោរក្ខេត្ថ ន វិជ្ជតិ
វណិជ្ជា តាទិសី នត្ថិ　　ហិរញ្ញេន កយាកយំ
ឥតោ ទិន្នេន យាបេន្តិ　　បេតា កាលកតា តហឹ
ឧណ្ណតេ ឧទកំ វុដ្ឋំ　　យថា និន្នំ បវត្តតិ
ឯវមេវ ឥតោ ទិន្នំ　　បេតានំ ឧបកប្បតិ

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ**
**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**
**អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ**
**បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ**
**ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា**
**ន តំ បេតានមត្ថាយ ឯវំ តិដ្ឋន្តិ ញាតយោ**
**អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុបតិដ្ឋិតា**
**ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ។**

**សោ ញាតិធម្មោ ច អយំ និទស្សិតោ**
**បេតាន បូជា ច កតា ឧឡារា**
**ពលញ្ច ភិក្ខូនមនុប្បទិន្នំ**
**តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ ។**

☸ **យទិ ហីនេ គតោ ឋានេ កាយទុច្ចរិតេន វា** បើញាតិណាមួយ ទៅកើតក្នុងទីដ៏ថោកទាប ព្រោះកាយទុច្ចរិតក្តី (វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី),

**ឥមិនា បុញ្ញតេជេន តម្ហា ឋានា បមុញ្ចតុ** ក៏សូមឱ្យរួចរដោះចាកទី (ដ៏ថោកទាប) នោះ ដោយតេជះគឺបុណ្យនេះ,

**យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ** ឬបើទៅកើតក្នុងទេវបុរី ជាវិមានគួរីករាយ ដែលជាឋានមានលំអដោយរតនៈ (ផ្សេងៗ) ស្រាប់ហើយ ។

**ឥមិនា បុញ្ញតេជេន ភិយ្យោ ភិយ្យោ បវឌ្ឍតិ** ក៏សូមឱ្យរីងរឹតតែចម្រើនជាភិយ្យោភាព ដោយតេជៈគឺបុណ្យនេះ,

**ឯវំ មហិទ្ធិយា ឯសា យទិទំ បុញ្ញសម្បទា** បុញ្ញសម្បទា គឺគុណជាតិជាហេតុដល់ព្រមដោយបុណ្យឯណា បុញ្ញសម្បទានេះ មានឫទ្ធិដ៏ធំក្រៃលែង ដោយប្រការយ៉ាងនេះ,

**តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ** ព្រោះហេតុនោះបណ្ឌិតទាំងឡាយ អ្នកមានប្រាជ្ញា រមែងសរសើរនូវភាពនៃបុគ្គលអ្នកមានបុណ្យធ្វើទុកហើយ,

**សុខោ វិបាកោ បុញ្ញានំ** ផលរបស់បុណ្យទាំងឡាយ រមែងនាំមកនូវសេចក្តីសុខ,

**អធិប្បាយោ សមិជ្ឈតិ** សេចក្តីប្រាថ្នារមែងសម្រេច,

**ខិប្បញ្ច បរិយោសានេ និព្វានំ សមធិគច្ឆតិ**ម្យ៉ាងទៀតក្នុងកាលជាទីបំផុត បុគ្គលរមែងបាននូវព្រះនិព្វានដ៏ឆាប់រហ័ស,

**យោ ភាជនសហស្សេហិ បូរណំ ឧរគោជនំ**

**ឧទេយ្យាបរិមាណានំ ឯកបត្តម្បិ នាលតេ**

**ពុទ្ធុប្បាទេ សារីបុត្តោ យេ ចញ្ញេ អគ្គសាវកា**

បុគ្គលគប្បីឱ្យនូវវរភោជន ដ៏ពេញដោយភាជនៈមួយពាន់ ក៏មិនបានស្មើនឹងភោជនមួយបាត្រ ដែលគេបានឱ្យហើយ ដល់ព្រះសារីបុត្ត និងពួកអគ្គសាវ័កដទៃក្នុងពុទ្ធុប្បាទ (នេះ) ដែលមានគុណប្រមាណមិនបាន,

**បត្តបូរានុភាវេន មាតាបិតា បមុច្ចរេ** (ព្រោះហេតុនោះ) បានជាមាតា និង បិតា រមែងរួច (ចាកទីដ៏ថោកទាប) ដោយអានុភាពនៃបាយដែលពេញក្នុងបាត្រ។./.

(<u>សេចក្ដីពន្យល់:</u> ធម៌ **យទិហិនេ** នេះ សូត្របាលីសុទ្ធក៏បាន សូត្រប្រែផងក៏បាន ។ តពីនេះទៅ ត្រូវសូត្រ **ពហូទេវា** ទៀត សឹមសូត្រ **បដិច្ចសមុប្បាទ** គឺ **អវិជ្ជាបច្ចយា** និង ធម៌ **បំសុ--កូល** ឯទៀតៗ) ៕

* **<u>កំណត់សម្គាល់:</u>** ក្នុងការប្រើស្រៈនិស្ស័យ ិ ី ឹ ឺ លើតួព្យញ្ជនៈ **ភ គ ត ភ ទ** ដោយប្រើ **Font Unicode** **<u>Khmer OS Muol</u>** មានការប្រែទិដ្ឋភាពពី **ភិ ភី ភឹ ភឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ទិ ទី ទឹ** ទៅជាយ៉ាងនេះវិញ ៖ **ភ ភ ភ ភ. គ គ គ គ, ត ត ត ត, ភ ភ ភ ភ, ទ ទ ទ**... (**ជារបៀបសំណេរបែបបុរាណជូនតាខ្មែរ**), អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ និង អស់លោក-អ្នកសិក្ខាកាមទាំងឡាយ មេត្តាជ្រាប និង គប្បីបានស្គាល់យល់ដឹង ។

# បដិច្ចសមុប្បាទ

➢ **អវិជ្ជាបច្ចយា សង្ខារា** សង្ខារទាំងឡាយ(កើតមាន) ព្រោះបច្ច័យ គឺ អវិជ្ជា ពោលគឺសេចក្ដីល្ងង់,

**សង្ខារប្បច្ចយា វិញ្ញាណំ** វិញ្ញាណ(កើតមាន) ព្រោះបច្ច័យគឺសង្ខារ,

**វិញ្ញាណប្បច្ចយា នាមរូបំ** នាម និង រូប(កើតមាន) ព្រោះបច្ច័យ គឺ វិញ្ញាណ,

**នាមរូបប្បច្ចយា សឡាយតនំ** អាយតនៈ៦ (កើតមាន)ព្រោះបច្ច័យ គឺ នាម និង រូប,

**សឡាយតនប្បច្ចយា ផស្សោ** សម្ផស្ស (កើតមាន) ព្រោះបច្ច័យ គឺ អាយតនៈ៦,

**ផស្សប្បច្ចយា វេទនា** វេទនា(កើតមាន) ព្រោះបច្ច័យ គឺសម្ផស្ស,

**វេទនាបច្ចយា តណ្ហា** តណ្ហា(កើតមាន) ព្រោះបច្ច័យ គឺវេទនា,

**តណ្ហាបច្ចយា ឧបាទានំ** ឧបាទាន(កើតមាន)ព្រោះបច្ច័យ គឺតណ្ហា,

**ឧបាទានប្បច្ចយា ភវោ** ភព(កើតមាន) ព្រោះបច្ច័យគឺឧបាទាន,

**ភវប្បច្ចយា ជាតិ** ជាតិ (កើតមាន) ព្រោះបច្ច័យ គឺ ភព,

**ជាតិប្បច្ចយា ជរាមរណំ** ជរា និង មរណៈ (កើតមាន) ព្រោះបច្ច័យ គឺ ជាតិ,

**សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និង សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងកើតមាន (ព្រោះជាតិជាបច្ច័យដែរ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** កិរិយាកើតមាន នៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

➢ **អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** កិរិយារលត់នៃសង្ខារ ព្រោះកិរិយារលត់ដោយអរិយមគ្គ ឥតមានសេសសល់ នៃអវិជ្ជាមែនពិត ។

**សង្ខារនិរោធា វិញ្ញាណនិរោធោ** កិរិយារលត់នៃវិញ្ញាណ ព្រោះរលត់នៃសង្ខារ,

**វិញ្ញាណនិរោធា នាមរូបនិរោធោ** កិរិយារលត់នៃនាម និង រូប ព្រោះរលត់នៃវិញ្ញាណ,

**នាមរូបនិរោធា សឡាយតននិរោធោ** កិរិយារលត់នៃអាយតនៈ ៦ ព្រោះរលត់នៃនាម និង រូប,

**សឡាយតននិរោធា ផស្សនិរោធោ** កិរិយារលត់នៃសម្ផស្ស ព្រោះរលត់នៃអាយតនៈ ៦,

**ផស្សនិរោធា វេទនានិរោធោ** កិរិយារលត់នៃវេទនាព្រោះរលត់នៃសម្ផស្ស,

**វេទនានិរោធា តណ្ហានិរោធោ** កិរិយារលត់នៃតណ្ហាព្រោះរលត់នៃវេទនា,

**តណ្ហានិរោធា ឧបាទាននិរោធោ** កិរិយារលត់នៃឧបាទានព្រោះរលត់នៃតណ្ហា,

**ឧបាទាននិរោធា ភវនិរោធោ** កិរិយារលត់នៃភព ព្រោះរលត់នៃឧបាទាន,

**ភវនិរោធា ជាតិនិរោធោ** កិរិយារលត់នៃជាតិ ព្រោះរលត់នៃភព,

**ជាតិនិរោធា ជរាមរណំ** ជរា និង មរណៈ (រលត់) ព្រោះកិរិយារលត់នៃជាតិ,

**សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និង សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងរលត់ទៅ (ព្រោះកិរិយារលត់ទៅនៃ ជាតិ ដែរ)។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ** កិរិយារលត់ទៅនៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

# សំវេជនីយគាថា

១.. **ន គាមធម្មោ និគមស្ស ធម្មោ**
**ន ចាបិយំ ឯកកុលស្ស ធម្មោ**
**សព្វស្ស លោកស្ស សទេវកស្ស**
**ឯសេវ ធម្មោ យទិទំ អនិច្ចតា**

ធម៌ណាដែលមានឈ្មោះថា **អនិច្ចតាធម៌** គឺសភាពប្រែប្រួលមិនទៀងទាត់ **អនិច្ចតាធម៌**នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សម្រាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនទេ **អនិច្ចតាធម៌**នោះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។

២.. **ន គាមធម្មោ និគមស្ស ធម្មោ**
**ន ចាបិយំ ឯកកុលស្ស ធម្មោ**
**សព្វស្ស លោកស្ស សទេវកស្ស**
**ឯសេវ ធម្មោ យទិទំ ទុក្ខតា**

ធម៌ណាដែលមានឈ្មោះថា **ទុក្ខតាធម៌** គឺសភាពជាទុក្ខ, **ទុក្ខតាធម៌**នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សម្រាប់អ្នកនិគមតែមួយៗទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗក៏មិនមែនទេ **ទុក្ខតាធម៌**នោះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។

៣.. **ន គាមធម្មោ និគមស្ស ធម្មោ**
**ន ចាបិយំ ឯកកុលស្ស ធម្មោ**
**សព្វស្ស លោកស្ស សទេវកស្ស**
**ឯសេវ ធម្មោ យទិទំ អនត្តតា**

ធម៌ណាដែលមានឈ្មោះថា **អនត្តាធម៌** គឺសភាពមិនមែនជារបស់ខ្លួន **អនត្តាធម៌**នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌ សម្រាប់អ្នកនិគមតែមួយៗ ទេ ឬនឹងថាជាធម៌ សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនទេ, **អនត្តាធម៌**នោះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតា មារព្រហ្មទាំងអស់គ្រប់រូប ។

៤.. **អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**
**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ**

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើង និងវិនាសទៅវិញជាធម្មតា រមែងកើតឡើងហើយរលត់ទៅវិញ, លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង ។

៥.. **សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ**
**យថា កម្មំ គមិស្សន្តិ បុញ្ញបាបផលូបគា**
**និរយំ បាបកម្មន្តា បុញ្ញកម្មា ច សុគតឹ**

សត្វទាំងឡាយ ទៀងតែនឹងស្លាប់គ្រប់ៗគ្នា ព្រោះថាជីវិតរបស់សត្វទាំងឡាយ សុទ្ធតែមានសេចក្ដីស្លាប់នៅខាងចុងបំផុតគ្រប់ៗប្រាណ ម្យ៉ាងទៀតសត្វទាំងឡាយ រមែងកាន់យកនូវផលបុណ្យ ផលបាប ហើយនឹងទៅតាមយថាកម្ម គឺទៅតាមគួរដល់អំពើល្អ និង អាក្រក់ដែលខ្លួនបានធ្វើ, អ្នកដែលធ្វើបាប តែងធ្លាក់ទៅសោយទុក្ខក្នុងនរក ចំណែកខាងអ្នកធ្វើបុណ្យ តែងឡើងទៅកាន់សុគតិភព ។

៦.. **តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ**
**បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ**

ព្រោះហេតុដូច្នោះហើយ សាធុជនអ្នកមានចំណង់ចង់បានសេចក្ដីសុខដល់ខ្លួន គួរតែប្រញាប់ប្រញាល់ធ្វើអំពើបុណ្យដែលជាគុណគឺអ្នកប្រាជ្ញតែងរាប់អាន ឱ្យបានជានិច្ច គឺខ្លួនត្រូវកសាងសន្សំគ្រាន់នឹងបានជាទីពឹងទៅក្នុងភពខាងនាយ ព្រោះថាបុណ្យទាំងឡាយ តែងជាទីពឹងពំនាក់របស់សត្វទាំងឡាយ ក្នុងបរលោក ។

៧.. **ផេណបិណ្ឌូបមំ រូបំ វេទនា បុព្វុឡូបមា**
**មរីចិកូបមា សញ្ញា សង្ខារា កទលូបមា**
**មាយូបមញ្ច វិញ្ញាណំ ទេសិតា និច្ចពន្ធុនា**

- រូប មានសេចក្ដីប្រៀបធៀបនឹង "ដុំនៃពពុះទឹក"
- វេទនា មានសេចក្ដីប្រៀបធៀបនឹង "ក្រពេញទឹក" ដែលប៉ោងឡើងព្រួច ៗ,

- សញ្ញា មានសេចក្តីប្រៀបធៀបនឹង "ថ្ងៃបណ្តើរកូន",
- សង្ខារទាំងឡាយ មានសេចក្តីប្រៀបធៀបនឹង "ដើមចេក",
- វិញ្ញាណ មានសេចក្តីប្រៀបធៀបនឹង "កលមាយា",

សេចក្តីប្រៀបធៀបនៃ "ខន្ធ" ទាំង៥នេះ គឺព្រះសម្ពុទ្ធមានផៅពង្ស ដ៏ខ្ពង់ខ្ពស់ ដូចជាព្រះអាទិត្យ ព្រះអង្គទ្រង់សំដែងហើយ ។

៨.. **អចិរំ វត យំ កាយោ ចឋវឹ អធិសេស្សតិ**
**ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំ វ កលិង្គរំ**

កាយនេះមិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅប្រាសហើយ ជាកាយគឺគេបោះបង់ ក៏នឹងដេកសង្កត់នៅលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

៩.. **អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ**
**អបវិដ្ឋោ តទា សេតិ និរត្ថំ វ កលិង្គរំ**

អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយនេះទៅក្នុងកាលណាហើយ (កាយនេះ ក៏ដល់នូវសេចក្តីមិនគួរនឹងទុកដាក់ឱ្យនៅលើផ្ទះសម្បែងបានឡើយ) គេតែងនាំយកទៅចោលឱ្យដេកនៅលើផែនដី ក្នុងកាលនោះឯង ដូចជាអង្កត់ឧស រកប្រយោជន៍គ្មានឡើយ ។

១០.. **យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ**
**ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ**

គង្វាលគោ កៀងគោទាំងឡាយទៅកាន់ទីគោចរ ដោយអាជ្ញា គឺដំបង ឬ រំពាត់យ៉ាងណាមិញ, **ជរា** គឺសេចក្ដីទ្រុឌទ្រោមគ្រាំគ្រា និង **មច្ចុរាជ** គឺសេចក្ដីស្លាប់ ក៏កៀងទៅនូវអាយុរបស់សត្វទាំងឡាយ យ៉ាងនោះឯង ។

* **<u>សេចក្ដីបញ្ជាក់:</u>** កាលសូត្រ **សំវេជនីយគាថា** នេះចប់ហើយ ត្រូវសូត្រ **យថា វារិវហា... សព្វីតយោ ... សព្វពុទ្ធានុភាវេន... សក្កត្វា... តេ អត្ថលទ្ធា...** តទៅទៀតតាមការគួរ ដើម្បីបញ្ចប់ពិធីបំសុកូល ។ សូមបញ្ជាក់ថា ធម៌ **យថា...** ជាដើម ដែលលោកត្រូវសូត្រខាងចុងនេះ ជាធម៌សម្រាប់ឱ្យពរដល់ម្ចាស់ទាន តែប៉ុណ្ណោះ ។

(ចប់ **ធម៌ជាវេរ-បំសុកូល**)



# ធម៌សូត្រមន្ត

# សត្តបរិត្ត

## អញ្ជើញពពួកទេវតា

**សរជ្ជំ សសេនំ សពន្ធុំ នរិន្ទំ**
**បរិត្តានុភាវោ សទា រក្ខតូតិ**
**ផរិត្វាន មេត្តំ សមេត្តា ភទន្តា**
**អវិក្ខិត្តចិត្តា បរិត្តំ ភណន្តុ**

អ្នកដ៏ចម្រើនទាំងឡាយ ជាអ្នកប្រកបដោយមេត្តា ចូរផ្សាយនូវមេត្តាចិត្ត ដោយគិតដូច្នេះថា សូមអានុភាពនៃព្រះបរិត្ត រក្សានូវព្រះមហាក្សត្រ ជាធំជាងនរជន ព្រមទាំងរាជសម្បត្តិ ព្រមទាំងសេនាមាត្យ ព្រមទាំងព្រះរាជវង្សានុវង្ស សព្វៗ កាលរៀងទៅ ហើយកុំមានចិត្តរាយមាយ ចូរសូត្រនូវព្រះបរិត្ត !

**សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា**
**សទ្ធម្មំ មុនិរាជស្ស សុណន្តុ សគ្គមោក្ខទំ**

ទេវតាទាំងឡាយ ក្នុងចក្កវាឡទាំងឡាយដោយជុំវិញ ចូរមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្ម ជាធម៌អាចឱ្យនូវសួគ៌ និងព្រះនិព្វាន (របស់ព្រះអនាវរណញ្ញាណ) ជាស្តេចនៃអ្នកប្រាជ្ញ ។

**សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ**

ទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភព និង រូបភពក្តី ភុម្មទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ព្វដ៏អាកាសក្តី នៅនាកោះនិងដែន និងស្រុកក្តី នៅនាដើមព្រឹក្សា និង ព្រៃញាតស្បាត ឬទីស្រែចំការក្តី យក្ខ និងគន្ធព្វ និង នាគទាំងឡាយ ដែលស្ថិតនៅនា-ទីទឹក ទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នា(ក្នុងទីនេះ), ពាក្យឯណា ដែលជាពាក្យព្រះសាក្យមុនីដ៏ប្រសើរ (ដែលយើងខ្ញុំនឹងសូធ្យឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ (អំពីសំណាក់) នៃខ្ញុំ (ដោយគោរព)!

**ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌!

**ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌!

**ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌!

# នមស្សការ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

*កិរិយានមស្សការថ្វាយបង្គំ (នៃខ្ញុំព្រះករុណា) ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ!*

# សរណគមន៍

☸ **ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរឭក !

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរឭក !

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឭក !

☸☸ **ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរឭក (ជាគម្រប់ពីរដងផង) !

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរឭក (ជាគម្រប់ពីរដងផង) !

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឭក (ជាគម្រប់ពីរដងផង) !

☸☸☸ **តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរឭក (ជាគម្រប់បីដងផង) !

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរឭក (ជាគម្រប់បីដងផង) !

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឭក (ជាគម្រប់បីដងផង) !

# សម្ពុទ្ធេ

- **សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ**
  **បញ្ចសតសហស្សានិ នមាមិ សិរសា អហំ**

  ៜ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ **២៨**ព្រះអង្គផង **១**ម៉ឺន**២**ពាន់ព្រះអង្គផង **៥**សែនព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា),

- **តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

  ៜ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព,

- **នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ**
  **អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ**

  ៜ ដោយអានុភាពនៃកិរិយានមស្សការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ !

- **សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ**
  **ទសសតសហស្សានិ នមាមិ សិរសា អហំ**

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ **៥៥**ព្រះអង្គផង **២**ម៉ឺន**៤**ពាន់ព្រះអង្គផង **១**លានព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា),

- ***តេសំ ធម្មញ្ច សង្ឃញ្ច*** *... ខ្ញុំព្រះករុណាសូម ...*
- ***នមក្ការានុភាវេន*** *... ដោយអានុភាពនៃកិរិយា ...*

- **សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ វីសតិសតសហស្សានិ នមាមិ សិរសា អហំ**

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ **១០៩** ព្រះអង្គផង **៤**ម៉ឺន **៨**ពាន់ ព្រះអង្គផង **២** លាន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា),

- ***តេសំ ធម្មញ្ច សង្ឃញ្ច*** *... ខ្ញុំព្រះករុណាសូម ...*
- ***នមក្ការានុភាវេន ... វិនស្សន្តុ អសេសតោ!***

- ដោយអានុភាពនៃកិរិយានមស្សការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេកក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ !

# មង្គលសុត្តារម្ភោ

**យេ សន្តា សន្តចិត្តា តិសរណសរណា ឯត្ថ លោក--ន្តរេ វា ភុម្មា ភុម្មា ច ទេវា គុណគណគហណព្យាវដា សព្វកាលំ** *ទេវតាទាំងឡាយឯណា ជាភុម្មទេវតាក្តី មិនមែនជាភុម្មទេវតាក្តី ជាអ្នកមានចិត្តស្ងប់ មានព្រះរតនត្រ័យជាទីពឹងទីរឭក ដែលមាននៅក្នុងលោកនេះ ឬក្នុងចន្លោះនៃលោក ជាអ្នកខ្វល់ខ្វាយក្នុងកិរិយាកាន់យកនូវពពួកនៃគុណ សព្វៗកាល ។*

**ឯតេ អាយន្តុ ទេវា វរកនកមយេ មេរុរាជេ វសន្តោ សន្តោ សន្តោ សហេតុំ មុនិវរវចនំ សោតុមគ្គំ សមគ្គំ** *សូមទេវតាទាំងឡាយនោះអញ្ជើញមក ម្យ៉ាងទៀត ទេវតាដែលស្ថិតនៅលើភ្នំមេរុរាជសុទ្ធសឹងតែមាសដ៏ប្រសើរ សូមអញ្ជើញមកផង សូមទេវតាជាសប្បុរសទាំងឡាយ អញ្ជើញមកកាន់ទីសមាគម ដើម្បីស្តាប់នូវពាក្យនៃព្រះមុនីដ៏បវរ ជាធម៌ដ៏ប្រសើរលើស ជាហេតុនាំឲ្យកើតសេចក្តីត្រេកអរ,*

**សព្វេសុ ចក្កវាឡេសុ  យក្ខា ទេវា ច ព្រហ្មុនោ**
**យំ អម្ហេហិ កតំ បុញ្ញំ  សព្វសម្បត្ត សាធកំ**

បុណ្យឯណាដែលយើងបានធ្វើហើយ ជាបុណ្យអាចឲ្យសម្រេចនូវសម្បត្តិទាំងពួង សូមយក្ខទាំងឡាយផង ទេវតាទាំងឡាយផង ព្រហ្មទាំងឡាយផង ក្នុងចក្រវាឡទាំងអស់ (អនុមោទនាត្រេកអរនឹងបុណ្យនោះ),

**សព្វេ តំ អនុមោទិត្វា សមគ្គា សាសនេ រតា**
**បមាទរហិតា ហោន្តុ អារក្ខាសុ វិសេសតោ**

យក្ខ និងទេវតា និង ព្រហ្មទាំងអស់ កាលបើបានអនុមោទនានូវបុណ្យនោះហើយ ចូរព្រមព្រៀងគ្នា ត្រេកអរក្នុងព្រះពុទ្ធសាសនា ហើយចូរប្រាសចាកសេចក្តីប្រហែសធ្វេសក្នុងការរក្សា (នូវព្រះពុទ្ធសាសនា) ដោយឧបាយដ៏វិសេស,

**សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា**
**សាសនម្បិ ច លោកញ្ច ទេវា រក្ខន្តុ សព្វទា**

សូមឲ្យសេចក្តីចម្រើន កើតមានដល់ព្រះពុទ្ធសាសនាផង ដល់សត្វលោកផង ឲ្យបានសព្វៗ កាលទៅ សូមទេវតាទាំងឡាយ អភិបាលរក្សា នូវព្រះពុទ្ធសាសនាផង នូវសត្វលោកផង ឲ្យបានសព្វៗ កាលរៀងទៅ,

**សទ្ធឹ ហោន្តុ សុខី សព្វេ បរិវារេហិ អត្តនោ**

**អនីឃា សុមនា ហោន្តុ សហ សព្វេហិ ញាតិភិ**

*សព្វសត្វទាំងអស់ ព្រមទាំងបរិវារទាំងឡាយរបស់ខ្លួន សូមឲ្យមានសេចក្តីសុខស្រួល សូមឲ្យជាអ្នកឥតមានទុក្ខភ័យ ជាអ្នកមានចិត្តល្អ ព្រមទាំងជនជាញាតិសន្តានទាំងអស់គ្នា ។*

**យញ្ច ទ្វាទស វស្សានិ ចិន្តយឹសុ សទេវកា**
**ចិរស្សំ ចិន្តយន្តាបិ នេវ ជានឹសុ មង្គលំ**
**ចក្កវាឡសហស្សេសុ ទសសុ យេន តត្តកំ**
**កាលំ កោលាហលំ ជាតំ យាវ ព្រហ្មនិវេសនា**

*មនុស្សព្រមទាំងទេវតាទាំងឡាយ បាននាំគ្នាគិតរកនូវមង្គលឯណា អស់១២ឆ្នាំ, មនុស្ស និង ទេវតាទាំងនោះ ក្នុងមួយម៉ឺនចក្រវាឡ ទោះខំប្រឹងគិតអស់កាលយូរម្ល៉ោះ ក៏នៅតែមិនដឹងនូវមង្គលនោះត្រឹមណា វីកោលាហលក៏កើតរហូតដល់ភពជាទីនៅនៃព្រហ្ម អស់កាលត្រឹមណោះឯង ។*

**យំ លោកនាថោ ទេសេសិ សព្វបាបវិនាសនំ**
**យំ សុត្វា សព្វទុក្ខេហិ មុញ្ចន្តា សំខិយា នរា**
**ឯវមាទិគុណូបេតំ មង្គលន្តម្ភណាម ហេ**

*ព្រះបរមលោកនាថ ទ្រង់ត្រាស់សម្តែងហើយនូវមង្គលឯណា ដែលជាគ្រឿងញុំាំងបាបទាំងពួងឲ្យវិនាស នរជន*

*ទាំងឡាយរាប់ចំនួនមិនបាន ស្តាប់នូវមង្គលឯណាហើយ បានរួចចាកទុក្ខទាំងពួង, ម្នាលទេវតាទាំងឡាយ យើងពោល ឥឡូវនេះ នូវមង្គលនោះ ដ៏ប្រកបដោយគុណ មានយ៉ាងនេះ ជាដើម ។*

# មង្គលសូត្រ

*(មង្គលជាសិរីសួស្តី ៣៨ ប្រការ)*

**ឯវម្មេ សុតំ** (សូត្រនេះ ឈ្មោះ **មង្គលសូត្រ**) គឺខ្ញុំ (ឈ្មោះ **អានន្ទ**) បានស្តាប់មកហើយយ៉ាងនេះថា :

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី,

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្ត--វណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុប--សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯង ទេវតាអង្គ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញ៉ាំងវត្តជេតពនជុំវិញទាំងអស់ ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅ

ដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ,

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យ ជាគាថា(យ៉ាងនេះ)ថា :

**ពហូ ទេវា មនុស្សា ច　　មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ　　ព្រូហិ មង្គលមុត្តមំ**

ទេវតា និង មនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្ដីសួស្ដី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តា សំដែងប្រាប់នូវមង្គលដ៏ឧត្តម (ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិត ជាគាថាយ៉ាងនេះ ថា) :

☞ **អសេវនា ច ពាលានំ　　បណ្ឌិតានញ្ច សេវនា**
**បូជា ច បូជនីយានំ　　ឯតម្មង្គលមុត្តមំ !**

**__កិរិយាមិនសេពគប់__** នូវបុគ្គលពាលទាំងឡាយ១, **__កិរិយាសេពគប់__** នូវបុគ្គលជាបណ្ឌិតទាំងឡាយ១, **__កិរិយាបូជា__** ដល់បុគ្គលដែលគួរបូជាទាំងឡាយ១, ទាំង៣នេះ ជាមង្គលដ៏ឧត្តម !

☞ **បដិរូបទេសវាសោ ច　　បុព្វេ ច កតបុញ្ញតា**
**អត្តសម្មាបណិធិ ច　　ឯតម្មង្គលមុត្តមំ !**

កិរិយានៅក្នុងប្រទេសដ៏សមគួរ១, ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន១, កិរិយាតម្កល់ខ្លួនដោយប្រពៃ១, ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម !

☞ **ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ**
**សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ !**

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន១, សិល្ប-សាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និង គ្រហស្ថ ១, វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១, វាចាដែលបុគ្គលពោលត្រឹមត្រូវ១, ទាំង ៤នេះ ជាមង្គលដ៏ឧត្តម !

☞ **មាតាបិតុ ឧបដ្ឋានំ បុត្តទារស្ស សង្គហោ**
**អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ !**

កិរិយាបម្រើនូវមាតា១, កិរិយាបម្រើនូវបិតា១, សេចក្តីសង្គ្រោះដល់បុត្រ និង ភរិយា១, ការងារទាំងឡាយ ដែលមិនច្របូកច្របល់១, ទាំង៤ នេះ ជាមង្គលដ៏ឧត្តម !

☞ **ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ**
**អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ !**

កិរិយាបរិច្ចាគទាន១, កិរិយាប្រព្រឹត្តនូវធម៌១, សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ១, ការងារទាំងឡាយដែលមិនមានទោស១, ទាំង៤ នេះ ជាមង្គលដ៏ឧត្តម !

☞ អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ !

កិរិយាមិនត្រេកអរក្នុងបាប និង កិរិយាវៀរចាកបាប១, សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង១, សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ១, ទាំង៣នេះ ជាមង្គលដ៏ឧត្តម !

☞ គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ !

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព១, កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន១, សេចក្តីត្រេកអរចំពោះរបស់ដែលមាន១, ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន១, កិរិយាស្តាប់នូវធម៌តាមកាល១, ទាំង៥នេះ ជាមង្គលដ៏ឧត្តម !

☞ ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ !

សេចក្តីអត់ធន១, ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ១, កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ១, ធម្មសាកច្ឆាគឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល១, ទាំង៤នេះជាមង្គលដ៏ឧត្តម !

☞ តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ !

សេចក្ដីព្យាយាមដុតនូវបាបធម៌១, កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ១, កិរិយាឃើញនូវអរិយសច្ចទាំងឡាយ១, កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន១, ទាំង៤នេះ ជាមង្គលដ៏ឧត្ដម !

☞ **ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**
**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ !**

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ១, មិនមានសេចក្ដីសោក១, មានធូលី គឺរាគៈ ទៅប្រាសហើយ១, ជាចិត្តក្សេមក្សាន្ត១, ទាំង៤នេះ ជាមង្គលដ៏ឧត្ដម !

☞ **ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**
**សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ !**

ទេវតា និង មនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង **៣៨** ប្រការ មានកិរិយាមិនសេពគប់នូវបុគ្គលពាល ជាដើមនោះ របស់ទេវតា និង មនុស្សទាំងអម្បាលណោះ **ជាមង្គលដ៏ឧត្ដម** ។

# រតនសុត្តារម្ភោ

**បណិធានតោ បដ្ឋាយ តថាគតស្ស ទស បារមិយោ ទស ឧបបារមិយោ ទស បរមត្ថបារមិយោ បញ្ច មហាបរិច្ចាគេ តស្សោ ចរិយា បច្ឆិមភវេ គព្ភាវក្កន្តឹ ជាតឹ អភិនិក្ខមនំ បធានចរិយ ពោធិបល្លង្កេ មារវិជយំ សព្វញ្ញុត្តញ្ញាណប្បដិវេធំ នវលោកុត្តរធម្មេ សព្វេបិមេ ពុទ្ធគុណេ អាវជ្ជិត្វា វេសាលិយា តីសុ បាការន្តរេសុ តិយាមរត្តឹ បរិត្តំ ករោន្តោ អាយស្មា អានន្ទត្ថេរោ វិយការុញ្ញចិត្តំ ឧបដ្ឋបេត្វា** *យើងទាំងឡាយតាំងចិត្ត ប្រកបដោយសេចក្ដីករុណា (ចំពោះសត្វទាំងឡាយ) ដូចជាព្រះអានន្ទត្ថេរដ៏មានអាយុ ដែលលោកពិចារណា នូវព្រះពុទ្ធគុណទាំងឡាយនេះគ្រប់ទាំងអស់ របស់ព្រះតថាគត ចាប់ដើមអំពីសេចក្ដីផ្ដើមតាំងប្រាថ្នាជាព្រះពុទ្ធមក គឺៈ បារមី១០ ឧបបារមី១០ បរមត្ថបារមី១០ មហាបរិច្ចាគ៥*[១] *ចរិយា៣*[២] *កិរិយាយាងចុះកាន់គភ៌នៃព្រះមាតាក្នុងបច្ឆិមភព កិរិយាប្រសូត កិរិយាយាង*

---

(១) **បរិច្ចាគ៥** គឺ បុត្តបរិច្ចាគ១, ទារបរិច្ចាគ១, ធនបរិច្ចាគ១, អង្គបរិច្ចាគ១, ជីវិតបរិច្ចាគ១ ។ (២) **ចរិយា៣** គឺ លោកត្ថចរិយា១, ញាតត្ថចរិយា១, ពុទ្ធត្ថចរិយា១ ។

ចេញសាងអភិនេស្ក្រមណ៍ កិរិយាបំពេញនូវទុក្ករកិរិយា កិរិយាផ្ចាញ់មារ កិរិយាត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណលើពោធិបល្ល័ង្ក លោកុត្តរធម៌៩ (ហើយព្រះអានន្ទត្ថេរ) លោកសូធ្យនូវព្រះបរិត្តអស់រាត្រីមានយាម ៣ ក្នុងខាងក្នុងកំផែងទាំងឡាយ ៣ ជាន់នៃក្រុងវេសាលី,

**កោដិសតសហស្សេសុ ចក្កវាឡេសុ ទេវតា**
**យស្សាណម្បដិគ្គណ្ហន្តិ យញ្ច វេសាលិយម្បុរេ**
**រោគាមនុស្សទុព្ភិក្ខ សម្ភូតន្តិវិធម្ភយំ**
**ខិប្បមន្តរធាបេសិ បរិត្តន្តម្ភណាម ហេ**

ទេវតាទាំងឡាយក្នុងសែនកោដិចក្រវាឡ តែងទទួលយកនូវអាជ្ញានៃព្រះបរិត្តឯណា ម្យ៉ាងទៀតព្រះបរិត្តឯណាញុាំងភ័យ ៣ ប្រការដែលកើតអំពីរោគ និង អមនុស្ស និង ទុព្ភិក្ស គឺគ្រាអំណត់[១] ក្នុងក្រុងវេសាលី ឲ្យអន្តរធានបាត់ទៅដោយឆាប់រហ័ស ម្នាលទេវតាទាំងឡាយ យើងសូធ្យឥឡូវនេះ នូវព្រះបរិត្តនោះ ។

[១] គ្រាអំណត់ គឺគ្រាដែលក្រខ្សត់ អត់មានសេចក្ដីសុខ ។

# រតនសូត្រ

☸ **យានីធ ភូតានិ សមាគតានិ**
**ភុម្មានិ វា យានិ វ អន្តលិក្ខេ**

*ពួក* **ភូត**[១] *ឯណាជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តីដែលមកប្រជុំគ្នាក្នុងទីនេះ,*

**សព្វេវ ភូតា សុមនា ភវន្តុ** *សូមពួកភូតទាំងអស់នោះមានចិត្តល្អ,*

**អថោបិ សក្កច្ច សុណន្តុ ភាសិតំ** *ម្យ៉ាងទៀត ចូរស្តាប់នូវភាសិតដោយគោរព,*

**តស្មា ហិ ភូតា និសាមេថ សព្វេ**
**មេត្តំ ករោថ មានុសិយា បជាយ**

*ព្រោះហេតុនោះ អ្នកទាំងឡាយជាភូតទាំងអស់ ចូរស្តាប់នូវព្រះបរិត្ត ចូរធ្វើនូវមេត្តាចិត្តចំពោះពពួកសត្វជាមនុស្សជាតិ*

---

[១] ពាក្យថា **ភូត** ក្នុងទីនេះ សំដៅយកសត្វដែលជា **អទិស្សមានកាយ** គឺមានកាយ តែមើលមិនឃើញ បានខាងពួកទេវតា ។

**ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ** មនុស្សទាំងឡាយឯណាតែងនាំមកនូវពលិកម្ម ក្នុងពេលថ្ងៃ និង ពេលយប់,

**តស្មា ហិ នេ រក្ខថ អប្បមត្តា** ព្រោះហេតុនោះ សូមអ្នកទាំងឡាយ កុំមើលបំណាំឡើយ សូមរក្សានូវមនុស្សទាំងឡាយនោះ,

**យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា**
**សគ្គេសុ វា យំ រតនំ បណីតំ**

ទ្រព្យឯណាមួយក្នុងលោកនេះ និង ក្នុងលោកឯទៀតក្តី រតនវត្ថុដ៏ឧត្តមឯណាក្នុងស្ថានសួគ៌ក្តី,

**ន នោ សមំ អត្ថិ តថាគតេន** ទ្រព្យ និង រតនវត្ថុទាំងនោះ ស្មើដោយព្រះតថាគត មិនមានឡើយ,

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម, **ឯតេន សច្ចេន សុវត្ថិ ហោតុ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

**ខយំ វិរាគំ អមតំ បណីតំ**
**យទជ្ឈគា សក្យមុនី សមាហិតោ**

ព្រះសក្យមុនីជាម្ចាស់ មានព្រះទ័យតម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ឯណា ជាទីក្ស័យនៃកិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ដ៏ឧត្តម,

**ន តេន ធម្មេន សមត្ថិ កិញ្ចិ** *របស់អ្វីមួយស្មើដោយព្រះធម៌នោះ មិនមានឡើយ,*

**ឥទម្បិ ធម្មេ រតនំ បណីតំ** *កែវ គឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម,*

**ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**យម្ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ** *ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរនូវសមាធិឯណា ថាជាធម៌ដ៏ស្អាត,*

**សមាធិមានន្តរិកញ្ញមាហុ** *បណ្ឌិតទាំងឡាយ ពោលហើយនូវសមាធិឯណា ថាជាធម៌ឲ្យផលដោយលំដាប់,*

**សមាធិនា តេន សមោ ន វិជ្ជតិ** *សមាធិឯទៀត ស្មើដោយសមាធិនោះ មិនមានឡើយ,*

**ឥទម្បិ ធម្មេ រតនំ បណីតំ** *កែវ គឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា**
**ចត្តារិ ឯតានិ យុគានិ ហោន្តិ**

*បុគ្គលទាំងឡាយឯណា ៨ ជំពូក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូ បាន ៤ គូៈ*

**តេ ទក្ខិណេយ្យា សុគតស្ស សាវកា** *បុគ្គលទាំងឡាយនោះ ជាសាវ័ករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន,*

**ឯតេសុ ទិន្នានិ មហប្ផលានិ** *ទានទាំងឡាយ ដែលបុគ្គលឲ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន,*

**ឥទម្បិ សង្ឃេ រតនំ បណីតំ** *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**យេ សុប្បយុត្តា មនសា ទឡ្ហេន**
**និក្កាមិនោ គោតមសាសនម្ហិ**

*អរិយបុគ្គលទាំងឡាយឯណា ក្នុងសាសនានៃព្រះសម្ពុទ្ធទ្រង់ព្រះនាមគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានកាម គឺសេចក្តីប្រាថ្នាឡើយ,*

**តេ បត្តិបត្តា អមតំ វិគយ្ហ**
**លទ្ធា មុធា និព្វុតឹ ភុញ្ជមានា**

*អរិយបុគ្គលទាំងឡាយនោះដល់ហើយនូវព្រះអរហត្តផល ហើយចូលទៅកាន់ព្រះនិព្វាន បាននូវកិរិយារលត់*

*កិលេសដោយទទេ គឺឥតមានទិញដូរឡើយ ហើយសោយនូវផល,*

**ឥទម្បិ សង្ឃេ រតនំ បណីតំ** *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**យថិន្ទខីលោ បថវិសិតោ សិយា**
**ចតុព្ភិ វាតេភិ អសម្បកម្បិយោ**

*សសរខឿនដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ,*

**តថូបមំ សប្បុរិសំ វទាមិ យោ**
**អរិយសច្ចានិ អវេច្ច បស្សតិ**

*អ្នកណាពិចារណាឃើញ នូវអរិយសច្ចទាំងឡាយ តថាគត ហៅអ្នកនោះថាជាសប្បុរស (មិនញាប់ញ័រដោយលោកធម៌ទាំងឡាយ) ប្រៀបដូចជាសសរខឿន ដូច្នោះឯង ។*

**ឥទម្បិ សង្ឃេ រតនំ បណីតំ** *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**យេ អរិយសច្ចានិ វិភាវយន្តិ**
**គម្ភីរបញ្ញេន សុទេសិតានិ**

*អរិយបុគ្គលទាំងឡាយឯណា ធ្វើឲ្យជាក់ច្បាស់នូវអរិយសច្ចទាំងឡាយ ដែលព្រះតថាគត ព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅ សម្ដែងល្អហើយ,*

**កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា** *អរិយបុគ្គលទាំងឡាយនោះ ទុកជាប្រមាទដ៏លើសលន់ក៏ដោយ,*

**ន តេ ភវំ អដ្ឋមមាទិយន្តិ** *អរិយបុគ្គលទាំងឡាយនោះ គង់មិនកាន់យកនូវភពជាគម្រប់៨ គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ,*

**ឥទម្បិ សង្ឃេ រតនំ បណីតំ** *កែវ គឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្ដម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន ។*

**សហាវស្ស ទស្សនសម្បទាយ**
**តយស្សុ ធម្មា ជហិតា ភវន្តិ**
**សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច**
**សីលព្វតំវាបិ យទត្ថិ កិញ្ចិ**

(**សំយោជនៈកិលេស ៣ យ៉ាង គឺៈ**) *សក្កាយទិដ្ឋិ វិចិកិច្ឆានិង សីលព្វតបរាមាសៈ ឯណាមួយតែងមាន ធម៌ទាំងឡាយ*

*៣នោះ សោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្ប័ទ គឺសោតាបត្តិមគ្គ,*

**ចតូហបាយេហិ ច វិប្បមុត្តោ** *ម្យ៉ាងទៀត សោតាបន្នបុគ្គល បានរួចស្រឡះចាកអបាយទាំងឡាយ ៤ ហើយ,*

**ឆ ចាភដ្ឋានានិ អភព្វោ កាតុំ** *មិនអាចធ្វើនូវឋានដ៏អាក្រក់ទាំងឡាយ ៦ គឺ អនន្តរិយកម្ម៥ និង កិរិយាផាកចិត្តទៅកាន់សាសនាដទៃឡើយ,*

**ឥទម្បិ សង្ឃេ រតនំ បណីតំ** *កែវ គឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ**
**កាយេន វាចាយុទ ចេតសា វា**

*ប្រសិនណាបើសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មខ្វះ ដោយកាយ វាចា ឬក៏ដោយចិត្ត (ព្រោះសេចក្តីភ្ញាំងភ្លាត់)*

**អភព្វោ សោ តស្ស បដិច្ឆទាយ** *សោតាបន្នបុគ្គលនោះ មិនអាចបិទបាំងនូវបាបកម្មនោះឡើយ,*

**អភព្វតា ទិដ្ឋបទស្ស វុត្តា** *ភាវៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វានឃើញហើយ ជាបុគ្គលមិនអាចនឹងបិទបាំងនូវបាបកម្ម ព្រះពុទ្ធទាំងឡាយ បានត្រាស់សម្តែងហើយ,*

**ឥទម្បិ សង្ឃេ រតនំ បណីតំ** *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**វនប្បគុម្ពេ យថា ផុស្សិតគ្គេ**
**គិម្ហានមាសេ បឋមស្មឹ គិម្ហេ**

*គុម្ពឈើក្នុងព្រៃ មានត្រួយលូតលាស់ ក្នុងខាងដើមគិម្ហរដូវ គឺខែក្តៅ យ៉ាងណាមិញ.*

**តថូបមំ ធម្មវរំ អទេសយិ**
**និព្វានគាមឹ បរមំ ហិតាយ**

*ព្រះសម្ពុទ្ធបានត្រាស់សម្តែងហើយ នូវធម៌ដ៏ប្រសើរជាធម៌ អាចញ៉ាំងសត្វទាំងឡាយឲ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ប្រៀបដូចជាគុម្ពឈើក្នុងព្រៃដូច្នោះឯង,*

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** *កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**វរោ វរញ្ញូ វរទោ វរាហរោ** *ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ,*

**អនុត្តរោ ធម្មវរំ អទេសយិ** *ព្រះអង្គប្រសើរឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្តែងហើយនូវធម៌ដ៏ប្រសើរ,*

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** *កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**ខីណំ បុរាណំ នវំ នត្ថិ សម្ភវំ** *កម្មចាស់ (របស់អរិយបុគ្គលឯណា) អស់ហើយ កម្មថ្មីរមែងមិនកើតប្រាកដ,*

**វិរត្តចិត្តាយតិកេ ភវស្មឹ** *អរិយបុគ្គលទាំងឡាយឯណា មានចិត្តនឿយណាយហើយ ក្នុងភពតទៅ,*

**តេ ខីណពីជា អវិរុឡ្ហិឆន្ទា** *អរិយបុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈ គឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះចម្រើនឡើយ,*

**និព្វន្តិ ធីរា យថាយម្បទីបោ** *ជាអ្នកមានប្រាជ្ញា តែងរលត់ទៅដូចជាប្រទីបដែលរលត់ទៅនេះ,*

**ឥទម្បិ សង្ឃេ រតនំ បណីតំ** *កែវ គឺព្រះសង្ឃនេះឯងជាកែវដ៏ឧត្តម,* **ឯតេន សច្ចេន សុវត្ថិ ហោតុ** *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

**☸ យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ**

*ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាស្ថិតនៅឰដ៍អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ,*

**តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ**

*យើងទាំងឡាយ **សូមនមស្សការនូវព្រះពុទ្ធជាម្ចាស់** ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតា និង មនុស្សតែងបូជា សូមសិរីសួស្តីកើតមាន ។*

**☸ យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ**

*ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ,*

**តថាគតំ ទេវមនុស្សបូជិតំ ធម្មំ នមស្សាម សុវត្ថិ ហោតុ**

*យើងទាំងឡាយ **សូមនមស្សការនូវព្រះធម៌** មានមកហើយដូចគ្នា ដែលទេវតា និង មនុស្សតែងបូជា សូមសិរីសួស្តីកើតមាន ។*

**☸ យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ**

*ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ,*

**តថាគតំ ទេវមនុស្សបូជិតំ សង្ឃំ នមស្សាម សុវត្ថិ ហោតុ**

*យើងទាំងឡាយ **សូមនមស្សការនូវព្រះសង្ឃ** មានមកហើយដូចគ្នា ដែលទេវតា និង មនុស្សតែងបូជា សូមសិរីសួស្តីកើតមាន ។៚*

# ករណីយមេត្តសុត្តប្បកាសនំ

**យស្សានុភាវតោ យក្ខា នេវ ទស្សេន្តិ ភីសនំ**

*យក្ខទាំងឡាយមិនហ៊ានសម្តែងនូវអាការគួរខ្លាចឡើយ ព្រោះអានុភាពនៃព្រះបរិត្តឯណា,*

**យម្ហិ ចេវានុយុញ្ជន្តោ រត្តិន្ទិវមតន្ទិតោ**

*ម្យ៉ាងទៀត បុគ្គលមិនខ្ជិលច្រអូស ក្នុងយប់ និង ថ្ងៃ ហើយព្យាយាមរៀនសូត្រព្រះបរិត្តឯណា,*

**សុខំ សុបត សុត្តោ ច បាបកំ កញ្ចិ ន បស្សត**

*កំពុងដេកលក់ ឬលក់រួចហើយក៏ជាសុខ រមែងមិនឃើញនូវសុបិនដ៏អាក្រក់តិចតួច,*

**ឯវមាទិគុណូបេតំ បរិត្តន្តម្ភណាម ហេ**

*យើងទាំងឡាយ សូធ្យឥឡូវនេះនូវព្រះបរិត្តនោះ ដែលប្រកបដោយគុណទាំងឡាយ មានយ៉ាងនេះជាដើម!*

# ករណីយមេត្តសូត្រ

**ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច**
កិច្ចឯណា (ដែលព្រះអរិយ) បានត្រាស់ដឹងនូវកោដ្ឋាសនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ គឺកុលបុត្រអ្នកឈ្លាស (*ឈ្លាសវៃ*) ក្នុងប្រយោជន៍ គួរធ្វើ,

**សក្កោ ឧជូ ច សុហុជូ ច** (កុលបុត្រនោះ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និង វាចាផង ត្រង់ល្អដោយចិត្តផង,

**សុវចោ ចស្ស មុទុ អនតិមានី** ជាអ្នកប្រដៅងាយផង សុភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង,

**សន្តុស្សកោ ច សុភរោ ច** ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង,

**អប្បកិច្ចោ ច សល្លហុកវុត្តិ** ជាអ្នកមានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាល(ក្នុងកាយ និង ចិត្ត)ផង,

**សន្តិន្ទ្រិយោ ច និបកោ ច** ជាអ្នកមានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង,

**អប្បគព្ភោ កុលេសុ អននុគិទ្ធោ** ជាអ្នកមិនឆ្គងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង,

**ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ វិញ្ញូជន**[១]ទាំងឡាយ គួរតិះដៀលនូវជនទាំងឡាយដទៃ ដោយកម្មឯណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្តចំពោះពពួកនៃសត្វ ថា)ៈ

**សុខិនោ វា ខេមិនោ ហោន្តុ សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួង សូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ!

**យេកេចិ បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា** សត្វមានជីវិតទាំងឡាយឯណា ឥតមានសេសសល់ ទោះសត្វដែលជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួន គឺឥតមានតណ្ហាក្តី,

**ទីឃា វា យេ មហន្តា វា** សត្វទាំងឡាយឯណា មានកាយវែងក្តី ធំក្តី,

**មជ្ឈិមា រស្សកា អណុកថូលា** មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយដ៏ស្តួម ឬធាត់ក្តី,

**ទិដ្ឋា វា យេ ច អទិដ្ឋា** សត្វទាំងឡាយឯណា ដែលយើងឃើញហើយក្តី មិនឃើញក្តី,

**យេ ច ទូរេ វសន្តិ អវិទូរេ** សត្វទាំងឡាយឯណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី,

---

[១] ជនអ្នកចេះដឹង (**អ្នកប្រាជ្ញ**) ។

**ភូតា វា សម្ភវេសី វា** ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី,

**សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួងសូមឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ!

**ន បរោ បរំ និកុព្វេថ** សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ,

**នាតិមញ្ញេថ កត្ថចិ នំ កញ្ចិ** មិនគួរមើលងាយគេតិចតួចក្នុងទីឯណាមួយឡើយ,

**ព្យារោសនា បដិឃសញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ**

មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានឹងគ្នា ដោយសេចក្តីក្រេវក្រោធ និង ដោយបដិឃសញ្ញា គឺសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ,

**មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ**

មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ដោយអាយុ គឺថាសូម្បីជីវិត ក៏ហ៊ានលះបង់ក្នុងការរក្សានូវបុត្របានយ៉ាងណាមិញ,

**ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ**

បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ចំពោះទៅរកសត្វទាំងឡាយទាំងពួង យ៉ាងនោះឯង ។

**មេត្តញ្ច សព្វលោកស្មឹ មានសម្ភាវយេ អបរិមាណំ**

**ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ**

បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ គឺក្នុងខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង,

**តដ្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវតស្សវិគត មិទ្ធោ** (បុគ្គលអ្នកចម្រើននូវមេត្តាចិត្តនោះ)ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាសហើយ គឺថាជាអ្នកមិនដេកលក់ អស់កាលត្រឹមណា,

**ឯតំ សតឹ អធិដ្ឋេយ្យ**[1] គួរតម្កល់នូវមេត្តានុស្សតិនុ៎ះ (អស់កាលត្រឹមនោះ),

**ព្រហ្មមេតំ វិហារំ ឥធមាហុ** បណ្ឌិតទាំងឡាយ ពោលនូវកិរិយានោះថាជា **ព្រហ្មវិហារ**[2] ក្នុងសាសនានេះ,

**ទិដ្ឋិញ្ច អនុបគម្ម សីលវា**
**ទស្សនេន សម្បន្នោ**
**កាមេសុ វិនេយ្យ គេធំ**
**ន ហិ ជាតុ គព្ភសេយ្យំ បុនរេតិ**

(បុគ្គលដែលមាន **មេត្តាព្រហ្មវិហារ**) មិនដល់ស៊ប់នូវទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្ប័ទគឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់គព្ភសេយ្យាស គឺថា មិនកើតក្នុងគភ៌ទៀតឡើយ ។៙៚

---

(១) ក្នុងសៀវភៅសត្តបរិត្ត-ទ្វាទសបរិត្ត ព.ស.២៥១៥ (// 1971) ជា **អធិដ្ឋហេយ្យ** ។
(២) ធម៌សម្រាប់នៅរបស់**ព្រហ្ម** (**មេត្តាព្រហ្មវិហារធម៌**) ។

# ខន្ធបរិត្តារម្ភោ

**សព្វាសីវិសជាតីនំ ទិព្វមន្តាគទំ វិយ**
**យន្នាសេតិ វិសំ ឃោរំ សេសញ្ចាបិ បរិស្សយំ**
**អាណាក្ខេត្តម្ហិ សព្វត្ថ សព្វទា សព្វបាណិនំ**
**សព្វសោបិ និវារេតិ បរិត្តន្តម្ភណាម ហេ**

ព្រះបរិត្តឯណា តែងញុំាងពិសដ៏ពន្លឹកនៃពួកសត្វទីឃជាតិទាំងអស់ ឱ្យវិនាសទៅ ដូចជាឱសថវិសេសដ៏ប្រកបដោយមន្តទិព្វ ម្យ៉ាងទៀតព្រះបរិត្តឯណា តែងឃាត់បង់នូវសេចក្តីអន្តរាយដ៏សេស របស់សត្វទាំងអស់ ក្នុងអាណាខេត្រទាំងមូល ដោយប្រការទាំងពួង សព្វៗកាល, យើងទាំងឡាយសូធ្យឥឡូវនេះនូវព្រះបរិត្តនោះ!

# ខន្ធបរិត្ត

**វិរូបក្ខេហិ មេ មេត្តំ** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគ ឈ្មោះ**វិរូបក្ខ** ទាំងឡាយផង,

**មេត្តំ ឯរាបថេហិ មេ** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះ**ឯរាបថៈ** ទាំងឡាយផង,

**ឆព្យាបុត្តេហិ មេ មេត្តំ** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះ**ឆព្យាបុត្ត** ទាំងឡាយផង,

**មេត្តំ កណ្ហាគោតមកេហិ ច** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះ**កណ្ហាគោតមកៈ** ទាំងឡាយផង,

**អបាទកេហិ មេ មេត្តំ** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វឥតជើងទាំងឡាយផង,

**មេត្តំ ទិបាទកេហិ មេ** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងពីរទាំងឡាយផង,

**ចតុប្បទេហិ មេ មេត្តំ** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើង៤ទាំងឡាយផង,

**មេត្តំ ពហុប្បទេហិ មេ** ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងច្រើនទាំងឡាយផង,

**មា មំ អបាទកោ ហឹសិ** សត្វឥតជើង កុំបៀតបៀនអាត្មាអញឡើយ,

**មា មំ ហឹសិ ទិបាទកោ** សត្វជើងពីរ កុំបៀតបៀនអាត្មាអញឡើយ,

**មា មំ ចតុប្បទោ ហឹសិ** សត្វជើងបួន កុំបៀតបៀនអាត្មាអញឡើយ,

**មា មំ ហឹសិ ពហុប្បទោ** សត្វជើងច្រើន កុំបៀតបៀនអាត្មាអញឡើយ,

**សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា ច កេវលា**

សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផង ទាំងអស់គ្នា,

**សព្វេ ភទ្រានិ បស្សន្តុ** សូមសព្វសត្វ (ទាំងនោះ) ឃើញនូវសេចក្ដីចម្រើនទាំងឡាយ,

**មា កញ្ចិ បាបមាគមា** សេចក្ដីលាមកអាក្រក់តិចតួច កុំមកដល់ឡើយ (គឺថា កុំកើតមានដល់សត្វទាំងនោះឡើយ),

**អប្បមាណោ ពុទ្ធោ** ព្រះពុទ្ធជាម្ចាស់ ទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន,

**អប្បមាណោ ធម្មោ** ព្រះធម៌ទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន,

**អប្បមាណោ សង្ឃោ** ព្រះសង្ឃទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន,

**បមាណវន្តានិ សិរីសបានិ អហិវច្ឆិកា សតបទី ឧណ្ណានាភី សរពូ មូសិកា** សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ និង កណ្ដុរ សុទ្ធតែមានប្រមាណ(គួររាប់ចំនួនបាន) គឺថា មិនច្រើនដូចគុណនៃព្រះរតនត្រ័យទេ,

**កតា មេ រក្ខា កតា មេ បរិត្តា** កិរិយារក្សា អាត្មាអញបានធ្វើហើយ ទាំងកិរិយាពាំង អាត្មាអញក៏បានធ្វើហើយ,

**បដិក្កមន្តុ ភូតានិ** ពួកសត្វ(កាច)ទាំងឡាយ ចូរចៀសចេញទៅ,

**សោហំ នមោ ភគវតោ** អាត្មាអញ(ធ្វើឥឡូវនេះ) នូវកិរិយានមស្សការ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់,

**នមោ សត្តន្នំ សម្មាសម្ពុទ្ធានន្តិ** អាត្មាអញ(ធ្វើឥឡូវនេះ) នូវកិរិយានមស្សការ ចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ ៕

# មោរបរិត្តារម្ភោ

**បូរេន្តំ ពោធិសម្ភារេ  និព្វត្តំ មោរយោនិយំ**
**យេន សំវិហិតារក្ខំ  មហាសត្តំ វនេ ចរា**
**ចិរស្សំ វាយមន្តាបិ  នេវ សក្ខិំសុ គណ្ហិតុំ**

ព្រានព្រៃទាំងឡាយ សូម្បីព្យាយាមអស់កាលយូរ ក៏មិនអាចដើម្បីចាប់នូវព្រះមហាសត្វ ដែលកើតហើយក្នុងកំណើតនៃក្ងោក ព្រះអង្គកំពុងបំពេញនូវពោធិសម្ភារ មានកិរិយារក្សា(នូវព្រះអង្គ)ចាត់ចែងល្អហើយ ដោយព្រះបរិត្តឯណា,

**ព្រហ្មមន្តន្តិ អក្ខាតំ បរិត្តន្តម្ភណាម ហេ**
យើងទាំងឡាយសូធ្យឥឡូវនេះ នូវព្រះបរិត្តនោះ ដែលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហៅថា **ព្រហ្មមន្ត** គឺ មន្តដ៏ប្រសើរ ។

# មោរបរិត្ត

☸ **ឧទេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បថ-វិប្បភាសោ** *ព្រះអាទិត្យនេះជាដួងភ្នែក(នៃលោក) ជាឯករាជ មានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង ហើយរះឡើង,*

**តំ តំ នមស្សាមិ ហរិស្សវណ្ណំ បថវិប្បភាសំ** *ព្រោះហេតុនោះ ខ្ញុំសូមនមស្សការនូវព្រះអាទិត្យនោះ ដែលមានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង,*

**តយជ្ជ គុត្តា វិហរេមុ ទិវសំ** *យើងទាំងឡាយដែលលោកគ្រប់គ្រងរក្សាហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់មួយថ្ងៃ,*

**យេ ព្រាហ្មណា វេទគូ សព្វធម្មេ** *ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ទាំងពួង,*

**តេ មេ នមោ តេ ច មំ បាលយន្តុ** *ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្សការរបស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ,*

**នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា** *សូមនមស្សការថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្សការថ្វាយបង្គំ ចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ),*

**នមោ វិមុត្តានំ នមោ វិមុត្តិយា** *សូមនមស្សការថ្វាយបង្គំចំពោះ (ព្រះអរិយបុគ្គលទាំងឡាយ) ដែលលោកផុតហើយ ចាករាគាទិក្កិលេស សូមនមស្សការថ្វាយបង្គំ ចំពោះវិមុត្តិធម៌ (នៃព្រះអរិយបុគ្គលទាំងឡាយនោះ),*

**ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា** *ក្ងោកនោះលុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបចរទៅដើម្បីស្វែងរកអាហារ។*

**❋ អបេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ** ព្រះអាទិត្យនេះជាដួងភ្នែក(នៃលោក) ជាឯករាជ មានពណ៌ដូចជាពណ៌នៃមាស ញ៉ាំងប្រឹថពីឱ្យភ្លឺស្វាងហើយអស្តង្គតទៅ,

**តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ** ព្រោះហេតុនោះ ខ្ញុំសូមនមស្សការនូវព្រះអាទិត្យនោះ ដែលមានពណ៌ដូចជាពណ៌នៃមាស ញ៉ាំងប្រឹថពីឱ្យភ្លឺស្វាង,

**តយជ្ជ គុត្តា វិហរេមុ រត្តិំ** យើងទាំងឡាយដែលលោកគ្រប់គ្រងរក្សាហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់មួយរាត្រី,

**យេ ព្រាហ្មណា វេទគូ សព្វធម្មេ** ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ទាំងពួង,

**តេ មេ នមោ តេ ច មំ បាលយន្តុ** ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល)នូវកិរិយានមស្សការរបស់ខ្ញុំ ម្យ៉ាងទៀតព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ,

**នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា** សូមនមស្សការថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្សការថ្វាយបង្គំ ចំពោះ**ពោធិញ្ញាណ**(នៃព្រះពុទ្ធទាំងឡាយនោះ),

**នមោ វិមុត្តានំ នមោ វិមុត្តិយា** សូមនមស្សការថ្វាយបង្គំចំពោះ(ព្រះអរិយបុគ្គលទាំងឡាយ) ដែលលោកផុតហើយ ចាករាគា- -ទិក្កិលេស សូមនមស្សការថ្វាយបង្គំ ចំពោះ**វិមុត្តិធម៌**(នៃព្រះអរិយបុគ្គលទាំងឡាយនោះ),

**ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយីតិ** ក្ងោកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបបានសម្រេចនូវកិរិយានៅ ៕ល៚

# ឆទ្ទន្តសុត្តារម្ភោ

**យស្សានុស្សរណេនាបិ អន្តលិក្ខេបិ បាណិនោ**
**បតដ្ឋមធិគច្ឆន្តិ ភូមិយំ វិយ សព្វទា**
**សព្ពុបទ្ទវជាលម្ហា យក្ខចោរាទិសម្ភវា**
**គណនា ន ច មុត្តានំ បរិត្តន្តម្ភណាម ហេ**

សត្វទាំងឡាយតែងបាននូវទីពឹង សូម្បីក្នុងអាកាសក៏ដូចជាលើផែនដីដែរ សព្វៗកាល សត្វទាំងឡាយ ដែលរួចហើយចាកសំណាញ់គឺសេចក្តីឧបទ្រពគ្រប់យ៉ាង ដែលកើតអំពីសត្រូវមានយក្ខ និង ចោរជាដើម ដោយកិរិយារលឹករឿយៗ នូវព្រះបរិត្តឯណា នឹងគណនាត្រារាប់ពុំបានឡើយ យើងទាំងឡាយសូធ្យឥឡូវនេះ នូវព្រះបរិត្តនោះ,

## ឆទ្ទន្តសូត្រ

**ឯវម្មេ សុតំ** ( សូត្រនេះឈ្មោះ**ឆទ្ទន្តសូត្រ** ) គឺខ្ញុំ( ឈ្មោះ**អានន្ទ** ) បានស្តាប់មកហើយយ៉ាងនេះ ថា:

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី,

**តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ** ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនូវភិក្ខុទាំងឡាយ ក្នុងទីនោះដូច្នេះថា **ភិក្ខវោ** ម្នាលភិក្ខុទាំងឡាយ!

**ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទាំងឡាយនោះ ក៏ទទួលឆ្លើយតបព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគ ដូច្នេះថា **ភទន្តេ** បពិត្រព្រះអង្គដ៏ចម្រើន!

**ភគវា ឯតទវោច** ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវ **ធជគ្គសូត្រ** នេះ ដោយព្រះពុទ្ធដីកា ដូច្នេះថា:

**ភូតបុព្វំ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងពីព្រេងនាយ មកថា:

**ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ** សង្គ្រាមនៃអសុរមួយអន្លើដោយទេវតា ជាសង្គ្រាមតទល់ប្រកៀកគ្នាហើយ,

**អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ ទេវេ តាវ-តឹសេ អាមន្តេសិ** ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ទេវរាជឈ្មោះថា*សក្ក* ជាធំជាងទេវតាទាំងឡាយ ហៅនូវទេវតាទាំងឡាយក្នុងតាវត្តិង្សពិភព មកប្រាប់ថា:

**សចេ មារិសា ទេវានំ សង្គាមគតានំ ឧប្បជ្ជេយ្យ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** ម្នាលអ្នកនិរទុក្ខទាំងឡាយ បើសេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម កើតឡើងដល់ទេវតាទាំងឡាយ ដែលទៅហើយកាន់សង្គ្រាម(ក្នុងកាលណា),

**មមេវ តស្មឹ សមយេ ធជគ្គំ ឧល្លោកេយ្យាថ** អ្នកទាំងឡាយ គប្បីក្រឡេកមើល នូវចុងទង់ជ័យរបស់អញក្នុងកាលនោះកុំខានឡើយ,

**មមំ ហិ វោ ធជគ្គំ ឧល្លោកយតំ** ព្រោះថា កាលបើអ្នកទាំងឡាយ ក្រឡេកមើលនូវចុងទង់ជ័យរបស់អញ,

**យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន,

**សោ បហិយ្យិស្សតិ** សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅបាន,

**នោ ចេ មេ ធជគ្គំ ឧល្លោកេយ្យាថ** បើអ្នកទាំងឡាយមិនក្រឡេកមើលនូវចុងទង់ជ័យរបស់អញទេ,

**អថ បជាបតិស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ** ក៏គប្បីក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជ ឈ្មោះ*បជាបតី* ក្នុងកាលនោះក៏បាន,

**បជាបតិស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ** ព្រោះថា កាលបើអ្នកទាំងឡាយ ក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជ ឈ្មោះ*បជាបតី*,

**យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន,

**សោ បហិយ្យិស្សតិ** សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅបាន,

**នោ ចេ បជាបតិស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ** បើអ្នកទាំងឡាយ មិនក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះ*បជាបតី* ទេ,

**អថ វរុណស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ** ក៏គប្បីក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជ ឈ្មោះ*វរុណៈ* ក្នុងកាលនោះក៏បាន,

**វរុណស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ** ព្រោះថា កាលបើអ្នកក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះ*វរុណៈ*, **យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន,

**សោ បហិយ្យិស្សតិ** សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅបាន,

**នោ ចេ វរុណស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ** បើអ្នកទាំងឡាយ មិនក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះ *វរុណៈ* ទេ,

**អថ ឦសានស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ** ក៏គប្បីក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះ*ឦសាន* ក្នុងកាលនោះក៏បាន,

**ឦសានស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ** ព្រោះថា កាលបើអ្នកទាំងឡាយ ក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះ*ឦសាន*, **យម្ភវស្សេត ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្ដីខ្លាច សេចក្ដីរន្ធត់ ឬសេចក្ដីព្រឺរោមឯណានឹងកើតមាន, **សោ បហិយ្យិស្សតេ** សេចក្ដីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅបាន,

**តំ ខោ បន ភិក្ខវេ សក្កស្ស វា ទេវានមិន្ទស្ស ធជគ្គំ ឧល្លោកយតំ** ម្នាលភិក្ខុទាំងឡាយ កាលបើទេវតាទាំងឡាយ កាលក្រឡេកមើលនូវចុងទង់ជ័យនោះ នៃទេវរាជឈ្មោះ*សក្កៈ* ជាធំជាងទេវតាទាំងឡាយក្ដី,

**បជាបតស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ** កាលក្រឡេកមើលនូវទង់ជ័យនោះ នៃទេវរាជឈ្មោះ*បជាបតី* ក្ដី,

**វរុណស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ** កាលក្រឡេកមើលនូវទង់ជ័យនោះ នៃទេវរាជឈ្មោះ*វរុណ* ក្ដី,

**ឦសានស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ** កាលក្រឡេកមើលនូវទង់ជ័យនោះ នៃទេវរាជឈ្មោះ*ឦសាន* ក្ដី,

**យម្ភវស្សេត ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្ដីខ្លាច សេចក្ដីរន្ធត់ ឬសេចក្ដីព្រឺរោមឯណានឹងកើតមាន,

**សោ បហិយ្យេថាបិ នោបិ បហិយ្យេថ** សេចក្ដីខ្លាចជាដើមនោះ គប្បីស្ងប់រម្ងាប់បានខ្លះ មិនបានខ្លះ,

**តំ កស្ស ហេតុ** សេចក្ដីខ្លាចជាដើម ដែលស្ងប់រម្ងាប់បានខ្លះ មិនបានខ្លះនោះ ព្រោះហេតុអ្វី?

**សក្កោ ហិ ភិក្ខវេ ទេវានមិន្ទោ អវីតរាគោ អវីតទោសោ អវីតមោហោ ភីរុ ឆម្ភី ឧត្រាសី បលាយីតិ**

ម្នាលភិក្ខុទាំងឡាយ ទេវរាជឈ្មោះ*សក្កៈ* ជាធំជាងទេវតាទាំងឡាយ មាន**រាគៈ**មិនទាន់ទៅប្រាសហើយ មាន**ទោសៈ**មិនទាន់ទៅប្រាសហើយ មាន**មោហៈ**មិនទាន់ទៅប្រាសហើយ ជាអ្នកនៅមានសេចក្ដីខ្លាច មានសេចក្ដីរន្ធត់ មានសេចក្ដីស្លុត មានកិរិយារត់ទៅជាប្រក្រតីនៅឡើយ,

**អហញ្ច ខោ ភិក្ខវេ ឯវំ វទាមិ** ម្នាលភិក្ខុទាំងឡាយ ឯចំណែកខាង**តថាគត** ពោលយ៉ាងនេះ ថាៈ

**សចេ តុម្ហាកំ ភិក្ខវេ អរញ្ញគតានំ វា រុក្ខមូលគតានំ វា សុញ្ញាគារគតានំ វា** ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយនៅក្នុងព្រៃក្ដី នៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះដ៏ស្ងាត់ក្ដី,

**ឧប្បជ្ជេយ្យ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្ដីខ្លាច សេចក្ដីរន្ធត់ ឬសេចក្ដីព្រឺរោម កើតឡើង (ក្នុងសម័យឯណា),

**មមេវ តស្មឹ សមយេ អនុស្សរេយ្យាថ** អ្នកទាំងឡាយ គប្បីរំឭកនូវតថាគត ក្នុងសម័យនោះ កុំខានឡើយ ថា:

**ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ***អរហំ*** ព្រោះព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង,

**សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា ***សម្មាសម្ពុទ្ធោ*** ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ,

**វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា ***វិជ្ជាចរណសម្បន្នោ*** ព្រោះព្រះអង្គបរិបូណ៌ដោយ វិជ្ជា និង ចរណៈ,

**សុគតោ** ទ្រង់ព្រះនាមថា***សុគតោ*** ព្រោះព្រះអង្គ មានដំណើរល្អទៅកាន់ព្រះនិព្វាន,

**លោកវិទូ** ទ្រង់ព្រះនាមថា ***លោកវិទូ*** ព្រោះព្រះអង្គ ជ្រាបច្បាស់នូវត្រៃលោក,

**អនុត្តរោ** ទ្រង់ព្រះនាមថា ***អនុត្តរោ*** ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន,

**បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា ***បុរិសទម្មសារថិ*** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន,

**សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា***សត្ថាទេវមនុស្សានំ*** ព្រោះព្រះអង្គ ជាគ្រូនៃទេវតា និង មនុស្សទាំងឡាយ,

**ពុទ្ធោ** ទ្រង់ព្រះនាមថា***ពុទ្ធោ*** ព្រោះព្រះអង្គ ត្រាស់ដឹងនូវអរិយសច្ចធម៌,

**ភគវាតិ** ទ្រង់ព្រះនាមថា***ភគវា*** ព្រោះព្រះអង្គ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។

**មមំ ហិ វោ ភិក្ខវេ អនុស្សរតំ** ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយរឭកនូវ**តថាគត**,

**យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំ-សោ វា** សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណា នឹងកើតមាន, **សោ បហិយ្យិស្សតិ** សេចក្តីខ្លាចជាដើមនោះនឹងស្ងប់រម្ងាប់ទៅបាន,

**នោ ចេ មំ អនុស្សរេយ្យាថ** បើអ្នកទាំងឡាយមិនរឭកនូវ**តថាគត**ទេ,

**អថ ធម្មំ អនុស្សរេយ្យាថ** ក៏គប្បីរឭកនូវព្រះធម៌ ក្នុងកាលណោះ ថា:

**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ,

**សន្ទិដ្ឋិកោ** ជាធម៌ គឺព្រះអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង,

**អកាលិកោ** ជាធម៌ឱ្យផលមិនរង់ចាំកាល,

**ឯហិបស្សិកោ** ជាធម៌ គឺព្រះអរិយបុគ្គលគួរហៅអ្នកដទៃឱ្យចូលមកមើលបាន,

**ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គល គួរបង្អោនចូលមកទុកក្នុងចិត្តបាន,

**បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ** ជាធម៌ គឺវិញ្ញូជនទាំងឡាយគប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ។

**ធម្មំ ហិ វោ ភិក្ខវេ អនុស្សរតំ** ម្នាលភិក្ខុទាំងឡាយព្រោះថា កាលបើអ្នកទាំងឡាយរឭកនូវព្រះធម៌,

**យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្ដីខ្លាច សេចក្ដីរន្ធត់ ឬសេចក្ដីព្រឺរោមឯណានឹងកើតមាន,

**សោ បហិយ្យិស្សតិ** សេចក្ដីខ្លាចជាដើមនោះនឹងស្ងប់រម្ងាប់ទៅបាន,

**នោ ចេ ធម្មំ អនុស្សរេយ្យាថ** បើអ្នកទាំងឡាយមិនរឭកនូវព្រះធម៌ទេ,

**អថ សង្ឃំ អនុស្សរេយ្យាថ** ក៏គប្បីរឭកនូវព្រះសង្ឃ ក្នុងកាលណោះ ថា:

**សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ,

**ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រង់,

**ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីព្រះនិព្វាន,

**សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រឹមត្រូវ,

**យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ បើរាប់ជាគូនៃបុរសមាន៤គូ ឯណា,

**អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គល មាន៨,

**ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះជាជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,

**អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា,

**បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និង មិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា,

**ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និង ផលនៃកម្មហើយបូជា,

**អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ,

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន,

**សង្ឃំ ហិ វោ ភិក្ខវេ អនុស្សរតំ** ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយរឭកនូវព្រះសង្ឃ,

**យម្ភវិស្សតិ ភយំ ឆម្ភិតត្តំ វា លោមហំសោ វា** សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន,

**សោ បហិយ្យិស្សតិ** សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅបាន,

**តំ កិស្ស ហេតុ** សេចក្តីខ្លាចជាដើម ដែលស្ងប់រម្ងាប់ទៅបាននោះ ព្រោះហេតុអ្វី?

**តថាគតោ ហិ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ វីតរាគោ វីតទោសោ វីតមោហោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយីតិ** ម្នាលភិក្ខុទាំងឡាយ ព្រោះ**តថាគត** ជាព្រះអរហន្តសម្មាសម្ពុទ្ធ មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ មានមោហៈទៅប្រាសហើយ ឥតមានសេចក្តីខ្លាច ឥតមានសេចក្តីរន្ធត់ ឥតមានសេចក្តីស្លុត មិនមានកិរិយារត់ទៅជាប្រក្រតីឡើយ ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគ បានត្រាស់នូវព្រះពុទ្ធដីកានេះហើយ,

**ឥទំ វត្វាន សុគតោ** ព្រះសុគត លុះត្រាស់នូវព្រះពុទ្ធដីកានេះហើយ,

**អថាបរំ ឯតទវោច សត្ថា** លំដាប់នោះ ព្រះសាស្តាត្រាស់នូវព្រះពុទ្ធដីកានេះ តទៅទៀតថា:

**អរញ្ញេ រុក្ខមូលេ វា សុញ្ញាគារេ វ ភិក្ខវោ** ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា កាលបើនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី,

**អនុស្សរេថ សម្ពុទ្ធំ** គប្បីរឭកនូវព្រះសម្ពុទ្ធ,

**ភយំ តុម្ហាក នោ សិយា** សេចក្តីខ្លាច នឹងមិនគប្បីមានដល់អ្នកទាំងឡាយ,

**នោ ចេ ពុទ្ធំ សរេយ្យាថ លោកជេដ្ឋំ នរាសភំ**
**អថ ធម្មំ សរេយ្យាថ និយ្យានិកំ សុទេសិតំ**

បើអ្នកទាំងឡាយ មិនរឭកនូវព្រះសម្ពុទ្ធ ដែលជាធំជាងលោក ដែលប្រសើរជាងនរជនទេ ក៏គប្បីរឭកនូវព្រះធម៌ ជាធម៌អាចដឹកនាំសត្វលោក ឱ្យចេញចាកសំសារវដ្តបាន ដែលតថាគតសម្តែងហើយដោយល្អ ក្នុងកាលនោះចុះ,

**នោ ចេ ធម្មំ សរេយ្យាថ និយ្យានិកំ សុទេសិតំ**
**អថ សង្ឃំ សរេយ្យាថ បុញ្ញក្ខេត្តំ អនុត្តរំ**

បើអ្នកទាំងឡាយ មិនរឭកនូវព្រះធម៌ ជាធម៌អាចដឹកនាំសត្វលោកឱ្យចេញចាកសំសារវដ្តបាន ដែលតថាគតសម្តែងដោយល្អហើយ(នោះ)ទេ ក៏គប្បីរឭកនូវព្រះសង្ឃ ជាបុញ្ញក្ខេត្តនៃសត្វលោករកខេត្តដទៃប្រសើរជាងគ្មាន(នោះ)ចុះ,

**ឯវម្ពុទ្ធំ សរន្តានំ ធម្មំ សង្ឃញ្ច ភិក្ខវោ** ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា កាលបើរឭកនូវព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃយ៉ាងនេះ,

**ភយំ វា ឆម្ភិតត្តំ វា លោមហំសោ ន ហេស្សតិ** សេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី នឹងមិនកើតមានឡើយ!

# អាដានាដិយបរិត្តារម្ភោ

**អប្បសន្នេហិ នាថស្ស សាសនេ សាធុ សម្មតេ**
**អមនុស្សេហិ ចណ្ឌេហិ សទា កិព្ពិសការិភិ**
**បរិសានញ្ច តិស្សន្នំ អហឹសាយ ច គុត្តិយា**
**យន្ទេសេសិ មហាវីរោ បរិត្តន្តម្ភណាម ហេ**

*(ព្រះសម្ពុទ្ធជាម្ចាស់) ព្រះអង្គមានសេចក្តីព្យាយាមធំទ្រង់ត្រាស់សម្តែងហើយនូវព្រះបរិត្តឯណា ដើម្បីកិរិយាមិនបៀតបៀនផង ដើម្បីគ្រប់គ្រងរក្សាផង ដល់បរិសទ្យទាំង*

*ឡាយ៤ អំពីពួកអមនុស្សកាចៗ ដែលធ្វើតែកម្មដ៏លាមកសព្វកាល ជាអ្នកមិនជ្រះថ្លាក្នុងសាសនានៃព្រះលោកនាថ ដែលសប្បុរស សន្មតហើយថាជាសាសនាដ៏ល្អ យើងទាំងឡាយសូមឲ្យឥឡូវនេះ នូវព្រះបរិត្តនោះ,*

# អាដានាដិយបរិត្ត

**វិបស្សិស្ស នមត្ថុ ចក្ខុមន្តស្ស សិរីមតោ**

សូមនមស្សការថ្វាយបង្គំ ចំពោះ**ព្រះសម្ពុទ្ធ** ទ្រង់ព្រះនាម **វិបស្សី** ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី,

**សិខិស្សបិ នមត្ថុ សព្វភូតានុកម្បិនោ**

សូមនមស្សការថ្វាយបង្គំ ចំពោះ**ព្រះសម្ពុទ្ធ** ទ្រង់ព្រះនាម**សិខី** ព្រះអង្គមានសេចក្តីអនុគ្រោះដល់សត្វទាំងពួងជាប្រក្រតី,

**វេស្សភុស្ស នមត្ថុ នហាតកស្ស តបស្សិនោ**

សូមនមស្សការថ្វាយបង្គំ ចំពោះ**ព្រះសម្ពុទ្ធ** ទ្រង់ព្រះនាម **វេស្សភូ** ព្រះអង្គមានកិលេសលាងស្អាតហើយ ព្រះអង្គមានតបធម៌,

**នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ**

សូមនមស្សការថ្វាយបង្គំ ចំពោះ**ព្រះសម្ពុទ្ធ** ទ្រង់ព្រះនាម **កកុសន្ធៈ** ព្រះអង្គញាំញីនូវមារ ព្រមទាំងសេនានៃមារ,

**កោនាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ**

សូមនមស្សការថ្វាយបង្គំ ចំពោះ**ព្រះសម្ពុទ្ធ** ទ្រង់ព្រះនាម **កោនាគមន** ព្រះអង្គមានបាបបន្សាត់ចោលហើយ មានព្រហ្មចរិយធម៌នៅរួចហើយ,

**កស្សបស្ស នមត្ថុ វិប្បមុត្តស្ស សព្វធិ**

សូមនមស្សការថ្វាយបង្គំ ចំពោះ**ព្រះសម្ពុទ្ធ** ទ្រង់ព្រះនាម **កស្សប** ព្រះអង្គផុតចាកកិលេសទាំងពួងហើយ,

**អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ**

សូមនមស្សការថ្វាយបង្គំ ចំពោះ**ព្រះសម្ពុទ្ធ** ទ្រង់ព្រះនាម **អង្គីរស** ព្រះអង្គជាបុត្រនៃសក្យរាជ ដ៏មានសិរី,

**យោ ឥមំ ធម្មមទេសេសិ សព្វទុក្ខាបនូទនំ**

**ព្រះសម្ពុទ្ធ**អង្គឯណា ទ្រង់បានត្រាស់សម្តែងហើយនូវធម៌នេះ ជាធម៌បន្ទោបង់នូវទុក្ខទាំងពួង,

**យេ ចាបិ និព្វុតា លោកេ យថាភូតំ វិបស្សិសុំ**

ម្យ៉ាងទៀត **ព្រះសម្ពុទ្ធ**ទាំងឡាយអង្គឯណា ព្រះអង្គរំលត់កិលេសហើយក្នុងលោក ទ្រង់ឃើញច្បាស់នូវធម៌តាមសេចក្តីពិត,

**តេ ជនា អបិសុណា មហន្តា វីតសារទា**

**ព្រះសម្ពុទ្ធ**ទាំងឡាយនោះ ព្រះអង្គមិនមានសេចក្តីញុះញង់ស៊កសៀត ទ្រង់ប្រសើរដោយព្រះគុណ មានសេចក្តីក្រវល់ក្រវាយ (ព្រោះកិលេស)ទៅប្រាសហើយ,

**ហិតំ ទេវមនុស្សានំ យំ នមស្សន្តិ គោតមំ**

**វិជ្ជាចរណសម្បន្នំ មហន្តំ វីតសារទំ**

ទេវតា និង មនុស្សទាំងឡាយ រមែងនមស្សការនូវព្រះសម្ពុទ្ធអង្គឯណា ជាគោតមគោត្រ ជាប្រយោជន៍ដល់ទេវតា និង មនុស្សទាំងឡាយ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និង ចរណៈ ប្រសើរដោយព្រះគុណ មានសេចក្តីក្រវល់ក្រវាយ(ព្រោះកិលេស)ទៅប្រាសហើយ,

**វិជ្ជាចរណសម្បន្នំ ពុទ្ធំ វន្ទាម គោតមន្តិ**

យើងទាំងឡាយ សូមក្រាបថ្វាយបង្គំនូវព្រះសម្ពុទ្ធអង្គនោះ ជាគោតមគោត្រ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និង ចរណៈ,

**ឯតេ ចញ្ញេ ច សម្ពុទ្ធា អនេកសតកោដិយោ**

ព្រះសម្ពុទ្ធទាំងនុ៎ះផង ព្រះសម្ពុទ្ធទាំងឡាយអង្គឯទៀតផង ច្រើនជាងរយកោដិ,

**សព្វេ ពុទ្ធា អសមសមា សព្វេ ពុទ្ធា មហិទ្ធិកា**

ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែស្មើដោយព្រះពុទ្ធដូចគ្នា ឥតមានបុគ្គលណាមួយស្មើឡើយ ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះសុទ្ធតែមានឫទ្ធិច្រើន,

**សព្វេ ទសពលូបេតា វេសារជ្ជេហុបាគតា**

ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែប្រកបដោយទសពលញ្ញាណ និង ប្រកបដោយវេសារជ្ជញ្ញាណទាំងឡាយ,

**សព្វេ តេ បដិជានន្តិ អាសភណ្ឌានមុត្តមំ**

ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែត្រាស់ដឹងនូវធម៌ជាទីតាំងដ៏ខ្ពង់ខ្ពស់ គឺព្រះសព្វញ្ញុតញ្ញាណដ៏ឧត្តម,

**សីហនាទំ នទន្តេ តេ បរិសាសុ វិសារទា**

ព្រះសម្ពុទ្ធទាំងឡាយនោះ ព្រះអង្គក្លៀវក្លា បន្លឺនូវសីហនាទ គឺព្រះសូរសំឡេងដ៏ប្រសើរ ក្នុងពពួកនៃបរិស័ទ,

**ព្រហ្មចក្កំ បវត្តេន្តិ លោកេ អប្បដិវត្តិយំ**

ព្រះអង្គទ្រង់ត្រាស់សម្ដែងនូវព្រះធម៌ដូចជាចក្កដ៏ប្រសើរ ដែលឥតមានអ្នកណាមួយឱ្យប្រព្រឹត្តទៅក្នុងលោកបានឡើយ,

**ឧបេតា ពុទ្ធធម្មេហិ អដ្ឋារសហិ នាយកា**

ព្រះអង្គប្រកបដោយ **ពុទ្ធធម៌**[១] ទាំងឡាយ**១៨**, ព្រះអង្គជានាយកដឹកនាំសត្វចេញចាកសំសារវដ្ដ,

**ទ្វត្តឹសលក្ខណូបេតា សីត្យានុព្យញ្ជនាធរា**

ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ**៣២**ប្រការ ព្រមទាំងទ្រទ្រង់នូវអនុព្យញ្ជនៈ**៨០**គត់,

---

[១] **ពុទ្ធធម៌** គឺធម៌ដែលធ្វើបុគ្គលឱ្យបានត្រាស់ជាព្រះពុទ្ធ មាន**១៨** គឺ បារមីទាំង១០ មានទានបារមីជាដើម... មានឧបេក្ខាបារមីជាទីបំផុត, ព្រមទាំងសម្បត្តិ៨ប្រការ គឺ **មនុស្សត្តំ** មានជាតិជាមនុស្ស១, **លិង្គសម្បត្តិ** មានភេទជាបុរស១, **ហេតុ** មានឧបនិស្ស័យគួរដល់ព្រះអរហត្តផល១, **សត្ថារទស្សនំ** បានជួបបានឃើញព្រះសាស្ដា១, **បព្វជ្ជា** បានទ្រទ្រង់ភេទជាបព្វជិត១, **គុណសម្បត្តិ** បាននូវគុណមានលោកិយឈានជាដើម១, **អធិការោ** បានបំពេញបរិច្ចាគទាំង៥ មានបុត្តបរិច្ចាគជាដើម១, **ឆន្ទតា** មានសេចក្ដីស្រឡាញ់ព្រះ-សព្វញ្ញុតញ្ញាណ១ **រួមជា១៨** ។

**ព្យាមប្បភាយ សុប្បភា សព្វេ តេ មុនិកុញ្ជរា**

ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់មានរស្មីដ៏ល្អ ដោយរស្មីមានមណ្ឌលមួយព្យាម(ម្ខាង),

**ពុទ្ធា សព្វញ្ញុនោ ឯតេ សព្វេ ខីណាសវា ជិនា**

ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែជាព្រះសព្វញ្ញូ អស់អាសវៈហើយ ឈ្នះហើយ(នូវបញ្ចពិធមារ),

**មហប្បភា មហាតេជា មហាបញ្ញា មហព្វលា**

ព្រះអង្គមានរស្មីច្រើន មានតេជះច្រើន មានប្រាជ្ញាច្រើន មានកម្លាំងច្រើន,

**មហាការុណិកា ធីរា សព្វេសានំ សុខាវហា**

ព្រះអង្គជាអ្នកប្រាជ្ញ មានសេចក្តីករុណាច្រើន នាំមកនូវសេចក្តីសុខ ដើម្បីសព្វសត្វទាំងឡាយ,

**ទីបា នាថា បតដ្ឋា ច តាណា លេណា ច បាណិនំ**

ព្រះអង្គជាទីពឹង ជាទីអាស្រ័យ ដូចជាកោះ ជាទីជ្រកកោន ជាទីពួន របស់សត្វទាំងឡាយ,

**គតី ពន្ធូ មហស្សាសា សរណា ច ហិតេសិនោ**
**សទេវកស្ស លោកស្ស សព្វេ ឯតេ បរាយនា**

ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ ដូចជាផ្លូវ ជាផៅពង្ស ជាទីត្រេកអរច្រើន និង ជាទីពឹង ទីរឭក ព្រះអង្គស្វែងរកប្រយោជន៍ ជាទីប្រព្រឹត្តទៅខាងមុខ របស់សត្វលោក ព្រមទាំងទេវលោក,

**តេសាហំ សិរសា បាទេ វន្ទាមិ បុរិសុត្តមេ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះព្រះបាទទាំងឡាយនៃព្រះសម្ពុទ្ធទាំងនោះ,

**វចសា មនសា ចេវ វន្ទាមេតេ តថាគតេ**

**សយនេ អាសនេ ឋានេ គមនេ ចាបិ សព្វទា**

ក្នុងឥរិយាបថដេកក្តី អង្គុយក្តី ឈរក្តី សូម្បីក្នុងឥរិយាបថដើរក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំដោយវាចា និង ចិត្ត សព្វៗកាលចំពោះព្រះតថាគតទាំងឡាយនោះ,

**សទា សុខេន រក្ខន្តុ ពុទ្ធា សន្តិករា តុវំ**

ព្រះសម្ពុទ្ធទាំងឡាយ ព្រះអង្គជាអ្នកធ្វើនូវសេចក្តីរម្ងាប់ សូមរក្សានូវអ្នកដោយសេចក្តីសុខ សព្វៗកាល,

**តេហិ ត្វំ រក្ខិតោ សន្តោ មុត្តោ សព្វភយេន ច**

ខ្លួនអ្នកកាលបើព្រះសម្ពុទ្ធទាំងឡាយនោះ ទ្រង់រក្សាហើយ ចូរជាអ្នកស្ងប់រម្ងាប់ផង ចូររួចចាកភ័យទាំងពួងផង,

**សព្វរោគវិនីមុត្តោ សព្វសន្តាបវជ្ជិតោ**

**សព្វវេរមតិក្កន្តោ និព្វុតោ ច តុវំ ភវ**

សូមឱ្យអ្នកជាបុគ្គលផុតចាករោគទាំងពួងផង ជាអ្នកចៀសចាកសេចក្តីក្តៅក្រហាយទាំងពួងផង ជាអ្នកកន្លងបង់នូវពៀរទាំងពួងផង ជាអ្នករលត់ទុក្ខព្រួយផង,

**សព្វីតិយោ វិវជ្ជន្តុ** សូមឱ្យចង្រៃទាំងពួងទាំងឡាយប្រាស ចេញ គឺថា ចូរឱ្យចៀសវាងចេញឆ្ងាយទៅ,

**សព្វរោគោ វិនស្សតុ** សូមឱ្យរោគទាំងពួង(របស់អ្នក)ជា សះស្បើយទៅ,

**មា តេ ភវត្វន្តរាយោ** អន្តរាយកុំបីមានដល់អ្នកឡើយ,

**សុខី ទីឃាយុកោ ភវ** សូមឱ្យអ្នកជាបុគ្គលមានសេចក្តី សុខ មានអាយុវែង,

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**
**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ**

**ធម៌** គឺ **ពរ**ទាំងឡាយ៤ប្រការ គឺៈ អាយុ១ ពណ៌សម្បុរកាយ១ សេចក្តីសុខ១ កម្លាំង១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែល មានសេចក្តីឱនកាយថ្វាយបង្គំដល់ព្រះរតនត្រ័យជាប្រក្រតី និង អ្នក ដែលមានសេចក្តីគោរពកោតក្រែងដល់បុគ្គល ដែលជាអ្នកចម្រើន ដោយគុណ មានសីលគុណជាដើម ឬដែលចម្រើនដោយវ័យ គឺចាស់ ព្រឹទ្ធាចារ្យ ៕៚

## អង្គុលិមាលបរិត្តារម្ភោ

**បរិត្តំ យម្ពណន្តស្ស និសិន្នដ្ឋានធោវនំ**
**ឧទកម្បិ វិនាសេតិ សព្វមេវ បរិស្សយំ**

ទឹកដែលលាងនូវទីអង្គុយនៃព្រះអង្គុលិមាលត្ថេរដែលលោកពោលនូវព្រះបរិត្តឯណា អាចញ៉ាំងសេចក្តីអន្តរាយគ្រប់យ៉ាងឱ្យវិនាសទៅ,

**សោត្ថិនា គព្ភវុដ្ឋានំ   យញ្ច សាធេតិ តំខណេ**
**ថេរស្សង្គុលិមាលស្ស   លោកនាថេន ភាសិតំ**

ម្យ៉ាងទៀត ព្រះបរិត្តឯណា ដែលព្រះលោកនាថ ត្រាស់សម្តែងហើយ ដល់ព្រះអង្គុលិមាលត្ថេរ ញ៉ាំងកិរិយាប្រសូតបុត្តឱ្យសម្រេចដោយសិរីសួស្តី ក្នុងខណៈនោះបាន,

**កប្បដ្ឋាយិមហាតេជំ   បរិត្តន្តម្ភណាម ហេ**

យើងទាំងឡាយសូធ្យឥឡូវនេះ នូវព្រះបរិត្តនោះ ដែលជាធម៌តាំងនៅអស់កប្ប ជាធម៌មានតេជៈច្រើន ។

## អង្គុលិមាលបរិត្ត *និង* ពោជ្ឈង្គបរិត្ត

**យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ** ម្នាលប្អូនស្រី តាំងអំពីអាត្មាកើតហើយដោយអរិយជាតិ,

**នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា** មិនបេះក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ,

**តេន សច្ចេន សោត្ថិ តេ** ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នក,

**ហោតុ សោត្ថិ គព្ភស្ស** សូមសិរីសួស្តីកើតមានដល់គភ៌ (នៃនាង) ។

**ពោជ្ឈង្គោ សតិសង្ខាតោ ធម្មានំ វិចយោ តថា**
**វិរិយម្បីតិបស្សទ្ធិ ពោជ្ឈង្គា ច តថាបរេ**
**សមាធុបេក្ខពោជ្ឈង្គា សត្តេតេ សព្វទស្សិនា**
**មុនិនា សម្មទក្ខាតា ភាវិតា ពហុលីកតា**

**ពោជ្ឈង្គ**ទាំងឡាយ៧ប្រការនេះ គឺ **សតិ**សម្ពោជ្ឈង្គ១ **ធម្មវិចយ**សម្ពោជ្ឈង្គ១ **វិរិយ**សម្ពោជ្ឈង្គ១ **បីតិ**សម្ពោជ្ឈង្គ១ **បស្សទ្ធិ**សម្ពោជ្ឈង្គ១ **សមាធិ**សម្ពោជ្ឈង្គ១ **ឧបេក្ខា**សម្ពោជ្ឈង្គ១ ដែលព្រះមុនីជាម្ចាស់ទ្រង់ជ្រាបនូវធម៌ទាំងពួង ត្រាស់សម្តែងហើយដោយប្រពៃ គឺបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ,

**សំវត្តន្តិ អភិញ្ញាយ និព្វានាយ ច ពោធិយា** តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងដ៏ក្រៃលែង ដើម្បីកិរិយាចេញចាកតណ្ហាផង ដើម្បីកិរិយាត្រាស់ដឹងផង,

**ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វៗកាល,

**ឯកស្មឹ សមយេ នាថោ មោគ្គល្លានញ្ច កស្សបំ**
**គិលានេ ទុក្ខិតេ ទិស្វា ពោជ្ឈង្គេ សត្ត ទេសយិ**

ក្នុងសម័យមួយ ព្រះលោកនាថជាម្ចាស់ ទ្រង់ឃើញនូវព្រះមោគ្គល្លាន និង ព្រះកស្សបៈ មានជម្ងឺដល់នូវទុក្ខវេទនា ហើយទ្រង់សម្តែងនូវពោជ្ឈង្គទាំងឡាយ ៧ ប្រការ,

**តេ ច តំ អភិនន្ទិត្វា រោគា មុច្ចឹសុ តំខណេ**

ព្រះថេរៈទាំងពីរអង្គនោះ ក៏រីករាយចំពោះព្រះពុទ្ធភាសិតនោះ ហើយបានជាសះស្បើយចាករោគ ក្នុងមួយរំពេចនោះ,

**ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វៗកាល,

**ឯកទា ធម្មរាជាបិ គេលញ្ញេនាភិបីឡិតោ**

ក្នុងគ្រាមួយ **ព្រះសម្ពុទ្ធជាព្រះធម្មរាជ** ដែលគិលានរោគបៀតបៀនហើយ,

**ចុន្ទត្ថេរេន តញ្ញេវ ភណាបេត្វាន សាទរំ**

ទ្រង់ត្រាស់ប្រើព្រះចុន្ទត្ថេរ ឱ្យសម្តែងនូវពោជ្ឈង្គនោះដែរដោយអើពើហើយ,

**សម្មោទិត្វា ច អាពាធា តម្ហា វុដ្ឋាសិ ឋានសោ**

ទ្រង់រីករាយ ហើយជាសះស្បើយចាកអាពាធនោះ ក្នុងមួយរំពេចនោះ,

**ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វៗកាល ។

**បហីនា តេ ច អាពាធា តណ្ហន្នម្បិ មហេសិនំ**

ក៏អាពាធទាំងឡាយនោះ ដែលព្រះអរិយបុគ្គលទាំង ៣ ព្រះអង្គ លោកជាអ្នកស្វែងរកនូវគុណធម៌ដ៏ធំ លះបង់ គឺថាលោកបានជាសះស្បើយហើយ,

**មគ្គាហតក្កិលេសា ច បត្តានុប្បត្តធម្មតំ**

ដល់ហើយនូវធម្មតា គឺកិរិយាមិនកើត (ទៀត) ដូចជាកិលេសដែលព្រះអរិយបុគ្គលកម្ចាត់បង់ហើយ ដោយព្រះអរិយមគ្គ,

**ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វៗ កាល ៕៚

# បកិណ្ណកបរិត្តគាថា

*(សម្រាប់សូធ្យបន្តខាងចុងនៃព្រះបរិត្ត)*

## អភយបរិត្តគាថា

**យន្ទុន្និមិត្តំ អវមង្គលញ្ច**
**យោ ចាមនាបោ សកុណស្ស សទ្ទោ**
**បាបគ្គហោ ទុស្សុបិនំ អកន្តំ**
**ពុទ្ធានុភាវេន វិនាសមេន្តុ**

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់មិនជាទីពេញចិត្តឯណាក្តី **ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់** សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

**យន្ទុន្និមិត្តំ អវមង្គលញ្ច**
**យោ ចាមនាបោ សកុណស្ស សទ្ទោ**
**បាបគ្គហោ ទុស្សុបិនំ អកន្តំ**
**ធម្មានុភាវេន វិនាសមេន្តុ**

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់មិនជាទីពេញចិត្តឯណាក្តី **ដោយអានុភាពនៃព្រះធម៌** សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

**យន្ទុន្និមិត្តំ អវមង្គលញ្ច**
**យោ ចាមនាបោ សកុណស្ស សទ្ទោ**
**បាបគ្គហោ ទុស្សុបិនំ អកន្តំ**
**សង្ឃានុភាវេន វិនាសមេន្តុ**

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់មិនជាទីពេញចិត្តឯណាក្តី **ដោយអានុភាពនៃព្រះសង្ឃ** សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**
**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ប្រាណិនោ**

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ, ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ!

**ឯត្តាវតា ច អម្ហេហិ សម្ភតំ បុញ្ញសម្បទំ**
**សព្វេ ទេវានុមោទន្តុ សព្វសម្បត្តិសិទ្ធិយា**

សូមទេវតាទាំងឡាយទាំងពួង អនុមោទនានូវសម្បទា គឺបុណ្យដែលយើងទាំងឡាយបានកសាងហើយទាំងប៉ុណ្ណោះ ដើម្បីឱ្យបានសម្រេចនូវសម្បត្តិទាំងពួង ។

**ទានំ ទទន្តុ សទ្ធាយ សីលំ រក្ខន្តុ សព្វទា**
**ភាវនាភិរតា ហោន្តុ គច្ឆន្តុ ទេវតា គតា**

មនុស្សទាំងឡាយ ចូរនាំគ្នាឱ្យទានដោយសទ្ធា ចូរនាំគ្នារក្សាសីល ចូរជាអ្នកត្រេកអរចំពោះភាវនា សព្វៗ កាលទៅ ទេវតាទាំងឡាយដែលមកហើយ សូមអញ្ជើញត្រឡប់ទៅវិញចុះ ។

**សព្វេ ពុទ្ធា ពលប្បត្តា បច្ចេកានញ្ច យម្ពលំ**
**អរហន្តានញ្ច តេជេន រក្ខំ ពន្ធាមិ សព្វសោ**

ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ សុទ្ធតែទ្រទ្រង់នូវកម្លាំង ទាំងព្រះបច្ចេកពុទ្ធទាំងឡាយក៏មានកម្លាំង ព្រះអរហន្តទាំង

ឡាយក៏មានកម្លាំង ខ្ញុំសូមចងនូវការរក្សាដោយតេជះ(នៃកម្លាំងទាំងឡាយនោះ) ដោយប្រការទាំងពួង ។

# ជយបរិត្តគាថា

**មហាការុណិកោ នាថោ  ហិតាយ សព្វបាណិនំ**
**បូរេត្វា បារមី សព្វា  បត្តោ សម្ពោធិមុត្តមំ**

**ព្រះសម្មាសម្ពុទ្ធ** ជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណា ព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួង ដើម្បីប្រយោជន៍ដល់សត្វទាំងអស់ ហើយទ្រង់បានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ,

**ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក ។

**ជយន្តោ ពោធិយា មូលេ  សក្យានំ នន្ទិវឌ្ឍនោ**
**ឯវំ ត្វំ វិជយោ ហោហិ  ជយស្សុ ជយមង្គលេ**
**អបរាជិតបល្លង្កេ  សីសេ បឋវិបោក្ខរេ**
**អភិសេកេ សព្វពុទ្ធានំ  អគ្គប្បត្តោ បមោទតិ**

**ព្រះសម្មាសម្ពុទ្ធ** ទ្រង់ញ៉ាំងសេចក្តីត្រេកអរនៃសាក្យៈទាំងឡាយឱ្យចម្រើន ព្រះអង្គឈ្នះមារ ហើយបានដល់ នូវភាពជាបុគ្គលប្រសើរ

បំផុត ទ្រង់រីករាយ(ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង) លើអបរាជិតបល្ល័ង្ក ជាជយមង្គល ទៀបគល់ពោធិព្រឹក្ស ត្រង់ផ្ចិតផែនដី ដូចជាស្លឹកឈូក ជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ(យ៉ាងណាមិញ) សូមឱ្យអ្នកជាបុគ្គលមានជំនះឈ្នះ(អស់សត្រូវ) យ៉ាងនោះឯង ។

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**
**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ**

(ពេលណាដែលសត្វទាំងឡាយប្រព្រឹត្តល្អ ដោយកាយ វាចា ចិត្ត ពេលនោះ) ឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**
**បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា**

(ក្នុងថ្ងៃនោះ) **កាយកម្ម** ក៏ឈ្មោះថានាំឱ្យមានសេចក្ដីចម្រើន, **វចីកម្ម** ក៏ឈ្មោះថានាំឱ្យមានសេចក្ដីចម្រើន, **មនោកម្ម** ក៏ឈ្មោះថានាំឱ្យមានសេចក្ដីចម្រើន, សេចក្ដីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្ដីចម្រើន,

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ**

បុគ្គលដែលបានធ្វើនូវ កាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើន( យ៉ាងនេះ )ហើយ ក៏រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

**សោ អត្ថលទ្ធោ សុខិតោ វិរូឡ្ហោ ពុទ្ធសាសនេ**
**អរោគោ សុខិតោ ហោហិ សហ សព្វេហិ ញាតិភិ**

អ្នក( **ជាបុរស** )នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា !

**សា អត្ថលទ្ធា សុខិតា វិរូឡ្ហា ពុទ្ធសាសនេ**
**អរោគា សុខិតា ហោហិ សហ សព្វេហិ ញាតិភិ**

អ្នក( **ជាស្ត្រី** )នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា !

**តេ អត្ថលទ្ធា សុខិតា វិរូឡ្ហា ពុទ្ធសាសនេ**
**អរោគា សុខិតា ហោថ សហ សព្វេហិ ញាតិភិ**

អ្នកទាំងឡាយ( ទាំងបុរស-ទាំងស្ត្រី )នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា !

# អាដានាដិយបរិត្តគាថា

**សក្កត្វា ពុទ្ធរតនំ ឱសថំ ឧត្តមំ វរំ**
**ហិតំ ទេវមនុស្សានំ ពុទ្ធតេជេន សោត្ថិនា**
**នស្សន្តុបទ្ទវា សព្វេ ទុក្ខា វូបសមេន្តុ តេ**

សូមឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យសេចក្តីទុក្ខទាំងឡាយរបស់អ្នក ស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះពុទ្ធជាម្ចាស់ ព្រោះធ្វើគោរពនូវព្រះពុទ្ធរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ,

**សក្កត្វា ធម្មរតនំ ឱសថំ ឧត្តមំ វរំ**
**បរិឡាហូបសមនំ ធម្មតេជេន សោត្ថិនា**
**នស្សន្តុបទ្ទវា សព្វេ ភយា វូបសមេន្តុ តេ**

សូមឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យភ័យទាំងឡាយរបស់អ្នក ស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះធម៌ ព្រោះធ្វើគោរពនូវព្រះធម្មរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាគ្រឿងរម្ងាប់នូវសេចក្តីក្រវល់ក្រវាយ,

**សក្កត្វា សង្ឃរតនំ ឱសថំ ឧត្តមំ វរំ**
**អាហុនេយ្យំ បាហុនេយ្យំ សង្ឃតេជេន សោត្ថិនា**
**នស្សន្តុបទ្ទវា សព្វេ រោគា វូបសមេន្តុ តេ**

សូមឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យរោគទាំងឡាយរបស់អ្នក ស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះសង្ឃ ព្រោះធ្វើគោរពនូវព្រះសង្ឃរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាវត្ថុគួរគេនាំមកបូជា ជាវត្ថុគួរគេទទួលរាក់ទាក់ ។

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងដ៏ប្រសើរ របស់ខ្ញុំ,

**ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក!

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះធម៌ ជាទីពឹងដ៏ប្រសើរ របស់ខ្ញុំ,

**ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក!

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**

ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះសង្ឃ ជាទីពឹងដ៏ប្រសើរ របស់ខ្ញុំ,

**ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ**

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក!

**យំកិញ្ចិ រតនំ លោកេ    វិជ្ជតិ វិវិធំ បុថុ**
**រតនំ ពុទ្ធសមំ នត្ថិ    តស្មា សោត្ថិ ភវន្តុ តេ**

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះពុទ្ធរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក!

**យំកិញ្ចិ រតនំ លោកេ    វិជ្ជតិ វិវិធំ បុថុ**
**រតនំ ធម្មសមំ នត្ថិ    តស្មា សោត្ថិ ភវន្តុ តេ**

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះធម្មរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក!

**យំកិញ្ចិ រតនំ លោកេ    វិជ្ជតិ វិវិធំ បុថុ**
**រតនំ សង្ឃសមំ នត្ថិ    តស្មា សោត្ថិ ភវន្តុ តេ**

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះសង្ឃរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក!

# មង្គលចក្កវាឡ

**សិរីធិតិមតិតេជោជយសិទ្ធិមហិទ្ធិមហាគុណា**
**បរិមិតបុញ្ញាធិការស្ស សព្វន្តរាយនិវារណ**
**សមត្ថស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**ទ្វត្តឹសមហាបុរិសលក្ខណានុភាវេន**

ដោយអានុភាពនៃមហាបុរិសលក្ខណៈ**៣២**ប្រការ នៃព្រះដ៏មានព្រះភាគ ជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ, ទ្រង់មានបុញ្ញាធិការនឹងកំណត់មិនបាន ដោយឫទ្ធិដ៏ធំ និង គុណដ៏ធំ ដ៏សម្រេចដោយសិរី, ដោយបញ្ញាជាគ្រឿងតម្កល់មាំ ដោយបញ្ញាជាគ្រឿងដឹង ដោយតេជះ ដោយជ័យជំនះ ព្រះអង្គអាចក្នុងកិរិយាឃាត់បង់នូវអន្តរាយគ្រប់យ៉ាង ។

**អសីត្យានុព្យញ្ជនានុភាវេន** ដោយអានុភាព នៃអនុព្យញ្ជនៈ៨០,

**អដ្ឋុត្តរសតមង្គលានុភាវេន**ដោយអានុភាពនៃមង្គល១០៨

**ឆព្វណ្ណរំស្យានុភាវេន** ដោយអានុភាពនៃរស្មីមានពណ៌៦,

**កេតុមាលានុភាវេន** ដោយអានុភាពនៃព្រះកេតុមាលា,

**ទសបារមិតានុភាវេន** ដោយអានុភាពនៃបារមី១០,

**ទសឧបបារមិតានុភាវេន** ដោយអានុភាពនៃឧបបារមី១០,

**ទសបរមត្ថបារមិតានុភាវេន** ដោយអានុភាព នៃបរមត្ថបារមី១០,

**សីលសមាធិបញ្ញានុភាវេន** ដោយអានុភាពនៃ សីល សមាធិ និង បញ្ញា នៃព្រះអង្គ,

**ពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធ,

**ធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌,

**សង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃ,

**តេជានុភាវេន** ដោយអានុភាពនៃតេជះ,

**ឥទ្ធានុភាវេន** ដោយអានុភាពនៃឫទ្ធិ,

**ពលានុភាវេន** ដោយអានុភាពនៃកម្លាំង,

**ញេយ្យធម្មានុភាវេន** ដោយអានុភាពនៃញេយ្យធម៌,

**ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន** ដោយអានុភាព នៃព្រះធម្មក្ខន្ធ **៨.៤000** (៨ម៉ឺន ៤ពាន់),

**នវលោកុត្តរធម្មានុភាវេន** ដោយអានុភាពនៃលោកុត្តរធម៌៩,

**អដ្ឋង្គិកមគ្គានុភាវេន** ដោយអានុភាពនៃព្រះអរិយមគ្គ មានអង្គ៨,

**អដ្ឋសមាបត្យានុភាវេន** ដោយអានុភាពនៃសមាបត្តិ៨,

**ឆឡភិញ្ញានុភាវេន** ដោយអានុភាពនៃអភិញ្ញា៦,

**ចតុសច្ចញ្ញាណានុភាវេន** ដោយអានុភាពនៃសច្ចញ្ញាណ៤,

**ទសពលញ្ញាណានុភាវេន**ដោយអានុភាពនៃពលញ្ញាណ១០,

**សព្វញ្ញុតញ្ញាណានុភាវេន**ដោយអានុភាពនៃសព្វញ្ញុតញ្ញាណ

**មេត្តាករុណាមុទិតាឧបេក្ខានុភាវេន** ដោយអានុភាពនៃមេត្តា ករុណា មុទិតា ឧបេក្ខា,

**សព្វបរិត្តានុភាវេន** ដោយអានុភាពនៃព្រះបរិត្តទាំងពួង,

**រតនត្តយសរណានុភាវេន** ដោយអានុភាពនៃកិរិយារឭកដល់ព្រះរតនត្រ័យ,

**តុយ្ហំ សព្វរោគសោកុបទ្ទវទុក្ខទោមនស្សុបាយាសា វិនស្សន្តុ** រោគ សោក ឧបទ្រព ទុក្ខ ទោមនស្ស និង ឧបាយាសៈ ទាំងពួងរបស់អ្នក ចូរវិនាសបាត់ទៅ,

**សព្វអន្តរាយាបិ វិនស្សន្តុ** សេចក្តីអន្តរាយទាំងពួង (របស់អ្នក) ចូរវិនាសបាត់ទៅ!

**សព្វសង្កប្បា តុយ្ហំ សមិជ្ឈន្តុ** សេចក្តីត្រិះរិះគ្រប់យ៉ាងរបស់អ្នក ចូរសម្រេចដោយល្អ,

**ទីឃាយុតា តុយ្ហំ ហោតុ** ភាវៈជាអ្នកមានអាយុវែង ចូរមានដល់អ្នក,

**សតវស្សជីវេន សមង្គិកោ ហោតុ សព្វទា** សូមឱ្យអ្នកជាបុគ្គល មានសេចក្តីសមប្រកប ដោយកិរិយារស់នៅអស់រយនៃឆ្នាំ សព្វៗកាល,

**អាកាសបព្វតវនភូមិគង្គាមហាសមុទ្ទា អារក្ខកា ទេវតា** ទេវតាទាំងឡាយ ជាអ្នករក្សាដោយយកចិត្តទុកដាក់ ដែលឋិតនៅក្នុងអាកាស បព៌ត វនស្ថាន ភូមិស្ថាន និង ទន្លេ និង មហាសមុទ្រ,

**សទា ត្វម្ពេ អនុរក្ខន្តុ** ចូរបីបាច់រក្សានូវអ្នកទាំងឡាយ សព្វៗ កាល,

**ភវតុ សព្វមង្គលំ** មង្គលទាំងពួង ចូរមាន(ដល់អ្នក)!

**រក្ខន្តុសព្វទេវតា**សូមទេវតាទាំងអស់បីបាច់រក្សា(នូវអ្នក)!

**សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ!

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាលសព្វវេលា!

**ភវតុ សព្វមង្គលំ** មង្គលទាំងពួង ចូរមាន(ដល់អ្នក)!

**រក្ខន្តុសព្វទេវតា**សូមទេវតាទាំងអស់បីបាច់រក្សា(នូវអ្នក)!

**សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង!

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាលសព្វវេលា!

**ភវតុ សព្វមង្គលំ** មង្គលទាំងពួង ចូរមាន(ដល់អ្នក)!

**រក្ខន្តុសព្វទេវតា**សូមទេវតាទាំងអស់បីបាច់រក្សា(នូវអ្នក)!

**សព្វសង្ឃានុភាវេន**ដោយអានុភាពនៃព្រះសង្ឃទាំងពួង!

**សទា សោត្ថី ភវន្តុ តេ** សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាលសព្វវេលា!

**នក្ខត្តយក្ខភូតានំ ប្បាបគ្គហនិវារណា**

កិរិយាពាំងនូវបាបគ្រោះទាំងឡាយ (ដែលកើតអំពីសំណាក់)
នៃ នក្ខត្តឫក្ស និង យក្ខ និង ភូតបិសាចទាំងឡាយ,

**បរិត្តស្សានុភាវេន ហន្ត្វា តេសំ ឧបទ្ទវេ**

ដោយអានុភាពនៃព្រះបរិត្ត សូមកម្ចាត់បង់នូវឧបទ្រពទាំងឡាយ
(ដែលកើតអំពីសំណាក់) នៃ នក្ខត្តឫក្ស និងយក្ខ និង ភូតបិសាច
ទាំងឡាយនោះ ។ល។

*(សូធ្យ* **១** *ចប់ ក៏បាន,* **៣** *ចប់ក៏បាន)*

**(ចប់ សត្តបរិត្ត)**



# ទ្វាទសបរិត្ត

ក្នុង**ទ្វាទសបរិត្ត**នេះ មានបំពេញធម៌ថែមច្រើនជាង**សត្តបរិត្ត** ដែលដូចគ្នានឹងសត្តបរិត្តក៏មាន ដែលផ្សេងចេញអំពីសត្តបរិត្តក៏មាន នឹងស្រង់យកតែត្រង់កន្លែងដែលផ្សេងអំពីសត្តបរិត្ត មករៀបរៀងក្នុងទីនេះ មានចុះលេខរៀងតាំងអំពី ១ ដល់ ៨ ជាគ្រឿងសម្គាល់, ត្រង់ដែលដូចគ្នានឹងសត្តបរិត្តនោះ ចំហគ្មានលេខរៀងក្នុងទីនេះទេ, ចូរបើកមើលក្នុងសត្តបរិត្ត ដែលមានហើយក្នុងខាងដើម ។

របៀប **ទ្វាទសបរិត្ត** នោះ លោករៀបរៀងដូច្នេះ ៖

| | | |
|---|---|---|
| | អញ្ជើញពពួកទេវតា ត្រង់ **សមន្តា... ភណន្តុ** | មានហើយ |
| ១ | សមន្តា... សគ្គមោក្ខទំ | គ្មាន |
| | សគ្គេ... អយម្ភទន្តា | មានហើយ |
| | នមោ តស្ស... សរណំ គច្ឆាមិ | មានហើយ |
| | សម្ពុទ្ធេ... អសេសតោ | មានហើយ |
| | មង្គលសុត្តារម្ភោ និង មង្គលសូត្រ | មានហើយ |
| ២ | រតនសុត្តារម្ភោ | មានប្លែកបន្តិច |
| | រតនសូត្រ | មានហើយ |
| |ករណីយមេត្តសុត្តារម្ភោ និង ករណីយមេត្តសូត្រ | មានហើយ |
| | ខន្ធបរិត្តារម្ភោ និង ខន្ធបរិត្ត | មានហើយ |
| ៣ | ឆទ្ទន្តបរិត្ត | គ្មាន |

| | | |
|---|---|---|
| | មោរបរិត្តារម្ភោ និង មោរបរិត្ត | មានហើយ |
| ៤ | វដ្ដកបរិត្តារម្ភោ និង វដ្ដកបរិត្ត | គ្មាន |
| | ធជគ្គសុត្តារម្ភោ និង ធជគ្គសូត្រ | មានហើយ |
| | អាដានាដិយបរិត្តារម្ភោ | មានហើយ |
| ៥ | អាដានាដិយបរិត្ត | មានប្លែកគ្នាបន្តិច |
| | អង្គុលិមាលបរិត្តារម្ភោ និង អង្គុលិមាលបរិត្ត | មានហើយ |
| ៦ | ពោជ្ឈង្គបរិត្តារម្ភោ | គ្មាន |
| | ពោជ្ឈង្គបរិត្ត | មានហើយ |
| ៧ | អភយបរិត្តារម្ភោ | គ្មាន |
| | អភយបរិត្ត គឺ យន្ទុន្និមិត្តំ...ទុក្ខប្បត្តា | មានហើយ |
| | សព្វេ ពុទ្ធា... សព្វសោ | មានហើយ |
| ៨ | ជយបរិត្តារម្ភោ | គ្មាន |
| | ជយបរិត្ត គឺ មហាការុណិកោ... សុនក្ខត្តំ | មានហើយ |
| | សោ អត្ថលទ្ធោ | មានហើយ |
| | មង្គលចក្កវាឡ | មានហើយ |
| | ភវតុ សព្វមង្គលំ និង នក្ខត្តយក្ខភូតានំ | មានហើយ |

ទ្វាទសបរិត្ត ដែលមិនមានក្នុងសត្តបរិត្ត និង ដែលប្លែកចេញអំពីសត្តបរិត្តនោះ ដូចបានស្រង់យកមកតម្កល់ទុកក្នុងខាងមុខ តាមចំនួនលេខ តាំងពីលេខ ១ ដល់ លេខ ៨ ដូចតទៅនេះ ៖

# អញ្ជើញពួកទេវតា

## ១- <u>សមន្តា ... សគ្គមោក្ខទំ</u>

**សមន្តា ចក្កវាឡេសុ   អត្រាគច្ឆន្តុ ទេវតា**
**សទ្ធម្មំ មុនិរាជស្ស   សុណន្តុ សគ្គមោក្ខទំ**

ទេវតាទាំងឡាយ ក្នុងចក្កវាឡទាំងឡាយដោយជុំវិញ ចូរមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្ម ជាធម៌អាចឱ្យនូវសួគ៌ និង ព្រះនិព្វាន (របស់ព្រះអនាវរណញ្ញាណ) ជាស្តេចនៃអ្នកប្រាជ្ញ ។

## ២- <u>រតនសុត្តារម្ភោ</u>

**បណិធានតោ បដ្ឋាយ តថាគតស្ស ទស បារមិយោ ទស ឧបបារមិយោ ទស បរមត្ថបារមិយោ សមត្តឹស បារមិយោ បញ្ច មហាបរិច្ចាគេ តិស្សោ ចរិយា បច្ឆិមភវេ គព្ភាវក្កន្តឹ ជាតឹ អភិនិក្ខមនំ បធានចរិយំ ពោធិបល្លង្កេ មារវិជយំ សព្វញ្ញុតញ្ញាណប្បដិវេធំ ធម្មចក្កប្បវត្តនំ នវលោកុត្តរធម្មេតិ សព្វេបិមេ ពុទ្ធគុណេ អាវជ្ជិត្វា វេសាលិយា តីសុ បាការន្តរេសុ តិយាមរត្តឹ បរិត្តំ ករោន្តោ អាយស្មា អានន្ទត្ថេរោ វិយ ការុញ្ញចិត្តំ ឧបដ្ឋបេត្វា ។**

*យើងទាំងឡាយតាំងចិត្ត ប្រកបដោយសេចក្តីករុណា (ចំពោះសត្វទាំងឡាយ) ដូចជាព្រះអានន្ទត្ថេរដ៏មានអាយុ ដែលលោកពិចារណានូវព្រះពុទ្ធគុណទាំងឡាយនេះគ្រប់ទាំងអស់ របស់ព្រះតថាគត ចាប់ដើមអំពីសេចក្តីផ្តើមតាំងប្រាថ្នាជាព្រះពុទ្ធភូមិមក ព្រះអង្គញុំាងបារមី ៣០ គត់ គឺបារមី១០ ឧបបារមី១០ បរមត្ថបារមី១០ ឱ្យបរិបូណ៌ និងមហាបរិច្ចាគ៥ ចរិយា៣ កិរិយាយាងចុះកាន់គភ៌នៃព្រះមាតាក្នុងបច្ឆិមភព កិរិយាប្រសូត កិរិយាយាងចេញសាងអភិនេស្រ្កម កិរិយាបំពេញនូវទុក្ករកិរិយា កិរិយាផ្ចាញ់មារ កិរិយាត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ លើពោធិបល្ល័ង្ក កិរិយាសម្តែងនូវធម្មចក្កប្បវត្តនសូត្រ លោកុត្តរធម៌៩ ហើយ (ព្រះអានន្ទត្ថេរ) លោកសូធ្យនូវព្រះបរិត្ត អស់រាត្រីមានយាម ៣ ក្នុងខាងក្នុងកំពែងទាំងឡាយ ៣ ជាន់នៃក្រុងវេសាលី ។*

តពីត្រង់នេះទៅ

(**កោដិសតសហស្សេសុ ... បរិត្តន្តម្ភណាម ហេ**)

# ៣- ឆទ្ទន្តបរិត្ត

**វធិស្សមេនន្តិ បរាមសន្តោ កាសាវមទ្ទក្ខ ធជំ ឥសីនំ** (ព្រះពោធិសត្វ) ជាស្តេចនៃដំរី កាលចាប់ព្រានព្រៃដោយបំណងថា អញនឹងសម្លាប់វាដូច្នេះ លុះទ្រង់បានឃើញនូវសំពត់កាសាវៈ ដ៏ជាទង់ជ័យនៃឥសី គឺលោកអ្នកស្វែងរកនូវសីលាទិគុណទាំងឡាយ,

**ទុក្ខេន ផុដ្ឋស្សុទបាទិ សញ្ញា**
**អរហទ្ធជោ សព្ភិ អវជ្ឈរូបោ**

សញ្ញាក៏កើតឡើងដល់ព្រះពោធិសត្វ ដែលសេចក្តីទុក្ខពាល់ត្រូវហើយថា ទង់ជ័យរបស់ព្រះអរហន្ត មានសភាព គឺសប្បុរសទាំងឡាយមិនគួរនឹងសម្លាប់,

**សល្លេន វិទ្ធោ ព្យថិតោបិ សន្តោ**
**កាសាវវត្ថម្ហិ មនំ ន ទុស្សយិ**

ព្រះពោធិសត្វ ដែលព្រួញមុតហើយ គួរនឹងក្រេវក្រោធញាប់ញ័រ តែព្រះអង្គស្ងប់រម្ងាប់បាន មិនធ្វើចិត្តប្រទូស្តទៅរកកាសាវព័ស្រ្តឡើយ,

**សចេ ឥមំ នាគវរេន សច្ចំ**
**មា មំ វនេ ពាលមិគា អគញ្ឆុន្តិ**

បើពាក្យដែលស្តេចដំរីដ៏ប្រសើរពោលហើយនេះ ជាពាក្យពិតមែន សូមពួកម្រឹគកាចក្នុងព្រៃ កុំមកជួបប្រទះនឹងខ្ញុំឡើយ ។

## ៤- វដ្ដកបរិត្តារម្ភោ

**បូរេន្តម្ភោធិសម្ភារេ និព្វត្តំ វដ្ដជាតិយំ**
**យស្ស តេជេន ទាវគ្គិ មហាសត្តំ វិវជ្ជយិ**

ភ្លើងព្រៃ ចៀសវាងហើយនូវព្រះមហាសត្ត ដែលកំពុងបំពេញនូវពោធិសម្ភារ ព្រះអង្គកើតក្នុងកំណើតនៃសត្វក្រួច[១] ដោយតេជះនៃព្រះបរិត្តឯណា,

**ថេរស្ស សារីបុត្តស្ស លោកនាថេន ភាសិតំ**
**កប្បដ្ឋាយិ មហាតេជំ បរិត្តន្តម្ភណាម ហេ**

យើងទាំងឡាយសូធ្យឥឡូវនេះនូវព្រះបរិត្តនោះដែលមានតេជះច្រើន អាចតាំងនៅអស់កប្ប ដែលព្រះលោកនាថ ទ្រង់ត្រាស់សម្ដែងហើយដល់ព្រះសារីបុត្តត្ថេរ ។

## វដ្ដកបរិត្ត

**អត្ថិ លោកេ សីលគុណោ សច្ចំ សោចេយ្យនុទ្ទយា**

គុណនៃសីល ពាក្យពិត សេចក្ដីស្អាតកាយ និង សេចក្ដីករុណា (ទាំងនេះ) សឹងមានក្នុងលោក,

**តេន សច្ចេន កាហាមិ សច្ចកិរិយមនុត្តរំ**

[១] វដ្ដ ឬ វដ្ដក ប្រែថា ក្រួចក៏បាន ប្រែថាចាបក៏បាន ។

ដោយពាក្យសច្ចៈនេះ ខ្ញុំនឹងធ្វើនូវសច្ចកិរិយា ដែលឥតមានអ្វីស្មើឡើយ,

**អាវជ្ជិត្វា ធម្មពលំ សរិត្វា បុព្វកេ ជិនេ**

**សច្ចពលមវស្សាយ សច្ចកិរិយមកាសហំ**

ខ្ញុំពិចារណានូវកម្លាំងនៃធម៌ ហើយរឭកនូវព្រះសម្ពុទ្ធទ្រង់ឈ្នះមារទាំងឡាយក្នុងកាលមុន អាស្រ័យនូវកម្លាំងនៃសច្ចៈ ហើយបានធ្វើនូវសច្ចកិរិយា,

**សន្តិ បក្ខា អបត្តនា សន្តិ បាទា អវញ្ចនា**

**មាតា បិតា ច និក្ខន្តា ជាតវេទ បដិក្កម**

ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនបាន ជើងទាំងឡាយរបស់ខ្ញុំមាន តែដើរមិនបាន, មាតា និង បិតារបស់ខ្ញុំ ចេញទៅរកអាហារហើយ, ម្នាលភ្លើង ចូរអ្នកចៀសចេញទៅ,

**សហ សច្ចេ កតេ មយ្ហំ មហាបជ្ជលិតោ សិខី**

**វជ្ជេសិ សោឡស ករីសានិ ឧទកំ បត្វា យថា សិខី**

នាកាលសច្ចៈដែលខ្ញុំបានធ្វើហើយ អណ្ដាតភ្លើងដ៏រុងរឿងធំចៀសចេញទៅហើយអស់ចម្ងាយទី ១៦ ករីស ព្រមជាមួយនឹងពាក្យសច្ចៈរបស់ខ្ញុំ ដូចជាអណ្ដាតភ្លើងធ្លាក់ចុះដល់ទឹក,

**សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ**

អ្វីមួយស្មើដោយសច្ចៈរបស់ខ្ញុំមិនមានឡើយ នេះជាសច្ចបារមីរបស់ខ្ញុំ !

# ៥- អាដានាដិយបរិត្ត

❁ (វិបស្សិស្ស នមត្ថុ ......... មហន្តំ វីតសារទំ : មានហើយ )

**នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះ គឺៈ)

**តណ្ហង្ករោ មហាវីរោ** ព្រះតណ្ហង្ករព្រះអង្គមានព្យាយាមធំ,

**មេធង្ករោ មហាយសោ** ព្រះមេធង្ករព្រះអង្គមានយសធំ,

**សរណង្ករោ លោកហិតោ** ព្រះសរណង្ករ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក,

**ទីបង្ករោ ជុតិន្ធរោ** ព្រះទីបង្ករព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង,

**កោណ្ឌញ្ញោ ជនប្បមោក្ខោ** ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន,

**មង្គលោ បុរិសាសភោ** ព្រះមង្គលព្រះអង្គជាបុរសដ៏ប្រសើរ,

**សុមនោ សុមនោ ធីរោ** ព្រះសុមន ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ,

**រេវតោ រតិវឌ្ឍនោ** ព្រះរេវត ព្រះអង្គញុំាងសេចក្ដីត្រេកអរឱ្យចម្រើន,

**សោភិតោ គុណសម្បន្នោ** ព្រះសោភិត ព្រះអង្គបរិបូណ៌ដោយព្រះគុណ,

**អនោមទស្សី ជនុត្តមោ** ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន,

**បទុមោ លោកបជ្ជោតោ** ព្រះបទុម ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង,

**នារទោ វរសារថី** ព្រះនារទ ព្រះអង្គដូចជាសារថីដ៏ប្រសើរ,

**បទុមុត្តរោ សត្តសារោ** ព្រះបទុមុត្តរ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ,

**សុមេធោ អប្បដិបុគ្គលោ** ព្រះសុមេធ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន,

**សុជាតោ សព្វលោកគ្គោ** ព្រះសុជាត ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង,

**បិយទស្សី នរាសភោ** ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន,

**អត្ថទស្សី ការុណិកោ** ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា,

**ធម្មទស្សីតមោនុទោ**ព្រះធម្មទស្សីព្រះអង្គបន្ទោបង់នូវងងឹត,

**សិទ្ធត្ថោ អសមោ លោកេ** ព្រះសិទ្ធត្ថ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក,

**តិស្សោ ច វទតំ វរោ** ព្រះតិស្ស ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ,

**ផុស្សោ ច វរទោ ពុទ្ធោ** ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ,

**វិបស្សី ច អនូបមោ** ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ,

**សិខី សព្វហិតោ សត្ថា** ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង,

**វេស្សភូ សុខទាយកោ** ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ,

**កកុសន្ធោ សត្ថវាហោ** ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស,

**កោនាគមនោ រណញ្ជហោ** ព្រះកោនាគមនៈ ព្រះអង្គបំបាក់បង់នូវសត្រូវ គឺកិលេស,

**កស្សបោ សិរិសម្បន្នោ** ព្រះកស្សប ព្រះអង្គបរិបូណ៌ដោយសិរី,

**គោតមោ សក្យបុង្គវោ** ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។

---

☸ (**ឯតេ ចញ្ញេ ច សម្ពុទ្ធា** ......... **និព្វុតោ ច តុវំ ភវ** មានហើយ)

---

**តេសំ សច្ចេន សីលេន ខន្តិមេត្តាពលេន ច**

ដោយសច្ចៈផង ដោយសីលផង ដោយកម្លាំងនៃខន្តី និង មេត្តាផង នៃព្រះសម្ពុទ្ធទាំងឡាយនោះ,

**តេបិ តុម្ហេ អនុរក្ខន្តុ អរោគ្យេន សុខេន ច**

ព្រះសម្ពុទ្ធទាំងឡាយនោះ សូមបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង,

**បុរត្ថិមស្មឹ ទិសាភាគេ សន្តិ ភូតា មហិទ្ធិកា**

ភូតគឺគន្ធព្វទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងកើត,

**តេបិ តុម្ហេ អនុរក្ខន្តុ អរោគ្យេន សុខេន ច**

គន្ធព្វទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង,

**ទក្ខិណស្មឹ ទិសាភាគេ សន្តិ ទេវា មហិទ្ធិកា**

ទេវតាទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងត្បូង,

**តេបិ តុម្ហេ អនុរក្ខន្តុ អរោគ្យេន សុខេន ច**

ទេវតាទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង,

**បច្ឆិមស្មឹ ទិសាភាគេ សន្តិ នាគា មហិទ្ធិកា**

នាគទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងលិច,

**តេបិ តុម្ហេ អនុរក្ខន្តុ អរោគ្យេន សុខេន ច**

នាគទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង,

**ឧត្តរស្មឹ ទិសាភាគេ សន្តិ យក្ខា មហិទ្ធិកា**

យក្ខទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងជើង,

**តេបិ តុម្ហេ អនុរក្ខន្តុ អរោគ្យេន សុខេន ច**

យក្ខទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង,

**បុរិមទិសំ ធតរដ្ឋោ** ស្ដេចធតរដ្ឋ(នៅរក្សា)ខាងបុរិមទិស,

**ទក្ខិណេន វិរុឡ្ហកោ** ស្ដេចវិរុឡ្ហក(នៅរក្សា)ខាងទក្ខិណទិស,

**បច្ឆិមេន វិរូបក្ខោ** ស្ដេចវិរូបក្ខ(នៅរក្សា)ខាងបច្ឆិមទិស,

**កុវេរោ ឧត្តរំ ទិសំ** ស្ដេចកុវេរ(នៅរក្សា)ខាងឧត្តរទិស,

**ចត្តារោ តេ មហារាជា លោកបាលា យសស្សិនោ**

មហារាជទាំងឡាយ ៤ នោះ សុទ្ធតែមានយសជាអ្នករក្សានូវលោក,

**តេបិ តុម្ហេ អនុរក្ខន្តុ អរោគ្យេន សុខេន ច**

មហារាជទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង,

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

ទេវតា និង នាគទាំងឡាយ មានឫទ្ធិច្រើន ដែលឋិតនៅក្នុងអាកាសក្ដី ឋិតនៅលើផែនដីក្ដី,

**តេបិ តុម្ហេ អនុរក្ខន្តុ អរោគេន សុខេន ច**

ទេវតា និង នាគទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយ ដោយមិនឱ្យមានរោគផង ឱ្យមានសេចក្ដីសុខផង!

❁ (**នត្ថិ មេ សរណំ...** មានហើយ)

❁ (**យំកិញ្ចិ រតនំ លោកេ...** មានហើយ)

❁ (**សក្កត្វា ពុទ្ធរតនំ...** មានហើយ)

❁ (**សព្វីតិយោ វិវជ្ជន្តុ...** មានហើយ)

## ៦- ពោជ្ឈង្គបរិត្តារម្ភោ

**សំសារេ សំសរន្តានំ សព្វទុក្ខវិនាសនេ**
**សត្ត ធម្មេ ច ពោជ្ឈង្គេ មារសេនប្បមទ្ទិនោ**
**ពុជ្ឈិត្វា យេបិមេ សត្តា តិភវា មុត្តកុត្តមា**

សត្វទាំងឡាយឯណា ជាបុគ្គលឧត្តម រួចផុតចាកត្រៃភព ព្រោះត្រាស់ដឹងនូវធម៌ទាំងឡាយ៧ ឈ្មោះពោជ្ឈង្គៈ គឺធម៌ជាអង្គនៃកិរិយាត្រាស់ដឹង ជាធម៌អាចញ៉ាំងទុក្ខទាំងពួងរបស់សត្វទាំងឡាយ ដែលកំពុងអន្ទោលទៅក្នុងសំសារវដ្ដ ឱ្យវិនាស, ជាធម៌អាចញ៉ាំញីនូវមារ និងសេនានៃមារ,

**អជាត អជរាព្យាធិ អមតំ និព្ភយំ គតា**

(សត្វទាំងឡាយនោះ)ឈ្មោះថាដល់នូវព្រះនិព្វាន ជាគុណជាត ឥតមានកំណើត ឥតមានជរា និង ព្យាធិ ឥតមានសេចក្ដីស្លាប់ ឥតមានភ័យ,

**ឯវមាទិគុណូបេតំ អនេកគុណសង្គហំ**

**ឱសថញ្ច[១] ឥមំ មន្តំ ពោជ្ឈង្គន្តម្ភណាម ហេ**

យើងទាំងឡាយ សូត្រឥឡូវនេះ នូវមន្តនេះ ឈ្មោះថា**ពោជ្ឈង្គបរិត្ត** ទុកដូចជាថ្នាំរម្ងាប់រោគដ៏ប្រាកដ សង្គ្រោះយកនូវគុណជាអនេកប្រកបដោយគុណ មានយ៉ាងនេះជាដើម ។

## ៧- អភយបរិត្តារម្ភោ

**បុញ្ញលាភំ មហាតេជំ វណ្ណកិត្តិមហាយសំ**

**សព្វសត្តហិតំ ជាតំ តំ សុណន្តុ អសេសតោ**

សាធុជនទាំងឡាយ ចូរស្ដាប់ឱ្យសព្វគ្រប់នូវព្រះបរិត្តនោះ ជាគុណជាតអាចនឹងឱ្យបាននូវបុណ្យ មានតេជៈច្រើន មានគុណ និង កិត្តិយសដ៏ធំ ជាប្រយោជន៍ដល់សព្វសត្វ,

---

[១] ជា **ឱសធញ្ច** ក៏មាន, បាលីទាំងពីរយ៉ាងនេះ ប្រែថា ថ្នាំរម្ងាប់រោគ ដូចគ្នា ។

**អត្ថបរហិតំ ជាតំ        បរិត្តន្តម្ភណាម ហេ**

យើងទាំងឡាយ សូធ្យឥឡូវនេះ នូវព្រះបរិត្តនោះ ដែលជាប្រយោជន៍ដល់ខ្លួន និង អ្នកដទៃ ។

## ៨- ជយបរិត្តារម្ភោ

**ជយំ ទេវមនុស្សានំ        ជយោ ហោតុ បរាជិតោ**

ជ័យជំនះ ចូរកើតមានដល់ទេវតា និង មនុស្សទាំងឡាយ អ្នកដែលចាញ់ហើយ ចូរត្រឡប់ទៅជាមានជ័យជំនះវិញ,

**មារសេនា អភិក្កន្តា        សមន្តា ទ្វាទសយោជនា**
**ខន្តិមេត្តា អធិដ្ឋានា        ចតុំសេត្វាន ចក្ខុមា**
**ភវាភវេ សំសរន្តោ        ទិព្វចក្ខុំ ចសោធយិ**

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់មានបញ្ញាចក្ខុ កាលដែលអន្ទោលទៅក្នុងភពតូចភពធំ ទ្រង់កំចាត់បង់នូវមារ និង សេនានៃមារ ឱ្យកន្លងផុតទៅអំពីទី ១២ យោជន៍ដោយជុំវិញ ដោយខន្តិបារមី មេត្តាបារមី និង អធិដ្ឋានបារមី ហើយទ្រង់ជម្រះនូវទិព្វចក្ខុ,

**បរិយាបន្នាធិសោត្ថានំ    ហិតាយ ច សុខាយ ច**
**ពុទ្ធភាវំ ចសោធេត្វា        បរិត្តន្តម្ភណាម ហេ**

ព្រះសាស្ដាទ្រង់បំពេញនូវពុទ្ធកិច្ច ដើម្បីប្រយោជន៍ផង ដើម្បីសេចក្ដីសុខផង ដល់សត្វទាំងឡាយ ដែលបាននូវសេចក្ដីចម្រើនដ៏ក្រៃលែង យើងទាំងឡាយ សូមឲ្យឥឡូវនេះ នូវព្រះបរិត្តនោះ ។

(**ទ្វាទសបរិត្ត** *ចប់*)

# ធម្មចក្កប្បវត្តនសុត្តារម្ភោ

**អនុត្តរំ អភិសម្ពោធឹ　សម្ពុជ្ឈិត្វា តថាគតោ**
**បឋមំ យំ អទេសេសិ　ធម្មចក្កំ អនុត្តរំ**
**សម្មទេវ បវត្តេន្តោ　លោកេ អប្បដិវត្តិយំ**

**ព្រះតថាគត**ជាម្ចាស់ ទ្រង់បានត្រាស់ដឹងនូវ**ព្រះអនុត្តរាភិសម្ពោធិញ្ញាណ**ហើយ កាលព្រះអង្គនឹងញ៉ាំងធម៌ ដែលឥតមានអ្នកណា នឹងឱ្យប្រព្រឹត្តទៅបានក្នុងលោក ព្រះអង្គអាចឱ្យប្រព្រឹត្តទៅបានដោយប្រពៃពិត ទ្រង់បានសម្ដែងហើយនូវធម៌ណា ដែលហៅថា **ធម្មចក្ក**ដ៏ប្រសើរ ជាមុនដំបូងបំផុត,

**យត្ថាក្ខាតា ឧភោ អន្តា　បដិបត្តិ ច មជ្ឈិមា**
**ចតូស្វារិយសច្ចេសុ　វិសុទ្ធំ ញាណទស្សនំ**

**អន្តធម៌** គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ ២ ប្រការ និង ផ្លូវប្រតិបត្តិជាកណ្តាល, និង ប្រាជ្ញាដែលដឹងច្បាស់ ឃើញច្បាស់ ក្នុង**អរិយសច្ច**ទាំងឡាយ ៤ ជាប្រាជ្ញាដ៏បរិសុទ្ធ ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សម្តែងហើយក្នុង**ព្រះធម៌** ដែលហៅថា**ធម្មចក្ក**ឯណា,

**ទេសិតំ ធម្មរាជេន សម្មាសម្ពោធិកត្តនំ**
**នាមេន វិស្សុតំ សុត្តំ ធម្មចក្កប្បវត្តនំ**
**វេយ្យាករណបាឋេន សង្គីតន្តម្ភណាម សេ**

យើងទាំងឡាយ សូធ្យឥឡូវនេះ នូវព្រះធម្មចក្កនោះ ដែលព្រះសម្មាសម្ពុទ្ធជាធម្មរាជ ទ្រង់សម្តែងហើយ ប្រាកដដោយឈ្មោះថាធម្មចក្កប្បវត្តនសូត្រ ជា ព្រះសូត្រប្រកាសនូវសម្មាសម្ពោធិញ្ញាណ ដែលព្រះសង្គីតិកាចារ្យ បានប្រជុំគ្នាសង្គាយនា រៀបរៀង ដោយរបៀបជាវេយ្យាករណបាឋ គឺជាបាលីបទរាយ ឥតមានគាថាលាយផងឡើយ ។

# ធម្មចក្កប្បវត្តនសូត្រ

**ព្រះសម្មាសម្ពុទ្ធ** ទ្រង់ប្រោសប្រទានសម្តែង **ព្រះធម្មចក្កប្បវត្តនសូត្រ**
ជាព្រះបឋមធម្មទេសនា ប្រារព្ធដល់ **បញ្ចវគ្គិយភិក្ខុ**
(កោណ្ឌញ្ញៈ វប្បៈ ភទ្ទិយៈ មហានាម អស្សជិ) នៅ ឥសិបតនមិគទាយវ័ន
នាថ្ងៃពេញបូណ៌មី ខែអាសាធ ឆ្នាំរកា, ជាថ្ងៃកំណើតនៃព្រះអរិយសង្ឃ
**ព្រះកោណ្ឌញ្ញៈ** បានសម្រេចធម្មចក្ខុ
**និង** ជា ព្រះអរិយសង្ឃសាវ័ក ទី ១ ក្នុង **ព្រះពុទ្ធសាសនា**

៩៧ **ឯវម្មេ សុតំ** សូត្រនេះ (ឈ្មោះ **ធម្មចក្កប្បវត្តនសុត្ត**)[១] **ធម្មចក្កប្បវត្តនសូត្រ**)[១] គឺខ្ញុំ (ឈ្មោះ **អានន្ទ**) បានស្តាប់មកហើយយ៉ាងនេះថា :

**ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ** សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិ-
-បតនមិគទាយវ័ន ជិតក្រុងពារាណសី ។

**តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ** ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុ[២] ទាំងឡាយ ក្នុងទីនោះឯង (ឱ្យតាំងចិត្តស្តាប់នូវភាសិតនេះថា),

**ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា** ម្នាលភិក្ខុទាំងឡាយ **អន្តធម៌** គឺធម៌ជាផ្លូវប្រតិបត្តិអមខាង ដ៏លាមកអាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺថាមិនគួរប្រព្រឹត្តឡើយ ។

**កតមេ ទ្វេ**[១] អន្តធម៌ទាំងឡាយពីរយ៉ាងនោះ ដូចម្តេច ?

---

[១] ព្រះសូត្រនេះ ចម្លងពីសៀវភៅ "**សត្តបរិត្ត ទ្វាទសបរិត្ត**" ដែលប្រែ និងរៀបរៀង និងរៀបរៀង ដោយព្រះវិសុទ្ធិវង្ស **ហួត-តាត** បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ លើកទី១៨ ព.ស. ២៥១៥ (1971) ។

[២] ភិក្ខុមានគ្នាចំនួន៥រូប គឺ ភិក្ខុ **កោណ្ឌញ្ញៈ វប្បៈ ភទ្ទិយៈ មហានាម** និង **អស្សជិ** ។

១).- **យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ** ធម៌ណា ដែលប្រកបខ្លួនឱ្យជាប់ជំពាក់ដោយកាម ក្នុងកាមទាំងឡាយ,

**ហីនោ** ជាធម៌ថោកទាប,

**គម្មោ** ជាធម៌របស់អ្នកស្រុក,

**បោថុជ្ជនិកោ** ជាធម៌របស់បុថុជ្ជន,

**អនរិយោ** មិនមែនជារបស់អរិយបុគ្គលទេ,

**អនត្ថសញ្ហិតោ** មិនប្រកបដោយប្រយោជន៍ឡើយ ។

២).- **យោ ចាយំ អត្តកិលមថានុយោគោ** ធម៌ណា ដែលប្រកបសេចក្ដីលំបាកដល់ខ្លួន,

**ទុក្ខោ** ជាហេតុនាំឱ្យលំបាកកាយទទេ ៗ,

**អនរិយោ** មិនមែនជារបស់អរិយបុគ្គលទេ,

**អនត្ថសញ្ហិតោ** មិនប្រកបដោយប្រយោជន៍ឡើយ ។

☸ **ឯតេ តេ ខោ**[(២)] **ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧប-សមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិជាកណ្ដាល មិនលាយច្រឡំ ដោយ **អន្តធម៌**

---

(១) ក្នុងបិដកច្បាប់សីហឡៈ មិនមានបាលីថា **ភគវា ទ្វេ** នេះទេ ។

(២) ក្នុងបិដកច្បាប់សីហឡៈ មិនមានស័ព្ទថា **ខោ** នេះទេ ។

ទាំងឡាយពីរយ៉ាងនោះឯង ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ (ភ្នែក គឺប្រាជ្ញា) ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ។

**កតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ គឺសេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខនោះ តើដូចម្តេច ?

☸ **អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ** អដ្ឋង្គិកមគ្គ គឺធម៌ដូចជាផ្លូវមានអង្គ ៨ ដ៏ប្រសើរ នេះឯង (ហៅថា សេចក្តីប្រតិបត្តិជាកណ្តាល),

**សេយ្យថីទំ** អដ្ឋង្គិកមគ្គនោះ ដូចម្តេចខ្លះ ?

- **សម្មាទិដ្ឋិ** ប្រាជ្ញាយល់ឃើញត្រូវ,
- **សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវ,
- **សម្មាវាចា** សម្តីត្រូវ,
- **សម្មាកម្មន្តោ** ការងារត្រូវ,

- ➢ **សម្មាអាជីវោ** កិរិយាចិញ្ចឹមជីវិតត្រូវ,
- ➢ **សម្មាវាយាមោ** ព្យាយាមត្រូវ,
- ➢ **សម្មាសតិ** សេចក្ដីរឭកត្រូវ,
- ➢ **សម្មាសមាធិ** កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ,

**អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គនេះឯង ដែលហៅថា សេចក្ដីប្រតិបត្តិជាកណ្ដាល ដែល**តថាគត** បានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងចំពោះ ដើម្បីសេចក្ដីដឹងដោយប្រពៃ ដើម្បីសេចក្ដីរំលត់ទុក្ខ ។

☸ **ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា (ព្យាធិបិ [៩] ទុក្ខោ) មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខ-ទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា** ម្នាលភិក្ខុទាំងឡាយ ជាតិ គឺកិរិយា

[៩] ☞ **ព្យាធិបិ ទុក្ខោ** ក្នុងភាណវារបាលីគ្មានទេ ។ ក្នុងវិនយបិដក មហាវគ្គ (បិ. ភាគ ៦, ទំព័រ ៣០) ជា ☞ **ព្យាធីបិ ទុក្ខា** ដូច្នេះវិញ ។

កកើតនៃខន្ធ ជាហេតុនាំមកនូវទុក្ខ, ជរា គឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ (ព្យាធិ គឺជំងឺដំកាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ) មរណៈ គឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ, សេចក្ដីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និង សេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ, កិរិយាប្រកបដោយសត្វ និង សង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ, កិរិយាព្រាត់ប្រាសចាកសត្វ និង សង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ, កាលបើចង់បាននូវវត្ថុណាមួយហើយមិនបាននូវវត្ថុនោះ កិរិយាមិនបាននោះ ក៏ជាហេតុនាំមកនូវទុក្ខ, ឧបាទាន--ក្ខន្ធទាំងឡាយ ៥ ដែលតថាគតសម្ដែងហើយដោយបំព្រួញ ក៏ជាហេតុនាំមកនូវទុក្ខ, **កងទុក្ខ** មាន **ជាតិ** ជាដើមនេះ ឈ្មោះថា **ទុក្ខអរិយសច្ច** ។

☸ **ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា** ម្នាលភិក្ខុទាំងឡាយ តណ្ហាឯណា ដែលរមែងតាក់តែងនូវភពថ្មី ប្រកបដោយតម្រេកដោយអំណាចនៃសេចក្ដីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះ ៗ ជាប្រក្រតី តណ្ហានោះដូចម្ដេចខ្លះ ? (តណ្ហានោះ) គឺ កាមតណ្ហា១

ភវតណ្ហា១ វិភវតណ្ហា១, តណ្ហាទាំង ៣ នេះ ឈ្មោះថា **ទុក្ខសមុទយ--អរិយសច្ច** ។

☸ **ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ** ម្នាលភិក្ខុទាំងឡាយ កិរិយារំលត់បង់នូវតណ្ហានោះ ដោយអរិយមគ្គ មិនឱ្យមានសេសសល់ កិរិយាលះបង់នូវតណ្ហានោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចផុតចាកតណ្ហានោះ កិរិយាមិនមានអាល័យក្នុងតណ្ហានោះឯណា កិរិយារំលត់បង់នូវតណ្ហា ដោយអរិយមគ្គ មិនឱ្យមានសេសសល់ ជាដើមនេះឯង ឈ្មោះថា**ទុក្ខនិរោធអរិយសច្ច** ។

☸ **ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មា--វាយាមោ សម្មាសតិ សម្មាសមាធិ** ម្នាលភិក្ខុទាំងឡាយ **អដ្ឋង្គិកមគ្គ** ដ៏ប្រសើរនេះឯង ដូចម្ដេចខ្លះ ? គឺ ប្រាជ្ញាយល់ឃើញត្រូវ សេចក្ដីត្រិះរិះត្រូវ សម្ដីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្ដីរឭកត្រូវ កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ, **អដ្ឋង្គិកមគ្គ** ដ៏ប្រសើរនេះឯង ឈ្មោះថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** ។

(កាលត្រាស់ទេសនានូវលក្ខណៈនៃអរិយសច្ច ៤ ប្រការដូច្នេះហើយ ទើបត្រាស់ទេសនានូវញាណទាំង ៣ ប្រការ គឺ **សច្ចញ្ញាណ កិច្ចញ្ញាណ កតញ្ញាណ** ឱ្យទូទៅ ក្នុងអរិយសច្ច ៤ តទៅទៀតថា ) :

## **បរិវដ្ដ** ទី១ : ☞ (សច្ចញ្ញាណក្នុងទុក្ខអរិយសច្ចៈ)

☸ **ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុ[១] កើតឡើងហើយ, ញាណ[២] កើតឡើងហើយ, បញ្ញា[៣] កើតឡើងហើយ, វិជ្ជា[៤] កើតឡើងហើយ, ពន្លឺភ្លឺស្វាង[៥] កើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម[៦] **តថាគត** មិនធ្លាប់បានឮ បានស្ដាប់ថា នេះជា **ទុក្ខអរិយសច្ច** ដូច្នេះឡើយ ។

## ☞ (កិច្ចញ្ញាណក្នុងទុក្ខអរិយសច្ចៈ)

---

(១) បញ្ញាដែលឃើញច្បាស់ ។

(២) បញ្ញាដែលដឹងច្បាស់ ។

(៣) បញ្ញាដែលដឹង មិនខុស មិនភ្លាត់ ។

(៤) បញ្ញាដែលកាត់បង់នូវសេចក្ដីសង្ស័យ ។

(៥) បញ្ញាដែលកំចាត់សេចក្ដីងងឹត គឺសេចក្ដីល្ងង់ ។

(៦) ពាក្យថា "ពីដើម" នេះ ចំពោះយកកាលក្នុងបច្ឆិមភពនេះឯង ចាប់ដើមតាំងអំពីប្រសូត្រមក ។

☸ **តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮបានស្តាប់ថា **ទុក្ខអរិយសច្ច** នេះឯង គួរតែកំណត់ដឹងដោយបញ្ញា ដូច្នេះឡើយ ។

☞ (កតញ្ញាណក្នុងទុក្ខអរិយសច្ចៈ)

☸ **តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើម **តថាគត** មិនធ្លាប់បានឮបានស្តាប់ថា **ទុក្ខអរិយ-សច្ច** នេះឯង **តថាគត** កំណត់ដឹងបានហើយ ដូច្នេះឡើយ ។

## **បរិវដ្ដ** ទី២ : ☞ (សច្ចញ្ញាណក្នុងទុក្ខសមុទយអរិយសច្ចៈ)

☸ **ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់ **តថាគត** ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា នេះជា **ទុក្ខសមុទយអរិយសច្ច** ដូច្នេះឡើយ ។

☞ (កិច្ចញ្ញាណក្នុងទុក្ខសមុទយអរិយសច្ចៈ)

☸ **តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា **ទុក្ខសមុទយអរិយសច្ច** នេះឯង **គួរតែលះបង់** ដូច្នេះឡើយ ។

☞ (កតញ្ញាណក្នុងទុក្ខសមុទយអរិយសច្ចៈ)

☸ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហីនន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខសមុទយអរិយសច្ចនេះឯង តថាគត លះបង់បានហើយ ដូច្នេះឡើយ។

## បរិវដ្ត ទី៣ : ☞ (សច្ចញ្ញាណក្នុងទុក្ខនិរោធអរិយសច្ចៈ)

☸ ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អន--នុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា នេះជា ទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ ។

☞ (កិច្ចញ្ញាណក្នុងទុក្ខនិរោធអរិយសច្ចៈ)

☸ **តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម **តថាគត** មិនធ្លាប់បានឮ បានស្តាប់ថា **ទុក្ខនិរោធអរិយសច្ច** នេះឯង គួរតែធ្វើឱ្យជាក់ច្បាស់ ដូច្នេះឡើយ ។

☞ (កតញ្ញាណក្នុងទុក្ខនិរោធអរិយសច្ចៈ)

☸ **តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា **ទុក្ខនិរោធអរិយសច្ច** នេះឯង **តថាគត** ធ្វើឱ្យជាក់ច្បាស់បានហើយ ដូច្នេះឡើយ ។

## <u>**បរិច្ឆេទ ទី៤**</u> : ☞ (<u>សច្ចញ្ញាណក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ</u>)

☸ **ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា នេះជា <u>**ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច**</u> ដូច្នេះឡើយ ។

☞ (<u>កិច្ចញ្ញាណក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ</u>)

☸ **តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា <u>**ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច**</u>នេះឯង <u>គួរតែចម្រើនឱ្យកើតឡើង</u> ដូច្នេះឡើយ ។

☞ (កតញ្ញាណក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ)

☸ **តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ** ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ, បញ្ញាកើតឡើងហើយ, វិជ្ជាកើតឡើងហើយ, ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮបានស្តាប់ថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** នេះឯង **តថាគតចម្រើនឱ្យកើតបានហើយ** ដូច្នេះឡើយ ។

✻

**យាវកីវញ្ច មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ** ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មាន**បរិវដ្ដៈ**[(១)] ៣ មាន**អាការៈ**[(២)] ១២ យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុង

---

(១) **បរិវដ្ដៈ៣** គឺ **សច្ចញ្ញាណ, កិច្ចញ្ញាណ, កតញ្ញាណ** ។

(២) **បរិវដ្ដៈ ៣** នោះឯង វិលទៅដូចជាចក្រ ក្នុងសច្ចៈទាំង៤ គឺក្នុងទុក្ខសច្ច ៣, ទុក្ខសមុទយសច្ច ៣, ទុក្ខនិរោធសច្ច ៣, ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ៣, ផ្សំគ្នាជា ១២ ហៅថា **អាការៈ ១២** ។

អរិយសច្ចទាំងឡាយ ៤ នៅមិនទាន់បរិសុទ្ធល្អ មានដល់តថាគត អស់កាលត្រឹមណា,

**នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ** ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្ដេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្ដីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និង មនុស្សដ៏សេស អស់កាលត្រឹមណោះនៅឡើយទេ,

**យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុវិសុទ្ធំ អហោសិ** ម្នាលភិក្ខុទាំងឡាយ ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មាន **បរិវដ្ដៈ**៣ មាន **អាការៈ**១២ យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុងអរិយសច្ចទាំងឡាយ៤ នេះបរិសុទ្ធល្អ មានដល់**តថាគត** ក្នុងកាលឯណា,

**អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ**

**សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ** ម្នាលភិក្ខុទាំងឡាយ តថាគតប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និង មនុស្សដ៏សេស ក្នុងកាលណោះឯង ។

**ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ** ក៏បញ្ញាដែលដឹងច្បាស់ឃើញច្បាស់ កើតឡើងហើយដល់តថាគត ដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះ ក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី គឺការត្រឡប់កើតទៀត ក៏មិនមានឡើយ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគ បានត្រាស់ទេសនា **ព្រះធម្មចក្កប្បវត្តនសូត្រ**នេះ (ចប់ហើយ),

**អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ** បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់**ព្រះដ៏មានព្រះភាគ** ដោយក្រៃពេក ។

☸ **ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ** នាកាលវេយ្យាករណ៍ គឺព្រះសូត្រដែលឥតមានគាថានេះ ដែលព្រះដ៏មានព្រះភាគ កំពុងត្រាស់

ទេសនា **ធម្មចក្ខុ** គឺ **សោតាបត្តិមគ្គ** ដ៏ប្រាសចាកធូលី គឺរាគៈ ប្រាសចាកមន្ទិលគឺអកុសល កើតឡើងហើយដល់**ព្រះកោណ្ឌញ្ញៈ** ដ៏មានអាយុថា ៖

> **យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតនោះទាំងអស់ មានកិរិយារលត់ទៅជាធម្មតា !**

**បវត្តិតេ ច ភគវតា ធម្មចក្កេ** ក៏នាកាលព្រះធម្មចក្កប្បវត្តនសូត្រ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទេសនាចប់ហើយ,

៥០ **ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ** ភុម្មទេវតាទាំងឡាយ ក៏ញុំាំងសំឡេងឱ្យលាន់ឮឡើងដូច្នេះថា ចក្រ គឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តី ក្នុងលោក សម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

៥០ **ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយ ក្នុងជាន់ចាតុម្មហារាជ បានឮ

សំឡេងនៃភុម្មទេវតាទាំងឡាយហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា) ។

**៥០ ចាតុម្មហារាជិកានំ ទេវានំ សទ្ទំ សុត្វា តាវត្តឹសា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយ ក្នុងជាន់តាវត្តិង្ស បានឮសំឡេងនៃទេវតាក្នុងជាន់ចាតុម្មហារាជហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា) ។

**៥០ តាវត្តឹសានំ ទេវានំ សទ្ទំ សុត្វា យាមា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយ ក្នុងជាន់យាមា បានឮសំឡេងនៃទេវតាក្នុងជាន់តាវត្តិង្សហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា) ។

**៥០ យាមានំ ទេវានំ សទ្ទំ សុត្វា តុសិតា ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់តុសិត បានឮសំឡេងនៃទេវតាក្នុងជាន់យាមាហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា) ។

**៥០ តុសិតានំ ទេវានំ សទ្ទំ សុត្វា និម្មានរតី ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយក្នុងជាន់និម្មានរតី បានឮសំឡេងនៃទេវតាក្នុងជាន់តុសិតហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា) ។

**៥០ និម្មានរតីនំ ទេវានំ សទ្ទំ សុត្វា បរនិម្មិតវសវត្តី ទេវា សទ្ទមនុស្សាវេសុំ** ទេវតាទាំងឡាយ ក្នុងជាន់បរនិម្មិតវសវត្តី បានឮសំឡេងនៃទេវតាក្នុងជាន់និម្មានរតីហើយ ក៏ញុំាំងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា) ។

**៥០ បរនិម្មិតវសវត្តីនំ ទេវានំ សទ្ទំ សុត្វា ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ** ទេវតាទាំងឡាយក្នុងពួកព្រហ្ម បានឮសំឡេងនៃទេវតាក្នុងជាន់បរនិម្មិតវសវត្តីហើយ ក៏ញុំាំងសំឡេងឱ្យលាន់ឮឡើង ដូច្នេះថា ចក្រគឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តីក្នុងលោក សម្តែងពុំបានឡើយ មានតែ **ព្រះដ៏មានព្រះភាគ** ព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតន--មិគទាយវ័ន ជិតក្រុងពារាណសី ។

**៥០ ឥតិហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ** សំឡេងសាធុការលាន់ឮឡើងទៅដរាបដល់ព្រហ្មលោក ក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយអាការលាន់ឮ ត ៗ គ្នាដូច្នេះ,

៤០ **អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ** ទាំងម៉ឺនលោកធាតុនេះ ក៏កក្រើកញាប់ញ័រ ទាំងខាងលើ ទាំងខាងក្រោម និង ញាប់ញ័រក្នុងទិសទាំងពួង ។

**អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ បាតុរហោសិ អតិក្កម្ម ទេវានំ ទេវានុភាវន្តិ** ទាំងរស្មីដ៏រុងរឿងក្រៃពេក នឹងប្រមាណមិនបាន កន្លងលើសទេវានុភាពនៃទេវតាទាំងឡាយ ក៏កើតឡើងប្រាកដក្នុងលោក ។

៤០ **អថខោ ភគវា ឧទានំ ឧទានេសិ អញ្ញាសិ វតភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោតិ** លំដាប់នោះព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បន្លឺនូវឧទានវាចា ថា : *ឱ! កោណ្ឌញ្ញៈ បានចេះដឹងហើយហ្ន៎! ឱ កោណ្ឌញ្ញៈ បានចេះដឹងហើយហ្ន៎!*

**ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ អហោសីតិ** ព្រោះហេតុនោះ ពាក្យថា **អញ្ញាកោណ្ឌញ្ញៈ** នេះឯងបានមកជាឈ្មោះនៃ**ព្រះកោណ្ឌញ្ញៈ**ដ៏មានអាយុ ។

( <u>**ព្រះធម្មចក្កប្បវត្តនសុត្រ**</u> ចប់ )



# អនត្តលក្ខណសុត្តារម្ភោ

**យន្តំ សត្ថេហិ ទុក្ខេន ញេយ្យំ អនត្តលក្ខណំ**

អនត្តលក្ខណៈ ឯណា ដែលសត្វទាំងឡាយគប្បីដឹងដោយកម្រ,

**អត្តវាទាត្តសញ្ញានំ សម្មទេវ វមោចនំ**

**សម្ពុទ្ធោ តំ បកាសេសិ ទិដ្ឋសច្ចាន យោគនំ**

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រកាសហើយដោយប្រពៃ នូវ **អនត្តលក្ខណៈ**នោះ ជាធម៌ដោះនូវ**អត្តវាទុបាទាន** គឺកិរិយាប្រកាន់

មាំដោយសំដីថា ខ្លួនៗ និង **អត្តសញ្ញា** គឺកិរិយាសំគាល់ថា ខ្លួនៗ ដល់ព្រះយោគី គឺភិក្ខុមានគ្នា ៥ នាក់ ជាពួកដែលមានសច្ចៈឃើញហើយ,

**ឧត្តរឹ បដិវេធាយ ភាវេតុំ ញាណមុត្តមំ**

ដើម្បីចម្រើននូវញាណដ៏ឧត្តម ដើម្បីនឹងឱ្យត្រាស់ដឹងនូវធម៌ ដ៏ខ្ពស់ក្រៃលែង,

**យន្តេសំ ទិដ្ឋធម្មានំ ញាណេនុបបរិក្ខតំ**

**សព្វាសវេហិ ចិត្តានិ វិមុច្ចិំសុ អសេសតោ**

ចិត្តរបស់បញ្ចវគ្គិយភិក្ខុទាំងឡាយនោះ ជាអ្នកមានធម៌ឃើញហើយ ដែលពិចារណាដោយញាណ ក៏រួចផុតហើយចាកអាសវៈទាំងពួង ឥតមានសេសសល់ ដោយព្រះសូត្រឯណា,

**តថា ញាណានុសារេន សាសនំ ភាតុមិច្ឆតំ**

**សាធូនំ អត្ថសិទ្ធត្ថំ តំ សុត្តន្តម្ភណាម សេ**

យើងទាំងឡាយ សូត្រឥឡូវនេះ នូវព្រះសូត្រនោះ ដើម្បីឱ្យសម្រេចប្រយោជន៍ដល់អស់សាធុជន ដែលត្រូវការចង់ធ្វើតាមនូវពាក្យប្រដៅ(**នៃព្រះពុទ្ធ**) តាមទំនងនៃញាណយ៉ាងនោះ ។

# អនត្តលក្ខណសូត្រ

**៩** **ឯវម្មេ សុតំ** (សូត្រនេះឈ្មោះ **អនត្តលក្ខណសូត្រ**) គឺខ្ញុំ (ឈ្មោះ **អានន្ទ**) បានស្តាប់មកហើយ យ៉ាងនេះថា :

**ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ** សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងទីព្រៃឥសិ-បតនមិគទាយវ័ន ជិតក្រុងពារាណសី ។

**តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ** ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុទាំងឡាយក្នុងទីនោះ (ឱ្យនាំគ្នាតាំងចិត្តស្តាប់នូវភាសិតនេះ) ថា :

☸ - **រូបំ ភិក្ខវេ អនត្តា** ម្នាលភិក្ខុទាំងឡាយ រូប គឺរាងកាយ ជាអនត្តា មិនមែនជារបស់ខ្លួនឡើយ,

**រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើរូបនេះ ជារបស់ខ្លួនពិតមែន,

**ន យិទំ រូបំ អាពាធាយ សំវត្តេយ្យ** រូបនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជំងឺដំកាត់ឡើយ,

**លព្ភេថ ច រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងរូបថា សូមឱ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឱ្យរូបរបស់អញយ៉ាងនេះឡើយ

**យស្មា ច ខោ ភិក្ខវេ រូបំ អនត្តា តស្មា រូបំ អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តាពិតមែន ព្រោះហេតុនោះ បានជារូបចេះតែប្រព្រឹត្តទៅដើម្បីអាពាធ,

**ន ច លព្ភតិ រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ**ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងរូបថាសូមឱ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឱ្យរូបរបស់អញយ៉ាងនេះឡើយ ។

❋

☸ - **វេទនា អនត្តា** វេទនា មិនមែនជារបស់ខ្លួនឡើយ,

**វេទនា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវេទនានេះ ជារបស់ខ្លួនពិតមែន,

**ន យិទំ វេទនា អាពាធាយ សំវត្តេយ្យ** វេទនានេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ,

**លព្ភេថ ច វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវេទនាថា សូមឱ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឱ្យវេទនារបស់អញយ៉ាងនេះឡើយ,

**យស្មា ច ខោ ភិក្ខវេ វេទនា អនត្តា តស្មា វេទនា អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ វេទនាជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវេទនា ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ,

**ន ច លព្ភតិ វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងវេទនាថា សូមឱ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឱ្យវេទនារបស់អញយ៉ាងនេះឡើយ ។

☸ - **សញ្ញា អនត្តា** សញ្ញា មិនមែនជារបស់ខ្លួនឡើយ,

**សញ្ញា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសញ្ញានេះ ជារបស់ខ្លួនពិតមែន,

**ន យិទំ សញ្ញា អាពាធាយ សំវត្តេយ្យ** សញ្ញានេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ,

**លព្ភេថ ច សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងសញ្ញាថា សូមឱ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឱ្យសញ្ញារបស់អញយ៉ាងនេះឡើយ,

**យស្មា ច ខោ ភិក្ខវេ សញ្ញា អនត្តា តស្មា សញ្ញា អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ **សញ្ញាជាអនត្តា**ពិតមែន ព្រោះហេតុនោះ បានជា**សញ្ញា**ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ,

**ន ច លព្ភតិ សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ**ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងសញ្ញាថា សូមឱ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឱ្យសញ្ញារបស់អញយ៉ាងនេះឡើយ ។

☸ - **សង្ខារា អនត្តា** សង្ខារទាំងឡាយ មិនមែនជារបស់ខ្លួនឡើយ,

**សង្ខារា ច ហិទំ ភិក្ខវេ អត្តា អភវិស្សំសុ** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសង្ខារទាំងឡាយនេះ ជារបស់ខ្លួនពិតមែន,

**ន យិទំ សង្ខារា អាពាធាយ សំវត្តេយ្យុំ** សង្ខារទាំងឡាយនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ,

**លព្ភេថ ច សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន(នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សូមឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ,

**យស្មា ច ខោ ភិក្ខវេ សង្ខារា អនត្តា តស្មា សង្ខារា អាពាធាយ សំវត្តន្តិ** ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាសង្ខារទាំងឡាយ ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ,

**ន ច លព្ភតិ សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ** ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សូមឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ ។

☸ - **វិញ្ញាណំ អនត្តា** វិញ្ញាណ មិនមែនជារបស់ខ្លួនឡើយ,

**វិញ្ញាណញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស** ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវិញ្ញាណនេះ ជារបស់ខ្លួនពិតមែន,

**ន យិទំ វិញ្ញាណំ អាពាធាយ សំវត្តេយ្យ** វិញ្ញាណនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ,

**លព្ភេថ ច វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវិញ្ញាណថា សូមឱ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឱ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ,

**យស្មា ច ខោ ភិក្ខវេ វិញ្ញាណំ អនត្តា តស្មា វិញ្ញាណំ អាពាធាយ សំវត្តតិ** ម្នាលភិក្ខុទាំងឡាយ វិញ្ញាណជាអនត្តាពិតមែន ព្រោះហេតុនោះ បានជា វិញ្ញាណ ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ,

**ន ច លព្ភតិ វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ** ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងវិញ្ញាណថា សូមឱ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឱ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ ។

**តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច រូបទៀង ឬ មិនទៀង ?

**អនិច្ចំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន រូបមិនទៀងទេ ។

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬ ជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណា

ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា **នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ** ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តំ កឹ មញ្ញថ ភិក្ខវេ វេទនា និច្ចា វា អនិច្ចា វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច វេទនាទៀង ឬ មិនទៀង ?

**អនិច្ចា ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន វេទនាមិនទៀងទេ !

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណា ដែលមិនទៀង របស់នោះជាទុក្ខ ឬ ជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ !

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា **នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ** ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តំ កឹ មញ្ញថ ភិក្ខវេ សញ្ញា និច្ចា វា អនិច្ចា វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច សញ្ញាទៀង ឬ មិនទៀង ?

**អនិច្ចា ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាមិនទៀងទេ !

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ !

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា **នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ** ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តំ កឹ មញ្ញថ ភិក្ខវេ សង្ខារា និច្ចា វា អនិច្ចា វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច សង្ខារទាំងឡាយ ទៀង ឬ មិនទៀង ?

**អនិច្ចា ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន សង្ខារទាំងឡាយ មិនទៀងទេ !

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** របស់ឯណា ដែល មិនទៀង របស់នោះជាទុក្ខ ឬ ជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ !

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹង យល់ឃើញនូវរបស់នោះថា **នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ** ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹង យល់ឃើញយ៉ាងនុ៎ះទេ !

**តំ កឹ មញ្ញថ ភិក្ខវេ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច វិញ្ញាណទៀង ឬ មិនទៀង ?

**អនិច្ចំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណមិនទៀងទេ !

**យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ** ក៏របស់ឯណាដែល មិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

**ទុក្ខំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ !

**យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ** ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹង យល់ឃើញនូវរបស់នោះថា **នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ** ?

**នោ ហេតំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹង យល់ឃើញយ៉ាងនុ៎ះទេ !

**តស្មាតិហ ភិក្ខវេ យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យន្ទូរេ សន្តិកេ វា សព្វំ រូបំ** ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូបឯណាមួយដែលជាអតីតក្ដី ជាអនាគតក្ដី ជាបច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្តមក្ដី រូបឯណា ដែលមានក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី រូបទាំងអស់នោះ ក៏គ្រាន់តែជារូប (ប៉ុណ្ណោះឯង) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេ តំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះដូច្នេះថា **នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ** ។

**យា កាចិ វេទនា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា វេទនា** វេទនាឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វេទនាឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វេទនាទាំងអស់នោះ ក៏គ្រាន់តែជាវេទនា (ប៉ុណ្ណោះឯង) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះដូច្នេះថា **នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ** ។

**យា កាចិ សញ្ញា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា សញ្ញា** សញ្ញាឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី

ថោកទាបក្តី ឧត្តមក្តី សញ្ញាឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សញ្ញាទាំងអស់នោះ ក៏គ្រាន់តែជាសញ្ញា (ប៉ុណ្ណោះឯង) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញ នូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះដូច្នេះថា **<u>នុ៎ះមិនមែនរបស់អញ</u> <u>នុ៎ះមិនមែនជាអញ</u> <u>នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ</u>** ។

**យេ កេចិ សង្ខារា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា សព្វេ សង្ខារា** សង្ខារទាំងឡាយឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សង្ខារទាំងឡាយឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សង្ខារទាំងឡាយទាំងអស់នោះ ក៏គ្រាន់តែជាសង្ខារ (ប៉ុណ្ណោះឯង) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះដូច្នេះថា **<u>នុ៎ះមិនមែនរបស់អញ</u> <u>នុ៎ះមិនមែនជាអញ</u> <u>នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ</u>** ។

**យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យន្ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ** វិញ្ញាណឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ ក៏គ្រាន់តែជាវិញ្ញាណ (ប៉ុណ្ណោះឯង) ។

**នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

**ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ** ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កបានស្តាប់ហើយ យល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង,

**និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ** កាលបើនឿយណាយ (យ៉ាងនេះហើយ) ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ព្រោះកិរិយាប្រាសចាកតម្រេក,

**វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ** កាលដែលចិត្តផុតស្រឡះ (ចាកអាសវៈ) ហើយ ញាណ (របស់អរិយសាវ័កនោះ) ក៏កើតឡើងប្រាកដថា ចិត្ត (របស់អញ) ផុតស្រឡះ (ចាកអាសវៈ) ហើយ។

**ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ** (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ដូច្នេះថា ជាតិ (របស់អញ) អស់ហើយ **មគ្គព្រហ្មចរិយធម៌** អញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អញក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន (ដល់អញ) ឡើយ ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់សម្តែងនូវសូត្រនេះចប់ហើយ,

**អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ** បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតនៃព្រះដ៏មានព្រះភាគជាម្ចាស់ ។

**ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ បញ្ចវគ្គិយានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ** ក៏កាលដែល

ព្រះដ៏មានព្រះភាគជាម្ចាស់ កំពុងត្រាស់សម្តែងនូវវេយ្យាករណ៍នេះ ចិត្ត របស់ភិក្ខុទាំង ៥ រូប បានរួចស្រឡះហើយ ចាកអាសវៈទាំងឡាយ ព្រោះ មិនប្រកាន់មាំ (ថាអញ ថាយើង ទៀតឡើយ) ។ ./.

**(អនត្តលក្ខណសូត្រ ចប់)**








**ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអនត្តលក្ខណសូត្រ**

**ជាទុតិយធម្មទេសនា បន្ទាប់ពីបានសម្តែង ធម្មចក្កប្បវត្តនសូត្រ**


ធម្មរាជិកចេតិយ (DHAMMARAJIKA STUPA)
ស្ថានទីព្រះមានព្រះភាគទ្រង់ប្រកាសសម្តែងអនត្តលក្ខណសូត្រ


ឥសិបតនមិគទាយវ័ន_សារនាថ
ស្ថានទីសម្តែងធម្មចក្កប្បវត្តនសូត្រ
និង អនត្តលក្ខណសូត្រ
ធម្មយាត្រានៅពុទ្ធភូមិ
ព.ស. ២៥៥៣
(2010)

# អាទិត្តបរិយាយសុត្តារម្ភោ

**វេនេយ្យទមនោបាយេ សព្វសោ បារមឹ គតោ**
**អមោឃវចនោ ពុទ្ធោ អភិញ្ញាយានុសាសកោ**

**ព្រះសម្មាសម្ពុទ្ធ**ជាម្ចាស់ ទ្រង់បានសម្រេចនូវព្រះបារមី ដោយសព្វគ្រប់ហើយ ព្រះអង្គមានវាចាមិនឥតអំពើ ទ្រង់ប្រៀនប្រដៅក្នុងឧបាយទូន្មាននូវវេនេយ្យសត្វ ដើម្បីឱ្យបានត្រាស់ដឹង,

**ចិណ្ណានុរូបតោ ចាបិ ធម្មេន វិនយំ បជំ** ទ្រង់ណែនាំពន្យល់នូវពពួកសត្វ ដោយធម៌ តាមសមគួរដល់ឧបនិស្ស័យ ដែលសត្វសន្សំទុកមក,

**ចិណ្ណាគ្គិបារិចរិយានំ សម្ភោជ្ឈាហយោគិនំ**
**យមាទិត្តបរិយាយំ ទេសយន្តោ មនោរហំ**

ទ្រង់ត្រាស់សម្តែងនូវសូត្រឯណា ឈ្មោះថាអាទិត្តបរិយាយសូត្រ ជាគ្រឿងនាំចិត្តនៃពួកព្រះយោគី ជាអ្នកគួរនឹងត្រាស់ដឹង ដែលជាជដិលធ្លាប់សន្សំខាងកិច្ចបម្រើភ្លើង,

**តេ សោតារោ វិមោចេសិ អសេក្ខាយ វិមុត្តិយា**

ទ្រង់ញុំាងព្រះយោគីទាំងនោះដែលជាអ្នកស្តាប់ ឱ្យបានរួចផុតស្រឡះហើយ ចាកអាសវៈទាំងឡាយ ដោយអសេក្ខវិមុត្តិ,

**តថេវោបបរិក្ខាយ វិញ្ញូនំ សោតុមិច្ឆតំ**

**ទុក្ខតាលក្ខណោបាយំ តំ សុត្តន្តម្ភណាម សេ**

យើងទាំងឡាយសូធ្យឥឡូវនេះ នូវព្រះសូត្រនោះ ជាឧបាយ ជាគ្រឿងកំណត់នូវភាវៈនៃសេចក្ដីទុក្ខ ដើម្បីវិញ្ញូជនទាំងឡាយ ដែលត្រូវការចង់ស្ដាប់ ដោយកិរិយាពិចារណា យ៉ាងនេះឯង ។

# អាទិត្តបរិយាយសូត្រ

(ទ្រង់ត្រាស់សម្ដែងប្រារព្ធនឹងភិក្ខុ ១.០០០ អង្គ ជា
អតីតជដិលបងប្អូន៣នាក់ : **ឧរុវេលកស្សប, នទីកស្សប និង
គយាកស្សប** និង សាវ័ករបស់ខ្លួន នៅគយាសីស ជិតស្ទឹងគយា)
(**វិនយបិដក មហាវគ្គ បឋមភាគ** : បិដក ទី៦, ទំព័រ ១០៤)

៥១ **ឯវម្មេ សុតំ** (សូត្រនេះឈ្មោះ **អាទិត្តបរិយាយសូត្រ**) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្ដាប់មកហើយ យ៉ាងនេះថា :

**ឯកំ សមយំ ភគវា គយាយំ វិហរតិ គយាសីសេ សទ្ធឹ ភិក្ខុសហស្សេន** សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងគយាសីសប្រទេស ជិតស្ទឹងឈ្មោះគយា ជាមួយនឹងភិក្ខុ ១.០០០ អង្គ,

**តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ** ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងគយាសីសប្រទេសនោះ (ឱ្យនាំគ្នាតាំងចិត្តស្តាប់នូវភាសិតដូច្នេះថា) :

**សព្វំ ភិក្ខវេ អាទិត្តំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ,

**កិញ្ចិ ភិក្ខវេ សព្វំ អាទិត្តំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ គឺអ្វីខ្លះ ?

១).- **ចក្ខុំ ភិក្ខវេ អាទិត្តំ** ម្នាលភិក្ខុទាំងឡាយ ភ្នែកជារបស់ក្តៅ,

**រូបា អាទិត្តា** រូបទាំងឡាយ ជារបស់ក្តៅ,

**ចក្ខុវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងភ្នែក ជារបស់ក្តៅ,

**ចក្ខុសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងភ្នែក ជារបស់ក្តៅ,

**យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យឯណា,

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ,

**កេន អាទិត្តំ** ក្តៅដោយអ្វី?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ**

**ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើង គឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និង សេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

២).-**សោតំ អាទិត្តំ** ត្រចៀក ជារបស់ក្តៅ,

**សទ្ទា អាទិត្តា** សំឡេងទាំងឡាយ ជារបស់ក្តៅ,

**សោតវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងត្រចៀកជារបស់ក្តៅ,

**សោតសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងត្រចៀកជារបស់ក្តៅ,

**យម្បិទំ សោតសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះសោតសម្ផស្សជាបច្ច័យឯណា,

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ,

**កេន អាទិត្តំ** ក្តៅដោយអ្វី?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ**

**ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្ដៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្ដៅដោយសេចក្ដីកើត ដោយសេចក្ដីចាស់គ្រាំគ្រា និង សេចក្ដីស្លាប់ ក្ដៅដោយសេចក្ដីសោក ដោយសេចក្ដីខ្សឹកខ្សួល ដោយសេចក្ដីទុក្ខក្នុងកាយ ដោយសេចក្ដីទុក្ខក្នុងចិត្ត ដោយសេចក្ដីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

៣).- **ឃានំ អាទិត្តំ** ច្រមុះ ជារបស់ក្ដៅ,

**គន្ធា អាទិត្តា** ក្លិនទាំងឡាយ ជារបស់ក្ដៅ,

**ឃានវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងច្រមុះ ជារបស់ក្ដៅ,

**ឃានសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងច្រមុះជារបស់ក្ដៅ,

**យម្បិទំ ឃានសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្ដីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្ដី ជាទុក្ខក្ដី មិនមែនទុក្ខមិនមែនសុខក្ដី កើតឡើងព្រោះឃានៈសម្ផស្សជាបច្ច័យឯណា,

**តម្បិ អាទិត្តំ** សេចក្ដីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្ដៅ,

**កេន អាទិត្តំ** ក្ដៅដោយអ្វី?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ**

**ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និង សេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

៤).- **ជិវ្ហា អាទិត្តា** អណ្តាត ជារបស់ក្តៅ,

**រសា អាទិត្តា** រសទាំងឡាយ ជារបស់ក្តៅ,

**ជិវ្ហាវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងអណ្តាត ជារបស់ក្តៅ,

**ជិវ្ហាសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងអណ្តាតជារបស់ក្តៅ,

**យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យឯណា,

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ,

**កេន អាទិត្តំ** ក្តៅដោយអ្វី?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ**

**ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និង សេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

៥).- **កាយោ អាទិត្តោ** កាយជារបស់ក្តៅ,

**ផោដ្ឋព្វា អាទិត្តា** ផោដ្ឋព្វៈ គឺអារម្មណ៍ដែលប៉ះពាល់ត្រូវដោយកាយទាំងឡាយ ជារបស់ក្តៅ,

**កាយវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងកាយ ជារបស់ក្តៅ,

**កាយសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងកាយ ជារបស់ក្តៅ,

**យម្បិទំ កាយសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះកាយ-សម្ផស្សជាបច្ច័យឯណា,

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ,

**កេន អាទិត្តំ** ក្តៅដោយអ្វី?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ**

**ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និង សេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

៦).- **មនោ អាទិត្តោ** ចិត្តជារបស់ក្តៅ,

**ធម្មា អាទិត្តា** ធម៌ទាំងឡាយ គឺអារម្មណ៍ដែលកើតក្នុងចិត្តជារបស់ក្តៅ,

**មនោវិញ្ញាណំ អាទិត្តំ** វិញ្ញាណអាស្រ័យនឹងចិត្ត ជារបស់ក្តៅ,

**មនោសម្ផស្សោ អាទិត្តោ** សម្ផស្សអាស្រ័យនឹងចិត្ត ជារបស់ក្តៅ,

**យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះមនោ-សម្ផស្សជាបច្ច័យឯណា,

**តម្បិ អាទិត្តំ** សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ,

**កេន អាទិត្តំ** ក្តៅដោយអ្វី?

**អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ** តថាគតពោលថា ក្តៅដោយភ្លើង

គឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និង សេចក្តីស្លាប់ ក្តៅដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ ។

**ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ** ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កកាលបើបានស្តាប់ហើយយល់ឃើញយ៉ាងនេះ, ក៏នឿយណាយក្នុងភ្នែកផង, នឿយណាយក្នុងរូបទាំងឡាយផង, នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងភ្នែកផង, នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងភ្នែកផង ។

**យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងអារម្មណ៍នោះ,

**៩ សោតស្មឹបិ និព្វិន្ទតិ សទ្ទេសុបិ និព្វិន្ទតិ សោតវិញ្ញាណេបិ និព្វិន្ទតិ សោតសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងត្រចៀកផង, នឿយណាយក្នុងសំឡេងទាំងឡាយផង នឿយណាយក្នុងវិញ្ញាណ

អាស្រ័យនឹងត្រចៀកផង, នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងត្រចៀកផង ។

**យម្បិទំ សោតសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះសោតសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងអារម្មណ៍នោះ,

៥៧ **ឃានស្មឹបិ និព្វិន្ទតិ គន្ធេសុបិ និព្វិន្ទតិ ឃានវិញ្ញាណេបិ និព្វិន្ទតិ ឃានសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងច្រមុះផង, នឿយណាយក្នុងក្លិនទាំងឡាយផង, នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹង ច្រមុះផង, នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងច្រមុះផង ។

**យម្បិទំ ឃានសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះឃានសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងអារម្មណ៍នោះ,

៥៧ **ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ ជិវ្ហាវិញ្ញាណេបិ និព្វិន្ទតិ ជិវ្ហាសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងអណ្តាតផង,

នឿយណាយក្នុងរសទាំងឡាយផង, នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងអណ្ដាតផង, នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងអណ្ដាតផង ។

**យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្ដីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្ដី ជាទុក្ខក្ដី មិនមែនទុក្ខមិនមែនសុខក្ដី កើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្ដីដឹងអារម្មណ៍នោះ,

៩៧ **កាយស្មឹបិ និព្វិន្ទតិ ផោដ្ឋព្វេសុបិ និព្វិន្ទតិ កាយវិញ្ញាណេបិ និព្វិន្ទតិ កាយសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងកាយផង, នឿយណាយក្នុងផោដ្ឋព្វៈទាំងឡាយផង, នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងកាយផង, នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងកាយផង ។

**យម្បិទំ កាយសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្ដីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្ដី ជាទុក្ខក្ដី មិនមែនទុក្ខមិនមែនសុខក្ដី កើតឡើងព្រោះកាយសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្ដីដឹងអារម្មណ៍នោះ,

៩៧ **មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ និព្វិន្ទតិ** នឿយណាយក្នុងចិត្តផង, នឿយ

ណាយក្នុងធម៌ទាំងឡាយផង, នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងចិត្តផង, នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងចិត្តផង ។

**យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ** សេចក្តីដឹងច្បាស់នូវអារម្មណ៍គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងអារម្មណ៍នោះ,

**និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ** កាលបើនឿយណាយ (យ៉ាងនេះហើយ)ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ(ចាកអាសវៈ) ព្រោះកិរិយាប្រាសចាកតម្រេក,

**វិមុត្តស្មឹ វិមុត្តមីតិ ញាណំ ហោតិ** កាលដែលចិត្តផុតស្រឡះ (ចាកអាសវៈ)ហើយ, ញាណ(របស់អរិយសាវ័កនោះ)ក៏កើតឡើងប្រាកដថា ចិត្ត(របស់អញ)ផុតស្រឡះ(ចាកអាសវៈ)ហើយ,

**ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ** (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ដូច្នេះថា ជាតិ(របស់អញ)អស់ហើយ **មគ្គព្រហ្មចរិយធម៌**អញបាននៅរួចហើយ, កិច្ចដែលគួរធ្វើ អញក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន(ដល់អញ)ឡើយ ។

**ឥទមវោច ភគវា** ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់សម្តែងនូវព្រះសូត្រនេះហើយ,

**អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ** ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតនៃព្រះដ៏មានព្រះភាគជាម្ចាស់ ។

**ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ តស្ស ភិក្ខុសហស្សស្ស អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ** ក៏កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ កំពុងត្រាស់សំដែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ១.០០០ រូបនោះ បានរួចស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថាអញថាយើងទៀតឡើយ) ។

**អាទិត្តបរិយាយសុត្រ** ចប់



**ព្រះមានព្រះភាគ** ទ្រង់ប្រោសប្រទានសំដែងនូវធម្មទេសនា ស្តីអំពី **អាទិត្តបរិយាយសុត្រ** (រូបកាយជាវរបស់ក្តៅ)
ដល់ជដិលបងប្អូន ៣ នាក់ : ឧរុវេលកស្សបៈ នទីកស្សបៈ គយាកស្សបៈ និង ជដិលជាបរិវារទាំង ១.០០០ នាក់
នៅគយាសីសៈ តាមបណ្តោយស្ទឹងនេរញ្ជរា

# គិរិមានន្ទសូត្រ

៩០ ឯវម្មេ សុតំ (សូត្រនេះឈ្មោះ គិរិមានន្ទសូត្រ)[១] គឺខ្ញុំ (ឈ្មោះ អានន្ទ) បានស្តាប់មកហើយ យ៉ាងនេះថា :

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី,

**តេន ខោ បន សមយេន អាយស្មា គិរិមានន្ទោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ** ក៏ក្នុងសម័យនោះឯង ព្រះគិរិមានន្ទដ៏មានអាយុ លោកមានអាពាធ ប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់ ,

**អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ** គ្រានោះឯង ព្រះអានន្ទត្ថេរដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មាន

---

[១] ចម្លងតាមសៀវភៅ **សត្តបរិត្ត ទ្វាទសបរិត្ត** (ព. ស. ២៥១៥) ។ អត្ថបទដើមមាននៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត : បិ. ៥០ / ទំ. ២៣៤ ។

ព្រះភាគ ត្រង់ទីដែលព្រះអង្គគង់ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

**ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច** ព្រះអានន្ទត្ថេរដ៏មានអាយុ កាលអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគ ថា :

**អាយស្មា ភន្តេ គិរិមានន្ទោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ** បពិត្រព្រះអង្គដ៏ចម្រើន គិរិមានន្ទដ៏មានអាយុ មានអាពាធ ប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់,

**សាធុ ភន្តេ ភគវា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ** បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ព្រះមេត្តាអនុគ្រោះ (ចំពោះគិរិមានន្ទ)សូមស្ដេចយាងចូលទៅ ត្រង់កន្លែងដែលគិរិមានន្ទដ៏មានអាយុអាស្រ័យនៅ ។

(**<u>ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់តបថា</u>**) :

**សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ទស សញ្ញា ភាសេយ្យាសិ** ម្នាលអានន្ទ ប្រសិនបើអ្នកចូលទៅកាន់សំណាក់នៃគិរិមានន្ទភិក្ខុហើយសម្ដែងប្រាប់នូវសញ្ញាទាំង ១០ ប្រការ,

**ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យ** ដំណើរនេះ ជាហេតុនឹងឱ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះ បានរម្ងាប់

សះស្បើយទៅដោយមួយរំពេច ព្រោះគិរិមានន្ទភិក្ខុ បានស្តាប់នូវសញ្ញាទាំង ១០ប្រការ ។

☞ **កតមា ទស** សញ្ញាទាំង ១០ ប្រការនោះ ដូចម្តេចខ្លះ ?

**អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទីនវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា សព្វលោកេ អនភិរតសញ្ញា សព្វសង្ខារេសុ អនិច្ឆសញ្ញា អានាបានស្សតិ** (សញ្ញា១០ ប្រការនោះ) គឺ : អនិច្ចសញ្ញា ១, អនត្តសញ្ញា ១, អសុភសញ្ញា ១, អាទីនវសញ្ញា ១, បហានសញ្ញា ១, វិរាគសញ្ញា ១, និរោធសញ្ញា ១, សព្វលោកេ អនភិរតសញ្ញា ១, សព្វេសង្ខារេសុ អនិច្ឆសញ្ញា ១, អានាបានស្សតិ ១ ។

☞ ☸- **កតមា ចានន្ទ អនិច្ចសញ្ញា** ម្នាលអានន្ទ **អនិច្ចសញ្ញា** (នោះ) ដូចម្តេច ?

**ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញ ដូច្នេះថា :

| | |
|---|---|
| **រូបំ អនិច្ចំ** | រូបមិនទៀង |
| **វេទនា អនិច្ចា** | វេទនាមិនទៀង |
| **សញ្ញា អនិច្ចា** | សញ្ញាមិនទៀង |
| **សង្ខារា អនិច្ចា** | សង្ខារទាំងឡាយមិនទៀង |

**វិញ្ញាណំ អនិច្ចន្តិ** វិញ្ញាណមិនទៀង

**ឥតិ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ អនិច្ចានុបស្សី វិហរតិ** ភិក្ខុពិចារណាឃើញរឿយ ៗ ថាមិនទៀង ក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ នេះ ដោយប្រការដូច្នេះ,

**អយំ វុច្ចតានន្ទ អនិច្ចសញ្ញា** ម្នាលអានន្ទ នេះហើយដែលតថាគត ហៅថា អនិច្ចសញ្ញា ។

☞ ☸- **កតមា ចានន្ទ អនត្តសញ្ញា** ម្នាលអានន្ទ អនត្តសញ្ញា (នោះ) ដូចម្ដេច ?

**ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្ដី នៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះដ៏ស្ងាត់ក្ដី ពិចារណាឃើញ ដូច្នេះថា :

**ចក្ខុំ អនត្តា** ភ្នែក មិនមែនជារបស់ខ្លួនទេ
**រូបា**[១] **អនត្តា** រូបទាំងឡាយ មិនមែនជារបស់ខ្លួនទេ,

**សោតំ អនត្តា** ត្រចៀក មិនមែនជារបស់ខ្លួនទេ
**សទ្ទា អនត្តា** សំឡេងទាំងឡាយ មិនមែនជារបស់ខ្លួនទេ,

[១] ធ្លាប់សូត្រមកថា **រូបំ** តែបានពិនិត្យក្នុងគម្ពីរច្រើន ឃើញថា **រូបា** ដូច្នេះ ។

**ឃានំ អនត្តា** ច្រមុះ មិនមែនជារបស់ខ្លួនទេ
**គន្ធា អនត្តា** ក្លិនទាំងឡាយ មិនមែនជារបស់ខ្លួនទេ,

**ជិវ្ហា អនត្តា** អណ្តាត មិនមែនជារបស់ខ្លួនទេ
**រសា អនត្តា** រសទាំងឡាយ មិនមែនជារបស់ខ្លួនទេ,

**កាយោ អនត្តា** កាយ មិនមែនជារបស់ខ្លួនទេ
**ផោដ្ឋព្វា អនត្តា** សម្ផស្សទាំងឡាយ មិនមែនជារបស់ខ្លួនទេ,

**មនោ អនត្តា** ចិត្ត មិនមែនជារបស់ខ្លួនទេ
**ធម្មា អនត្តាតិ** ធម៌ទាំងឡាយ ក៏មិនមែនជារបស់ខ្លួនទេ ។

**ឥតិ ឥមេសុ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ អនត្តានុបស្សី វិហរតិ** ភិក្ខុពិចារណាឃើញរឿយ ៗ ថា មិនមែនជារបស់ខ្លួន ក្នុងអាយតនៈខាងក្នុង ៦ និង អាយតនៈខាងក្រៅ ៦ នេះ ដោយប្រការដូច្នេះ,

**អយំ វុច្ចតានន្ទ អនត្តសញ្ញា** ម្នាលអានន្ទ នេះហើយដែលតថាគត ហៅថា អនត្តសញ្ញា ។

☞ ☸- **កតមា ចានន្ទ អសុភសញ្ញា** ម្នាលអានន្ទ **អសុភសញ្ញា** (នោះ) ដូចម្តេច ?

**ឥធានន្ទ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយនេះឯង ខាងលើអំពីផ្ទៃនៃបាតជើងឡើងទៅ ខាងក្រោមអំពីចុងនៃសក់ចុះមក ពាសជុំវិញដោយស្បែក ពេញដោយគ្រឿងមិនស្អាត មានប្រការផ្សេង ៗ ដូច្នេះថា,

**អត្ថិ ឥមស្មឹ កាយេ** មានក្នុងរូបកាយនេះ :

☞ **កេសា** សក់ទាំងឡាយ, **លោមា** រោមទាំងឡាយ, **នខា** ក្រចកទាំងឡាយ, **ទន្តា** ធ្មេញទាំងឡាយ, **តចោ** ស្បែក, **មំសំ** សាច់, **នហារូ** សរសៃទាំងឡាយ, **អដ្ឋី** ឆ្អឹងទាំងឡាយ, **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង, **វក្កំ** ទាច[១], **ហទយំ** បេះដូង, **យកនំ** ថ្លើម, **កិលោមកំ** វាវ, **បិហកំ** ក្រពះ, **បប្ផាសំ** សួត, **អន្តំ** ពោះវៀនធំ, **អន្តគុណំ** ពោះវៀនតូច, **ឧទរិយំ** អាហារថ្មី, **ករីសំ** អាហារចាស់, **បិត្តំ** ប្រមាត់, **សេម្ហំ** ស្លេស្ម, **បុព្វោ** ខ្ទុះ, **លោហិតំ** ឈាម, **សេទោ** ញើស, **មេទោ** ខ្លាញ់ខាប់, **អស្សុ** ទឹកភ្នែក, **វសា** ខ្លាញ់រាវ, **ខេឡោ** ទឹកមាត់, **សិង្ឃាណិកា** ទឹកសម្បោរ, **លសិកា** ទឹករំអិល, **មុត្តន្តិ** ទឹកមូត្រ ។

**ឥតិ ឥមស្មឹ កាយេ អសុភានុបស្សី វិហរតិ** ភិក្ខុពិចារណាឃើញរឿយ ៗ ថាជាគ្រឿងមិនស្អាតក្នុងរូបកាយនេះ ដោយប្រការដូច្នេះ,

---

[១] ប្រែថា តម្រងបស្សាវៈ សមជាង ។

**អយំ វុច្ចតានន្ទ អសុភសញ្ញា** ម្នាលអានន្ទ នេះហើយដែលតថាគត ហៅថា **អសុភសញ្ញា** ។

☞ ☸- **កតមា ចានន្ទ អាទីនវសញ្ញា** ម្នាលអានន្ទ **អាទីនវ-សញ្ញា** (នោះ) ដូចម្តេច ?

**ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា,

**ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោតិ** រូបកាយនេះ មានទុក្ខច្រើន មានទោសច្រើនមែនពិត ។

**ឥតិ ឥមស្មឹ កាយេ វិវិធា អាពាធា ឧប្បជ្ជន្តិ** អាពាធគឺជំងឺតម្កាត់ទាំងឡាយផ្សេង ៗ តែងកើតឡើង ក្នុងកាយនេះ ដូច្នេះ ។

**សេយ្យថីទំ** អាពាធនោះ ដូចម្តេចខ្លះ ?

**ចក្ខុរោគោ** គឺ រោគក្នុងភ្នែក, **សោតរោគោ** រោគក្នុងត្រចៀក, **ឃានរោគោ** រោគក្នុងច្រមុះ, **ជិវ្ហារោគោ** រោគក្នុងអណ្តាត, **កាយរោគោ** រោគក្នុងកាយ, **សីសរោគោ** រោគក្នុងក្បាល, **កណ្ណរោគោ** រោគខាងក្រៅ

ត្រចៀក, **មុខរោគោ** រោគក្នុងមាត់, **ទន្តរោគោ** រោគត្រង់គល់ធ្មេញ, **កាសោ** រោគក្អក, **សាសោ** រោគហឺត, **បិនាសោ** រោគខាងក្រៅច្រមុះ, **ឌហោ** រោគក្តៅក្រហាយ, **ជរោ** រោគស្គាំងស្គម, **កុច្ឆិរោគោ** រោគក្នុងផ្ទៃ, **មុច្ឆា** រោគខ្យល់ចាប់វិលមុខ, **បក្ខន្ទិកា** រោគធ្លាក់ឈាម, **សុលា** រោគចុកសៀត, **វិសូចិកា** រោគចុះរាក, **កុដ្ឋំ** រោគឃ្លង់, **គណ្ឌោ** រោគពក, **កិលាសោ** រោគស្រែង, **សោសោ** រោគរីងរៃ, **អបមារោ** រោគឆ្កួតជ្រូក, **ទទ្ទុ** រោគ ដំណួចពិស, **កណ្ឌុ** រោគរមាស់, **កច្ឆុ** រោគកមក្រើន, **រខសា**[១] រោគកញ្ជ្រើល, **វិតច្ឆិកា** រោគកមរលាយ, **លោហិតំ** រោគឈាម, **បិត្តំ** រោគប្រមាត់, **មធុមេហោ** រោគប្រមេះទឹកបាយ, **អំសា** រោគឫសដូងបាតដុះជុំវិញទ្វារធំ, **បិឡកា** រោគរលកកែរ, **ភគណ្ឌលា** រោគឫសដូងបាតដុះខាងក្នុង[២], **បិត្តសមុដ្ឋានា អាពាធា** អាពាធកើតអំពីប្រមាត់, **សេម្ហសមុដ្ឋានា អាពាធា** អាពាធកើតអំពីស្លេស្ម, **វាតសមុដ្ឋានា អាពាធា** អាពាធកើតអំពីខ្យល់, **សន្និបាតិកា អាពាធា** អាពាធកើតអំពីសន្និបាត គឺកម្រើកប្រមាត់ ស្លេស្ម និង ខ្យល់ប្រជុំគ្នា, **ឧតុបរិណាមជា អាពាធា** អាពាធកើតអំពីរដូវប្រែប្រួល, **វិសមបរិហារជា អាពាធា** អាពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នា, **ឱបក្កមិកា អាពាធា** អាពាធកើតអំពីសេចក្តីព្យាយាម (របស់អ្នកឯទៀត មានចាប់ចងវាយកាប់ជាដើម),

[១] គួរប្រែថា **រោគមហារីក** (តាមសេចក្តីពន្យល់របស់ **អដ្ឋកថា**) ។

[២] **អដ្ឋកថា**ប្រាប់ថា ឫសដូងបាត ដែលដុះខាងក្នុង ត្រង់ចន្លោះទ្វារធំ និង ទ្វារតូច ។

**កម្មវិបាកជា អាពាធា** អាពាធកើតអំពីវិបាករបស់កម្ម, **សីតំ** អាពាធកើតអំពីត្រជាក់, **ឧណ្ហំ** អាពាធកើតអំពីក្ដៅ, **ជិឃច្ឆា** អាពាធកើតអំពីសេចក្ដីឃ្លាន, **បិបាសា** អាពាធកើតអំពីសេចក្ដីស្រេក, **ឧច្ចារោ** អាពាធកើតអំពីឧច្ចារៈ, **បស្សាវោតិ** អាពាធកើតអំពីបស្សាវៈ ។

**ឥតិ ឥមស្មឹ កាយេ អាទីនវានុបស្សី វិហរតិ** ភិក្ខុពិចារណាឃើញរឿយ ៗ ថាជាទោស ក្នុងរូបកាយនេះ ដោយប្រការដូច្នេះ,

**អយំ វុច្ចតានន្ទ អាទីនវសញ្ញា** ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា **អាទីនវសញ្ញា** ។

☞ ☸- **កតមា ចានន្ទ បហានសញ្ញា** ម្នាលអានន្ទ **បហានសញ្ញា** (នោះ) ដូចម្ដេច ?

**ឥធានន្ទ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀតនូវ**កាមវិតក្កៈ** គឺសេចក្ដីត្រិះរិះក្នុងកាមដែលកើតឡើងហើយ ។

**ឧប្បន្នំ ព្យាបាទវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោន្តិ អនភាវំ គមេតិ** មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់

ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀត នូវ**ព្យាបាទវិតក្កៈ** គឺសេចក្តីត្រិះរិះក្នុងកិរិយាញ៉ាំងសត្វដទៃឱ្យវិនាស ដែលកើតឡើងហើយ ។

**ឧប្បន្នំ វិហឹសាវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោន្តិ អនភាវំ គមេតិ** មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀត នូវ**វិហឹសាវិតក្កៈ** គឺ សេចក្តីត្រិះរិះក្នុងការបៀតបៀនសត្វ ដែលកើតឡើងហើយ ។

**ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ** មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀត នូវធម៌ដែលជា**បាបអកុសល** ដែលកើតឡើងហើយរឿយ ៗ ។

**អយំ វុច្ចតានន្ទ បហានសញ្ញា** ម្នាលអានន្ទ នេះហើយដែល**តថាគត** ហៅថា **បហានសញ្ញា** ។

☞ ☸- **កតមា ចានន្ទ វិរាគសញ្ញា** ម្នាលអានន្ទ **វិរាគសញ្ញា** (នោះ) ដូចម្តេច ?

**ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញ ដូច្នេះថា :

**ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និព្វានន្តិ វិរាគធម៌** គឺព្រះនិព្វានឯណា ដែលរម្ងាប់បង់នូវសង្ខារទាំងពួង លះបោលនូវកិលេសទាំងពួង អស់តណ្ហាហើយ, **វិរាគធម៌** គឺព្រះនិព្វាននុ៎ះ ជាគុណជាតិស្ងប់រម្ងាប់, **វិរាគធម៌** គឺព្រះនិព្វាននុ៎ះ ជាគុណជាតិដ៏ឧត្តម,

**អយំ វុច្ចតានន្ទ វិរាគសញ្ញា** ម្នាលអានន្ទ នេះហើយដែលតថាគត ហៅថា **វិរាគសញ្ញា** ។

☞ ☸ - **កតមា ចានន្ទ និរោធសញ្ញា** ម្នាលអានន្ទ **និរោធសញ្ញា** (នោះ) ដូចម្តេច ?

**ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញ ដូច្នេះថា :

**ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ និរោធោ និព្វានន្តិ និរោធធម៌** គឺព្រះនិព្វានឯណា ដែលរម្ងាប់បង់នូវសង្ខារទាំងពួង លះបោលនូវកិលេសទាំងពួង អស់តណ្ហាហើយ, **និរោធធម៌** គឺព្រះនិព្វាននុ៎ះ ជាគុណជាតិស្ងប់រម្ងាប់, **និរោធធម៌** គឺព្រះនិព្វាននុ៎ះ ជាគុណជាតិដ៏ឧត្តម,

**អយំ វុច្ចតានន្ទ និរោធសញ្ញា** ម្នាលអានន្ទ នេះហើយ ដែល**តថាគត** ហៅថា **និរោធសញ្ញា** ។

☞ ☸- **កតមា ចានន្ទ សព្វលោកេ អនភិរតសញ្ញា** ម្នាលអានន្ទ **សព្វលោកេ អនភិរតសញ្ញា** (នោះ) ដូចម្ដេច ?

**ឥធានន្ទ ភិក្ខុ យេ លោកេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ បជហន្តោ វិរមតិ ន ឧបាទិយន្តោ** ម្នាលអានន្ទ ឧបាយគឺតណ្ហា និង ទិដ្ឋិឯណា, **ឧបាទាន** គឺសេចក្ដីប្រកាន់មាំឯណា, **អភិនិវេសៈ** គឺ **សស្សតទិដ្ឋិ** និង **ឧច្ឆេទទិដ្ឋិ** ជាទីអាស្រ័យនៅនៃចិត្តណា, **អនុស័យ** គឺកិលេសដែលដេកនៅរឿយ ៗ ក្នុងសត្តសន្តានឯណាក្នុងលោក, ភិក្ខុក្នុងសាសនានេះ កាលបើលះបង់នូវបាបធម៌ទាំងនោះ (ដោយតទង្គាទិប្បហាន) មិនបានប្រកាន់មាំដោយចិត្តក៏រមែងវៀរ (ចាកបាបធម៌ទាំងនោះ)បាន ។

**អយំ វុច្ចតានន្ទ សព្វលោកេ អនភិរតសញ្ញា** ម្នាលអានន្ទ នេះហើយ ដែល**តថាគត** ហៅថា **សព្វលោកេ អនភិរតសញ្ញា** ។

☞ ☸- **កតមា ចានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា** ម្នាលអានន្ទ **សព្វសង្ខារេសុ អនិច្ចសញ្ញា** (នោះ) ដូចម្ដេច ?

**ឥធានន្ទ ភិក្ខុ សព្វសង្ខារេហិ អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នឿយណាយធុញទ្រាន់ ស្អប់ខ្ពើមសង្ខារទាំងពួង,

**អយំ វុច្ចតានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា** ម្នាលអានន្ទ នេះហើយ ដែល **តថាគត** ហៅថា **សព្វសង្ខារេសុ អនិច្ចសញ្ញា**[១] ។

☞ ☸- **កតមា ចានន្ទ អានាបានស្សតិ** ម្នាលអានន្ទ **អានាបានស្សតិ** (នោះ) ដូចម្ដេច ?

**ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា** ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្ដី នៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះដ៏ស្ងាត់ក្ដី អង្គុយផ្គត់ភ្នែន តាំងកាយឱ្យត្រង់ តម្កល់ស្មារតីឱ្យឆ្ពោះត្រង់ទៅរកព្រះកម្មដ្ឋាន,

➢ **សោ សតោវ អស្សសតិ** ភិក្ខុនោះមានស្មារតីចាំជាក់ ដកដង្ហើមចេញ, **សតោ បស្សសតិ** មានស្មារតីចាំជាក់ ដកដង្ហើមចូល ។

➢ **ទីឃំ វា អស្សសន្តោ ទីឃំ អស្សសិស្សាមីតិ បជានាតិ** កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង,

---

[១] ប្រែថា សេចក្ដីសម្គាល់ក្នុងកិរិយាមិនប្រាថ្នា ឬមិនលុះលង់ទៅក្នុងសង្ខារទាំងពួង ។

**ទីឃំ វា បស្សសន្តោ ទីឃំ បស្សសិស្សាមីតិ បជានាតិ** កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។

➢ **រស្សំ វា អស្សសន្តោ រស្សំ អស្សសិស្សាមីតិ បជានាតិ** កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី,

**រស្សំ វា បស្សសន្តោ រស្សំ បស្សសិស្សាមីតិ បជានាតិ** កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។

➢ **សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា[១] ដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវកាយ[២] គឺដង្ហើមចេញទាំងអស់ឱ្យប្រាកដ ទើបដកដង្ហើមចេញ,

**សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវកាយ[៣] គឺដង្ហើមចូលទាំងអស់ឱ្យប្រាកដ ទើបដកដង្ហើមចូល ។

---

(១) **អដ្ឋកថា** ថា ព្យាយាម ។

(២) **អដ្ឋកថា**ពន្យល់ថាធ្វើខាងដើម ខាងកណ្តាល និង ទីបំផុតនៃកាយ គឺដង្ហើមចេញទាំងអស់ឱ្យប្រាកដ ។

(៣) **អដ្ឋកថា** ពន្យល់ថា ធ្វើខាងដើម ខាងកណ្តាល និង ទីបំផុត នៃកាយ គឺដង្ហើមចូលទាំងអស់ ឱ្យប្រាកដ។

➢ **បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នករម្ងាប់នូវកាយសង្ខារ[១] គឺដង្ហើមចេញ ទើបដកដង្ហើមចេញ, **បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នករម្ងាប់នូវកាយសង្ខារ[២] គឺដង្ហើមចូល ទើបដកដង្ហើមចូល ។

➢ **បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចេញ,

**បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចូល ។

➢ **សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវសេចក្ដីសុខ ទើបដកដង្ហើមចេញ,

**សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវសេចក្ដីសុខ ទើបដកដង្ហើមចូល ។

➢ **ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ[២] ទើបដកដង្ហើម

---

[១] និង [២] **អដ្ឋកថា** ពន្យល់ថា **កាយសង្ខារ** ដ៏គ្រោតគ្រាត ។
[២] **ចិត្តសង្ខារ** គឺ **វេទនាខន្ធ** និង **សញ្ញាខន្ធ** ។

ចេញ, **ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល។

➢ **បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញ នឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ,

**បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល ។

➢ **ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះ ថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចេញ,

**ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះ ថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចូល ។

➢ **អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងធ្វើចិត្តឱ្យរីករាយ ទើបដកដង្ហើមចេញ,

**អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងធ្វើចិត្តឱ្យរីករាយ ទើបដកដង្ហើមចូល ។

➢ **សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះ ថា អាត្មាអញ នឹងតម្កល់ចិត្តឱ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចេញ,

**សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះ ថា អាត្មាអញ នឹងតម្កល់ចិត្តឱ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចូល ។

➢ **វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងដោះចិត្តឱ្យរួចចាកនីវរណធម៌ជាដើម[(១)] ទើបដកដង្ហើមចេញ, **វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងដោះចិត្តឱ្យរួចចាកនីវរណធម៌ជាដើម ទើបដកដង្ហើមចូល។

➢ **អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ថាមិនទៀង ទើបដកដង្ហើមចេញ, **អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ថាមិនទៀង ទើបដកដង្ហើមចូល ។

➢ **វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយ ៗ នូវធម៌ ដែលប្រាសចាក**រាគៈ** ទើបដកដង្ហើមចេញ, **វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុ

---

(១) **អដ្ឋកថា** ពន្យល់ថា ភិក្ខុដោះចិត្តឱ្យរួចចាក**នីវរណធម៌**ដោយ**បឋមជ្ឈាន**, ឱ្យរួចចាក**វិតក្កៈ** និង **វិចារៈ** ដោយ**ទុតិយជ្ឈាន**, ឱ្យរួចចាក**បីតិ**ដោយ**តតិយជ្ឈាន**, ឱ្យរួចចាក **សុខ** និង **ទុក្ខ** ដោយ**ចតុត្ថជ្ឈាន**, ឱ្យរួចចាក**និច្ចសញ្ញា** ដោយ**អនិច្ចានុបស្សនា**, ឱ្យរួចចាក**សុខសញ្ញា** ដោយ**ទុក្ខានុបស្សនា**, ឱ្យរួចចាក**អត្តសញ្ញា** ដោយ**អនត្តានុបស្សនា**, ឱ្យរួចចាក**នន្ទិ** ដោយ**និព្វិទានុបស្សនា**, ឱ្យរួចចាក**រាគៈ** ដោយ**វិរាគានុបស្សនា**, ឱ្យរួចចាក**សមុទយៈ** ដោយ**និរោធានុបស្សនា**, ឱ្យរួចចាក**អាទានៈ** ដោយ**បដិនិស្សគ្គានុបស្សនា**។

សិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយ ៗ នូវធម៌ ដែលប្រាស ចាក **រាគៈ** ទើប ដកដង្ហើមចូល ។

➢ **និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាដូច្នេះ ថា អាត្មាអញនឹងជាអ្នកឃើញរឿយ ៗ នូវធម៌ ដែលរំលត់បង់នូវ**កងទុក្ខ** ទើបដកដង្ហើមចេញ, **និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុ សិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយ ៗ នូវធម៌ដែលរំលត់បង់ នូវ**កងទុក្ខ** ទើបដកដង្ហើមចូល ។

➢ **បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយ ៗ នូវធម៌ ជាគ្រឿងលះចោល នូវកិលេស ទើបដកដង្ហើមចេញ,

**បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយ ៗ នូវធម៌ ជាគ្រឿងលះចោល នូវកិលេស ទើបដកដង្ហើមចូល ។

**អយំ វុច្ចតានន្ទ អានាបានស្សតិ** ម្នាលអានន្ទ នេះហើយ ដែល**តថាគត** ហៅថា **អានាបានស្សតិ** ។

**សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ឥមា ទស សញ្ញា ភាសេយ្យាសិ** ម្នាលអានន្ទ បើអ្នកចូលទៅ (កាន់សម្នាក់) នៃគិរិមានន្ទភិក្ខុហើយ គប្បីសំដែងសញ្ញាទាំង ១០ ប្រការនេះ :

**ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យាតិ** ដំណើរនេះ ជាហេតុនឹងឱ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះ រម្ងាប់សះស្បើយទៅដោយមួយរំពេច ព្រោះគិរិមានន្ទភិក្ខុបានស្តាប់នូវសញ្ញាទាំងឡាយ ១០ ប្រការនេះ ។

**អថខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ ឥមា ទស សញ្ញា ឧគ្គហេត្វា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា អភាសិ** លំដាប់នោះ ព្រះអានន្ទត្ថេរដ៏មានអាយុ ក៏រៀននូវសញ្ញាទាំងឡាយ ១០ ប្រការនេះ ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ហើយចូលទៅត្រង់កន្លែងដែលគិរិមានន្ទលោកគង់នៅ លុះចូលទៅដល់ហើយ ទើបសម្តែងនូវសញ្ញាទាំងឡាយ ១០ ប្រការនេះ ដល់ព្រះគិរិមានន្ទដ៏មានអាយុ ។

**អថខោ អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភិ** លំដាប់នោះឯងអាពាធរបស់ព្រះគិរិមានន្ទដ៏មានអាយុនោះ ក៏រម្ងាប់សះស្បើយទៅ ដោយមួយរំពេច ព្រោះបានស្តាប់នូវសញ្ញាទាំងឡាយ ១០ ប្រការនេះ ។

**វុដ្ឋហិ ចាយស្មា គិរិមានន្ទោ តម្ហា អាពាធា** ឯព្រះគិរិមានន្ទដ៏មានអាយុ ក៏បានជាសះស្បើយចាកអាពាធនោះ ។

តថា បហីនោ ច បនាយស្មតោ គិរិមានន្ទស្ស សោ អាពាធោ អហោសីតិ ក៏អាពាធនោះ គឺព្រះគិរិមានន្ទដ៏មានអាយុ លះបង់បានហើយ ដោយកិរិយាបានស្តាប់នូវសញ្ញាទាំង ១០ ប្រការ ដែលព្រះអានន្ទត្ថេរ សម្តែងហើយដូច្នោះ ដោយប្រការដូច្នោះហោង ។ ./.

## គិរិមានន្ទសុត្តំ និដ្ឋិតំ ។

## (គិរិមានន្ទសូត្រ ចប់) ។



# ខខធគាថា

## (គាថាផ្សេងៗ)

# ពុទ្ធជយមង្គលគាថា

(ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ប្រែជាពាក្យកាព្យ)

១.- **ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ**
**គ្រីមេខលំ ឧទិតឃោរសសេន មារំ**
**ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សស្ត្រា-វុធនានា ។
- ជិះគ្រិមេខលជាតិ គោពន្ធនាទ ខ្ពរពសុធា
ព្រមដោយមារសេនា ពន្លឹកលន់ កងស័ព្ទស៊ាន ។
- ដោយធម្មពិធី ទានបារមី ជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយ ថ្វាយវន្ទា ។
- វីជយមង្គល ចូរមានដល់ អ្នករាល់គ្នា
ដោយតេជជះជយា ព្រះឈ្នះមារ គ្រានោះហោង !

២.- **មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ**

**ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ**
**ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទ ពិននាយកៈ ផ្ចាញ់អាឡវក យក្សឃោរឃៅ
  រឹងរូសមិនតាំងនៅ ក្នុងខន្តី គុណសត្យា ។
- រហូតដល់រាត្រី ព្រះជិនស្រី ទ្រង់យុទ្ធនា
  ក្រៃលែងក្រុងមារា ក្នុងបឋម សម្ពោធិ ។
- ដោយព្រះពិធីញាណ ទ្រង់ទូន្មាន ដោយខន្តី
  ញុាំងចិត្តអសុរី ឱ្យបង់ព្យសន៍ ចុះវន្ទា ។
- វីជយមង្គល ចូរមានដល់ អ្នករាល់គ្នា
  ដោយតេជះជយា ព្រះឈ្នះអាឡវកយក្សហោង ។

៣.- **នាឡាគិរឹ គជវរំ អតិមត្តភូតំ**
**ទាវគ្គិចក្កមសនីវ សុទារុណន្តំ**
**មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទ ពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
  គីរី វរគជា ដ៏ហានក្លា ចុះប្រេងព្រេច ។
- សាហាវឆេវឆេះក្រៃ ដូចភ្លើងព្រៃ ឆេះកំទេច
  មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកម្មអសនី ។
- ដោយព្រះពិធីស្រប់ ស្រោចទឹកអប់ គឺបារមី

មេត្តាព្រះជិនស្រី ញាំុងដំរី ឱ្យជ្រះថ្លា ។
- វិជយមង្គល ចូរមានដល់ អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះនា-ឡាគីរី ។

**៤.- ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ**
**ធាវន្តិ យោជនបថង្គុលិមាលវន្តំ**
**ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទ្រ ពិនលោកត្រៃ មានព្រះទ័យ ធ្វើបាដិហារ្យ
ផ្ចាញ់ចោរ អង្គុលិមាល៍ មានកម្រង គឺម្រាមដៃ ។
- នៃមនុស្សដែលគាត់កាត់ មកដោតចាត់ ជាមាល័យ
អង់អាចអំណាចក្រៃ ដ៏មានដៃ ស្ទាត់ប្រហារ ។
- កាន់ដាវ ងាគ្រវី ដេញព្រះមុនី សាស្តាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃ បីយោជនា ។
- វិជយមង្គល ចូរមានដល់ អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអ-ង្គុលីមាល៍ ។

**៥.- កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា**
**ចិញ្ចាយ ទុដ្ឋវចនំ ជនកាយ មជ្ឈេ**
**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទ មានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យ នាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ ចាស់ចើលពោះ។
- យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួន ពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមា_ចារពិធី ។
- រម្ងាប់ពាក្យចណ្ឌាល នាកណ្តាល ជនប្រុសស្រី
ចិញ្ចាចាញ់បារមី គឺសច្ចំ ពាក្យសត្យា ។
- វីជយមង្គល ចូរមានដល់ អ្នករាល់គ្នា
ដោយតេជះជយា ព្រះសាស្តា ឈ្នះចិញ្ចា ។

៦.. **សច្ចំ វិហាយ មតិសច្ចកវាទកេតុំ**
**វាទាភិរោបិតមនំ អតិអន្ធភូតំ**
**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទ ពិនអ្នកប្រាជ្ញ រុងរឿងស្វាច ដោយបញ្ញា
ផ្ចាញ់សច្ចកៈ ជា និគ្រន្ថក្រៅ ពុទ្ធវិន័យ ។
- អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់ តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ ដូចដងទង់ ។
- បង្កើតមោហ៍ងងឹត ដោយពោលឥត_ពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់ ដោយប្រទីប គឺបញ្ញា ។
- វីជយមង្គល ចូរមានដល់ អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះសច្ចកៈនិគ្រន្ថ ។

៧.- **នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ**
**បុត្តេន ថេរភុជគេន ទមាបយន្តោ**
**ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទ ពិនទ្រង់ញាណ ញុាំងមោគ្គល្លាន មានអំណាច
ឱ្យប្លែងជានាគរាជ ទៅទូន្មាន ព្យសន៍ភុជង្គ ។
- ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធ រឿងឫទ្ធិវង្គ
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយ ពិធីឈាន ។
- គឺឱ្យឧបទេស ឫទ្ធិវិសេស ដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ ព្រះថេរ្នា ។
- វីជយមង្គល ចូរមានដល់ អ្នករាល់គ្នា
ដោយតេជះជយា ព្រះភគវា ឈ្នះនាគហោង ។

៨.- **ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ**
**ព្រហ្មំ វិសុទ្ធិ ជុតិមិទ្ធិពកាភិធានំ**
**ញាណាគទេន វិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ !**

- ព្រះមុនិន្ទ ពិនគោតម ផ្ចាញ់មហាព្រហ្ម ឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយ គុណវិសុទ្ធិ ។
- ដៃកាន់អាសិរពិស គឺចិត្តទ្រឹស្ត ដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាក លះបង់ប្រាណ

- ទ្រង់ឈ្នះដោយពិធី ឱសថវិ-សេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណ ប្រោសទេសនា ។
- វិជយមង្គល ចូរមានដល់ អ្នករាល់គ្នា
ដោយតេជះជយា ឈ្នះព្រហ្មា ឥតមានហ្មង ។

☞ **ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា**
**យោ វាចនោ ទិនទិនេ សរតេ មតន្ទី**
**ហិត្វានេកវិវិធានិ ចុបទ្ទវានិ**
**មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ !**

- **យោ នរោ** ជនឯណា កបបញ្ញា ប្រាសក្តីខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំឭក ព្រះធម៌ថ្លៃ ។
- គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូធ្យសព្វៗថ្ងៃ កើតមង្គលជានិរន្តន៍ ។
- **សោ នរោ** វិជននោះ បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការ ផ្សេងៗ ផង ។
- នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វាន សុខកន្លង
លែងទុក្ខទាំង ៤ កង ដោយពុទ្ធជ័យ-មង្គលនេះ !

(ចប់ **ពុទ្ធជយមង្គល**)

# សរណាទីបិកាគាថា

~ **ពហុំ វេ សរណំ យន្តិ    បព្វតានិ វនានិ ច**
**អារាមរុក្ខចេត្យានិ    មនុស្សា ភយតជ្ជិតា ។**

មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាម និង ដើមឈើ ដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង,

~ **នេតំ ខោ សរណំ ខេមំ    នេតំ សរណមុត្តមំ**
**នេតំ សរណមាគម្ម    សព្វទុក្ខា បមុច្ចតិ ។**

ទីពឹងនុ៎ះឯងមិនមែនជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះមិនមែនជាទីពឹងដ៏ឧត្តម បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះទេ ។

~ **យោ ច ពុទ្ធញ្ច ធម្មញ្ច    សង្ឃញ្ច សរណំ គតោ**
**ចត្តារិ អរិយសច្ចានិ    សម្មប្បញ្ញាយ បស្សតិ**
**ទុក្ខំ ទុក្ខសមុប្បាទំ    ទុក្ខស្ស ច អតិក្កមំ**
**អរិយញ្ចដ្ឋង្គិកំ មគ្គំ    ទុក្ខូបសមគាមិនំ ។**

បុគ្គលណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ជាទីពឹង ទីរលឹក ហើយឃើញនូវ **អរិយសច្ច** ទាំង៤ គឺ សេចក្តីទុក្ខ១, **សមុទយៈ** ជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ១, **និរោធ** ជាទីកន្លងបង់

នូវសេចក្ដីទុក្ខ១, **មគ្គ** មានអង្គ ៨ ដ៏ប្រសើរ ដែលញុំាងសត្វឱ្យដល់នូវ**ព្រះនិព្វាន** ជាឋានរម្ងាប់បង់នូវសេចក្ដីទុក្ខ១ ដោយប្រាជ្ញាដ៏ត្រូវ,

~ **ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ**

**ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។**

ទីពឹងនុ៎ះឯងជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះជាទីពឹងដ៏ឧត្ដម (របស់បុគ្គលនោះ) បុគ្គលរមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។

( គាថាធម្មបទ **"ពុទ្ធវគ្គ"** សុត្តន្ត. ខុទ្ទកនិកាយ : បិ. ៥២, ទំ. ៦១-៦២ )

# ទលិទ្ទសុត្តគាថា

**យស្ស សទ្ធា តថាគតេ អចលា សុបតិដ្ឋិតា**

បុគ្គលឯណាមានសេចក្ដីជឿ តម្កល់មាំឥតកម្រើក ចំពោះព្រះតថាគត,

**សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ**

បុគ្គលឯណាមានសីលដ៏ល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈទាំងឡាយ លោកសរសើរហើយ,

**សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ**

បុគ្គលឯណា មានសេចក្តីជ្រះថ្លាចំពោះព្រះសង្ឃផង មានសេចក្តីយល់ឃើញដ៏ត្រឹមត្រូវផង,

**អទលិទ្ទោតិ តំ អាហុ អមោឃន្តស្ស ជីវិតំ**

បណ្ឌិតទាំងឡាយលោកហៅបុគ្គលនោះថាមិនមែនជាអ្នកទាល់ក្រឡើយ ជីវិតរបស់បុគ្គលនោះ មិនមែនសោះសូន្យឥតប្រយោជន៍ឡើយ,

**តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ**

**អនុយុញ្ជេថ មេធាវី សរំ ពុទ្ធាន សាសនំ**

ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញា កាលរឭកឃើញនូវសាសនា គឺពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ក៏គួរប្រកបរឿយៗ នូវសេចក្តីជឿផង នូវសីលផង នូវសេចក្តីជ្រះថ្លាផង នូវកិរិយាឃើញនូវធម៌ផង ។

# ការវសុត្តគាថា

**យេ ច អតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា**

**យោ ចេតរហិ សម្ពុទ្ធោ ពហុន្នំ សោកនាសនោ**

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់កន្លងហួសទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលមិនទាន់បានត្រាស់ក្តី ព្រះសម្មាសម្ពុទ្ធអង្គឯណា ជាអ្នកញុំាងសេចក្តីសោក

របស់ជនទាំងឡាយច្រើន ឱ្យវិនាសទៅ (មាន)ក្នុងកាលឥឡូវនេះក្តី, **សព្វេ សទ្ធម្មគរុនោ** ព្រះសម្មាសម្ពុទ្ធ(ទាំងឡាយនោះ)គ្រប់ព្រះអង្គ សុទ្ធតែមានសេចក្តីគោរពចំពោះព្រះសទ្ធម្ម,

**វិហរឹសុ វិហាតិ ច** ព្រះអង្គគង់នៅរួចទៅហើយក្តី គង់នៅក្នុងកាលឥឡូវនេះក្តី,

**អថាបិ វិហរិស្សន្តិ** នឹងគង់នៅតទៅទៀតក្តី,

**ឯសា ពុទ្ធាន ធម្មតា** កិរិយាបែបនេះ ជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ,

**តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា**
**សទ្ធម្មោ គរុកាតព្វោ សរំ ពុទ្ធាន សាសនំ**

ក៏ព្រោះហេតុដូច្នោះ បុគ្គលអ្នកស្រឡាញ់នូវខ្លួន អ្នកប្រាថ្នានូវភាវៈជាធំ កាលរឭកឃើញនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គួរតែធ្វើនូវសេចក្តីគោរពចំពោះព្រះសទ្ធម្ម ។

# បព្វតោបមសុត្តគាថា

**យថាបិ សេលា វិបុលា នភំ អាហច្ច បព្វតា**
**សមន្តា អនុបរិយេយ្យុំ និប្បោថេន្តា ចតុទ្ទិសា**

ប្រសិនណាបើភ្នំទាំងឡាយ សុទ្ធសឹងតែថ្មដ៏ខ្ពស់ពេញអាកាស រមៀលកិននូវសត្វទាំងឡាយ ដែលមកដោយជុំវិញទាំង៤ទិស យ៉ាងណាមិញ,

**ឯវំ ជរា ច មច្ចុ ច អធិវត្តន្តិ បាណិនោ**

**ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ទេ ចណ្ឌាលបុក្កុសេ**

សេចក្តីចាស់ សេចក្តីស្លាប់ តែងគ្របសង្កត់នូវសត្វទាំងឡាយ (មិនរើសមុខ) ទោះជាក្សត្រក៏ដោយ ជាព្រាហ្មណ៍ក៏ដោយ ជាអ្នកជំនួញក៏ដោយ ជាពួកគូលីក៏ដោយ ជាពួកចណ្ឌាលក៏ដោយ ជាអ្នកចាក់សំរាមចោលក៏ដោយ យ៉ាងនោះឯង,

**ន កិញ្ចិ បរិវជ្ជេតិ សព្វមេវាភិមទ្ទតិ**

ឥតមានវៀរលែងនូវបុគ្គលណាមួយឡើយ តែងគ្របសង្កត់ញាំញីនូវសត្វទាំងអស់មិនឱ្យសល់មួយ,

**ន តត្ថ ហត្ថីនំ ភូមិ** ភូមិនៃដំរីទាំងឡាយ មិនមានក្នុងជរា និង មរណៈនោះទេ,

**ន រថានំ ន បត្តិយា** (ភូមិ)នៃរថទាំងឡាយក៏មិនមាន ទាំង(ភូមិ)នៃពលថ្មើរជើងទាំងឡាយ ក៏មិនមាន(ក្នុងជរា និង មរណៈនោះឡើយ),

**ន ចាបិ មន្តយុទ្ធេន សក្កា ជេតុំ ធនេន វា**

ម្យ៉ាងទៀត ឥតមានអ្នកណាមួយនឹងឈ្នះ(នូវជរា និង មរណៈនោះ) ដោយការតតាំងច្បាំងដោយនូវវេទមន្ត ឬ ដោយនូវទ្រព្យសម្បត្តិបានឡើយ,

**តស្មា ហិ បណ្ឌិតោ បោសោ សម្បស្សំ អត្ថមត្តនោ**

**ពុទ្ធេ ធម្មេ ច សង្ឃេ ច ធីរោ សទ្ធំ និវេសយេ**

ព្រោះហេតុនោះ បុរសជាបណ្ឌិតអ្នកមានប្រាជ្ញា កាលឃើញនូវប្រយោជន៍របស់ខ្លួន ក៏គួរនឹងបណ្តុះនូវសទ្ធា ចំពោះព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ,

**យោ ធម្មចារី កាយេន វាចាយ ឧទ ចេតសា**

បុគ្គលណាមួយ ជាអ្នកប្រព្រឹត្តនូវធម៌ ដោយកាយ ដោយវាចា ឬដោយចិត្ត,

**ឥធេវ នំ បសំសន្តិ** បណ្ឌិតទាំងឡាយ តែងសរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង,

**បេច្ច សគ្គេ បមោទតិ** បុគ្គលនោះ លុះទៅកាន់បរលោកនាយហើយ តែងត្រេកអររីករាយក្នុងឋានសួគ៌ទៀត ៕ល៚

***ចំណាំ:*** *តពីនេះទៅមាន**សំវេជនីយគាថា**ទៀត ដូចមាននៅក្នុង**ធម៌បំសុកូល** ត្រង់ទំព័រខាងដើមសព្វគ្រប់ហើយ ។*

**(ចប់ ខទិរធគាថា)**

# ធម៌នមស្សការផ្សេងៗ

# ភាសិតោវាទសង្ខេប



៩០ ឱកាស ខ្ញុំសូមគោរព !

យោ បន [១] ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិ--បន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ អ្នកឯណាមួយ ជាអ្នក

(១) ច្បាប់ភាណវារខ្លះថា យោ បន ភិក្ខុ, ច្បាប់ខ្លះមានត្រឹមតែប៉ុណ្ណេះ ។

ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អានបូជា នូវ **ព្រះតថាគត** ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់, ទាំងនេះ ជាពាក្យប្រៀនប្រដៅ នៃ **ព្រះពុទ្ធ**ទាំងឡាយ ។

**ខន្តិ បរមំ តបោ តីតិក្ខា**
**និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ ។**

អំណត់គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនតិះដៀល (អ្នកដទៃ)១, កិរិយាមិនបៀតបៀន (អ្នកដទៃ)១ កិរិយាសង្រួមក្នុងបាតិមោក្ខ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ១ ទីដេក និង ទីអង្គុយដ៏ស្ងាត់១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត១ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

☸ **សីលសមាធិគុណានំ ខន្តិ បធានការណំ**
**សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ**

សេចក្តីអត់ធន់ ជាហេតុទីតាំងនៃគុណ គឺ : **សីល** និង **សមាធិ** ទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្តីអត់ធន់មែនពិត ។

☸ **កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**
**គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫស នៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយមានពាក្យតិះដៀល និង ការឈ្លោះប្រកែកជាដើម ។

☸ **ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ**
**ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា ។**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់ នូវបាបរបស់អ្នកដែលមានតបធម៌ សេចក្តីអត់ធន់ ជា

កម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍ និង សេចក្តីសុខ ។

☸ **ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**
**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ ។**

អ្នកអត់ធន់ជាអ្នកមានមិត្រសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកអត់ធន់រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃទេវតា និង មនុស្សទាំងឡាយ ។

☸ **អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ**
**សគ្គមោក្ខគមំ មគ្គំ អារូឡ្ហោ ហោតិ ខន្តិកោ ។**

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង, អ្នកអត់ធន់ជាអ្នកឡើងកាន់ផ្លូវជាទីទៅស្ថានសួគ៌ និងព្រះនិព្វាន ។

☸ **សត្ថុនោ វចនោវាទំ ករោតិ យេវ ខន្តិកោ**
**បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ ។**

អ្នកអត់ធន់ ឈ្មោះថាធ្វើតាម នូវព្រះពុទ្ធដីកាជាឱវាទ នៃព្រះសាស្តាមែនពិត, អ្នកអត់ធន់ ឈ្មោះថា បូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្តម ។

☸ **ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ**
**ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ ។**

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬ នឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

☸ **សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ កិរិយាសម្តែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នារបស់សង្ឃ ឬ ពួកក្រុម នាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្តីសុខ ។

☸ **សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ**
**អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សញ្ញមោ ។**

សេចក្តីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ(ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញ(នូវធម៌) នាំមកនូវសេចក្តីសុខ, កិរិយាមិនបៀតបៀន គឺ កិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

☸ **សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ**
**អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ ។**

ភាវៈប្រាសចាករាគៈ គឺ កិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានះ នេះឯង នាំមកនូវសេចក្តីសុខដ៏ឧត្តម ។

☸ **កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។**

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក, សេចក្តីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក, កិរិយាស្តាប់នូវព្រះសទ្ធម្ម ជាការកម្រ, កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក ។

☸ **សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មិំ ជិនសាសនេ**
**កប្បានិ សតសហស្សានិ ទុគ្គតិំ សោ ន គច្ឆតិ ។**

បុគ្គលឯណា បានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

☸ **បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ**
**បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហនំ**
**បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ**

**ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ**

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធ-កិច្ចទាំងឡាយ៥ ប្រការនេះ គឺ ក្នុងពេលព្រឹក ទ្រង់ស្ដេចទៅបិណ្ឌបាត១, ក្នុងពេលល្ងាច ទ្រង់សម្ដែងធម្មទេសនា១, ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ១, ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា១, ក្នុងពេលជិតភ្លឺ(១) ទ្រង់ប្រមើលនូវសត្វលោក ដែលគួរត្រាស់ដឹង និង មិនគួរត្រាស់ដឹង១ ។

☸ **កុក្កុដេ គព្ភវាសោ ច សោណេ ចុតនិក្ខមិ**
**ឧសភេ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា)ក្នុងឆ្នាំ **រកា** ទ្រង់ប្រសូត្រចាកព្រះគភ៌ក្នុងឆ្នាំ **ច** ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

☸ **កុក្កុដេ សព្វញ្ញុ ពុទ្ធោ តត្ថ ចក្កំ បវត្តយិ**
**និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ ។**

---

(១) ក្នុង **អដ្ឋកថាធម្មបទ** សម្ដែងថា ព្រះអង្គប្រមើលមើលឧបនិស្ស័យសត្វ ក្នុងមួយថ្ងៃ-មួយយប់ ២ដង គឺ ក្នុងពេលជិតភ្លឺម្ដង ពេលល្ងាចម្ដង, ពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្ដាប់មាត់ចក្រវាឡ រហូតមកដល់គន្ធកុដិ ពេលល្ងាច ទ្រង់ប្រមើលមើលពី គន្ធកុដិ រហូតដល់ទៅកណ្ដាប់មាត់ចក្រវាឡ ។

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សម្ដែងនូវព្រះធម្មចក្កក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធ-សាសនា នឹងគ្រប់ ៥.០០០ គត់ ក្នុងឆ្នាំជូត ។

☸ **ឱក្កន្តោ ច គរុវារស្មឹ  សុក្រវារេ ច និក្ខមិ**
**សម្ពុទ្ធោ ពុធវារស្មឹ  អង្គារេ បរិនិព្វុតោ ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូត្រក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វាន ក្នុងថ្ងៃអង្គារ ។

☸ **អាសាឡ្ហបុណ្ណមោក្កន្តោ  វិសាខេ យេវ និក្ខមិ**
**វិសាខបុណ្ណមី សម្ពុទ្ធោ  វិសាខេ បរិនិព្វុតោ ។**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌-មីខែអាសាឍ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វាន ក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

☸ **និព្វុតេ លោកនាថម្ហិ  សម្ពុទ្ធេ អគ្គបុគ្គលេ**
**បដិមា ពោធិរុក្ខា ច  ថូបា ច ជិនធាតុយោ**
**ចតុរាសីតិសហស្ស-  ធម្មក្ខន្ធា សុទេសិតា**
**អគ្គប្បវត្តនដ្ឋានេ  ឋបិតា ហោន្តិ បាណិនំ ។**

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិ-និព្វានទៅហើយ ព្រះពុទ្ធបដិមាផង ពោធិព្រឹក្សផង ព្រះសថូប(ស្តូប)ផង ព្រះជិនធាតុផង ព្រះធម៌៨មុឺន ៤ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុ គឺ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅ ដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វទាំងឡាយ ។

☸ **ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ**
**ឋបេត្វា សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិ**
**បូជាយ បូជំ ករោន្តេន លោកិយលោកុត្តរ-**
**សម្បត្តិសិទ្ធំ ភាគវំ ឧកាស អារាធនំ ករោមិ ។**

បុគ្គលគួរតម្កល់នូវឱវាទដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយទុកក្នុងចិត្ត ហើយធ្វើការបូជា ដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងហើយ គួរធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយៈ និង លោកុត្តរៈ ខ្ញុំសូមគោរព អារាធនាទុកដោយប្រការដូច្នេះ ។

☸ **ឧកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេ-សាយ និព្វានធាតុយា ។**

ខ្ញុំសូមគោរព **សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធ** ជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធៈ ក្នុងថ្ងៃអង្គារ យាមអង្គារ ជា **តិថី** ពេញបូណ៌មីខាងខ្នើតខែវិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ ឯណោះហោង ។




*(ពីនេះទៅ ត្រូវបកសករាជប្រាប់ថ្ងៃខែឆ្នាំ ដែលកន្លងហើយ និង បច្ចុប្បន្ន និង អនាគត ដរាបដល់ចប់)* ។ល។

# ខណីបកសករាជ

**តស្ស ភគវតោ សម្មាសម្ពុទ្ធស្ស បរិនិព្វុតទិវសតោ បដ្ឋាយ យាវជ្ជតនា ចតុទ្ទសទិវសុត្តរទសមាសាធិក អដ្ឋសត្តតសំវច្ឆរុត្តរចតុស្សតាធិកានិ ទ្វេ សំវច្ឆរសហស្សានិ អតិក្កន្តានិ អហេសុំ ។ ឥមស្មឹ បច្ចុប្បន្នកាលេ សូករសំវច្ឆរេ គិម្ហឧតុម្ហិ ផល្គុណមាសេ កាឡបក្ខេ បណ្ណរសិយា តថិយំ រវិវារេ អនាគតេ កាលេ បណ្ណរស ទិវសុត្តរឯកមាសាធិក ឯកវីសតិសំវច្ឆរុត្តរបញ្ចសតាធិកានិ ទ្វេ សំវច្ឆរសហស្សានិ ភវិស្សន្តិ**

*សូមគោរពរំឭក ដល់កាលដែលព្រះសក្យមុនីសព្វញ្ញុពុទ្ធទ្រង់មានសិរី ព្រះអង្គចូលនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងថ្ងៃប្រកបដោយអនុរាធនក្ខត្តឫក្ស នាថ្ងៃអង្គារ យាមអង្គារ នៅថ្ងៃ១៥កើត ខែវិសាខ ក្នុងគិម្ហរដូវឆ្នាំម្សាញ់ឯណោះ ក្រោមចន្លោះមែកសាលព្រឹក្សទាំងគូ (នាសាលវ័នឧទ្យាន ជិតក្រុងកុសិនារា ក្នុងសម័យជិតភ្លឺ) ។*

*រាប់ចាប់ដើមតាំងអំពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធ ដ៏មានព្រះភាគព្រះអង្គនោះ ទ្រង់ចូលបរិនិព្វានទៅដរាបមកដល់ថ្ងៃនេះ ព្រះពុទ្ធសាសនកាល កន្លងទៅហើយបាន ២៤៧៨ឆ្នាំ ១០ខែ និង ១៤ថ្ងៃ, ឥឡូវនេះ ឆ្នាំកុរសប្តស័ក គិម្ហរដូវ ខែផល្គុន ១៥ រោច ថ្ងៃអាទិត្យ (ថ្ងៃ ខែ ឆ្នាំនេះ លោកកំណត់ទុកជាបច្ចុប្បន្ន*

កាល) ឯព្រះពុទ្ធសាសនកាលចំណែកខាងអនាគតនៅសល់ ២៥២១ឆ្នាំ ១ខែ និង១៥ថ្ងៃ បើរួបរួមថ្ងៃ ខែ ឆ្នាំ ទាំងបីកាល ត្រូវជាព្រះពុទ្ធសាសនកាលចំនួន ៥.០០០វស្សា ដោយបរិបូណ៌ ។

# ពុទ្ធបាទនមស្សការគាថា

☸ វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោកទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអនន្តឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

☸ យំ នម្មទាយ នទិយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្លូវខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះ**នម្មទា**,ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើ**ភ្នំសច្ចពន្ធ** និង លើ**ភ្នំសុមនកូដ**, ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុង**យោនកបុរី** ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទ និង ស្នាមព្រះបាទទាំងនោះនៃ **ព្រះសក្យមុនី** ។

☸ **សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

ខ្ញុំសូមនមស្សការអំពីចម្ងាយ នូវឋានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺឋានលើ**ភ្នំសុវណ្ណមាលិក**១, លើ**ភ្នំសុវណ្ណបព៌ត**១, លើ**ភ្នំសុមនកូដ**១, ក្នុង**យោនកបុរី**១, ក្បែរស្ទឹង**នម្មទា**១ ។



# ធាតុចេតិយនមស្សការគាថា

☸ មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ
ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ ។

ព្រះគោតមបរមសម្ពុទ្ធ ដ៏ប្រសើរ ព្រះអង្គបរិនិព្វានហើយ ជិតក្រុងកុសិនារា ធ្វើនូវកិរិយាផ្សាយនូវព្រះសារីរិកធាតុ ក្នុងទីទាំងឡាយនោះៗ ដោយផ្សេងៗ គ្នា ។

☸ ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា
អសម្ភិន្នា វ តា សត្ត សេសា ភិន្នា វ ធាតុយោ ។

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកចេញ មាន ៧អង្គ គឺ : ព្រះឧណ្ហីសធាតុ[(១)] ១, ព្រះទាឋធាតុ[(២)] ៤, ព្រះអក្ខកធាតុ[(៣)] ២, ព្រះសារីរិកធាតុដ៏សេសក្រៅពីនោះ សុទ្ធតែបែកចេញ (ជាបំណែកតូចៗ)។

☸ មហន្តា បញ្ច នាឡី ច មជ្ឈិមា ច ឆ នាឡិយោ
ខុទ្ទកា បញ្ច នាឡី ច សម្ភិន្នា តិវិធា មតា ។

---

(១) ឆ្អឹងថ្ងាស ។
(២) ព្រះចង្កូមកែវ ។
(៣) ឆ្អឹងដងកាំបិត ។

ព្រះបរមធាតុទាំងឡាយដែលបែកចេញ លោកពោលថាមាន ៣ យ៉ាង : គឺព្រះធាតុខ្នាតធំ វាល់បានចំនួន ៥ នាឡិ, ព្រះធាតុខ្នាតកណ្តាល វាល់បានចំនួន ៦ នាឡិ, ព្រះធាតុខ្នាតតូច វាល់បានចំនួន ៥ នាឡិ ។

☸ **មហន្តា ភិន្នមុគ្គា ច មជ្ឈិមា ភិន្នតណ្ឌុលា**
**ខុទ្ទកា សាសបមត្តា ឯវំ ធាតុប្បមាណិកា ។**

**ព្រះបរមធាតុ**ទាំងឡាយ មានប្រមាណយ៉ាងនេះ គឺ : ព្រះធាតុខ្នាតធំ មានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ ព្រះធាតុខ្នាតកណ្តាល មានទំហំប៉ុនកំណាត់គ្រាប់អង្ករ ព្រះធាតុខ្នាតតូច មានទំហំប៉ុនគ្រាប់ស្ពៃ។

☸ **មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា**(១)
**ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ ។**

ព្រះបរមធាតុទាំងឡាយ (មានពណ៌ផ្សេងគ្នាយ៉ាងនេះ) គឺ: ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស, ព្រះធាតុខ្នាតកណ្តាល មានពណ៌ដូចកែវផលិក, ព្រះធាតុខ្នាតតូច មានពណ៌ដូចផ្កាផ្កុល ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយនោះ ។

☸ **ឯកោ ទូរោ រាជគ្គហោ ឯកោ វេសាលិយា អហុ**

(១) បាលីថា **មុត្តិកប្បភា** មានពណ៌ដូចកែវមុក្តា ដូច្នេះក៏មាន ។

**ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ**
**ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ**
**ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ ។**

**ព្រះស្តូប** (ព្រះសថូប)១ ប្រតិស្ឋាននៅក្នុងក្រុងរាជគ្រឹះ, ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងវេសាលី, ព្រះស្តូប១ ប្រតិស្ឋាននៅក្នុងក្រុងកបិលព័ស្តុ, ព្រះស្តូប១ ប្រតិស្ឋាននៅក្នុងក្រុងអលកប្បកៈ, ព្រះស្តូប ១ ប្រតិស្ឋាននៅរាមគ្រាម, ព្រះស្តូប១ ប្រតិស្ឋាននៅក្នុងក្រុងវេដ្ឋទីបកៈ, ព្រះស្តូប១ ប្រតិស្ឋាននៅក្នុងក្រុងបាវេយ្យកៈ ក្នុងមល្លរដ្ឋជនបទ, ព្រះស្តូប១ ប្រតិស្ឋាននៅក្នុងក្រុងកុសិនារា ។

☸ **ឯតេ សារីរិកា ថូបា ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។**

**ព្រះស្តូប** (ទាំង៨) នុ៎ះ ជាព្រះស្តូបបញ្ចុះព្រះបរមសារីរិកធាតុ ប្រតិស្ឋាននៅក្នុងជម្ពូទ្វីប ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយ (ក្នុងព្រះស្តូបទាំង ៨ នោះ) ដែលទេវតា និង មនុស្សទាំងឡាយ តែងបូជា ។

☸ **ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ**
**ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ ។**

**ព្រះទាឋធាតុ** អង្គ១ ប្រតិស្ឋាននៅក្នុងស្ថានត្រ័យត្រិង្ស, ព្រះទាឋធាតុអង្គ១ ប្រតិស្ឋាននៅក្នុងពិភពនាគ, ព្រះទាឋធាតុអង្គ១ ប្រតិ-ស្ឋាននៅក្នុងគន្ធាររដ្ឋ, ព្រះទាឋធាតុអង្គ១ ប្រតិស្ឋាននៅក្នុងសីហឡទ្វីប។

☸ **ឥមា ចតូសុ ឋានេសុ　សត្ថុ ទាឋា បតិដ្ឋិតា**
**បូជិតា នរទេវេហិ　អហំ វន្ទាមិ ធាតុយោ ។**

**ព្រះទាឋធាតុ** ទាំងឡាយនេះ របស់ **ព្រះបរមសាស្តា** ប្រតិ-ស្ឋាននៅក្នុងទីទាំងឡាយ ៤ កន្លែង ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

☸ **ឧទ្ធំ ទក្ខិណទាឋា ច　តាវតិំសេ បតិដ្ឋិតា**
**អធោ ទក្ខិណទាឋា ច　សីហឡទីបេ បតិដ្ឋិតា**
**វាមទាឋា ច ឧទ្ធម្បិ　គន្ធាររដ្ឋេ បតិដ្ឋិតា**
**វាមទាឋា ច អធោបិ　នាគលោកេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ　អហំ វន្ទាមិ ធាតុយោ ។**

ព្រះទាឋធាតុស្តាំខាងលើ ប្រតិស្ឋាននៅក្នុងស្ថានតាវត្តិង្ស, ព្រះទាឋធាតុស្តាំខាងក្រោម ប្រតិស្ឋាននៅក្នុងសីហឡទ្វីប, ព្រះទាឋធាតុឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុងដែនគន្ធារ, ព្រះទាឋធាតុឆ្វេងខាងក្រោម ប្រតិស្ឋាននៅក្នុងពិភពនាគ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

☸ **ព្រហ្មលោកេ ទុស្សធាតុ វាមអក្ខកធាតុយោ**
**សព្វេ ព្រហ្មាភិបូជេន្តិ ថូបំ ទ្វាទសយោជនំ ។**

ព្រះទុស្សធាតុ[១] និង ព្រះអក្ខកធាតុ ខាងឆ្វេង ប្រតិស្ឋាននៅក្នុងព្រហ្មលោក, ព្រហ្មទាំងឡាយទាំងអស់គ្នា តែងបូជានូវព្រះស្តូប កំពស់ ១២ យោជន៍ (ដែលបញ្ចុះនូវព្រះធាតុទាំងនោះ) ។

☸ **តាវត្តឹសម្ហិ ទេវានំ ចូឡាមណិម្ហិ កេសកំ**
**សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។**

ទេវតាទាំងឡាយទាំងពួងដែលជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តែងបូជានូវព្រះកេសធាតុ ដែលប្រតិស្ឋាននៅក្នុងចូឡាមណីចេតិយរបស់ទេវតាទាំងឡាយក្នុងឋានត្រៃត្រិង្ស ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធាតុទាំងឡាយ ដែលទេវតា និង មនុស្សទាំងឡាយ តែងបូជា ។

☸ **ចត្តាឡីស សមា ទន្តា កេសា លោមា នខាបិ ច**
**ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។**

---

[១] **ព្រះទុស្សធាតុ** គឺព្រះពស្ត្រដែលព្រះអង្គផ្លាស់ចេញ ហើយទ្រង់សំពត់-កាសាវៈ ដែលឃដិការមហាព្រហ្មយកមកថ្វាយ រួចទ្រង់ប្រទានព្រះពស្ត្រនោះ ទៅ **ឃដិការមហាព្រហ្ម** ៗ បានទទួលយកទៅប្រតិស្ឋានឯព្រហ្មលោក ។

ព្រះទន្តធាតុទាំងឡាយ ៤០ គត់ផង ព្រះកេសធាតុទាំងឡាយផង ព្រះលោមធាតុទាំងឡាយផង ព្រះនខធាតុទាំងឡាយផង ទេវតាទាំងឡាយនាំទៅនូវព្រះធាតុមួយអង្គ ៗ កាន់ចក្រវាលដទៃ និង ដទៃ គឺ ព្រះធាតុមួយអង្គ ៗ ក្នុងចក្រវាលមួយៗ, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

☸ **អដ្ឋារស ទេ្វ វស្សសតេ** **ធម្មាសោកោ តទា អាហុ**
**ចតុរាសីតិសហស្សា** **ចេតិយា ច ការាបិតា**
**បូជិតា នរទេវេហិ** **អហំ វន្ទាមិ ធាតុយោ ។**

នាកាលព្រះពុទ្ធសករាជបាន **២១៨** ឆ្នាំ មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាម**ធម្មាសោក** ក្នុងកាលនោះ ព្រះអង្គបានកសាងព្រះចេតិយចំនួន ៨ម៉ឺន ៤ ពាន់, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ (ក្នុងព្រះចេតិយទាំងនោះ) ដែលទេវតា និង មនុស្សទាំង-ឡាយតែងបូជា ។

☸ **តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ**
*សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរក្នុងធម៌ជាគ្រឿងអស់តណ្ហា !*

# ពាក្យសម្រាប់ក្រាលកឋិន

## ☸ វារៈទី១ ☸

**ភន្តេ** បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន, រីអង្គកឋិនទាននេះជារបស់អស់លោក-អ្នកពុទ្ធបរិស័ទសប្បុរសទាំងឡាយ (.............) ជាប្រធាន, សុទ្ធសឹងតែជាពុទ្ធមាមកជនប្រកបដោយបសាទសទ្ធា និងកុសលចេតនា ជាអសង្ខារិក ជ្រះថ្លាចំពោះគុណព្រះរតនត្រៃ បានបំពេញនូវបុញ្ញកិរិយាវត្ថុ ចេះលៃលកយកធនធានដែលគ្មានខ្លឹមសារ ធ្វើឱ្យជារបស់មានខ្លឹមសារ កប់ទុកក្នុងព្រះពុទ្ធសាសនា ដើម្បីជាទ្រព្យមត៌ក សម្រាប់ប្រើប្រាស់ទៅក្នុងភពខាងមុខទៀត, បានស្រុះស្រួលបបួលគ្នាផ្តួចផ្តើមបង្កើតជាអង្គកឋិនទាននេះឡើង ព្រមទាំងហែហមដ៏ឧឡារិក គគ្រឹកគគ្រេងតាមដងផ្លូវ ដើម្បីនឹងយកមកវេរថ្វាយព្រះភិក្ខុសង្ឃ ដែលគង់ចាំវស្សាអស់ត្រីមាសក្នុងទីវត្ត (.........)នេះ ហាក់ដូចជាសំពត់កោសេយ្យព័ស្ត្រ អណ្តែតត្រសែតឮដ៏អាកាសវេហាស៍នភាល័យ ហើយធ្លាក់ចុះមកក្នុងកណ្តាលជំនុំសង្ឃ ជាសង្ឃទានស្មោះឥតមានចំពោះព្រះករុណាអង្គណាមួយឡើយ ។

ហេតុនេះហើយ បើព្រះករុណាអង្គណា មានត្រៃចីវរទុព្វលភាពដាច់ដាច មិនអាចនឹងប្រើប្រាស់បាន ហើយចេះនូវ **អានិសង្ស៥** នូវ **មាតិកា៨ បលិពោធ២ អនត្ថការៈ២៤ អត្ថាការៈ១៧** អាច

ញ៉ាំងសង្ឃឱ្យត្រេកអរដោយ**កឋិនត្ថារកិច្ច**បាន ក៏សូមមានព្រះថេរដីកាឆ្លើយមកចុះ, ព្រះសង្ឃនឹងអបលោកន៍សំពត់កឋិននេះ ដល់ព្រះករុណាអង្គនោះ ដោយ **ញត្តិទុតិយកម្មវាចា** ក្រាលគ្រងតទៅ ។

*(ភិក្ខុទី១ ប្រកាសសង្ឃចប់ហើយ ត្រូវឈប់បង្អង់ ២-៣ នាទីសិន សឹមភិក្ខុទី២ ប្រកាសសង្ឃតទៅទៀត)* ។

## ☸ វារៈទី២ ☸

**ភន្តេ** បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន, ខ្ញុំព្រះករុណាជាអ្នកតំណាងព្រះសង្ឃគ្រប់អង្គ ក្នុងឱកាសនេះ សូមពិត្រព្រះសង្ឃដីកាចំពោះព្រះសង្ឃគ្រប់អង្គ សូមទានជ្រាប!

យើងខ្ញុំទាំងអស់អង្គ សុទ្ធសឹងមានត្រៃចីវរល្មមគ្រប់គ្រាន់ប្រើប្រាស់ហើយ, ប៉ុន្តែ តាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញថា មានតែលោកម្ចាស់......................... ទើបសមគួរនឹងក្រាលគ្រងនូវសំពត់កឋិននេះ ដោយលោកជាអ្នកចេះនូវ**អានិសង្ស៥** ចាំនូវ**មាតិកា៨ បលិពោធ២ អនត្ថារៈ២៤ អត្ថារាការៈ១៧** ហើយឆ្លៀវឆ្លាតក្នុងកឋិនត្ថារកិច្ច អាចញ៉ាំងសង្ឃឱ្យត្រេកអរបាន ។

ហេតុនេះហើយ បើព្រះសង្ឃគ្រប់អង្គយល់ឃើញថា សមគួរដូចជាបកាសនវាចា ដែលខ្ញុំព្រះករុណាបានថ្លែងមកនេះ ក៏សូមបញ្ចេញនូវសទ្ទសញ្ញាថា **សាធុ** ឱ្យព្រមៗគ្រប់ព្រះអង្គទៅហោង ៕

# បាលីសម្រាប់សូត្រក្នុងកឋិនកម្ម

**សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ *ឯសា ញត្តិ* ។**

**សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ឥត្ថន្នាមស្ស ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ, សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ[២] ឥត្ថន្នាមស្ស ភិក្ខុនោ កឋិនំ អត្ថរិតុំ ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។**

បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន! សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ, សំពត់កឋិននេះ កើតឡើងដល់សង្ឃហើយ ។ បើ(ការនេះ) មានការគួរដល់សង្ឃហើយ សង្ឃគួរឱ្យសំពត់កឋិននេះទៅភិក្ខុ (ឈ្មោះនេះ...) ដើម្បីក្រាលកឋិន ។ *នេះជាពាក្យផ្សេង* ។

---

(១) បាលីថា **ឥត្ថន្នាមស្ស** នេះត្រូវផ្លាស់ដាក់តាមនាមរបស់ភិក្ខុអ្នកក្រាលឱ្យរាល់បទ ។

(២) បាលីថា **ចីវរំ ទុស្សំ វត្ថំ** ប្រែថាសំពត់ដូចគ្នា ។

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន! សូមព្រះសង្ឃស្តាប់ខ្ញុំ, សំពត់កឋិននេះ កើតឡើងដល់ព្រះសង្ឃហើយ ។ (ឥឡូវ)សង្ឃឱ្យសំពត់នេះទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន ការដែលឱ្យសំពត់កឋិនទៅភិក្ខុឈ្មោះនេះដើម្បីក្រាលកឋិន គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម, មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង ។ សំពត់កឋិននេះ សង្ឃឱ្យទៅភិក្ខុ(ឈ្មោះនេះ)ហើយ ដើម្បីក្រាលកឋិន ។ (ការនេះ)គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវការនេះ ដោយភាពដែលសង្ឃស្ងៀម យ៉ាងនេះ ។

(កាលបើសង្ឃសូត្រប្រគល់សំពត់កឋិន ដោយញត្តិទុតិយកម្មវាចា ដូច្នេះហើយ, បើសំពត់កឋិននោះ ទាយកធ្វើបរិកម្មសម្រេចមកជាស្បង់ចីពរសង្ឃាដិរួចហើយ ភិក្ខុត្រូវការក្រាលដោយស្បង់ ឬ ចីពរ ឬ សង្ឃាដិ គប្បី**បច្ចុទ្ធរ៍** ដកស្បង់ ចីពរ សង្ឃាដិចាស់ចេញ ហើយធ្វើ**កប្បពិន្ទុអធិដ្ឋាន**ស្បង់ ចីពរ សង្ឃាដិ ថ្មីឡើង ។

# កប្បពិន្ទុអធិដ្ឋាន

## **ពិធី**ដក ដូច្នេះ

- ដក **សង្ឃាដិ** ថាៈ

**ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ** អាត្មាអញដកនូវ**សង្ឃាដិ**នេះ,

- ដក **ឧត្តរាសង្គៈ** ( ចីពរ ) ថាៈ

**ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ** អាត្មាអញដកនូវ**ឧត្តរាសង្គៈ** ( ចីពរ )នេះ,

- ដក **អន្តរវាសកៈ** ( ស្បង់ ) ថាៈ

**ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ** អាត្មាអញដកនូវ**ស្បង់**នេះ,

ដកចីពរ ស្បង់ សង្ឃាដិ រួចហើយ ត្រូវធ្វើ**កប្បពិន្ទុ**ចីវរថ្មី ដែលបម្រុងក្រាលកឋិននោះ ត្រង់ជ្រុង ឬ មុមចីវរ ដោយពណ៌ ៣ យ៉ាង ពណ៌ណាមួយ ដែលមានសម្តែងក្នុងសិក្ខាបទស្រាប់ ។

## **ឯពិធីពិន្ទុកប្ប** ដូច្នេះ

**ឥមំ ពិន្ទុកប្បំ ករោមិ** អាត្មាអញធ្វើនូវ**ពិន្ទុកប្ប**នេះ ។

( តពីនេះ ត្រូវអធិដ្ឋានចីវរថ្មីឡើង ) ពិធីអធិដ្ឋាននោះ ដូច្នេះ ៖

- អធិដ្ឋាន **សង្ឃាដិ** ថាៈ

**ឥមំ សង្ឃាដឹ អធិដ្ឋាមិ ។** ***ទុតិយម្បិ ។ តតិយម្បិ ។*** អាត្មាអញអធិដ្ឋាននូវ **សង្ឃាដិ** នេះ ។

*អស់វារៈពីរដង៏ផង, អស់វារៈបីដង៏ផង ។*

- អធិដ្ឋាន **ឧត្តរាសង្គៈ** ( ចីពរ ) ថា:

**ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។ *ទុតិយម្បិ ។ តតិយម្បិ ។***

អាត្មាអញអធិដ្ឋាននូវ **ឧត្តរាសង្គៈ** នេះ ។

*អស់វារៈពីរដងផង, អស់វារៈបីដងផង ។*

- អធិដ្ឋាន **អន្តរវាសកៈ** ( ស្បង់ ) ថា:

**ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។ *ទុតិយម្បិ ។ តតិយម្បិ ។***

អាត្មាអញអធិដ្ឋាននូវ **អន្តរវាសកៈ** នេះ ។

*អស់វារៈពីរដងផង, អស់វារៈបីដងផង ។*

កាលបើធ្វើអធិដ្ឋានរួចហើយ ត្រូវក្រាលកឋិនដោយចីវរណាមួយតាមត្រូវការ ហើយគប្បីបញ្ចេញវាចាឱ្យជំនុំសង្ឃបានឮច្បាស់ ។

- បើចង់ក្រាលដោយ **សង្ឃាដិ** ថា :

**ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ**, ខ្ញុំក្រាលកឋិនដោយ **សង្ឃាដិ** នេះ ។

- បើចង់ក្រាលដោយ **ឧត្តរាសង្គៈ** ( ចីពរ ) ថា :

**ឥមានិ ឧត្តរាសង្គេន កឋិនំ អត្ថរាមិ**, ខ្ញុំក្រាលកឋិនដោយ **ឧត្តរាសង្គៈ**( ចីពរ ) នេះ ។

- បើចង់ក្រាលដោយ **អន្តរវាសកៈ** ( ស្បង់ ) ថា :

**ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ**, ខ្ញុំក្រាលកឋិនដោយ **អន្តរាវាសកៈ** (ស្បង់) នេះ ។

កាលបើភិក្ខុបានក្រាលកឋិនតាមបែបនេះរួចហើយ ត្រូវចូលទៅជិតសង្ឃ ឬគណៈ ឬបុគ្គល គ្រងចីពរ អង្គុយច្រហោង ប្រណម្យអញ្ជលីឡើង ពោលប្រាប់ឱ្យលោកទាំងនោះ **អនុមោទនា** ថា **អត្ថតំ អាវុសោ**[១] **សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ** ម្នាលលោកដ៏មានអាយុ កឋិនរបស់សង្ឃ ខ្ញុំក្រាលរួចហើយ, ការក្រាលកឋិន(នុ៎ះ)ប្រកបដោយធម៌ សូមលោកទាំងឡាយ **អនុមោទនា**ចុះ ។

ចំណែកខាង **ភិក្ខុអ្នកអនុមោទនា**វិញ ត្រូវគ្រងចីពរស្ពាយម្ខាង អង្គុយច្រហោង ប្រណម្យអញ្ជលីឡើង ពោលអនុមោទនាថាៈ

**អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម**! បពិត្រលោកម្ចាស់ដ៏ចម្រើន! កឋិនរបស់សង្ឃលោកក្រាលរួចហើយ, ការក្រាលកឋិន(នុ៎ះ)ប្រកបដោយធម៌ យើងសូម**អនុមោទនា**!

<u>**អនុមោទនា** មួយបែបទៀត ក៏បានៈ</u>

---

[១] បើភិក្ខុអ្នកក្រាល ខ្ចីជាង ត្រូវថា **ភន្តេ** ប្រែថា បពិត្រលោកទាំងឡាយ ដ៏ចម្រើន ។

**អត្ថតំ ភន្តេ[១] សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទនាម[២]!**

បពិត្រ[៣] ព្រះករុណាដ៏ចម្រើន កឋិនរបស់សង្ឃ ដែលសង្ឃបានឱ្យហើយដល់លោក ៗ បានក្រាលហើយ កឋិនដែលលោកបានក្រាលហើយនេះ ជាធម៌សមគួរតាមពុទ្ធានុញ្ញាត, ខ្ញុំសូម**អនុមោទនា** គឺថា **ត្រេកអរតាម** នូវកឋិន ។

**វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ**
**បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។**

*ចិត្តនេះ ដែលបុគ្គលលើកឡើងចាកអាល័យ គឺកាមគុណ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រដូចត្រី ដែលគេលើកឡើងចាកទីនៅ គឺទឹក បោះទៅលើគោកដូច្នោះឯង ។*

(ស្រង់ចាកគាថាធម្មបទ គាថាទី ៣៤ **ចិត្តវគ្គ**)

---

(១) បើភិក្ខុអ្នកអនុមោទនា ចាស់ជាង ត្រូវថា **អាវុសោ** ប្រែថា ម្នាលលោកដ៏មានអាយុ ។

(២) បើភិក្ខុតែមួយរូបអនុមោទនាថា **អនុមោទនាមិ** ខ្ញុំសូមអនុមោទនា ។

(៣) ប្រែនេះគឺប្រែសម្រួលសេចក្តីបើភិក្ខុគាប់ចិត្តយកតាមបែបណាក៏គប្បីយកតាមបែបនោះចុះ,

# ព្រះត្រៃបិដកសង្ខេប

អំពីនេះ នឹងសម្ដែងបាឋ ព្រះវិន័យ ព្រះសូត្រ ព្រះបរមត្ថសង្ខេប ដែលលោករួមទុកឱ្យព្រះសង្ឃសូធ្យ ក្នុងកាលចប់សង្គីតិទេសនានោះ តាមលំដាប់តទៅ ៖

## ព្រះវិន័យ

**យេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយំ បញ្ញត្តន្តិ ។ កំ អារព្ភាត ។ សុទិន្នំ កលន្ទបុត្តំ អារព្ភាត ។ កស្មឹ វត្ថុស្មិន្តិ ។ សុទិន្នោ កលន្ទបុត្តោ បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវ តស្មឹ វត្ថុស្មិន្តិ ។**

**តេន សមយេ ពុទ្ធោ ភគវា វេរញ្ជាយំ វិហរត ន-ឡេរុបុចិមន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ អស្សោសិ ខោ វេរញ្ជោ ព្រាហ្មណោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ វេរញ្ជាយំ វិហរត នឡេរុបុចិមន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ តំ ខោ បន ភគវន្តំ**

គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

# ព្រះសូត្រ

ឯវម្មេ សុតំ ឯកំ សមយំ ភគវា អន្តរា ច រាជគ្គហំ អន្តរា ច នាលន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ សុប្បិយោបិ ខោ បរិព្វាជកោ អន្តរា ច រាជគ្គហំ អន្តរា ច នាលន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ សទ្ធឹ អន្តេវាសិនា ព្រហ្មទត្តេន មាណវេន ។ តត្រ សុទំ សុប្បិយោ បរិព្វាជកោ អនេកបរិយាយេន ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស

អវណ្ណំ ភាសត ។ សុប្បិយស្ស បន បរិព្វាជកស្ស អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសត ធម្មស្ស វណ្ណំ ភាសត សង្ឃស្ស វណ្ណំ ភាសត ។ ឥតិហ តេ ឧភោ អាចរិយន្តេវាសី អញ្ញមញ្ញស្ស ឧជុវបច្ច-និកវាទា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា ហោន្តិ ភក្ខុសង្ឃញ្ច ។

# ព្រះអភិធម្ម

## ☸ ធម្មសង្គណី :

កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ។ កតមេ ធម្មា កុសលា ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោត សោមនស្សសហគតំ ញាណសម្បយុត្តំ រូបារម្មណំ វា សទ្ទារម្មណំ វា គន្ធារម្មណំ វា រសារម្មណំ វា ផោដ្ឋព្វារម្មណំ វា ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោត អវក្ខេបោ ហោត ។ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា កុសលា ។

☸ **វិភង្គ** : បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។ តត្ថ កតមោ រូបក្ខន្ធោ ។ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ ។

☸ **ធាតុកថា** : សង្គហោ អសង្គហោ ។ សង្គហិតេន អសង្គហិតំ អសង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន អសង្គហិតំ ។ សម្បយោគោ វិប្បយោគោ ។ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ អសង្គហិតំ ។

☸ **បុគ្គលបញ្ញត្តិ** : ឆ បញ្ញត្តិយោ ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តិ ។ កិត្តាវតា បុគ្គលានំ បុគ្គលប្បញ្ញត្តិ ។ សមយវិមុត្តោ អសមយវិមុត្តោ កុប្បធម្មោ អកុប្បធម្មោ បរិហានធម្មោ អបរិហានធម្មោ ចេតនាភព្វោ អនុរក្ខនាភព្វោ បុថុជ្ជនោ គោត្រភូ ភយូបរតោ អភយូបរតោ ភព្វាគមនោ អភព្វាគមនោ និយតោ អនិយតោ បដិបន្នកោ ផលេ ឋិតោ អរហា អរហត្តាយ បដិបន្នោ ។

☸ **កថាវត្ថុ** : បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ ។ អាមន្តា ។ យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ

សច្ចិកដ្ឋបរមត្ថេនាតិ ។ ន ហេវំ វត្តព្វេ ។ អាជានាហិ និគ្គហំ ហញ្ចិ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេន តេន វត រេ វត្តព្វេ យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ ។ មិច្ឆា ។

☸ **យមក** : យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា ។ យេ វា បន កុសលមូលា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលា ។ យេ វា បន កុសលមូលេន ឯកមូលា សព្វេ តេ ធម្មា កុសលា ។

☸ **មហាបដ្ឋាន** : ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ ។

*(ព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម សង្ខេប ចប់តែប៉ុណ្ណេះ)*

# សត្តប្បករណាភិធម្ម

## សំ. វិ. ធា. បុ. ក. យ. ប.

## (ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលបញ្ញត្តិ កថាវត្ថុ យមក បដ្ឋាន)

# អភិធម្មបិដកធម្មសង្គណី

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង) ។**

សូមនមស្ការ ចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ដោយគោរព !

## តិកមាតិកា

**១. កុសលា ធម្មា, អកុសលា ធម្មា, អព្យាកតា ធម្មា,**

**២. សុខាយ វេទនាយ សម្បយុត្តា ធម្មា, ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា, អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា,**

**៣. វិបាកា ធម្មា, វិបាកធម្មធម្មា, នេវវិបាកនវិបាកធម្ម ធម្មា,**

**៤. ឧបាទិន្នុបាទានិយា ធម្មា, អនុបាទិន្នុបាទានិយា ធម្មា, អនុបាទិន្នានុបាទានិយា ធម្មា,**

**៥. សង្កិលិដ្ឋសង្កិលេសិកា ធម្មា, អសង្កិលិដ្ឋសង្កិលេសិកា ធម្មា, អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា,**

៦. សវិតក្កសវិចារា ធម្មា, អវិតក្កវិចារមត្តា ធម្មា, អវិតក្កាវិចារា ធម្មា,

៧. បីតិសហគតា ធម្មា, សុខសហគតា ធម្មា, ឧបេក្ខា-សហគតា ធម្មា,

៨. ទស្សនេន បហាតព្វា ធម្មា, ភាវនាយ បហាតព្វា ធម្មា, នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា,

៩. ទស្សនេន បហាតព្វហេតុកា ធម្មា, ភាវនាយ បហាតព្វ-ហេតុកា ធម្មា, នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា,

១០. អាចយគាមិនោ ធម្មា, អបចយគាមិនោ ធម្មា, នេវាចយគាមិនោ នាបចយគាមិនោ ធម្មា,

១១. សេក្ខា ធម្មា, អសេក្ខា ធម្មា, នេវសេក្ខា នាសេក្ខា ធម្មា,

១២. បរិត្តា ធម្មា, មហគ្គតា ធម្មា, អប្បមាណា ធម្មា,

១៣. បរិត្តារម្មណា ធម្មា, មហគ្គតារម្មណា ធម្មា, អប្បមា-ណារម្មណា ធម្មា,

១៤. ហីនា ធម្មា, មជ្ឈិមា ធម្មា, បណីតា ធម្មា,

១៥. មិច្ឆត្តនិយតា ធម្មា, សម្មត្តនិយតា ធម្មា, អនិយតា ធម្មា,

១៦. មគ្គារម្មណា ធម្មា, មគ្គហេតុកា ធម្មា, មគ្គាធិបតិនោ ធម្មា,

១៧. ឧប្បន្នា ធម្មា, អនុប្បន្នា ធម្មា, ឧប្បាទិនោ ធម្មា,

១៨. អតីតា ធម្មា, អនាគតា ធម្មា, បច្ចុប្បន្នា ធម្មា,

១៩. អតីតារម្មណា ធម្មា, អនាគតារម្មណា ធម្មា, បច្ចុប្បន្នា-រម្មណា ធម្មា,

២០. អជ្ឈត្តា ធម្មា, ពហិទ្ធា ធម្មា, អជ្ឈត្តពហិទ្ធា ធម្មា,

២១. អជ្ឈត្តារម្មណា ធម្មា, ពហិទ្ធារម្មណា ធម្មា, អជ្ឈត្ត-ពហិទ្ធារម្មណា ធម្មា,

២២. សនិទស្សនសប្បដិឃា ធម្មា, អនិទស្សនសប្បដិឃា ធម្មា, អនិទស្សនាប្បដិឃា ធម្មា ។

(ពាវីសតិ តិកមាតិកា ធម្មសង្គណិប្បករណំ នាម សមត្តំ)

## ប្រែ : ធម្មសង្គណី

១).. កុសលា ធម្មា, អកុសលា ធម្មា, អព្យាកតា ធម្មា,
ពួកធម៌ជាកុសល, ពួកធម៌ជាអកុសល, ពួកធម៌ជាអព្យាក្រឹត,

២).. សុខាយ វេទនាយ សម្បយុត្តា ធម្មា, ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា, អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា, ពួកធម៌ប្រកបដោយសុខវេទនា, ពួកធម៌

ប្រកបដោយទុក្ខវេទនា, ពួកធម៌ប្រកបដោយវេទនា មិនជាទុក្ខ មិនជាសុខ,

៣).. **វិបាកា ធម្មា, វិបាកធម្មធម្មា, នេវ វិបាកនវិបាក-ធម្មធម្មា,** ពួកធម៌ជាវិបាក, ពួកធម៌មានវិបាកជាប្រក្រតី, ពួកធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតី,

៤).. **ឧបាទិន្នុបាទានិយា ធម្មា, អនុបាទិន្នុបាទានិយា ធម្មា, អនុបាទិន្នានុបាទានិយា ធម្មា,** ពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ; *ពួកធម៌មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើម មិនកាន់យកទេ តែជាប្រយោជន៍ដល់ឧបាទាន ;* ពួកធម៌ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនទាន់កាន់យកទេ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ;

៥).. **សង្កិលិដ្ឋសង្កិលេសិកា ធម្មា, អសង្កិលិដ្ឋសង្កិលេសិកា ធម្មា, អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា,** ពួកធម៌ ដែលសៅហ្មង ទាំងគួរដើម្បីដល់នូវសេចក្តីសៅហ្មង ; *ពួកធម៌ ដែលមិនសៅហ្មង តែគួរដើម្បីដល់នូវសេចក្តីសៅហ្មង ;* ពួកធម៌ ដែលមិនសៅហ្មង ទាំងមិនគួរដើម្បីដល់នូវសេចក្តីសៅហ្មង ;

៦).. **សវិតក្កសវិចារា ធម្មា, អវិតក្កវិចារមត្តា ធម្មា, អវិតក្កាវិចារា ធម្មា,** ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកប

ដោយវិចារៈ ; *ពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ ;* ពួកធម៌គ្មានវិតក្កៈ ទាំងគ្មានវិចារៈ ;

៧).. **បីតិសហគតា ធម្មា, សុខសហគតា ធម្មា, ឧបេក្ខា-សហគតា ធម្មា,** ពួកធម៌ ប្រកបដោយបីតិ ; *ពួកធម៌ប្រកបដោយសុខៈ ;* ពួកធម៌ ប្រកបដោយឧបេក្ខា ;

៨).. **ទស្សនេន បហាតព្វា ធម្មា, ភាវនាយ បហាតព្វា ធម្មា, នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា,** ពួកធម៌ដែលត្រូវលះដោយទស្សនៈ ; *ពួកធម៌ដែលត្រូវលះដោយភាវនា ;* ពួកធម៌ ដែលមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយ ភាវនា ;

៩).. **ទស្សនេន បហាតព្វហេតុកា ធម្មា, ភាវនាយ បហា--តព្វហេតុកា ធម្មា, នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា,** ពួកធម៌មានហេតុ ដែលត្រូវលះដោយទស្សនៈ ; *ពួកធម៌មានហេតុ ដែលត្រូវលះដោយភាវនា ;* ពួកធម៌មានហេតុ ដែលមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយ ភាវនា ;

១០).. **អាចយគាមិនោ ធម្មា, អបចយគាមិនោ ធម្មា, នេវាចយគាមិនោ នាបចយគាមិនោ ធម្មា,** ពួកធម៌ដល់នូវការសន្សំ កពូនឡើងដោយកម្មក្កិលេស ; *ពួកធម៌ មិនដល់នូវ*

*ការសន្សំកពូនឡើងដោយកម្មក្កិលេស*; ពួកធម៌ មិនមែនជាដល់នូវការសន្សំពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំ កពូនឡើងដោយកម្មក្កិលេស ;

១១)..**សេក្ខា ធម្មា, អសេក្ខា ធម្មា, នេវសេក្ខា នាសេក្ខា ធម្មា**, ពួកធម៌ជារបស់សេក្ខបុគ្គល; *ពួកធម៌ជារបស់អសេក្ខបុគ្គល;* ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ;

១២)..**បរិត្តា ធម្មា, មហគ្គតា ធម្មា, អប្បមាណា ធម្មា**, ពួកធម៌មានសភាពដ៏តូចឆ្មារ ; *ពួកធម៌ដល់នូវសភាពដ៏ធំ* ; ពួកធម៌មានប្រមាណមិនបាន ;

១៣)..**បរិត្តារម្មណា ធម្មា, មហគ្គតារម្មណា ធម្មា, អប្បមា--ណារម្មណា ធម្មា**, ពួកធម៌ មានអារម្មណ៍តូចឆ្មារ ; *ពួកធម៌មានអារម្មណ៍ដល់នូវសភាពដ៏ធំ* , ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន,

១៤)..**ហីនា ធម្មា, មជ្ឈិមា ធម្មា, បណីតា ធម្មា**, ពួកធម៌ថោកទាប, ពួកធម៌ជាកណ្តាល, ពួកធម៌ដ៏ឧត្តម ;

១៥)..**មិច្ឆត្តនិយតា ធម្មា, សម្មត្តនិយតា ធម្មា, អនិយតា ធម្មា**, ពួកធម៌ មានសភាពដ៏ខុស និង ទៀង, *ពួកធម៌ មានសភាពដ៏ត្រូវ និង ទៀង*, ពួកធម៌ មិនទៀង ;

១៦).. **មគ្គារម្មណា ធម្មា, មគ្គហេតុកា ធម្មា, មគ្គាធិបតិ--នោ ធម្មា,** ពួកធម៌ មានមគ្គជាអារម្មណ៍, *ពួកធម៌ មានមគ្គជាហេតុ*, ពួកធម៌ មានមគ្គជាអធិបតី ;

១៧).. **ឧប្បន្នា ធម្មា, អនុប្បន្នា ធម្មា, ឧប្បាទិនោ ធម្មា,** ពួកធម៌ ដែលកើតឡើងហើយ, *ពួកធម៌ ដែលមិនទាន់កើតឡើង* , ពួកធម៌ ដែលប្រុងនឹងកើតឡើង ;

១៨).. **អតីតា ធម្មា, អនាគតា ធម្មា, បច្ចុប្បន្នា ធម្មា,** ពួកធម៌ជាអតីត, ពួកធម៌ជាអនាគត, ពួកធម៌ជាបច្ចុប្បន្ន ;

១៩).. **អតីតារម្មណា ធម្មា, អនាគតារម្មណា ធម្មា, បច្ចុប្បន្នា-រម្មណា ធម្មា,** ពួកធម៌មានអារម្មណ៍ជាអតីត, ពួកធម៌មានអារម្មណ៍ជាអនាគត, ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ;

២០).. **អជ្ឈត្តា ធម្មា, ពហិទ្ធា ធម្មា, អជ្ឈត្តពហិទ្ធា ធម្មា,** ពួកធម៌ជាខាងក្នុង, ពួកធម៌ជាខាងក្រៅ, ពួកធម៌ជាខាងក្នុង និង ខាងក្រៅ ;

២១).. **អជ្ឈត្តារម្មណា ធម្មា, ពហិទ្ធារម្មណា ធម្មា, អជ្ឈត្ត--ពហិទ្ធារម្មណា ធម្មា,** ពួកធម៌មានអារម្មណ៍ជាខាងក្នុង, ពួកធម៌មានអារម្មណ៍ជាខាងក្រៅ, ពួកធម៌មានអារម្មណ៍ជាខាងក្នុង និង ខាងក្រៅ ;

២២).. **សនិទស្សនសប្បដិឃា ធម្មា, អនិទស្សនសប្បដិឃា ធម្មា, អនិទស្សនាប្បដិឃា ធម្មា,** ពួកធម៌ប្រកបដោយការឃើញ និង ប្រកបដោយការប៉ះពាល់ , ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ , ពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ;

**(ពាវីសតិ តិកមាតិកា ធម្មសង្គណិប្បករណំ នាម សមត្តំ)**

(គម្ពីរឈ្មោះ **ធម្មសង្គណី** ដែលមានមាតិកា ២២ ចប់តែប៉ុណ្ណេះ )

## ទុកមាតិកា

១).. (១) **ហេតូ ធម្មា, ន ហេតូ ធម្មា,**
ពួកធម៌ជាហេតុ, ពួកធម៌មិនមែនជាហេតុ,

២).. (២) **សហេតុកា ធម្មា, អហេតុកា ធម្មា,** ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ, ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ,

៣).. (៣) **ហេតុសម្បយុត្តា ធម្មា, ហេតុវិប្បយុត្តា ធម្មា,** ពួកធម៌ប្រកបដោយហេតុ, ពួកធម៌ប្រាសចាកហេតុ,

៤).. (៤) **ហេតូ ចេវ ធម្មា សហេតុកា ច សហេតុកា ចេវ ធម្មា ន ច ហេតូ** ពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង, ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ,

៥)..- (៥) **ហេតូ ចេវ ធម្មា ហេតុសម្បយុត្តា ច ហេតុ-សម្បយុត្តា ចេវ ធម្មា ន ច ហេតូ** ពួកធម៌ ជាហេតុផង ប្រកបដោយហេតុផង, ពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ,

៦)..- (៦) **ន ហេតូ ខោ បន ធម្មា សហេតុកាបិ អហេតុ-កាបិ** ពួកធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ, ពួកធម៌មិនមែនជាហេតុផង មិនប្រព្រឹត្តទៅជាមួយនឹងហេតុផង ។

( **ហេតុគោច្ឆកំ** ចប់ពួកហេតុតែប៉ុណ្ណេះ )

៧)..- (១) **សប្បច្ចយា ធម្មា, អប្បច្ចយា ធម្មា** ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ, ពួកធម៌មិនមានបច្ច័យ ;

៨)..- (២) **សង្ខតា ធម្មា, អសង្ខតាធម្មា** ពួកធម៌មានបច្ច័យតាក់តែង, ពួកធម៌មិនមានបច្ច័យតាក់តែង ;

៩)..- (៣) **សនិទស្សនា ធម្មា, អនិទស្សនា ធម្មា** ពួកធម៌ប្រកបដោយការឃើញ, ពួកធម៌មិនប្រកបដោយការឃើញ ;

១០)..- (៤) **សប្បដិឃា ធម្មា, អប្បដិឃា ធម្មា** ពួកធម៌ប្រកបដោយការប៉ះពាល់, ពួកធម៌មិនប្រកបដោយការប៉ះពាល់ ;

១១)..- (៥) **រូបិនោ ធម្មា, អរូបិនោ ធម្មា** ពួកធម៌មានរូប, ពួកធម៌មិនមានរូប ;

១២).- (៦) **លោកិយា ធម្មា លោកុត្តរា ធម្មា** ពួកធម៌ជាលោកិយ, ពួកធម៌ជាលោកុត្តរៈ ;

១៣).- (៧) **កេនចិ វិញ្ញេយ្យា ធម្មា កេនចិ ន វិញ្ញេយ្យា ធម្មា** ពួកធម៌ ដែលគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ (មានចក្ខុវិញ្ញាណជាដើម), ពួកធម៌ដែលមិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ;

**(ចូឡន្តរទុកំ** ចប់ចូឡន្តរទុកៈតែប៉ុណ្ណេះ) ។

១៤).- (១) **អាសវា ធម្មា នោ អាសវា ធម្មា** ពួកធម៌ជាអាសវៈ, ពួកធម៌មិនមែនជាអាសវៈ ;

១៥).- (២) **សាសវា ធម្មា, អនាសវា ធម្មា** ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ, ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ ;

១៦).- (៣) **អាសវសម្បយុត្តា ធម្មា, អាសវវិប្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយអាសវៈ, ពួកធម៌មិនប្រកបដោយអាសវៈ;

១៧).- (៤) **អាសវា ចេវ ធម្មា សាសវា ច សាសវា ចេវ ធម្មា នោ ច អាសវា** ពួកធម៌ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង, ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ;

១៨).- (៥) **អាសវា ចេវ ធម្មា អាសវសម្បយុត្តា ច អាសវសម្បយុត្តា ចេវ ធម្មា នោ ច អាសវា** ពួកធម៌ ជា

អាសវៈផង ប្រកបដោយអាសវៈផង, ពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ;

១៩).- (៦) **អាសវវិប្បយុត្តា ខោ បន ធម្មា សាសវាបិ អនាសវាបិ** ពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ, ពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ;

**(អាសវគោច្ឆកំ ចប់ពួកអាសវៈតែប៉ុណ្ណេះ)**

២០).- (១) **សញ្ញោជនា ធម្មា នោ សញ្ញោជនា ធម្មា** ពួកធម៌ជាសញ្ញោជនៈ[១], ពួកធម៌មិនមែនជាសញ្ញោជនៈ ;

២១).- (២) **សញ្ញោជនិយា ធម្មា អសញ្ញោជនិយា ធម្មា** ពួកធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ, ពួកធម៌មិនជាប្រយោជន៍ដល់សញ្ញោជនៈ;

២២).- (៣) **សញ្ញោជនសម្បយុត្តា ធម្មា សញ្ញោជនវិប្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយសញ្ញោជនៈ, ពួកធម៌ប្រាសចាកសញ្ញោជនៈ;

---

[១] ធម៌ប្រកបសត្វទុកក្នុងវដ្តៈ ។

២៣).- (៤) **សញ្ញោជនា ចេវ ធម្មា សញ្ញោជនិយា ច សញ្ញោជនិយា ចេវ ធម្មា នោ ច សញ្ញោជនា** ពួកធម៌ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង, ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ;

២៤).- (៥) **សញ្ញោជនា ចេវ ធម្មា សញ្ញោជនសម្បយុត្តា ច សញ្ញោជនសម្បយុត្តា ចេវ ធម្មា នោ ច សញ្ញោជនា** ពួកធម៌ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង, ពួកធម៌គ្រាន់តែជាប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ;

២៥).- (៦) **សញ្ញោជនវិប្បយុត្តា ខោ បន ធម្មា សញ្ញោជនិយាបិ អសញ្ញោជនិយាបិ** ពួកធម៌ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ, ពួកធម៌ ប្រាសចាកសញ្ញោជនៈផង មិនជាប្រយោជន៍ដល់សញ្ញោជនៈផង ;

( **សញ្ញោជនគោច្ឆកំ** ចប់ពួកសញ្ញោជនៈតែប៉ុណ្ណេះ ) ។

២៦).- (១) **គន្ថា ធម្មា, នោ គន្ថា ធម្មា** ពួកធម៌ជាគន្ថៈ[១] ,ពួកធម៌ ពួកធម៌ មិនមែនជាគន្ថៈ ;

---

(១) ធម៌ដោតក្រងសត្វទុកក្នុងវដ្តៈ ដោយអំណាចចុតិ និង បដិសន្ធិ ។

២៧)._ (២) **គន្ថនិយា ធម្មា, អគន្ថនិយា ធម្មា** ពួកធម៌ដែលគន្ថៈ គប្បីដោតក្រង , ពួកធម៌ដែលគន្ថៈ មិនគប្បីដោតក្រង ;

២៨)._ (៣) **គន្ថសម្បយុត្តា ធម្មា, គន្ថវិប្បយុត្តា ធម្មា** ពួកធម៌ ប្រកបដោយគន្ថៈ, ពួកធម៌ប្រាសចាកគន្ថៈ ;

២៩)._ (៤) **គន្ថា ចេវ ធម្មា គន្ថនិយា ច គន្ថនិយា ចេវ ធម្មា នោ ច គន្ថា** ពួកធម៌ជាគន្ថៈផង ដែលគន្ថៈគប្បីដោត ក្រងផង, ពួកធម៌ដែលគន្ថៈគប្បីដោតក្រង តែមិនមែនជាគន្ថៈ ;

៣០)._ (៥) **គន្ថា ចេវ ធម្មា គន្ថសម្បយុត្តា ច គន្ថសម្បយុត្តា ចេវ ធម្មា នោ ច គន្ថា** ពួកធម៌ជាគន្ថៈផង ប្រកបដោយគន្ថៈ ផង, ពួកធម៌គ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈ ;

៣១)._ (៦) **គន្ថវិប្បយុត្តា ខោ បន ធម្មា គន្ថនិយាបិ អគន្ថនិយាបិ** ពួកធម៌ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងៈ, ពួកធម៌ ប្រាសចាកគន្ថៈផង ដែលគន្ថៈមិនគប្បីដោតក្រងផង ;

( **គន្ថគោច្ឆកំ** ចប់ពួកគន្ថៈតែប៉ុណ្ណោះ ) ។

៣២)._ (១) **ឱឃា ធម្មា នោ ឱឃា ធម្មា** ពួកធម៌ជាឱឃៈ[១], ពួកធម៌ មិនមែនជាឱឃៈ ;

---

[១] ធម៌ញ៉ាំងសត្វឱ្យលិចនៅក្នុងវដ្តៈ ។

៣៣).- (២) **ឱឃនិយា ធម្មា អនោឃនិយា ធម្មា** ពួកធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លង , ពួកធម៌ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ;

៣៤).- (៣) **ឱឃសម្បយុត្តា ធម្មា, ឱឃវិប្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយឱឃៈ, ពួកធម៌ប្រាសចាកឱឃៈ ;

៣៥).- (៤) **ឱឃា ចេវ ធម្មា ឱឃនិយា ច ឱឃនិយា ចេវ ធម្មា នោ ច ឱឃា** ពួកធម៌ជាឱឃៈផង ដែលឱឃៈគប្បីប្រព្រឹត្តកន្លងផង, ពួកធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លងតែមិនមែនជាឱឃៈ;

៣៦).- (៥) **ឱឃា ចេវ ធម្មា ឱឃសម្បយុត្តា ច ឱឃសម្បយុត្តា ចេវ ធម្មា នោ ច ឱឃា** ពួកធម៌ជាឱឃៈផង ប្រកបដោយឱឃៈផង, ពួកធម៌គ្រាន់តែប្រកបដោយឱឃៈ តែមិនមែនជាឱឃៈ;

៣៧).- (៦) **ឱឃវិប្បយុត្តា ខោ បន ធម្មា ឱឃនិយាបិ អនោឃនិយាបិ** ពួកធម៌ប្រាសចាកឱឃៈ តែដែលឱឃៈគប្បីប្រព្រឹត្តកន្លង, ពួកធម៌ប្រាសចាកឱឃៈផង ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងផង ;

( **ឱឃគោច្ឆកំ** ចប់ពួកឱឃៈ តែប៉ុណ្ណេះ ) ។

៣៨)..- (១) **យោគា ធម្មា នោ យោគា ធម្មា** ពួកធម៌ជាយោគៈ[១] , ពួកធម៌មិនមែនជាយោគៈ ;

៣៩)..- (២) **យោគនិយា ធម្មា អយោគនិយា ធម្មា** ពួកធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លង, ពួកធម៌ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង;

៤០)..- (៣) **យោគសម្បយុត្តា ធម្មា, យោគវិប្បយុត្តា ធម្មា** ពួកធម៌ដែលប្រកបដោយយោគៈ, ពួកធម៌ដែលប្រាសចាកយោគៈ ;

៤១)..- (៤) **យោគា ចេវ ធម្មា យោគនិយា ច យោគនិយា ចេវ ធម្មា នោ ច យោគា** ពួកធម៌ជាយោគៈផង ដែលយោគៈគប្បីប្រព្រឹត្តកន្លងផង, ពួកធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លង តែមិនមែនជាយោគៈ ;

៤២)..- (៥) **យោគា ចេវ ធម្មា យោគសម្បយុត្តា ច យោគសម្បយុត្តា ចេវ ធម្មា នោ ច យោគា** ពួកធម៌ជាយោគៈផង ប្រកបដោយយោគៈផង, ពួកធម៌គ្រាន់តែប្រកបដោយយោគៈ តែមិនមែនជាយោគៈ ;

៤៣)..- (៦) **យោគវិប្បយុត្តា ខោ បន ធម្មា យោគនិយាបិ អយោគនិយាបិ** ពួកធម៌ប្រាសចាកយោគៈ តែដែលយោគៈ

[១] ធម៌ញាំងសត្វឱ្យជាប់នៅក្នុងវដ្តៈ ។

គប្បីប្រព្រឹត្តកន្លង, ពួកធម៌ប្រាសចាកយោគៈផង ដែលយោគៈ
មិនគប្បីប្រព្រឹត្តកន្លងផង ;

**(យោគគោច្ឆកំ ចប់ពួកយោគៈ តែប៉ុណ្ណេះ)**

៤៤)..₍₁₎ **នីវរណា ធម្មា នោ នីវរណា ធម្មា** ពួកធម៌ជានីវរណៈ[១], ពួកធម៌ មិនមែនជានីវរណៈ ;

៤៥)..₍₂₎ **នីវរណិយា ធម្មា អនីវរណិយា ធម្មា** ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ, ពួកធម៌មិនជាប្រយោជន៍ដល់នីវរណៈ;

៤៦)..₍₃₎ **នីវរណសម្បយុត្តា ធម្មា, នីវរណវិប្បយុត្តា ធម្មា** ពួកធម៌ដែលប្រកបដោយនីវរណៈ, ពួកធម៌ដែលប្រាសចាកនីវរណៈ;

៤៧)..₍₄₎ **នីវរណា ចេវ ធម្មា នីវរណិយា ច នីវរណិយា ចេវ ធម្មា នោ ច នីវរណា** ពួកធម៌ជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង, ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ ;

៤៨)..₍₅₎ **នីវរណា ចេវ ធម្មា នីវរណសម្បយុត្តា ច នីវរណ-សម្បយុត្តា ចេវ ធម្មា នោ ច នីវរណា** ពួកធម៌ជា

[១] ធម៌របាំង ឬ រាំងរាចិត្តសត្វ ។

នីវរណៈផង ប្រកបដោយនីវរណៈផង, ពួកធម៌គ្រាន់តែប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈ ;

៤៩).- (៦) **នីវរណវិប្បយុត្តា ខោ បន ធម្មា នីវរណិយាបិ អនីវរណិយាបិ** ពួកធម៌ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ, ពួកធម៌ប្រាសចាកនីវរណៈផង មិនមែនជាប្រយោជន៍ដល់នីវរណៈផង ;

**(នីវរណគោច្ឆកំ** ចប់ពួកនីវរណៈ តែប៉ុណ្ណេះ)

៥០).- (១) **បរាមាសា ធម្មា នោ បរាមាសា ធម្មា** ពួកធម៌ជាបរាមាសៈ[១], ពួកធម៌ មិនមែនជាបរាមាសៈ ;

៥១).- (២) **បរាមដ្ឋា ធម្មា អបរាមដ្ឋា ធម្មា** ពួកធម៌ដែលបរាមាសៈស្ទាបអង្អែល, ពួកធម៌ដែលបរាមាសៈមិនស្ទាបអង្អែល ;

៥២).- (៣) **បរាមាសសម្បយុត្តា ធម្មា, បរាមាសវិប្បយុត្តា ធម្មា** ពួកធម៌ដែលប្រកបដោយបរាមាសៈ,ពួកធម៌ដែលប្រាសចាកបរាមាសៈ ;

៥៣).- (៤) **បរាមាសា ចេវ ធម្មា បរាមដ្ឋា ច បរាមដ្ឋា ចេវ ធម្មា នោ ច បរាមាសា** ពួកធម៌ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង, ពួកធម៌គ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ ;

---

[១] សេចក្តីប្រកាន់ខុស ។

៥៤).. (៥) **បរាមាសវិប្បយុត្តា ខោ បន ធម្មា បរាមដ្ឋាបិ អបរាមដ្ឋាបិ** ពួកធម៌ប្រាសចាកបរាមាសៈ តែដែលបរាមាសៈស្ទាបអង្អែល, ពួកធម៌ប្រាសចាកបរាមាសៈផង ដែលបរាមាសៈមិនស្ទាបអង្អែលផង ;

**(បរាមាសគោច្ឆកំ** ចប់ពួកបរាមាសៈ តែប៉ុណ្ណេះ)

៥៥).. **សារម្មណា ធម្មា អនារម្មណា ធម្មា** ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍, ពួកធម៌មិនមានអារម្មណ៍ ;

៥៦).. **ចិត្តា ធម្មា នោ ចិត្តា ធម្មា** ពួកធម៌ជាចិត្ត, ពួកធម៌មិនមែនជាចិត្ត ;

៥៧).. **ចេតសិកា ធម្មា អចេតសិកា ធម្មា** ពួកធម៌ជាចេតសិក, ពួកធម៌មិនមែនជាចេតសិក ;

៥៨).. **ចិត្តសម្បយុត្តា ធម្មា ចិត្តវិប្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយចិត្ត, ពួកធម៌ប្រាសចាកចិត្ត ;

៥៩).. **ចិត្តសំសដ្ឋា ធម្មា ចិត្តវិសំសដ្ឋា ធម្មា** ពួកធម៌ច្រឡូកច្រឡំដោយចិត្ត, ពួកធម៌មិនច្រឡូកច្រឡំដោយចិត្ត ;

៦០).. **ចិត្តសមុដ្ឋានា ធម្មា នោ ចិត្តសមុដ្ឋានា ធម្មា** ពួកធម៌តាំងឡើងដោយចិត្ត, ពួកធម៌មិនតាំងឡើងដោយចិត្ត ;

៦១).. **ចិត្តសហភុនោ ធម្មា នោ ចិត្តសហភុនោ ធម្មា** ពួកធម៌កើតជាមួយនឹងចិត្ត, ពួកធម៌មិនកើតជាមួយនឹងចិត្ត ;

៦២).. **ចិត្តានុបរិវត្តិនោ ធម្មា នោ ចិត្តានុបរិវត្តិនោ ធម្មា** ពួកធម៌ប្រព្រឹត្តទៅតាមចិត្ត, ពួកធម៌មិនប្រព្រឹត្តទៅតាមចិត្ត ;

៦៣).. **ចិត្តសំសដ្ឋសមុដ្ឋានា ធម្មា នោ ចិត្តសំសដ្ឋសមុដ្ឋានា ធម្មា** ពួកធម៌ប្រឡូកប្រឡំ តាំងឡើងដោយចិត្ត, ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើងដោយចិត្ត ;

៦៤).. **ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ធម្មា នោ ចិត្តសំសដ្ឋ-សមុដ្ឋានសហភុនោ ធម្មា** ពួកធម៌ប្រឡូកប្រឡំ តាំងឡើងកើតជាមួយនឹងចិត្ត, ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិន-កើតជាមួយនឹងចិត្ត ;

៦៥).. **ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ធម្មា នោ ចិត្តសំសដ្ឋ-សមុដ្ឋានានុបរិវត្តិនោ ធម្មា** ពួកធម៌ប្រឡូកប្រឡំ តាំងឡើងប្រព្រឹត្តទៅតាមចិត្ត, ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិន-ប្រព្រឹត្តទៅតាមចិត្ត ;

៦៦).. **អជ្ឈត្តិកា ធម្មា ពាហិរា ធម្មា** ពួកធម៌ជាខាងក្នុង, ពួកធម៌ជាខាងក្រៅ ;

៦៧).. **ឧបាទា ធម្មា នោ ឧបាទា ធម្មា** ពួកធម៌ជាឧបាទា, ពួកធម៌មិនមែនជាឧបាទា ;

៦៨).. **ឧបាទិន្នា ធម្មា អនុបាទិន្នា ធម្មា** ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ, ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ;

**(មហន្តរទុកំ** ចប់ពួកមហន្តរទុកៈ តែប៉ុណ្ណេះ**)**

៦៩).. (១) **ឧបាទានា ធម្មា នោ ឧបាទានា ធម្មា** ពួកធម៌ជាឧបាទាន[១], ពួកធម៌ មិនមែនជាឧបាទាន ;

៧០).. (២) **ឧបាទានិយា ធម្មា អនុបាទានិយា ធម្មា** ពួកធម៌ជាប្រយោជន៍ដល់ឧបាទាន, ពួកធម៌មិនមែនជាប្រយោជន៍ដល់ឧបាទាន,

៧១).. (៣) **ឧបាទានសម្បយុត្តា ធម្មា ឧបាទានវិប្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយឧបាទាន, ពួកធម៌ប្រាសចាកឧបាទាន ;

៧២).. (៤) **ឧបាទានា ចេវ ធម្មា ឧបាទានិយា ច ឧបានិយា ចេវ ធម្មា នោ ច ឧបាទានា** ពួកធម៌ជាឧបាទានផង ជា

[១] សេចក្ដីប្រកាន់មាំ ។

ប្រយោជន៍ដល់ឧបាទានផង, ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ;

៧៣).. (៥) **ឧបាទានា ចេវ ធម្មា ឧបាទានសម្បយុត្តា ច ឧបាទានសម្បយុត្តា ចេវ ធម្មា នោ ច ឧបាទានា** ពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង, ពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ;

៧៤).. (៦) **ឧបាទានវិប្បយុត្តា ខោ បន ធម្មា ឧបាទានិយាបិ អនុបាទានិយាបិ** ពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន, ពួកធម៌ប្រាសចាកឧបាទានផង មិនមែនជាប្រយោជន៍ដល់ឧបាទានផង ;

**(ឧបាទានគោច្ឆកំ** ចប់ពួកឧបាទាន តែប៉ុណ្ណេះ)

៧៥).. (១) **កិលេសា ធម្មា នោ កិលេសា ធម្មា** ពួកធម៌ជាកិលេស[១], ពួកធម៌មិនមែនជាកិលេស ;

៧៦).. (២) **សង្កិលេសិកា ធម្មា អសង្កិលេសិកា ធម្មា** ពួកធម៌គួរដល់នូវសេចក្ដីសៅហ្មង, ពួកធម៌មិនគួរដល់នូវសេចក្ដីសៅហ្មង,

៧៧).. (៣) **សង្កិលិដ្ឋា ធម្មា, អសង្កិលិដ្ឋា ធម្មា** ពួកធម៌ដែលសៅហ្មងហើយ, ពួកធម៌ដែលមិនសៅហ្មងហើយ ;

---

[១] ធម៌សៅហ្មង ។

៧៨).- (៤) **កិលេសសម្បយុត្តា ធម្មា កិលេសវិប្បយុត្តា ធម្មា** ពួកធម៌ប្រកបដោយកិលេស, ពួកធម៌ប្រាសចាកកិលេស ;

៧៩).- (៥) **កិលេសា ចេវ ធម្មា សង្កិលេសិកា ច សង្កិលេសិកា ចេវ ធម្មា នោ ច កិលេសា** ពួកធម៌ជាកិលេសផង គួរដល់នូវសេចក្ដីសៅហ្មងផង, ពួកធម៌គ្រាន់តែគួរដល់នូវសេចក្ដីសៅហ្មង តែមិនមែនជាកិលេស;

៨០).- (៦) **កិលេសា ចេវ ធម្មា សង្កិលិដ្ឋា ច សង្កិលិដ្ឋា ចេវ ធម្មា នោ ច កិលេសា** ពួកធម៌ជាកិលេសផង សៅហ្មងហើយផង, ពួកធម៌គ្រាន់តែសៅហ្មងហើយ តែមិនមែនជាកិលេស;

៨១).- (៧) **កិលេសា ចេវ ធម្មា កិលេសសម្បយុត្តា ច កិលេសសម្បយុត្តា ចេវ ធម្មា នោ ច កិលេសា** ពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង, ពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស ;

៨២).- (៨) **កិលេសវិប្បយុត្តា ខោ បន ធម្មា សង្កិលេសិកាបិ អសង្កិលេសិកាបិ** ពួកធម៌ប្រាសចាកកិលេស តែគួរដល់នូវសេចក្ដីសៅហ្មង, ពួកធម៌ប្រាសចាកកិលេសផង មិនគួរដល់នូវសេចក្ដីសៅហ្មងផង;

**(កិលេសគោច្ឆកំ** ចប់ពួកកិលេស តែប៉ុណ្ណេះ**)**

៨៣)..₍₁₎ **ទស្សនេន បហាតព្វា ធម្មា ន ទស្សនេន បហា-តព្វា ធម្មា** ពួកធម៌ គួរលះដោយទស្សនៈ[(១)], ពួកធម៌មិនគួរលះដោយទស្សនៈ;

៨៤)..₍₂₎ **ភាវនាយ បហាតព្វា ធម្មា ន ភាវនាយ បហា-តព្វា ធម្មា** ពួកធម៌ដែលគួរលះដោយភាវនា[(២)], ពួកធម៌មិនគួរលះដោយភាវនា;

៨៥)..₍₃₎ **ទស្សនេន បហាតព្វហេតុកា ធម្មា ន ទស្សនេន បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលគួរលះដោយទស្សនៈ, ពួកធម៌មិនមានហេតុដែលគួរលះដោយទស្សនៈ;

៨៦)..₍₄₎ **ភាវនាយ បហាតព្វហេតុកា ធម្មា ន ភាវនាយ បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលគួរលះដោយភាវនា, ពួកធម៌មិនមានហេតុ ដែលគួរលះដោយភាវនា;

៨៧)..₍₅₎ **សវិតក្កា ធម្មា អវិតក្កា ធម្មា** ពួកធម៌ប្រកបដោយវិតក្កៈ[(៣)], ពួកធម៌មិនមានវិតក្កៈ;

---

(១) ការឃើញ គឺ សំដៅយកសោតាបត្តិមគ្គ ។

(២) មគ្គ ៣ ខាងលើ ។

(៣) ការត្រិះរិះ ។

៨៨)..₍៦₎ **សវិចារា ធម្មា អវិចារា ធម្មា** ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងវិចារៈ[(១)], ពួកធម៌មិនមានវិចារៈ;

៨៩)..₍៧₎ **សប្បីតិកា ធម្មា អប្បីតិកា ធម្មា** ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ[(២)], ពួកធម៌មិនមានបីតិ;

៩០)..₍៨₎ **បីតិសហគតា ធម្មា ន បីតិសហគតា ធម្មា** ពួកធម៌ប្រកបដោយបីតិ, ពួកធម៌មិនប្រកបដោយបីតិ;

៩១)..₍៩₎ **សុខសហគតា ធម្មា ន សុខសហគតា ធម្មា** ពួកធម៌ប្រកបសុខ, ពួកធម៌មិនប្រកបដោយសុខ;

៩២)..₍១០₎ **ឧបេក្ខាសហគតា ធម្មា ន ឧបេក្ខាសហគតា ធម្មា** ពួកធម៌ប្រកបដោយឧបេក្ខា, ពួកធម៌មិនប្រកបដោយឧបេក្ខា;

៩៣)..₍១១₎ **កាមាវចរា ធម្មា ន កាមាវចរា ធម្មា** ពួកធម៌ជាកាមាវចរ[(៣)], ពួកធម៌មិនមែនជាកាមាវចរ;

៩៤)..₍១២₎ **រូបាវចរា ធម្មា ន រូបាវចរា ធម្មា** ពួកធម៌ជារូបាវចរ, ពួកធម៌មិនមែនជារូបាវចរ;

---

(១) ការពិចារណា ។

(២) ការត្រេកអរ ។

(៣) ប្រព្រឹត្តទៅក្នុងកាម ។

៩៥)..- (១៣) **អរូបាវចរា ធម្មា ន អរូបាវចរា ធម្មា** ពួកធម៌ជាអរូបាវចរ, ពួកធម៌មិនមែនជាអរូបាវចរ;

៩៦)..- (១៤) **បរិយាបន្នា ធម្មា អបរិយាបន្នា ធម្មា** ពួកធម៌ជាបរិយាបន្នៈ[១], ពួកធម៌ជាអបរិយាបន្នៈ;

៩៧)..- (១៥) **និយ្យានិកា ធម្មា អនិយ្យានិកា ធម្មា** ពួកធម៌ជានិយ្យានិកៈ[២], ពួកធម៌មិនមែនជានិយ្យានិកៈ;

៩៨)..- (១៦) **និយតា ធម្មា អនិយតា ធម្មា** ពួកធម៌ទៀង, ពួកធម៌មិនទៀង;

៩៩)..- (១៧) **សឧត្តរា ធម្មា អនុត្តរា ធម្មា** ពួកធម៌ប្រកបដោយឧត្តរៈ[៣], ពួកធម៌មិនមានឧត្តរៈ;

១០០)..-(១៨) **សរណា ធម្មា អរណា ធម្មា** ពួកធម៌ប្រកបដោយ **រណៈ**[៤], ពួកធម៌មិនមាន **រណៈ**;

**(បិដ្ឋិនុកំ ចប់បិដ្ឋិទុកៈតែប៉ុណ្ណេះ)** ។

# ចប់ អភិធម្មមាតិកា

---

[១] រាប់បញ្ចូលក្នុងតេភូមិកវដ្តៈ ។

[២] ធម៌កាត់នូវវដ្តមូល ធ្វើព្រះនិព្វានឱ្យជាអារម្មណ៍ ហើយចេញចាកវដ្តៈ ។

[៣] ការរើខ្លួន ។

[៤] លាមក ឬ សត្រូវ ។

# សុត្តន្តមាតិកា

១).. **វិជ្ជាភាគិនោ ធម្មា អវិជ្ជាភាគិនោ ធម្មា** ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា, ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃអវិជ្ជា;

២).. **វិជ្ជូបមា ធម្មា វិជ្ជុបមា ធម្មា** ពួកធម៌ប្រៀបដូចជាផ្លេកបន្ទោរ[(១)], ពួកធម៌ប្រៀបដូចជាពេជ្រ[(២)];

៣).. **ពាលា ធម្មា បណ្ឌិតា ធម្មា** ពួកធម៌ (ដែលស្ថិតនៅក្នុងបុគ្គល) ពាល, ពួកធម៌ (ដែលស្ថិតនៅក្នុងបុគ្គលជា) បណ្ឌិត;

៤).. **កណ្ហា ធម្មា សុក្កា ធម្មា** ពួកធម៌ មានសភាពដ៏ខ្មៅ[(៣)], ពួកធម៌មានសភាព ដ៏ **ស**[(៤)];

៥).. **តបនិយា ធម្មា អតបនិយា ធម្មា** ពួកធម៌ដែលគួរដល់ការដុតកំដៅ[(៥)], ពួកធម៌មិនគួរដល់ការដុតកំដៅ;

៦).. **អធិវចនា ធម្មា អធិវចនបថា ធម្មា** ពួកធម៌គ្រាន់តែជាឈ្មោះ, ពួកធម៌គ្រាន់តែជាគន្លងនៃឈ្មោះ;

---

(១) ធម៌ដែលមានកម្លាំងរស្មីស្តួចស្តើង មិនអាចនឹងកំចាត់នូវភាពងងឹត គឺកិលេសបាន។
(២) ធម៌ដែលមានកម្លាំងរស្មីភ្លៀវក្លា អាចនឹងកំចាត់នូវភាពងងឹត គឺ កិលេសបាន ។
(៣) ធម៌ ធ្វើចិត្តឱ្យអាប់រស្មី ។
(៤) ធម៌ ធ្វើចិត្តឱ្យមានរស្មីភ្លឺថ្លា ។
(៥) ធម៌ដុតកំដៅក្នុងលោកនេះ និង លោកខាងមុខ ។

៧).. **និរុត្តិ ធម្មា និរុត្តិបថា ធម្មា** ពួកធម៌ជានិរុត្តិ[១], ពួកធម៌ជាគន្លងនៃនិរុត្តិ;

៨).. **បញ្ញត្តិ ធម្មា បញ្ញត្តិបថា ធម្មា** ពួកធម៌ជាបញ្ញត្តិ, ពួកធម៌ជាគន្លងនៃបញ្ញត្តិ;

៩).. **នាមញ្ច រូបញ្ច** នាម[២], និង រូប[៣];

១០)..**អវិជ្ជា ច ភវតណ្ហា ច** អវិជ្ជា[៤], និង ភវតណ្ហា[៥];

១១)..**ភវទិដ្ឋិ ច វិភវទិដ្ឋិ ច** ភវទិដ្ឋិ[៦], និង វិភវទិដ្ឋិ[៧];

១២)..**សស្សតទិដ្ឋិ ច ឧច្ឆេទទិដ្ឋិ ច** សស្សតទិដ្ឋិ[៨], និងឧច្ឆេទទិដ្ឋិ[៩]; និងឧច្ឆេទទិដ្ឋិ[៩];

១៣)..**អន្តវាទិដ្ឋិ ច អនន្តវាទិដ្ឋិ ច** អន្តវាទិដ្ឋិ[១០], និង អនន្តវាទិដ្ឋិ[១];

---

[១] ប្រែថា ពោលដោយមិនសេសសល់ សំដៅយកពាក្យវិគ្គហៈ ឬវិគ្រោះ អធិប្បាយប្រាប់ហេតុផល ដូចពាក្យថាសភាវៈឯណាតាក់តែងសត្វ សភាវៈនោះ ហៅថាសង្ខារជាដើម។

[២] ប្រែថា ឈ្មោះ, ប្រែថាទន់ទៅ ឬបង្អោនទៅ ។

[៣] ប្រែថា វិនាសទៅ, លំបាក ។

[៤] មិនដឹងនូវអរិយសច្ចទាំង៤ ។

[៥] សេចក្តីប្រាថ្នាក្នុងភព ។

[៦] សេចក្តីយល់ឃើញថា សត្វកើតទៀត ។

[៧] សេចក្តីយល់ឃើញថា សត្វមិនកើតទៀត ។

[៨ សេចក្តីយល់ឃើញថា ខ្លួន និង លោក ជាសភាវៈទៀង ។

[៩] សេចក្តីយល់ឃើញថា សត្វសូន្យមិនកើតទៀត ។

[១០] សេចក្តីយល់ឃើញថា លោកមានទីបំផុត ។

១៤)..**បុព្វន្តានុទិដ្ឋិ ច អបរន្តានុទិដ្ឋិ ច** បុព្វន្តានុទិដ្ឋិ[២] និង អបរន្តានុទិដ្ឋិ[៣];

១៥).. **អហិរិកញ្ច អនោត្តប្បញ្ច** សេចក្ដីមិនខ្មាសបាប និង សេចក្ដីមិនក្ដៅចំពោះបាប;

១៦).. **ហិរិ ច ឱត្តប្បញ្ច** សេចក្ដីខ្មាសបាប និង សេចក្ដីក្ដៅនឹងបាប;

១៧).. **ទោវចស្សតា ច បាបមិត្តតា ច** ភាពជាបុគ្គលប្រដៅក្រ និង ភាពជាបុគ្គលមានមិត្តអាក្រក់;

១៨).. **សោវចស្សតា ច កល្យាណមិត្តតា ច** ភាពជាបុគ្គលប្រដៅងាយ, និង ភាពជាបុគ្គលមានមិត្តល្អ;

១៩).. **អាបត្តិកុសលតា ច អាបត្តិវុដ្ឋានកុសលតា ច** សេចក្ដីឈ្លាសវៃក្នុងអាបត្តិ និង សេចក្ដីឈ្លាសវៃក្នុងការចេញចាកអាបត្តិ;

២០).. **សមាបត្តិកុសលតា ច សមាបត្តិវុដ្ឋានកុសលតា ច** សេចក្ដីឈ្លាសវៃក្នុងសមាបត្តិ និងសេចក្ដីឈ្លាសវៃក្នុងការចេញចាកសមាបត្តិ,

២១).. **ធាតុកុសលតា ច មនសិការកុសលតា ច** សេចក្ដីឈ្លាសវៃក្នុងធាតុ និង សេចក្ដីឈ្លាសវៃក្នុងការធ្វើទុកក្នុងចិត្ត;

---

[១] សេចក្ដីយល់ឃើញថា លោកមិនមានទីបំផុត ។

[២] សេចក្ដីយល់ឃើញតាមចំណែកនៃខន្ធខាងដើម ។

[៣] សេចក្ដីយល់ឃើញតាមចំណែកនៃខន្ធខាងចុង ។

២២).. **អាយតនកុសលតា ច បដិច្ចសមុប្បាទកុសលតា ច** សេចក្តីឈ្លាសវៃក្នុងអាយតនៈ និង សេចក្តីឈ្លាសវៃក្នុងបដិច្ចសមុប្បាទ;

២៣).. **ឋានកុសលតា ច អដ្ឋានកុសលតា ច** សេចក្តីឈ្លាសវៃក្នុងហេតុ និង សេចក្តីឈ្លាសវៃក្នុងការមិនមែនជាហេតុ;

២៤).. **អាជ្ជវោ ច មទ្ទវោ ច** សេចក្តីត្រឹមត្រង់ និង សេចក្តីទន់ភ្លន់;

២៥).. **ខន្តិ ច សោរច្ចញ្ច** សេចក្តីអត់ធន់ និង សេចក្តីស្ងប់ស្ងៀម;

២៦).. **សាខល្យញ្ច បដិសន្ថារោ ច** សេចក្តីស្រស់ស្រាយរាក់ទាក់ និង ការស្រុះស្រួលទទួល;

២៧).. **ឥន្ទ្រិយេសុ អគុត្តទ្វារតា ច ភោជនេ អមត្តញ្ញុតា ច** ការមិនរក្សានូវទ្វារក្នុងឥន្ទ្រិយ និងសេចក្តីមិនដឹងនូវប្រមាណក្នុងភោជន;

២៨).. **ឥន្ទ្រិយេសុ គុត្តទ្វារតា ច ភោជនេ មត្តញ្ញុតា ច** ការរក្សានូវទ្វារក្នុងឥន្ទ្រិយ និង សេចក្តីដឹងប្រមាណក្នុងភោជន;

២៩).. **មុដ្ឋស្សច្ចញ្ច អសម្បជញ្ញញ្ច** សេចក្តីភ្លេចស្មារតី និង សេចក្តីមិនដឹងខ្លួន;

៣០).. **សតិ ច សម្បជញ្ញញ្ច** ស្មារតី និង សេចក្តីដឹងខ្លួន;

៣១).. **បដិសង្ខានពលញ្ច ភាវនាពលញ្ច** កម្លាំងនៃការពិចារណា និង កម្លាំងនៃភាវនា;

៣២).. **សមថោ ច វិបស្សនា ច** សមថៈ និង វិបស្សនា;

៣៣).. **សមថនិមិត្តញ្ច បគ្គាហនិមិត្តញ្ច** និមិត្តរបស់សមថៈ និង និមិត្តនៃការព្យាយាមផ្គងឡើង;

៣៤).. **បគ្គាហោ ច អវិក្ខេបោ ច** ការផ្គងឡើង និង សេចក្ដីមិនរាយមាយ;

៣៥).. **សីលវិបត្តិ ច ទិដ្ឋិវិបត្តិ ច** វិបត្តិនៃសីល និង វិបត្តិនៃទិដ្ឋិ;

៣៦).. **សីលសម្បទា ច ទិដ្ឋិសម្បទា ច** ការបរិបូណ៌នៃសីល និង ការបរិបូណ៌នៃទិដ្ឋិ;

៣៧).. **សីលវិសុទ្ធិ ច ទិដ្ឋិវិសុទ្ធិ ច** សេចក្ដីបរិសុទ្ធនៃសីល និង សេចក្ដីបរិសុទ្ធនៃទិដ្ឋិ;

៣៨).. **ទិដ្ឋិវិសុទ្ធិ ខោ បន យថាទិដ្ឋិស្ស ច បធានំ** សេចក្ដីបរិសុទ្ធនៃទិដ្ឋិ និង សេចក្ដីព្យាយាមរបស់បុគ្គល ដែលមានទិដ្ឋិដ៏សមគួរ;

៣៩).. **សំវេគោ ច សំវេជនិយេសុ ឋានេសុ សំវិគ្គស្ស ច យោនិសោ បធានំ** សេចក្ដីសង្វេគក្នុងទីដែលគួរសង្វេគទាំងឡាយ និង សេចក្ដីព្យាយាមដោយឧបាយនៃបុគ្គលដែលមានសេចក្ដីសង្វេគ;

៤០).. **អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ អប្បដិវានិតា ច បធានស្មិំ** សេចក្ដីមិនសន្ដោសក្នុងកុសលធម៌ទាំងឡាយ និង សេចក្ដីមិនបន្ធូរបន្ថយក្នុងការព្យាយាម;

៤១).. **វិជ្ជា ច វិមុត្តិ ច** វិជ្ជា និង វិមុត្តិ;

៤២).. **ខយេ ញាណំ អនុប្បាទេ ញាណន្តិ** សេចក្តីដឹងក្នុងធម៌[១] ជាគ្រឿងអស់ទៅនៃកិលេស និង សេចក្តីដឹងក្នុងធម៌[២] ដែលធ្វើកិលេសមិនឱ្យកើតឡើងទៀត ។

**(សុត្តន្តមាតិកា ទ្វាចត្តាឡីសទុកំ សមត្តំ)**

(សុត្តន្តមាតិកា មាន **ទុកៈ ៤២** ចប់តែប៉ុណ្ណេះ) ។

## ខន្ធវិភង្គ (ក្នុងបាលី)

**(តត្ថនន្តរំ[៣] វិភង្គប្បករណំ នាមេតំ)**

លំដាប់អំពីបករណៈឈ្មោះធម្មសង្គណីនោះមក យើងនឹងសូត្រ នូវ **បករណៈ**ឈ្មោះ**វិភង្គ**, ឯ **បករណៈ**ឈ្មោះវិភង្គនោះ គឺ :

**បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារ--ក្ខន្ធោ វិញ្ញាណក្ខន្ធោ** ខន្ធទាំងឡាយ ៥ គឺ រូបក្ខន្ធ១ វេទនាខន្ធ១ សញ្ញាខន្ធ១ សង្ខារក្ខន្ធ១ វិញ្ញាណក្ខន្ធ១ ។

---

(១) អរិយមគ្គ ។

(២) អរិយផល ។

(៣) ត្រង់វង់ក្រចកខាងដើម គ្រប់ធម៌ទាំង ៦ មេ មិនមានក្នុងបាលីអភិធម្មបិដកទេ តែលោកអ្នកប្រាជ្ញជាន់ដើម បានរៀបរៀងក្នុង**ភាណវារ**បាលី ដាក់ខាងដើមនេះ ដើម្បីឱ្យងាយដឹងឈ្មោះធម៌មួយសង្កាត់ៗ ប៉ុណ្ណោះ ។

១. **តត្ថ កតមោ រូបក្ខន្ធោ** បណ្តាខន្ធទាំងនោះ រូបក្ខន្ធ តើដូចម្តេច ?

**យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា** រូបណាមួយ ជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី,

**តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ** ខន្ធនេះ លោកបានប្រមូលរួបរួម នូវរូបទាំងអស់នោះ ជាមួយគ្នា ហៅថា រូបក្ខន្ធ ។

២. **តត្ថ កតមោ វេទនាខន្ធោ** បណ្តាខន្ធទាំងនោះ វេទនាខន្ធ តើដូចម្តេច?

**យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា** វេទនាណាមួយ ជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី,

**តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វេទនាខន្ធោ** ខន្ធនេះ លោកបានប្រមូលរួបរួមនូវវេទនាទាំងអស់នោះជាមួយគ្នា ហៅថា វេទនាខន្ធ ។

៣. **តត្ថ កតមោ សញ្ញាខន្ធោ** បណ្ដាខន្ធទាំងនោះ សញ្ញាខន្ធ តើដូចម្ដេច?

**យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា** សញ្ញាណាមួយ ជាអតីតក្ដី ជាអនាគតក្ដី ជាបច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្តមក្ដី ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី,

**តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សញ្ញាខន្ធោ** ខន្ធនេះ លោកបានប្រមូលរួបរួមនូវសញ្ញាទាំងអស់នោះ ជាមួយគ្នា ហៅថា សញ្ញាខន្ធ ។

៤. **តត្ថ កតមោ សង្ខារក្ខន្ធោ** បណ្ដាខន្ធទាំងនោះ សង្ខារក្ខន្ធ តើដូចម្ដេច ?

**យេ កេចិ សង្ខារា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា** សង្ខារទាំងឡាយណាមួយ ជាអតីតក្ដី ជាអនាគតក្ដី ជាបច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្តមក្ដី ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី,

**តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សង្ខារក្ខន្ធោ** ខន្ធនេះ លោកបានប្រមូលរួបរួមនូវសញ្ញាទាំងអស់នោះ ជាមួយគ្នា ហៅថា សង្ខារក្ខន្ធ ។

៥. **តត្ថ កតមោ វិញ្ញាណក្ខន្ធោ** បណ្ដាខន្ធទាំងនោះ វិញ្ញាណក្ខន្ធ តើដូចម្ដេច ?

**យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា** វិញ្ញាណណាមួយ ជាអតីតក្ដី ជាអនាគតក្ដី ជាបច្ចុប្បន្នក្ដី ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី,

**តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ** ខន្ធនេះលោកបានប្រមូលរួបរួមនូវសញ្ញាទាំងអស់នោះជាមួយគ្នា ហៅថា វិញ្ញាណក្ខន្ធ ។

**(អយំ ខន្ធវិភង្គោតិ អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ)**

(*នេះឈ្មោះថាវិភង្គ មានខន្ធវិភង្គជាដើម,* **បករណៈ** ឈ្មោះ **វិភង្គ** *ដែលលោកចែកហើយ ដោយចំណែក ១៨ ប្រការ ចប់តែប៉ុណ្ណេះ*)

## **វិភង្គ** (ក្នុងអដ្ឋកថា)

**(តទនន្តរំ វិភង្គប្បករណំ នាមេតំ)**

(លំដាប់អំពី**ធម្មសង្គណិប្បករណ៍**នោះមក យើងនឹងស្វាធ្យាយនូវ **វិភង្គប្បករណ៍** ដូចតទៅ) :

**ខន្ធវិភង្គោ អាយតនវិភង្គោ ធាតុវិភង្គោ សច្ចវិភង្គោ ឥន្ទ្រិយវិភង្គោ បច្ចយាការវិភង្គោ សតិប្បដ្ឋានវិភង្គោ សម្មប្ប-**

**ធាតុវិភង្គោ ឥទ្ធិបាទវិភង្គោ ពោជ្ឈង្គវិភង្គោ មគ្គវិភង្គោ ឈានវិភង្គោ អប្បមញ្ញាវិភង្គោ សិក្ខាបទវិភង្គោ បដិសម្ភិទាវិភង្គោ ញាណវិភង្គោ ខុទ្ទកវត្ថុវិភង្គោ ធម្មហទយវិភង្គោតិ**

**( អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ)**

(វិភង្គប្បករណ៍ ចែកចេញដោយវិភង្គ ១៨ ប្រការ ចប់តែប៉ុណ្ណេះ)

## ធាតុកថា (ក្នុងបាលី)

**(តទនន្តរំ ធាតុកថាបករណំ នាមេតំ)**

(លំដាប់អំពីបករណៈឈ្មោះវិភង្គនោះមក យើងនឹងសូត្រនូវ បករណៈឈ្មោះធាតុកថា, ឯបករណៈឈ្មោះ**ធាតុកថា**នោះ គឺ ) :

**សង្គហោ អសង្គហោ** (ធាតុ១៨គឺ) ការសង្គ្រោះ ការមិនសង្គ្រោះ,

**សង្គហិតេន អសង្គហិតំ** ការមិនសង្គ្រោះ មួយអន្លើ ដោយការសង្គ្រោះ,

**អសង្គហិតេន សង្គហិតំ** ការសង្គ្រោះ មួយអន្លើ ដោយការមិនសង្គ្រោះ,

**សង្គហិតេន សង្គហិតំ** ការសង្គ្រោះមួយអន្លើដោយការសង្គ្រោះ,

**អសង្គហិតេន អសង្គហិតំ** ការមិនសង្គ្រោះ មួយអន្លើ ដោយការមិនសង្គ្រោះ,

**សម្បយោគោ វិប្បយោគោ** ការសមប្រកប ការប្រាសចេញ,

**សម្បយុត្តេន វិប្បយុត្តំ** ការប្រាសចេញមួយអន្លើដោយការសមប្រកប,

**វិប្បយុត្តេន សម្បយុត្តំ** ការសមប្រកប មួយអន្លើដោយការប្រាសចេញ,

**សម្បយុត្តេន សម្បយុត្តំ** ការសមប្រកប មួយអន្លើដោយការសមប្រកប,

**វិប្បយុត្តេន វិប្បយុត្តំ** ការប្រាសចេញ មួយអន្លើដោយការសប្រាសចេញ,

**សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ** ការសមប្រកប និង ការប្រាសចេញមួយអន្លើដោយការសង្គ្រោះ,

**សម្បយុត្តេន សង្គហិតំ អសង្គហិតំ** ការសង្គ្រោះ និង ការការមិនសង្គ្រោះ មួយអន្លើដោយការសមប្រកប,

**អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ** ការសមប្រកប និងការប្រាសចេញ មួយអន្លើដោយការមិនសង្គ្រោះ,

**វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ** ការសង្គ្រោះ និង ការការមិនសង្គ្រោះ មួយអន្លើដោយការប្រាសចេញ ។

**បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារស ធាតុយោ ចត្តារិ សច្ចានិ ពាវីសតិន្ទ្រិយានិ បដិច្ចសមុប្បាទោ ចត្តារោ សតិប្ប-**

**-ដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា ចត្តារិ ឈានា-និ ចតស្សោ អប្បមញ្ញាយោ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ**, ខន្ធ៥, អាយតនៈ១២, ធាតុ ១៨, សច្ចៈ៤, ឥន្ទ្រិយ ២២, បដិច្ចសមុប្បាទ, សតិប្បដ្ឋាន ៤, សម្មប្បធាន ៤, ឥទ្ធិបាទ៤, ឈាន ៤, អប្បមញ្ញា ៤, ឥន្ទ្រិយ ៥, ពលៈ ៥, ពោជ្ឈង្គៈ ៧, មគ្គមានអង្គ ៨ ជាមគ្គដ៏ប្រសើរ,

**ផស្សោ វេទនា សញ្ញា ចេតនា ចិត្តំ អធិមោក្ខោ មនសិ-ការោ** ផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត ការជឿស៊ប់ ការធ្វើទុកក្នុងចិត្ត,

**តីហិ សង្គហោ តីហិ អសង្គហោ ចតូហិ សម្បយោគោ ចតូហិ វិប្បយោគោ សភាគោ វិសភាគោ សព្វាបិ ធម្មសង្គណិ ធាតុកថា មាតិកា** ការសង្គ្រោះដោយបទ[១] ៣ ការមិនសង្គ្រោះដោយបទ៣, ការសម្រប្រកបដោយបទ ៤ (គឺ អរូបក្ខន្ធ៤) ការប្រាសចេញចាកបទ ៤, ធម៌មានចំណែកស្មើគ្នា និង ធម៌មានចំណែកមិនស្មើគ្នា, ធម្ម-សង្គណីទាំងអស់ ជាមាតិកានៃធាតុកថា ។

**(នយមាតិកាតិ បញ្ចវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ)**

(នេះឈ្មោះមាតិកាមាន **នយមាតិកា**ជាដើម, **បករណៈ** ឈ្មោះ **ធាតុកថា** ដែលលោកចែកហើយ ដោយចំណែក៥ ប្រការ ចប់តែប៉ុណ្ណេះ)

[១] បទ៣ គឺ ខន្ធ ធាតុ អាយតនៈ ។

## ធាតុកថា (ក្នុងអដ្ឋកថា)

**(តទនន្តរំ ធាតុកថាបករណំ នាមេតំ)**

**សង្គហោ អសង្គហោ សង្គហិតេន អសង្គហិតំ អសង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន អសង្គហិតំ សម្បយោគោ វិប្បយោគោ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ សម្បយុត្តេន សម្បយុត្តំ វិប្បយុត្តេន វិប្បយុត្តំ សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ សម្បយុត្តេន សង្គហិតំ អសង្គហិតំ អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ ។**

**(ចុទ្ទសវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ)**

(ធាតុកថាបករណ៍ ចែកចេញដោយធាតុ ១៤ ប្រការ ចប់តែប៉ុណ្ណេះ)

## បុគ្គលប្បញ្ញត្តិ (ក្នុងអដ្ឋកថា)

**(តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសា)**

**ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ ។**

**(ឆ វិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ)**

( បុគ្គលប្បញ្ញត្តិប្បករណ៍ ចែកចេញដោយបញ្ញត្តិ ៦ ប្រការ ចប់តែប៉ុណ្ណេះ )

# បុគ្គលប្បញ្ញត្តិ (ក្នុងបាលី)

## (តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសា)

(លំដាប់អំពីបករណៈឈ្មោះធាតុកថានោះមក យើងនឹងសូត្រនូវ បករណៈឈ្មោះបុគ្គលប្បញ្ញត្តិ, ឯបករណៈឈ្មោះបុគ្គលប្បញ្ញត្តិនោះ គឺ) :

ឆ បញ្ញត្តិយោ *ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ* **បញ្ញត្តិ ៦**[១] ប្រការ គឺ *ខន្ធប្បញ្ញត្តិ១ អាយតនប្បញ្ញត្តិ១ ធាតុប្បញ្ញត្តិ១ សច្ចប្បញ្ញត្តិ ១ ឥន្ទ្រិយប្បញ្ញត្តិ១ បុគ្គលប្បញ្ញត្តិ១,*

**កិត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ** ខន្ធប្បញ្ញត្តិ របស់ខន្ធទាំងឡាយ មានប៉ុន្មានយ៉ាង?

**យាវតា បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ** **ខន្ធទាំងឡាយ ៥** គឺ *រូបក្ខន្ធ១ វេទនា-ខន្ធ១ សញ្ញាខន្ធ១ សង្ខារក្ខន្ធ១ វិញ្ញាណក្ខន្ធ១* ដោយកំណត់ប្រមាណឯណា,

**ឯត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ** ខន្ធប្បញ្ញត្តិ របស់ខន្ធទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណេះ ។

**កិត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ** អាយតនប្បញ្ញត្តិ របស់អាយតនៈទាំងឡាយ មានប៉ុន្មានយ៉ាង?

---

[១] ប្រែថា ការតែងតាំង ការសំដែង ការប្រកាស ការតាំងទុក ។

**យាវតា ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហា-យតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ មនាយតនំ ធម្មាយតនំ, <u>អាយតនៈ១២</u>** គឺ : ចក្ខាយតនៈ ១ រូបាយតនៈ ១ សោតា-យតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មា-យតនៈ១ ដោយកំណត់មានប្រមាណឯណា,

**ឯត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ** អាយតនប្បញ្ញត្តិ របស់អាយតនៈទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណេះ ។

**កិត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ** ធាតុប្បញ្ញត្តិ របស់ធាតុទាំងឡាយ មានប៉ុន្មានយ៉ាង?

**យាវតា អដ្ឋារស ធាតុយោ ចក្ខុធាតុ រូបធាតុ ចក្ខុ-វិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណ-ធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ <u>ធាតុ ១៨</u>** គឺ ចក្ខុធាតុ១ រូបធាតុ១ ចក្ខុវិញ្ញាណធាតុ១; សោតធាតុ១ សទ្ទធាតុ១ សោត-វិញ្ញាណធាតុ១; ឃានធាតុ១ គន្ធធាតុ១ ឃានវិញ្ញាណធាតុ១; ជិវ្ហាធាតុ១ រសធាតុ១ ជិវ្ហាវិញ្ញាណធាតុ១; កាយធាតុ១ ផោដ្ឋព្វធាតុ១ កាយវិញ្ញាណ ធាតុ១; មនោធាតុ១ ធម្មធាតុ១ មនោវិញ្ញាណធាតុ១;

**ឯត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ** ធាតុប្បញ្ញត្តិ របស់ធាតុទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណេះ ។

**កិត្តាវតា សច្ចានំ សច្ចប្បញ្ញត្តិ** សច្ចប្បញ្ញត្តិ របស់សច្ចៈទាំងឡាយ មានប៉ុន្មានយ៉ាង?

**យាវតា ចត្តារិ សច្ចានិ ទុក្ខសច្ចំ សមុទយសច្ចំ និរោធសច្ចំ មគ្គសច្ចំ <u>សច្ចៈទាំងឡាយ ៤</u>** គឺ ទុក្ខសច្ចៈ១ សមុទយសច្ចៈ១ និរោធសច្ចៈ១ មគ្គសច្ចៈ១ ដោយកំណត់មានប្រមាណឯណា ។

**ឯត្តាវតា សច្ចានំ សច្ចប្បញ្ញត្តិ** សច្ចប្បញ្ញត្តិ របស់សច្ចៈទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណេះ ។

**កិត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយប្បញ្ញត្តិ** ឥន្ទ្រិយប្បញ្ញត្តិ របស់ឥន្ទ្រិយទាំងឡាយ មានប៉ុន្មានយ៉ាង ?

**យាវតា ពាវីសតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតាវិន្ទ្រិយំ <u>ឥន្ទ្រិយទាំងឡាយ ២២</u>** គឺ ចក្ខុន្ទ្រិយ១ សោតិន្ទ្រិយ១ ឃានិន្ទ្រិយ១ ជិវ្ហិន្ទ្រិយ១ កាយិន្ទ្រិយ១ មនិន្ទ្រិយ១ ឥត្ថិន្ទ្រិយ១ បុរិសិន្ទ្រិយ១ ជីវិតិន្ទ្រិយ១ សុខិន្ទ្រិយ១ ទុក្ខិន្ទ្រិយ១ សោមនស្សិ-

ន្ទ្រិយ១ ទោមនស្សិន្ទ្រិយ១ ឧបេក្ខិន្ទ្រិយ១ សទ្ធិន្ទ្រិយ១ វីរិយិន្ទ្រិយ១ សតិន្ទ្រិយ១ សមាធិន្ទ្រិយ១ បញ្ញិន្ទ្រិយ១ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ១ អញ្ញិន្ទ្រិយ១ អញ្ញាតាវិន្ទ្រិយ១[១] ដោយកំណត់ មានប្រមាណឯណា,

**ឯត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយប្បញ្ញត្តិ** ឥន្ទ្រិយប្បញ្ញត្តិ របស់ឥន្ទ្រិយទាំងឡាយ ដោយកំណត់ មានប្រមាណប៉ុណ្ណេះ ។

**កិត្តាវតា បុគ្គលានំ បុគ្គលប្បញ្ញត្តិ** បុគ្គលប្បញ្ញត្តិ របស់បុគ្គលទាំងឡាយ មានប៉ុន្មានយ៉ាង ?

**សមយវិមុត្តោ អសមយវិមុត្តោ** បុគ្គលអ្នករួចស្រឡះ តាមកាលគួរ បុគ្គលអ្នករួចស្រឡះតាមកាលមិនគួរ ។

**កុប្បធម្មោ អកុប្បធម្មោ** បុគ្គលអ្នកមានធម៌ នៅកម្រើកញាប់ញ័រ, បុគ្គលអ្នកមានធម៌ មិនកម្រើកញាប់ញ័រ ។

**បរិហានធម្មោ អបរិហានធម្មោ** បុគ្គលអ្នកមានធម៌ សាបសូន្យ, បុគ្គលអ្នកមានធម៌ មិនសាបសូន្យ ។

**ចេតនាភព្វោ អនុរក្ខនាភព្វោ** បុគ្គលអ្នកគួរដល់នូវសេចក្តីមិនសាបសូន្យដោយចេតនា, បុគ្គលអ្នកគួរដល់នូវសេចក្តីមិនសាបសូន្យដោយការរក្សា,

---

[១] តាំងពីចក្ខុន្ទ្រិយរហូតដល់សុខិន្ទ្រិយ១០នេះ ជាកាមាវចរ(ប្រព្រឹត្តទៅក្នុងកាម), ពីទុក្ខិន្ទ្រិយ ដល់បញ្ញិន្ទ្រិយ ៩ នេះ ជាមិស្សកៈ (ច្រឡូកច្រឡំគ្នា), ឯឥន្ទ្រិយ ៣ ខាងចុងជាលោកុត្តរៈ ។

**បុថុជ្ជនោ គោត្រភូ** បុគ្គលជាបុថុជ្ជន, បុគ្គលជាគោត្រភូ,

**ភយូបរតោ អភយូបរតោ** បុគ្គលអ្នកវៀរចាកបាបដោយភ័យ, បុគ្គលអ្នកវៀរចាកបាប ដោយមិនភ័យ,

**ភព្វាគមនោ អភព្វាគមនោ** បុគ្គលអ្នកគួរដល់ការមកកាន់សម្មត្តនិយាម គឺមគ្គ, បុគ្គលអ្នកមិនគួរដល់ ការមកកាន់សម្មត្តនិយាម គឺមគ្គ,

**និយតោ អនិយតោ** បុគ្គលទៀង, បុគ្គលមិនទៀង,

**បដិបន្នកោ ផលេ ឋិតោ** បុគ្គលអ្នកប្រតិបត្តិព្រមព្រៀងដោយមគ្គ, បុគ្គលអ្នកឋិតនៅក្នុងផល,

**សមសីសី ឋិតកប្បី** បុគ្គលអ្នកមានធម៌ស្មើគ្នា, បុគ្គលអ្នកញ៉ាំងកប្បឱ្យឋិតនៅ,

**អរិយោ អនរិយោ** បុគ្គលជាអរិយៈ, បុគ្គលមិនមែនជាអរិយៈ,

**សេក្ខោ អសេក្ខោ** បុគ្គលជាសេក្ខៈ, បុគ្គលជាអសេក្ខៈ,

**នេវសេក្ខោ នាសេក្ខោ** បុគ្គលមិនមែនជាសេក្ខៈ, បុគ្គលមិនមែនជាអសេក្ខៈ,

**តេវិជ្ជោ ឆឡភិញ្ញោ** បុគ្គលអ្នកបានវិជ្ជា ៣, បុគ្គលអ្នកបានអភិញ្ញា ៦,

**សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ** បុគ្គលជាព្រះសម្មាសម្ពុទ្ធ, បុគ្គលជាព្រះបច្ចេកពុទ្ធ,

**ឧភតោ ភាគវិមុត្តោ បញ្ញាវិមុត្តោ** បុគ្គលអ្នករួចស្រឡះចាក កិលេសដោយចំណែកទាំងពីរ, បុគ្គលអ្នករួចស្រឡះចាកកិលេសដោយបញ្ញា,

**កាយសក្ខី ទិដ្ឋិប្បត្តោ** បុគ្គលអ្នកមានកាយជាបន្ទាល់, បុគ្គល អ្នកសម្រេចហើយដោយសម្មាទិដ្ឋិ,

**សទ្ធាវិមុត្តោ ធម្មានុសារី** បុគ្គលអ្នករួចស្រឡះដោយសទ្ធា, បុគ្គលអ្នករឭកតាមនូវធម៌,

**សទ្ធានុសារី សត្តក្ខត្តុំបរមោ កោលំកោលោ** បុគ្គលអ្នករឭក តាមនូវសទ្ធា បុគ្គលអ្នកកើតអស់វារៈ៧ដង បុគ្គលអ្នកចេញអំពីត្រកូល ទៅកាន់ត្រកូល,

**ឯកពីជី សកទាគាមី** បុគ្គលមានពូជ គឺខន្ធតែម្តង, បុគ្គលអ្នក មកកាន់លោកនេះម្តងទៀត,

**អនាគាមី អន្តរាបរិនិព្វាយី** បុគ្គលមិនមកកាន់លោកនេះទៀត, បុគ្គលបរិនិព្វាន កាលពាក់កណ្តាលអាយុ,

**ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី** បុគ្គលអ្នកកន្លងហួស ពាក់កណ្តាលអាយុទើបបរិនិព្វាន, បុគ្គលបរិនិព្វានដោយមិនបាច់ព្យាយាមខ្លាំង,

**សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី** បុគ្គលអ្នក បរិនិព្វានដោយព្យាយាមខ្លាំង, បុគ្គលមានខ្សែនៃមគ្គទៅខាងលើ ដរាប ដល់ អកនិដ្ឋព្រហ្មហើយ ទើបបរិនិព្វាន,

**សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ** បុគ្គលជាសោតាបន្នៈ, បុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតា-បត្តិផល,

**សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ** បុគ្គលជាសកទាគាមី, បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល,

**អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ** បុគ្គលជាអនាគាមី, បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល,

**អរហា អរហត្តផលសច្ឆិកិរិយាយ បដិបន្នោតិ**[១] បុគ្គលជាព្រះអរហន្ត, បុគ្គលប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល ។

**(អយំ ខន្ធប្បញ្ញត្តាទិ ឆព្វិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ)**

(នេះឈ្មោះថាបញ្ញត្តិ មានខន្ធប្បញ្ញត្តិជាដើម, **បករណៈ** ឈ្មោះ **បុគ្គលប្បញ្ញត្តិ** ដែលលោកចែកហើយ ដោយចំណែក ៦ ប្រការ ចប់តែប៉ុណ្ណេះ)

[១] ក្នុងអភិធម្មបិដកគ្មាន "តិ" ទេ ក្នុងភាណវារៈមាន "តិ" ។

# កថាវត្ថុ (ក្នុងបាលី)

## (តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ)

(លំដាប់អំពីបករណៈឈ្មោះបុគ្គលប្បញ្ញត្តិនោះមក យើងនឹងសូត្រនូវបករណៈឈ្មោះ **កថាវត្ថុ**, ឯ **បករណៈ** ឈ្មោះ **កថាវត្ថុ** នោះ គឺ) :

**បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ** សកវាទីសួរថា **សភាវៈ**[(១)] ដែលបណ្ឌិតដឹងថាជាបុគ្គលដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ?

**អាមន្តា** បរវាទី ឆ្លើយថា អើ !

**យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ** សកវាទីសួរថា សភាវៈឯណាមានអត្ថដ៏ពិត មានអត្ថ ដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះដែលបណ្ឌិតដឹងថា ជាបុគ្គលដោយ អត្ថដ៏ពិត និង អត្ថដ៏ឧត្តមឬ ?

**ន ហេវំ វត្តព្វេ** បរវាទី ឆ្លើយថា អ្នកមិនគួរពោលយ៉ាងនេះទេ!

**អាជានាហិ និគ្គហំ ហញ្ចិ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេន តេន វត រេ វត្តព្វេ យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ** សកវាទីពោលថា អ្នកចូរដឹងនូវទោសចុះ, ប្រសិនបើសភាវៈដែលបណ្ឌិតដឹងថា ជាបុគ្គល

---

[(១)] ពាក្យថា **សភាវៈ** បានដល់ប្រភេទនៃធម៌ ៥៧ គឺ ខន្ធ៥, អាយតនៈ១២, ធាតុ ១៨, ឥន្ទ្រិយ ២២ ។

ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តម, ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា សភាវៈឯណាមានអត្ថដ៏ពិត និង មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមដែរ,

**យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេន នោ ច វត្តព្វេ យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ មិច្ឆា** បណ្ដាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យឯណា អ្នកគប្បីពោលនូវពាក្យនោះថា សភាវៈដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា សភាវៈឯណា មានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះ ដែលបណ្ឌិតដឹងថាជាបុគ្គលដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមទេ, ពាក្យរបស់អ្នកខុសទេ,

**នោ ចេ បន វត្តព្វេ យោ សច្ចិកដ្ឋោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ នោ វត រេ វត្តព្វេ បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ** ប្រសិនបើអ្នក មិនគប្បីពោលថា សភាវៈឯណាមានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមទេ, ម្នាលអ្នកដ៏ចម្រើន អ្នកមិនគប្បីពោលថាសភាវៈ ដែលបណ្ឌិតដឹងថាជាបុគ្គលដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមទេ,

**យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ឆិកត្ថ-បរមត្ថេន នោ ច វត្តព្វេ យោ សច្ឆិកត្ថោ បរមត្ថោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកត្ថបរមត្ថេនាតិ មិច្ឆា** បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យឯណា អ្នកគប្បីពោលតែ ពាក្យនោះថាសភាវៈដែលបណ្ឌិតដឹងថាជាបុគ្គល ដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តម តែអ្នកមិនគួរពោលថា សភាវៈឯណាមានអត្ថដ៏ពិត មានអត្ថដ៏ឧត្តម ព្រោះហេតុនោះ សភាវៈនោះ ដែលបណ្ឌិតដឹងថាជាបុគ្គលដោយអត្ថដ៏ពិត និង អត្ថដ៏ឧត្តមទេ ពាក្យរបស់អ្នកខុសទេ ។

**អនុលោមបញ្ចកំ** ចប់អនុលោមបញ្ចកៈ ។

**( សកវាទេ បញ្ចសុត្តសតានិ បរវាទេ បញ្ចសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វាន វិភត្តំ កថាវត្ថុប្បករណំ នាម សមត្តំ )**

(**បករណៈ**ឈ្មោះ **កថាវត្ថុ** ដែលលោកប្រជុំមកនូវសូត្រ ១.០០០ គឺ ៥០០ សូត្រ ក្នុងសកវាទី, ៥០០ ក្នុងបរវាទី ដែលលោកចែកហើយ ចប់តែប៉ុណ្ណេះ) ។

## **កថាវត្ថុ** (ក្នុងអដ្ឋកថា)

**(តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ)**

**សកវាទេ បញ្ចសុត្តសតានិ បរវាទេ បញ្ចសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វា វិភត្តំ កថាវត្ថុប្បករណំ នាម សមត្តំ ។**

**(ឆ វិធេន វិភត្តំ បុគ្គលបញ្ញត្តិប្បករណំ នាម សមត្តំ)**

(កថាវត្ថុប្បករណ៍ ដែលប្រជុំចែកជា ១.០០០ សូត្រ, គឺ ៥០០សូត្រ របស់សកវាទី ៥០០ សូត្រ របស់បរវាទី, ចប់តែប៉ុណ្ណោះ)

# យមកៈ (ក្នុងបាលី)[១]

## (តទនន្តរំ យមកប្បករណំ នាមេតំ)

(លំដាប់អំពីបករណៈឈ្មោះកថាវត្ថុនោះមក យើងនឹងសូត្រនូវ បករណៈឈ្មោះ **យមកៈ**, ឯបករណៈឈ្មោះ **យមកៈ** នោះ គឺ) :

**យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា យេ វា បន កុសលមូលា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំអស់នោះ មានកុសលជាមូល, មួយយ៉ាងទៀត ពួកធម៌ណាមានកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

**យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលា យេ វា បន កុសលមូលេន ឯកមូលា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយកុសលមូល, មួយយ៉ាងទៀត ពួកធម៌ណាមានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

[១] មាននៅក្នុងមូលយមកៈ អភិធម្មបិដក យមក បឋមភាគ បិដក ៨៧, ទំព័រ ១ ។

**យេកេចិ កុសលមូលេន ឯកមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយ មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានឹងគ្នាជាមូលដោយកុសលមូល, មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានឹងគ្នាជាមូលដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

**យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា យេ វា បន កុសលមូលមូលា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល, មួយយ៉ាងទៀត ពួកធម៌ណា មានកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

**យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលា យេ វា បន កុសលមូលេន ឯកមូលមូលា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយកុសលមូល, មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល,

**យេកេចិ កុសលមូលេន ឯកមូលមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលា យេ វា បន កុសលមូលេន**

**អញ្ញមញ្ញមូលមូលា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយកុសលមូល, ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល, មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

**យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលកា យេ វា បន កុសលមូលកា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល, មួយយ៉ាងទៀត ពួកធម៌ណា មានកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

**យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលកា យេ វា បន កុសលមូលេន ឯកមូលកា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយដោយកុសលមូល, មួយយ៉ាងទៀត ពួកធម៌ណាមានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

**យេ កេចិ កុសលមូលេន ឯកមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលកា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយ មាន

មូលតែមួយ ដោយកុសលមូល, ពួកធម៌ទាំងអស់នោះ មានគ្នានឹងគ្នាជាមូល ដោយកុសលមូល, មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានឹងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល ។

**យេកេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលកា យេ វា បន កុសលមូលមូលកា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលមូលជាមូល, មួយយ៉ាងទៀត ពួកធម៌ណាមានកុសលមូលជាមូល ពួកធម៌ទាំងអស់នោះជាកុសល។

**យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលកា យេ វា បន កុសលមូលេន ឯកមូលមូលកា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយកុសលមូល, មួយយ៉ាងទៀតពួកធម៌ណាមានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល ។

**យេកេចិ កុសលមូលេន ឯកមូលមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលកា សព្វេ តេ ធម្មា កុសលា** ពួកធម៌ណាមួយមានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មាន

មូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល, មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

**មូលំ ហេតុ និទានញ្ច សម្ភវោ បភវេន ច សមុដ្ឋានា--ហារារម្មណា បច្ចយោ សមុទយេន ចាតិ** មូល១ ហេតុ១ និទាន១ សម្ភវៈ១ បភវៈ១ សមុដ្ឋាន១ អាហារ១ អារម្មណ៍១ បច្ច័យ១ សមុទយ១

**(មូលយមកាទិទសយមកប្បដិមណ្ឌិតំ យមកប្បករណំ នាម សមត្តំ)**

(**បករណៈ**ឈ្មោះ **យមកៈ** ដែលប្រដាប់ដោយ **យមកៈ** ១០ មានមូលយមកៈជាដើម ចប់តែប៉ុណ្ណេះ) ។

## **យមកៈ** (ក្នុងអដ្ឋកថា)

**(តទនន្តរំ យមកប្បករណំ នាមេតំ)**

**មូលយមកំ ខន្ធយមកំ អាយតនយមកំ ធាតុយមកំ សច្ចយមកំ សង្ខារយមកំ អនុសយយមកំ ចិត្តយមកំ ធម្មយមកំ ឥន្ទ្រិយយមកន្តិ** ។

**(ទសវិធេន វិភត្តំ យមកប្បករណំ នាម សមត្តំ)**

(យមកប្បករណ៍ ចែកចេញដោយ **យមកៈ** ១០ ប្រការ ចប់តែប៉ុណ្ណេះ)

# បដ្ឋាន (ក្នុងបាលី)

## (តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ)

(លំដាប់អំពីបករណៈឈ្មោះ **យមកៈ** នោះមក យើងនឹងសូត្រនូវ
បករណៈឈ្មោះ **មហាបដ្ឋាន** ឯបករណៈឈ្មោះ **មហាបដ្ឋាន** នោះ គឺ) :

| | | | |
|---|---|---|---|
| ~ | **ហេតុប្បច្ចយោ** | **អារម្មណប្បច្ចយោ** | **អធិបតិប្បច្ចយោ** |
| | ហេតុប្បច្ច័យ [១] | អារម្មណប្បច្ច័យ | អធិបតិប្បច្ច័យ, |
| ~ | **អនន្តរប្បច្ចយោ** | **សមនន្តរប្បច្ចយោ** | **សហជាតប្បច្ចយោ** |
| | អនន្តរប្បច្ច័យ | សមនន្តរប្បច្ច័យ | សហជាតប្បច្ច័យ |
| ~ | **អញ្ញមញ្ញប្បច្ចយោ** | **និស្សយប្បច្ចយោ** | **ឧបនិស្សយប្បច្ចយោ** |
| | អញ្ញមញ្ញប្បច្ច័យ | និស្សយប្បច្ច័យ | ឧបនិស្សយប្បច្ច័យ |
| ~ | **បុរេជាតប្បច្ចយោ** | **បច្ឆាជាតប្បច្ចយោ** | **អាសេវនប្បច្ចយោ** |
| | បុរេជាតប្បច្ច័យ | បច្ឆាជាតប្បច្ច័យ | អាសេវនប្បច្ច័យ |
| ~ | **កម្មប្បច្ចយោ** | **វិបាកប្បច្ចយោ** | **អាហារប្បច្ចយោ** |
| | កម្មប្បច្ច័យ | វិបាកប្បច្ច័យ | អាហារប្បច្ច័យ |
| ~ | **ឥន្ទ្រិយប្បច្ចយោ** | **ឈានប្បច្ចយោ** | **មគ្គប្បច្ចយោ** |
| | ឥន្ទ្រិយប្បច្ច័យ | ឈានប្បច្ច័យ | មគ្គប្បច្ច័យ |

[១] **បច្ច័យ** ទាំង២៤នេះ មានសេចក្ដីពិស្ដារក្រៃពេក សូមមើលអភិធម្មបិដកត្រង់គម្ពីរ **បដ្ឋាន** បន្ថែមទៀតផងចុះ ។

~ **សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ**

សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ

~ **នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ**

នត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ ។

~ **តិកញ្ច បដ្ឋានវរំ ទុកុត្តមំ**

**ទុកត្តិកញ្ចេវ តិកទុកញ្ច**

**តិកត្តិកញ្ចេវ ទុកទុកញ្ច**

**ឆ អនុលោមម្ហិ នយា សុគម្ភីរា ។**

ន័យទាំងឡាយ ៦ គឺ : តិកប្បដ្ឋានដ៏ប្រសើរ១, ទុកប្បដ្ឋានដ៏ឧត្តម១, ទុកត្តិកប្បដ្ឋាន១, តិកទុកប្បដ្ឋាន១, តិកត្តិកប្បដ្ឋាន១, ទុកទុក-ប្បដ្ឋាន១ ជាន័យដ៏ជ្រៅក្នុងអនុលោម ។

~ **តិកញ្ច បដ្ឋានវរំ ទុកុត្តមំ**

**ទុកត្តិកញ្ចេវ តិកទុកញ្ច**

**តិកត្តិកញ្ចេវ ទុកទុកញ្ច**

**ឆ បច្ចនីយម្ហិ នយា សុគម្ភីរា ។**

ន័យទាំងឡាយ ៦ គឺ : តិកប្បដ្ឋានដ៏ប្រសើរ១, ទុកប្បដ្ឋានដ៏ឧត្តម១, ទុកត្តិកប្បដ្ឋាន១, តិកទុកប្បដ្ឋាន១, តិកត្តិកប្បដ្ឋាន១, ទុកទុកប្បដ្ឋាន១ ជាន័យដ៏ជ្រៅក្នុងបច្ចនីយៈ ។

~ តិកញ្ច បដ្ឋានវរំ ទុកុត្តមំ
ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច
ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភិរា ។

ន័យទាំងឡាយ ៦ គឺ : តិកប្បដ្ឋានដ៏ប្រសើរ១, ទុកប្បដ្ឋានដ៏ឧត្តម១, ទុកត្តិកប្បដ្ឋាន១, តិកទុកប្បដ្ឋាន១, តិកត្តិកប្បដ្ឋាន១, ទុកទុកប្បដ្ឋាន១ ជាន័យដ៏ជ្រៅ ក្នុងអនុលោមបច្ចនីយៈ ។

~ តិកញ្ច បដ្ឋានវរំ ទុកុត្តមំ
ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច
ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ភិរាតិ ។

ន័យទាំងឡាយ ៦ គឺ : តិកប្បដ្ឋានដ៏ប្រសើរ១, ទុកប្បដ្ឋានដ៏ឧត្តម១, ទុកត្តិកប្បដ្ឋាន១, តិកទុកប្បដ្ឋាន១, តិកត្តិកប្បដ្ឋាន១, ទុកទុកប្បដ្ឋាន១ ជាន័យដ៏ជ្រៅ ក្នុងបច្ចនីយានុលោម ។

**(ចតុវីសតិប្បច្ចយវសេន អយំ សមន្តប្បដ្ឋានប្បករណវណ្ណនា និដ្ឋិតា)**

(វណ្ណនានៃ **បដ្ឋានប្បករណៈ** ជាទីបំផុតនេះ
ដោយអំណាចនៃ **បច្ច័យ ២៤** ចប់តែប៉ុណ្ណេះ) ។

# បដ្ឋាន (ក្នុងអដ្ឋកថា)

(តទនន្តរំ មហាបដ្ឋានប្បករណំ នាមេត្តំ)

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្ប--ច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្ប-ច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារ--ប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្ត--ប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោតិ ។

(បច្ចយវសេន តា ចតុវីសតិវិធេន វិភត្តំ មហាប្បដ្ឋានប្បករណំ នាម សមត្តំ)

(មហាបដ្ឋានប្បករណ៍ ចែកចេញជាធម៌ ២៤ ប្រការ

ដោយអំណាចនៃបច្ច័យ ចប់តែប៉ុណ្ណេះ)

(ចប់ សត្តប្បករណាភិធម្ម ត្រឹមប៉ុណ្ណេះ)

* **កំណត់សម្គាល់:** ក្នុងការប្រើស្រៈនិស្ស័យ ិ ី ឹ ឺ លើតួព្យញ្ជនៈ **ភ គ ត ភ ទ** ដោយប្រើ **Font Unicode** Khmer OS Muol មានការប្រែទិដ្ឋភាពពី **ភិ ភី ភឹ ភឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ទិ ទី ទឹ** ទៅជាយ៉ាងនេះវិញ ៖ **ភ ភ ភ ភ. គ គ គ គ, ត ត ត ត, ភ ភ ភ ភ,ទ ទ ទ**... អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ អស់លោក-អ្នក មេត្តាជ្រាប ។

# តិរោកុឌ្ឌកណ្ឌគាថា[១]

- **តិរោកុឌ្ឌេសុ តិដ្ឋន្តិ　　សន្ធិសិង្ឃាដកេសុ ច**
**ទ្វារពាហាសុ តិដ្ឋន្តិ　　អាគន្ត្វាន សកំ ឃរំ**

*ពួកប្រេតទាំងឡាយមកហើយ កាន់ផ្ទះនៃញាតិដោយគិតថាផ្ទះរបស់ខ្លួន រមែងឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និង ផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និង ទ្វារផ្ទះទាំងឡាយខ្លះ,*

**បហូតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ** នាកាលបាយ និងទឹក និងបង្អែម និងចំអាបដ៏ល្មមគ្រាន់ គឺពួកញាតិចូលទៅតាំងទុកហើយ,

**ន តេសំ កោចិ សរតិ សត្តានំ កម្មប្បច្ចយា** ញាតិណាមួយ មិននឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយ ជាបច្ច័យ,

**ឯវំ ទទន្តិ ញាតីនំ　　យេ ហោន្តិ អនុកម្បកា**
**សុចឹ បណីតំ កាលេន　　កប្បិយំ បានភោជនំ**

---

[១]បានប្រែតាមសៀវភៅ **អនុមោទនាវិធី** ។

ញាតិទាំងឡាយឯណា តែងអនុគ្រោះ ញាតិទាំងឡាយនោះរមែងឧទ្ទិសឱ្យនូវទឹក និង ភោជនដ៏ឆ្ងាញ់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ ជាអ្នកលះលោកនេះទៅហើយនោះ យ៉ាងនេះថា :

**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ**

ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្តីសុខ !

**តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា**

ក៏ប្រេតជាញាតិទាំងឡាយនោះ មកប្រជុំគ្នាហើយ ក្នុងស្ថានដែលឱ្យទាននោះ ជាអ្នកមកហើយដោយបំណងល្អ,

**បហូតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ**

កាលបើចំណីបាយ និង ទឹកដ៏ល្មមគ្រាន់ ក៏គប្បីអនុមោទនាដោយគោរពថា :

**ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាម** សេ យើងទាំងឡាយបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយឯណា សូមញាតិទាំងឡាយនោះរបស់យើងទាំងឡាយ ចូររស់នៅយឺនយូរ,

**អម្ហាកញ្ច កតា បូជា** ក៏បូជាគឺញាតិទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយ,

**ទាយកា ច អនិប្ផលា** ឯទាយកគឺអ្នកឱ្យទាន ក៏មិនឥតផល,

**ន ហិ តត្ថ កសី អត្ថិ** កសិកម្មគឺការភ្ជួរស្រែចំការក៏មិនមានក្នុងភូមិនៃប្រេតនោះ,

**គោរក្ខេត្ថ ន វិជ្ជតិ** គោរក្ខកម្មគឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេតនោះ,

**វណិជ្ជា តាទិសី នត្ថិ** ពាណិជ្ជកម្មគឺការជួញ ដែលជាហេតុបានសម្បត្តិដូច្នោះ ក៏មិនមាន,

**ហិរញ្ញេន កយាកយំ** មិនមានការលក់ទិញផ្លាស់ប្តូរដោយប្រាក់

**ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហឹ**

បុគ្គលទាំងឡាយ ធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទាន ដែលញាតិឱ្យហើយអំពីលោកនេះ,

**ឧណ្ណតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ**
**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ**

ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទំនាប ដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ,

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ**
**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**

ជ្រលងផ្លូវទឹកទាំងឡាយ មានទន្លេ និង ស្ទឹងជាដើម រមែងញ៉ាំងសាគរឱ្យពេញព្រៀបដូចម្ដេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ។

**អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ**

**បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ**

បុគ្គលកាលរលឹកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ, ជនទាំងឡាយនោះ ជាញាតិមិត្រ និង ជាសម្លាញ់របស់អញដូច្នេះហើយ គួរឱ្យទក្ខិណាទាន ដើម្បីប្រេតទាំងឡាយ,

**ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា** ការយំ ឬការសោកសៅ ឬការខ្សឹកខ្សួលដទៃ ៗ មិនមានប្រយោជន៍ឡើយ,

**ន តំ បេតានមត្ថាយ** ធ្វើដូច្នេះរកបានជាប្រយោជន៍ ដល់ប្រេតទាំងឡាយគ្មាន,

**ឯវំ តិដ្ឋន្តិ ញាតយោ** ញាតិទាំងឡាយរមែងស្ថិតនៅ ឥតបានដឹង បានឮ យ៉ាងនេះ,

**អយញ្ច ខោ ទក្ខិណា ទិន្នា** បើទក្ខិណាទាន ដែលបុគ្គលបានឱ្យហើយនេះឯង,

**សង្ឃម្ហិ សុបតិដ្ឋិតា** ជាទានតម្កល់នៅល្អហើយក្នុងសង្ឃ,

**ទីយរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ** ទក្ខិណាទាននោះ ទើបចូលទៅសម្រេចតាមស្ថាន ដើម្បីជាប្រយោជន៍ដល់ប្រេតទាំងនោះ អស់កាលជាអង្វែង,

**សោ ញាតិធម្មោ ច អយំ និទស្សិតោ** ក៏ញាតិធម៌នោះគឺអ្នកបានសំដែងជាបែបយ៉ាងហើយ,

**បេតាន បូជា ច កតា ឧឡារា** ការបូជាដ៏ថ្លៃថ្លាចំពោះដល់ប្រេតទាំងឡាយ គឺអ្នកបានធ្វើហើយ,

**ពលញ្ច ភិក្ខូនមនុប្បទិន្នំ** កម្លាំងកាយនៃភិក្ខុទាំងឡាយឈ្មោះថា គឺអ្នកបានបំពេញឱ្យហើយ,

**តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ** បុណ្យគឺអ្នកសន្សំទុកហើយមិនមែនតិចដូច្នេះ ។ ៚.

**យទិ ហីនេ គតោ ឋានេ កាយទុច្ចរិតេន វា** បើញាតិណាមួយ ទៅកើតក្នុងទីដ៏ថោកទាប ព្រោះកាយទុច្ចរិតក្តី (វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី),

**ឥមិនា បុញ្ញតេជេន តម្ហា ឋានា បមុញ្ចតុ** ក៏សូមឱ្យរួចរដោះចាកទី (ដ៏ថោកទាប) នោះ ដោយតេជះគឺបុណ្យនេះ,

**យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ** ឬបើទៅកើតក្នុងទេវបុរី ជាវិមានគួរីករាយ ដែលជាឋានមានលំអដោយរតនៈ (ផ្សេងៗ) ស្រាប់ហើយ,

**ឥមិនា បុញ្ញតេជេន អភិយ្យោ អភិយ្យោ បវឌ្ឍតុ** ក៏សូមឱ្យរីងរឹតតែចម្រើនជាអភិយ្យោភាព ដោយតេជះគឺបុណ្យនេះ,

**ឯវំ មហិទ្ធិយា ឯសា យទិទំ បុញ្ញសម្បទា** បុញ្ញសម្បទា គឺគុណជាតិជាហេតុដល់ព្រមដោយបុណ្យឯណា បុញ្ញសម្បទានេះ មានឫទ្ធិដ៏ធំក្រៃលែង ដោយប្រការយ៉ាងនេះ,

**តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ** ព្រោះហេតុនោះបណ្ឌិតទាំងឡាយ អ្នកមានប្រាជ្ញា រមែងសរសើរនូវភាពនៃបុគ្គល អ្នកមានបុណ្យធ្វើទុកហើយ,

**សុខោ វិបាកោ បុញ្ញានំ** ផលរបស់បុណ្យទាំងឡាយ រមែងនាំមកនូវសេចក្ដីសុខ,

**អធិប្បាយោ សមិជ្ឈតិ** សេចក្ដីប្រាថ្នារមែងសម្រេច,

**ខិប្បញ្ច បរិយោសានេ និព្វានំ សមធិគច្ឆតិ** ម្យ៉ាងទៀតក្នុងកាលជាទីបំផុត បុគ្គលរមែងបាននូវព្រះនិព្វានដ៏ឆាប់រហ័ស,

**យោ ភាជនសហស្សេហិ បូរណំ វរភោជនំ**

**ទទេយ្យាបរិមាណានំ ឯកបត្តម្បិ នាលភេ**

**ពុទ្ធុប្បាទេ សារីបុត្តោ យេ ចញ្ញេ អគ្គសាវកា**

បុគ្គលគប្បីឱ្យនូវវរភោជន ដ៏ពេញដោយភាជនៈមួយពាន់ ក៏មិនបានស្មើនឹងភោជនមួយបាត្រ ដែលគេបានឱ្យហើយ ដល់ព្រះសារីបុត្ត និងពួកអគ្គសាវកដទៃក្នុងពុទ្ធុប្បាទ (នេះ) ដែលមានគុណប្រមាណមិនបាន,

បត្តប្បានុភាវេន មាតាបិតា បមុព្ភូវេ (ព្រោះហេតុនោះ) បានជាមាតា និង បិតា រមែងរួច (ចាកទីដ៏ថោកទាប) ដោយអានុភាព នៃបាយដែលពេញក្នុងបាត្រ។./.

* **<u>កំណត់សម្គាល់:</u>** ក្នុងការប្រើស្រៈនិស្ស័យ ិ ី ឹ ឺ លើតួព្យញ្ជនៈ **ភ គ ត ភ ខ** ដោយប្រើ Font Unicode <u>Khmer OS Muol</u> មានការប្រែប្រួលទិដ្ឋភាពពី **ភិ ភី ភឹ ភឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ខិ ខី ខឹ** ទៅជាយ៉ាងនេះវិញ ៖ **ភិ ភី ភឹ ភឺ. គិ គី គឹ គឺ, តិ តី តឹ តឺ, ភិ ភី ភឹ ភឺ,ខិ ខី ខឹ**... អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ អស់លោក-អ្នកសិក្ខាកាម មេត្តាជ្រាប និង បានសិក្សាឈ្វេងយល់ពីសំណេរបែបបុរាណខ្មែរ ។

## <u>បទពិចារណា</u>

**អធុវំ មេ ជីវិតំ** ជីវិតរបស់យើង មិនទៀងទាត់,

**ធុវំ មេ មរណំ** សេចក្តីស្លាប់របស់យើង ទៀងទាត់,

**អវស្សំ មយា មរិតព្វំ** យើងត្រូវស្លាប់ជាប្រាកដ!

**មរណបរិយោសានំ មេ ជីវិតំ!**

ជីវិតរបស់យើង មានសេចក្តីស្លាប់ ជាទីបំផុត!

**ជីវិតំ មេ អនិយតំ** ជីវិតរបស់យើង មិនទៀង,

**មរណំ និយតន្តិ** សេចក្តីស្លាប់ ទៀង!

**ឯវំ មរណស្សតិ** ទីបំផុត គឺសេចក្តីស្លាប់ !

**<u>ស្រង់ចាកគម្ពីរធម្មបទដ្ឋកថាបាលី ភាគទី៦</u> (លោកវគ្គ)*

# ផ្សាយធម៌មេត្តាដល់សព្វសត្វ

- **សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**
  **សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ,**
- **សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**
  **សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ,**
- **សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**
  **សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ,**
- **សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**
  **សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ,**
- **សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ,**
  **សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ !**

*បាលីផ្សាយមេត្តាចំពោះសព្វសត្វ ក្នុងទិសទាំង១០នេះ មានសេចក្តីដូចគ្នាដដែលៗ ដោយហេតុនេះ សូមប្រែរួបរួមដោយខ្លីថា:*

ពួកសត្វទាំងអស់ ក្នុងទិសបូព៌ ទិសអគ្នេយ៍ ទិសទក្សិណ ទិសនិរតី ទិសបស្ចិម ទិសពាយ័ព្យ ទិសឧត្តរ ទិសឦសាន ទិសខាងក្រោម ទិសខាងលើ សូមឱ្យជាសត្វមិនមានពៀរនឹងគ្នា សូមឱ្យមានតែសេចក្តីសុខ (ជានិច្ចនិរន្តរ៍តទៅ) ។

- **សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តិហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ!**

*ពួកសត្វទាំងអស់ សូមកុំមានពៀរនឹងគ្នា, សូមឱ្យបានតែសេចក្តីសុខ, ឱ្យប្រាសចាកទុក្ខ, កុំព្យាបាទគ្នា, កុំមានសេចក្តីព្រួយចំបែង, សូមឱ្យមានអាយុវែង, កុំឱ្យមានរោគ សូមឱ្យសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឱ្យជាសុខ (តរៀងទៅ)!*

- **ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ !**

*សត្វទាំងឡាយទាំងពួង ដែលកំពុងដល់នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលកំពុងដល់នូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ, ដែលកំពុងដល់នូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង !!!*

**(ចប់ ប្រជុំភាណវារ បាលី-ប្រែ ពិសេស)**

# ឯកសារពិគ្រោះ

១._ **គម្ពីរព្រះត្រៃបិដកខ្មែរ**

២._ **ប្រជុំភាណវារ** .......... ប្រមូលរៀបរៀងដោយលោក សែម_សូរ ព.ស.២៥០៨

៣._ **ភិក្ខុប្បាតិមោក្ខ** បាលី_ប្រែ. ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៤៩២

៤._ **សត្តបរិត្ត_ទ្វាទសបរិត្ត** ... ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១៥

៥._ **សត្តបរិត្ត_ទ្វាទសបរិត្ត** ... ការផ្សាយរបស់គណៈកម្មការធម្មវិន័យព្រះពុទ្ធសាសនា បោះពុម្ពក្នុង ព.ស.២៥៣២

៦._ **បញ្ចខ្ជាខន្ធកៈ** ..................... ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព. ស. ២៥១៣

៧._ **សាមណេរវិន័យ** ............. ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព. ស. ២៥១៥

៨._ **អនុមោទនាវិធី** ................ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០៩

៩._ **វចនានុក្រមខ្មែរ** ........................................ សម្តេចព្រះសង្ឃរាជ **ជួន_ណាត**

© រៀបរៀងអត្ថបទ និង ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ចប់សព្វគ្រប់
ក្នុងវស្សានរដូវ ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ **២៥៦០** (Aug. 2016)
© **ព្រហ្ម-មេត្តា គគបណ្ឌិតោ** (ហៅ *ជយវិទ្ធ*)

*បោះពុម្ពសម្រាប់ជាធម្មទាន ដោយ*

**ក្រុមធម្មមាមកជន សហគមន៍ធម្មទាន**

# ភទ្ទេករត្តសូត្រ[១]

## ភគវា ឯតទវោច

- អតីតំ នាន្វាគមេយ្យ នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ អប្បត្តញ្ច អនាគតំ
បច្ចុប្បន្នញ្ច យោ ធម្មំ តត្ថ តត្ថ វិបស្សតិ
អសំហីរំ អសង្កុប្បំ តំ វិទ្វា មនុព្រូហយេ
- អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា
ឯវំ វិហារិមាតាបឹ អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ សន្តោ អាចិក្ខតេ មុនីតិ !

**ព្រះមានព្រះភាគ** ទ្រង់ត្រាស់ដូច្នេះថា: បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធដែលកន្លងទៅហើយ, មិនគប្បីប្រាថ្នាបញ្ចក្ខន្ធដែលមិនទាន់មកដល់ទេ ព្រោះបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះកន្លងហួសទៅហើយ, បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះក៏មិនទាន់មកដល់, *មួយទៀត បុគ្គលណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម និងមិនបានកម្រើក(ដោយពួកកិលេស) គប្បីចម្រើនឱ្យរឿយៗនូវផលសមាបត្តិដែលមានព្រះនិព្វានជាអារម្មណ៍នោះ* **ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ,** *អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិលច្រអូសអស់យប់ និង ថ្ងៃនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន!*

---

[១] ស្រង់ចាក **សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក** (បិដកភាគ ២៨ / ទំ.២) ។

# ព្រះពុទ្ធោវាទ

- **ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ**

**ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។**

បុគ្គល កាលស្វះស្វែងរកកល្យាណមិត្ត បើមិនបាន មិត្តដ៏ប្រសើរជាងខ្លួន ឬ មិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្ត នៅតែម្នាក់ឯងឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា **សហាយតាគុណ** មិនមានក្នុងបុគ្គលពាលឡើយ !

(ស្រង់ចាក **សុត្តន្តបិដក ខុទ្ទកនិកាយ** : បិដកលេខ ៥២ / ទំព័រ ៣៤)

- **សព្វំ បរវសំ ទុក្ខំ សព្វំ ឥស្សរិយំ សុខំ**

**សាធារណេ វិហញ្ញន្តិ យោគា ហិ ទុរតិក្កមាតិ ។**

(ប្រយោជន៍ណាមួយ) ដែលនៅក្នុងអំណាចនៃជនដទៃ ទាំងអស់ នាំមកនូវទុក្ខ, **ឥស្សរភាព** ទាំងអស់ នាំមកនូវសុខ, សត្វទាំងឡាយ ដែលជ្រមុជទៅក្នុងហេតុនៃទុក្ខទូទៅ តែង នឿយព្រួយ ព្រោះកិលេសជាគ្រឿងប្រកបទាំងឡាយ សត្វ កន្លងបានដោយក្រ !

(ស្រង់ចាក **សុត្តន្តបិដក ខុទ្ទកនិកាយ** : បិដកលេខ ៥២ / ទំព័រ ១៥៤)

☸ **សោចតិ បុត្តេហិ បុត្តិមា (ឥតិ ភគវា)**
**គោមិកោ គោហិ តថេវ សោចតិ**
**ឧបធីហិ នរស្ស សោចនា**
**ន ហិ សោ សោចតិ យោ និរូបធីតិ ។**

(**ព្រះមានព្រះភាគ** ត្រាស់ថា) បុគ្គលមានបុត្រ រមែងសោក នឹងបុត្រទាំងឡាយ, បុគ្គលមានគោ រមែងសោកនឹងគោទាំងឡាយ ដូច្នោះដែរ, ការសោករបស់នរជនរមែងមាន ព្រោះតែ**ឧបធិ**ទាំងឡាយ លុះតែបុគ្គលណាមិនមានឧបធិ បុគ្គលនោះទើបមិនសោក ។

(ស្រង់ចាក **ធនិយសូត្រ**, **សុត្តន្ត. ខុទ្ទក.** សុត្តនិបាត, បិ. ៥៤, ទំ.១២)

☸ **ន មានំ ព្រាហ្មណ សាធុ អត្ថិ កស្សីធ ព្រាហ្មណ**
**យេន អត្ថេន អាគច្ឆិ តមេវមនុព្រូហយេតិ ។**

ម្នាលព្រាហ្មណ៍! មានះរបស់បុគ្គលណា ក្នុងលោកនេះ ម្នាល ព្រាហ្មណ៍ មានះនោះ មិនប្រពៃទេ, **បុគ្គលមកហើយដោយប្រយោជន៍ ណា បុគ្គលត្រូវបម្រើននូវប្រយោជន៍នោះឯង ។**

(ស្រង់ចាក **មានត្ថទ្ធសូត្រ**, **សុត្តន្ត. សំយុត្ត.** សគាថវគ្គ, បិ. ៣០, ទំ.១៣០)

☸ នាភិនន្ទាមិ មរណំ		នាភិនន្ទាមិ ជីវិតំ
និក្ខិបិស្សំ ឥមំ កាយំ		សម្បជានោ បតិស្សតោ ។

នាភិនន្ទាមិ មរណំ		នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ		និព្វិសំ ភតកោ យថា ។

ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំជាបុគ្គលដឹងខ្លួន មានស្មារតីខ្ជាប់ខ្ជួន ទម្លាយចោលនូវរាងកាយនេះ ។

ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំរង់ចាំតែកាល( **បរិនិព្វាន** ) ដូចអ្នកស៊ីឈ្នួល ទន្ទឹងតែការអស់ទៅនៃថ្ងៃ ។

☸ ឧភយេនមិទំ មរណមេវ		នាមរណំ បច្ឆា វា បុរេ វា
បដិបជ្ជថ មា វិនស្សថ		ខណោ វេ មា ឧបច្ចគា ។

**មរណៈ**នេះឯង រមែងមានក្នុងកាលទាំងពីរ **មរណៈ**មិនមែនមានតែក្នុងកាលខាងក្រោយ ឬខាងមុខទេ, អ្នកទាំងឡាយចូរប្រតិបត្តិ អ្នកទាំងឡាយចូរកុំវិនាស កុំឱ្យខណៈប្រព្រឹត្តកន្លង ។

( ស្រង់ចាក **ថេរគាថា, សុត្តន្ត. ខុទ្ទក.**, បិ. ៥៧, ទំ. ២៧, ៤១, ៩១ )

☸ ន គណេន បុរក្ខតោ ចរេ
ទមនោ ហោតិ សមាធិ ទុល្លភោ
នានាជនសង្គហោ ទុក្ខោ
ឥតិ ទិស្វាន គណំ ន រោចយេ ។

..............................................

បង្កោតិ ហិ នំ អវេទយុំ
យាយំ វន្ទនបូជនា កុលេសុ
សុខុមំ សល្លំ ទុរុព្វហំ
សក្ការោ កាបុរិសេន ទុជ្ជហោ ។

ភិក្ខុមិនគប្បីប្រព្រឹត្តមានគណៈចោមរោម (ព្រោះ)រមែងមានចិត្តក្តៅក្រហាយ បានសមាធិដោយលំបាក, ការសង្គ្រោះជននានា នាំមកនូវសេចក្តីទុក្ខ ភិក្ខុឃើញដូច្នេះហើយ មិនគប្បីត្រេកអរនឹងគណៈឡើយ ។ អ្នកប្រាជ្ញ មិនគប្បីចូលទៅអែបអបនឹងត្រកូលទាំងឡាយទេ (ព្រោះ) រមែងមានចិត្តក្តៅក្រហាយ បានសមាធិដោយលំបាក ភិក្ខុណាជាអ្នកល្មោភក្នុងរសមានចម្ងាញ់ ភិក្ខុនោះជាអ្នករនេះរនាត ជាប់ចិត្តក្នុងរស រមែងខូចបង់ប្រយោជន៍ ។ មែនពិត អ្នកប្រាជ្ញទាំងឡាយបានដឹងនូវការថ្វាយបង្គំ និង ការបូជាក្នុងត្រកូលទាំងឡាយ ថាដូចជាភក់(ព្រោះថា) **សរ គឺកិលេសល្អិតៗ** ភិក្ខុកន្លងបង់បានដោយលំបាក **គ្រឿងសក្ការៈ** បុរសលាមក លះបង់បានដោយក្រ ។

(ស្រង់ចាក **ថេរគាថា** *ចត្តាឡីសនិបាត:* **សុត្តន្ត. ខុទ្ទក.** បិ. ៥៧,ទំ.៩៩)

- រូបា សទ្ទា គន្ធា រសា ផស្សា ធម្មា ច កេវលា
ឥដ្ឋា កន្តា មនាបា ច យាវតត្ថីតិ វុច្ចតិ
សទេវកស្ស លោកស្ស ឯតេ វោ សុខសម្មតា
យត្ថ ចេ តេ និរុជ្ឈន្តិ តំ នេសំ ទុក្ខសម្មតំ ។

- សុខន្តិ ទិដ្ឋមរិយេហិ សក្កាយស្សុបរោធនំ
បច្ចនីកមិទំ ហោតិ សព្វលោកេន បស្សតំ ។

- យំ បរេ សុខតោ អាហុ តទរិយា អាហុ ទុក្ខតោ
យំ បរេ ទុក្ខតោ អាហុ តទរិយា សុខតោ វិទូ
បស្ស ធម្មំ ទុរាជានំ សម្បមូឡ្ហេត្ថ អវិទ្ទសូ ។

- និវុតានំ តមោ ហោតិ អន្ធការោ អបស្សតំ
សតញ្ច វិវដំ ហោតិ អាលោកោ បស្សតាមិវ
សន្តិកេ ន វិជានន្តិ មគ្គា ធម្មស្ស កោវិទា ។

- ភវរាគបរេតេហិ ភវសោតានុសារិហិ
មារធេយ្យានុប្បន្នេហិ នាយំ ធម្មោ សុសម្ពុទ្ធោ ។
- កោ នុ អញ្ញត្រ អរិយេហិ បទំ សម្ពុទ្ធុមរហតិ
យំ បទំ សម្មទញ្ញាយ បរិនិព្វន្តិ អនាសវាតិ ។

(ស្រង់ចាក**ទ្វយតានុបស្សនាសូត្រ**ទី១២, សុត្តន្ត. ខុទ្ទក. សុត្តនិបាត, បិ. ៥៤ /ទំ.២៦២)
សូមសិក្សាផងដែរនៅក្នុងឧទាននៃ**ទេវទហវគ្គ**, សុត្តន្ត. សំយុត្ត. សឡាយតនវគ្គ, បិ. ៣៥ /ទំ.២៩២
ស័ព្ទបាលីមានការប្លែកគ្នា( ពីក្នុងសុត្តន្ត. ខុទ្ទក. សុត្តនិបាត ) ដោយអន្លើខ្លះ ។

**រូប សំឡេង ក្លិន រស ផស្សៈ ធម្មារម្មណ៍** ទាំងអស់ ជាទីប្រាថ្នា ជាទីស្រឡាញ់ និង ជាទីពេញចិត្ត លោកពោលថា មាននៅដរាបណា អារម្មណ៍ទាំងនុ៎ះ សត្វលោក ព្រមទាំងទេវលោក សន្មតថាជាសុខ(ដរាបនោះ), **អារម្មណ៍ទាំងនោះតែងរលត់ទៅ ក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ** ពួកសត្វលោកទាំងនោះ សន្មតថាជាទុក្ខវិញ ។

**ការរលត់នូវសក្កាយ គឺខន្ធទាំង៥** ព្រះអរិយៈទាំងឡាយ ឃើញថាជាសុខពិត,ការឃើញ(របស់ព្រះអរិយៈ)អ្នកយល់នេះជាទំនាស់នឹងសត្វលោកទាំងពួង។ពួកជនពាលដទៃ ពោលនូវវត្ថុកាមណាថាជាសុខ ព្រះអរិយៈទាំងឡាយពោលនូវវត្ថុកាមនោះថាជាទុក្ខ, ពួកជនពាលដទៃ ពោលនូវព្រះនិព្វានណាថាជាទុក្ខ ព្រះអរិយៈទាំងឡាយ ដឹងច្បាស់នូវព្រះនិព្វាននោះថាជាសុខ, អ្នកចូរឃើញនូវនិព្វានធម៌ ដែលដឹងបានដោយក្រ ពួកអ្នកមិនដឹង វង្វេងហើយក្នុងធម៌នុ៎ះ ។ សេចក្ដីងងឹតធ្វើនូវភាពខ្វាក់ តែងប្រាកដដល់ពួកជនពាលដែលអវិជ្ជាបិទបាំង មិនឃើញនូវព្រះនិព្វាន, ឯព្រះនិព្វានដូចជាពន្លឺ រមែងបើកបង្ហាញដល់ពួកសប្បុរសអ្នកឃើញ ពួកជនអ្នកមិនឈ្លាសវៃនូវធម៌ គឺព្រះនិព្វាន រមែងមិនដឹងច្បាស់(នូវព្រះនិព្វាន) សូម្បីមានក្នុងទីជិតឡើយ ។

**ព្រះនិព្វាននេះ** ពួកជនពាលដែលមានភវរាគៈ គ្របសង្កត់ហើយ កំពុងអន្ទោលទៅ តាមខ្សែក្នុងភព កើតហើយក្នុងកន្លែងរបស់មារ មិនងាយនឹងត្រាស់ដឹងបានឡើយ ។ នរណាហ្ន៎! វៀរលែងតែព្រះអរិយៈចេញ គួរនឹងត្រាស់ដឹងនូវព្រះនិព្វានបាន, ព្រះអរហន្តទាំងឡាយ មិនមានអាសវធម៌ បរិ--និព្វានហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ នូវព្រះនិព្វាន ៕ល៚

(ស្រង់ចាក **ទ្វយតានុបស្សនាសូត្រ** ទី១២, សុត្តន្ត. ខុទ្ទក. សុត្តនិបាត, បិ. ៥៤/ទំ.២៦២)

រឿងលោកិយ ប្រាំបីរឿង គ្រឿងញាប់ញ័រ
នាំចិត្តចរ គ្រាច់តក្រុក រកសុខលោក
សែនរវល់ អំពល់ទុក្ខ មុខមាត់មោយ
រស់មានជោគ ទោះមានក្រ **ប្រព្រឹត្តធម៌** !

---

រឿងជីវិត ប្រព្រឹត្តទៅ នៅក្នុងលោក
សែនវិយោគ រោគអួតអាង សាងអញឯង
ជញ្ជីងកម្ម ចាំថ្លឹងផល ផ្តល់ជាក់ស្តែង
លះចំបែង វែងជីវិត **ប្រព្រឹត្តធម៌** !

---

រឿងជីវិត គិតឲ្យល្អ ធម៌សន្តោស
រឿងទាំងអស់ ដោះដោយធម៌ ស្មោះសរព្រម
តម្កល់ចិត្ត ឋិតក្នុងធម៌ ឥតប្រឈម
សុខ ស្ងប់ ព្រម ល្ហមនឹងរស់ **ប្រព្រឹត្តធម៌** !

---

ភ្លើងរលោក ពាក្យសរសើរ ស្មើសម្លាប់
ពាក្យបង្អាប់ ប្រាប់ដំណឹង ដឹងដំណើរ
រក្សាចិត្ត ឥតខ្វាយខ្វល់ តម្កល់ស្មើ
ប្រុងដំណើរ ប្រើជីវិត **ប្រព្រឹត្តធម៌** !

---

☸ ភ្លើងកិលេស ឆេះទ្រលោម បន្ទ្រាមលោក
អញជោរជោក កញ្ច្រោកចិត្ត ត្រាច់ដូចព្រាន
**អវិជ្ជា** **គ្នាតណ្ហា** **ឧបាទាន**
នាំ**វិញ្ញាណ** ហ៊ានត្រាច់ទៅ លំនៅខ្មាំង ។

☸ **មុត្រព្រះពុទ្ធ** បរិសុទ្ធពិត **ប្រព្រឹត្តធម៌**
លះញាប់ញ័រ ធម៌លោកិយ ប្រាំបីបាំង
កំណត់ដឹង ហ្នឹងជំរំ លំនៅខ្មាំង
អវិជ្ជាបាំង ខ្មាំងក្នុងខ្លួន បំពួនទុក្ខ ។

☸ លះលោភៈ ទោសៈចិត្ត ជ្បិតមោហៈ
នាំចិត្តខ្វាក់ ធ្លាក់លង់ខ្លៅ ក្ដៅគគុក
ចិត្តស្រវឹង មិនដឹងធម៌ ត្រាច់តត្រុក
ស្វែងរកសុខ ក្នុងទុក្ខជ្រៅ ទៅអបាយ ។

☸ ជាតិបណ្ឌិត ពិតពេញប្រាជ្ញ ខ្លាចចិត្តខ្លៅ
ស្គាល់ទិសដៅ ផ្លូវត្រូវដើរ ដំណើរឆ្ងាយ
ឃើញធម៌ពិត គិតហាត់លះ ឈ្នះសក្កាយ
មិនសោកស្ដាយ **ចាយជីវិត** **ប្រព្រឹត្តធម៌** !

***វិភាគទាននៃការពិចារណា*** © **ព្រហ្ម-មេត្តា** (**ជយវិទ្ធ**)

# លោកនេះមិនគួរនៅ !!!

(បទនិពន្ធ របស់ លោកគ្រូអគ្គបណ្ឌិត ធម្មាចារ្យ **ប៊ុត-សាវង្ស**)

---

\- កណ្តាលទីក្រុងចាស់ មើលឃើញច្បាស់ ភ្នំជុំវិញ
នឹកព្រះខំបំពេញ ធម៌ដើរចេញ ចាកលោកា ។

\- ដើរតាមស្នាមព្រះបាទ ព្រះលោកនាថ ព្រះសាស្តា
ព្រមទាំងអរហន្តា ចាកលោកា ចូលនិព្វាន ។

\- **លោកនេះមិនគួរនៅ សុទ្ធសត្រូវ តែងរុករាន**
ព្រះនាំទៅនិព្វាន សត្វកោដិលានចេញចាកឋាន ។

\- ឥឡូវទៅអស់ហើយ គឺនៅឡើយ តែលំអាន
មិនយូរនឹងបាត់ដាន ផ្លូវនិព្វាន គ្មានអ្នកដើរ ។

\- កាលនោះដែនមគធៈ សុទ្ធអរិយៈ អ្នកប្រសើរ
ឥឡូវចេញដំណើរ ដើរទៅបាត់ ស្ងាត់អស់ហើយ !

(ស្រង់ចាកសៀវភៅ **ជីវិតខ្ញុំ** ភាគទី ១៤ / ទំព័រ ១៩៩)

# ធម្មទស្សនទាន

* វាលវដ្តសង្សារ មហាធំធេង សត្វលោកវង្វេង លេងលោកប្រាំមួយ
សក្កាយប្រកាន់ លើកខន្ធប្រាំស្ងួយ ញាប់ញ័រព្រួយ ជាមួយតណ្ហា ។

* កិលេសកាមលោក ហូរបញ្ជោកចិត្ត ប្រកាន់ជាប់ស្អិត ស្និទ្ធស្នាលកាមា
សេពគប់អកុសល ខ្វាយខ្វល់ចិន្តា ទាសភាពតណ្ហា រស់ក្ររហោម ។

* ភពផែនលោកិយ បុរីមច្ចុរាជ តណ្ហាព្រោងព្រាត វាតអំណាចកាម
មិនដឹងធម៌ពិត គិតតែរត់តាម... ស្លាប់ក្ររហាម រត់តាមតណ្ហា ។

* កើតរស់រួចស្លាប់ ច្បាប់ដែនលោកិយ ជីវិតប្រក្រតី គប្បីសិក្សា
**សព្វេ ធម្មា** ជា **អនត្តា** មិនគួរប្រាថ្នា មហិច្ឆតាកម្លៅ ។

* បើមិនដឹងធម៌ ស្រវឹងខ្លាំងណាស់ អវិជ្ជាក្រៃក្រាស់ ខ្វះការយល់ត្រូវ
ទាសករតណ្ហា អត្តាល្ងង់ខ្លៅ នាំជីវិតទៅ លំនៅវដ្តៈ ។

* **ធម៌នៅឯណា? ពិចារណាចុះ! ឃើញឮដឹងរស ទោះផោដ្ឋព្វៈ**
**សតិដឹងច្បាស់ ប្រកាសធម្មៈ គ្មានតួអត្តៈ គ្មានអ្នក... ជាអ្វី !**

* លោកនេះសោះសូន្យ កូនចៅគ្រួសារ មច្ចុប្រហារ ឥតត្រាប្រណី
អវិជ្ជាតណ្ហា ប្រាថ្នាល្បាញល្បី មិនស្គាល់លោកិយ បុរីមរណៈ ។

* លោកនេះទទេ! ...រិះរេធម៌ពិត មើលឃើញជីវិត ពិតជាធម្មៈ
គ្មានអញគ្មានឯង តំណែងឋានៈ យល់ដឹងសច្ចៈ ប្រត្យក្សជីវិត !

* **ឃើញអ្វីមិនស្មើ ប្រសើរឃើញធម៌ ល្អអ្វីស្មើល្អ ចិត្តស្មោះសរពិត**
**បុគ្គលប្រសើរ ចេះប្រើជីវិត សិក្សាការពិត ហើយប្រព្រឹត្តធម៌!**

© *ធម្មទស្សនទាន* **ព្រហ្ម-មេត្តា គតបណ្ឌិតោ**

សប្បុរសជន អ្នកមានឧបការៈ ប្រកបដោយមហាកុសលសម្បយុត្ត

បរិច្ចាគថវិកាទ្រទ្រង់ការបោះពុម្ពសៀវភៅ **ប្រជុំភាណវារ**

(រៀបចំរចនាសាជាថ្មី)

បោះពុម្ពលើកទី១ ក្នុងឆ្នាំរក អដ្ឋស័ក

(**ពុទ្ធសករាជ ២៥៦០**)

1. ឧបាសក **ចាន់-ហ៊ាច** / ឧ.សិ. **ជា-ហាំចហួរ** ព្រមទាំងបុត្រ-ធីតា,
2. ឧបាសិកា **សុច-ចន្ថា** និង **ស្វាមី** ព្រមទាំងបុត្រ-ធីតា,
3. ឧ. **ហោច-អេចឆួន** / ឧ.សិ. **ជ្រេច-ឆេចគ** ព្រមទាំងកូន-ចៅ,
4. ក្រុមវេន **ពុទ្ធបរិស័ទ មហាសង្គហៈ ជ្រកក្រោមម្លប់ព្រះសទ្ធម្ម**,
5. *ក្រុមធម្មមាមកជន សហគមន៍ធម្មទាន* ក្នុង និង ក្រៅប្រទេស ។

បោះពុម្ពនៅរោងពុម្ព **ពិភពពណ៌** ទូរស័ព្ទលេខ: 012-54 12 28.

(បោះពុម្ពលើកទី១ ចំនួន ១៣.៥០០ សៀវភៅ = **25.650 $ US.**)

**សម្រាប់ជាធម្មទាន**

ឧទ្ទិស ប្រតិស្ឋាន ប្រារព្ធចំពោះភាពឋិតថេរតាំងនៅដោយវឌ្ឍនភាព
នៃព្រះពុទ្ធសាសនាព្រះបរមសាស្តាព្រះជិនស្រី
គ្រប់៥.០០០ព្រះវស្សា ដោយបរិបូណ៌ ជាភិយ្យោភាព!

**អាទិភាព** សម្រាប់តម្កល់តាមធម្មបណ្ណាល័យ
ក្នុងវត្តអារាមព្រះពុទ្ធសាសនា ក្នុង និង ក្រៅប្រទេស

# ឧទ្ទិសកថា

ដោយ **គុណានុភាព** នៃ **ធម្មទាន** នេះ (បុណ្យកុសលទាំងឡាយដែលសម្រេចបាន) យើងខ្ញុំទាំងឡាយ ជាអ្នកប្រាថ្នាបុណ្យ និង ការសន្សំបារមីដើម្បីការអស់ទៅនូវតណ្ហាអាសវក្កិលេស សូមផ្គងអញ្ជលីចំពោះព្រះគុណព្រះរតនត្រ័យ ប្រារព្ធចំពោះភាពឋិតថេរតាំងនៅ ថ្កុំថ្កើង រុងរឿង ប្រកបដោយវឌ្ឍនភាពពិតប្រាកដ គ្រប់**៥.០០០**ព្រះវស្សា ដោយបរិបូណ៌ ជាភិយ្យោភាព នៃ **ព្រះពុទ្ធសាសនា** របស់ **ព្រះបរមសាស្តា** និងសេចក្តីសុខសន្តិភាពក្សេមក្សាន្តពិតប្រាកដ នៃ**មាតុភូមិកម្ពុជា** និង **ប្រជាជាតិខ្មែរ** ព្រមជាមួយនឹង**សន្តិភាពនៃមនុស្សជាតិលើពិភពលោកទាំងមូល**!

សូម **គុណធម៌** ផ្សព្វផ្សាយទៅកាន់គ្រប់មណ្ឌលចក្រវាល!

សូមសព្វសត្តនិករទាំងឡាយ បានក្រេបនូវធម្មរស ដើម្បីបន្សាបនូវពិសពុលនៃកិលេសតណ្ហា ដែលប្រហារសត្វលោក ដោយសភាពនៃអវិជ្ជាធាតុ!

- ... **តណ្ហាក្ខយរតោ ហោត សម្មាសម្ពុទ្ធសាវកោ**
  សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរក្នុងធម៌ ជាគ្រឿងអស់តណ្ហា ។
- **តណ្ហាក្ខយោ សព្វទុក្ខំ ជិនាត** ការអស់ទៅនៃតណ្ហា គឺជាការឈ្នះទុក្ខ!
- **សព្វទានំ ធម្មទានំ ជិនាត** ធម្មទាន ឈ្នះអាមិសទានទាំងពួង!
- **សព្វរសំ ធម្មរសោ ជិនាត** រសនៃព្រះធម៌ ឈ្នះអស់រសទាំងពួង!
- **នត្ថិ សន្តិ បរំ សុខំ** សុខក្រៅពីសេចក្តីស្ងប់(ព្រះនិព្វាន) មិនមាន!

<u>សូមអនុមោទនា</u>!!!

ដោយសេចក្តីជ្រះថ្លា មេត្តា និង ការគោរពបំផុតក្នុងព្រះធម៌

អំពី ខ្ញុំព្រះករុណា-យើងខ្ញុំ **ក្រុមធម្មមាមកជន សហគមន៍ធម្មទាន**



- បុគ្គលអ្នកមានក្បាលត្រងោល ដណ្ដប់សង្ឃាដី ជាអ្នកបានបាយ ទឹក សំពត់ និង ទីដេក ឈ្មោះថាបានវត្ថុជាសត្រូវច្រើន ។ **ភិក្ខុអ្នកមានសតិ** លុះដឹងទោសនុ៎ះថាជាភ័យធំក្នុងសក្ការៈទាំងឡាយហើយ គួរជាអ្នកមានលាភតិច មិនឈ្លក់ដោយលាភ វៀរឱ្យស្រឡះ !

(ស្រង់ចាក សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា (**តិស្សត្ថេរ**) បិ. ៥៦, ទំ. ១៨០)

ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមចំណង់ចិត្តបានយ៉ាងណា វិញ្ញូជន កាលបើឃើញសេរីភាព(យ៉ាងនោះ) គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

((ស្រង់ចាក ខគ្គវិសាណសូត្រ : សុត្តន្តបិដកខុទ្ទកនិកាយ សុត្តនិបាត បិ. ៥៤ /ទំ. ១៤)





# បដិបទា ជាទីសប្បាយដើម្បី ព្រះនិព្វាន

(នវបុរាណវគ្គ សុត្តន្ត. សំយុត្ត. សឡាយតនវគ្គ : បិដកភាគទី ៣៥ ទំព័រ ៣០៧_៣១១)

ម្នាលភិក្ខុទាំងឡាយ ! **តថាគត** នឹងសម្តែងនូវបដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ចូរអ្នកទាំងឡាយស្តាប់នូវបដិបទានោះចុះ ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញថា **ចក្ខុ** រូប ចក្ខុវិញ្ញាណ ចក្ខុសម្ផ័ស្ស មិនទៀង ជាទុក្ខ ជាអនត្តា, **វេទនា**ណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើងព្រោះចក្ខុសម្ផ័ស្សជាបច្ច័យ ភិក្ខុឃើញ **វេទនា** នោះ ថាមិនទៀង ជាទុក្ខ ជាអនត្តា ... (**សោត**_សំឡេង ... **ឃាន**_ក្លិន ... **ជិវ្ហា**_រស ... **កាយ**_ផោដ្ឋព្វៈ ...) ឃើញថា**មនោ** ធម្មារម្មណ៍ មនោវិញ្ញាណ មនោសម្ផ័ស្ស មិនទៀង ជាទុក្ខ ជាអនត្តា, វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើងព្រោះមនោសម្ផ័ស្សជាបច្ច័យ ភិក្ខុឃើញវេទនានោះ ថាមិនទៀង ជាទុក្ខ ជាអនត្តា ។

ម្នាលភិក្ខុទាំងឡាយ នេះឯង **បដិបទា**ជាទីសប្បាយដើម្បី **ព្រះនិព្វាន** ។

ម្នាលភិក្ខុទាំងឡាយ ! កាលបើអរិយសាវ័កអ្នកចេះដឹង ឃើញយ៉ាងនេះថា របស់ណាមិនទៀង ជាទុក្ខ ជាអនត្តា មានកិរិយាប្រែប្រួលជាធម្មតា មិនគួរនឹងយល់ឃើញថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដូច្នេះឡើយ ... កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុវិញ្ញាណផង ... (**សោត**_សំឡេង ... **ឃាន**_ក្លិន ... **ជិវ្ហា**_រស ... **កាយ**_ផោដ្ឋព្វៈ ...) រមែងនឿយណាយនឹងមនោផង នឿយណាយនឹងធម្មារម្មណ៍ផង នឿយណាយនឹងមនោវិញ្ញាណផង ... វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខ មិនជាសុខក្តី ដែលកើតឡើងព្រោះមនោសម្ផ័ស្សជាបច្ច័យ វេទនានោះឯងក៏មិនទៀង ជាទុក្ខ ជាអនត្តា មិនមែនជារបស់អញ មិនមែនជាអញ មិនមែនជាខ្លួនរបស់អញឡើយ ... កាលបើឃើញដូច្នេះហើយ រមែងនឿយណាយនឹងវេទនានោះផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះបាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កអ្នកចេះដឹងឃើញយ៉ាងនេះ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ នេះឯង **បដិបទា**ជាទីសប្បាយដើម្បី **ព្រះនិព្វាន** ។

© ធម្មទាន ដោយ ក្រុមធម្មាមកជនសហគមន៍ធម្មទាន

ឆ្នាំ វក អដ្ឋស័ក ព.ស.២៥៦០ (2016)